ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# របាយការណ៍
# ប្រចាំឆ្នាំ២០២៥



# ទស្សនវិស័យ

អភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជីស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# បេសកកម្ម

- អភិវឌ្ឍស្របតាមគោលនយោបាយរាជរដ្ឋាភិបាល
- បង្កើនគុណភាពសេវាកម្ម តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ផែ ការធ្វើទំនើបកម្មគ្រប់គ្រងកំពង់ផែ និងការអភិវឌ្ឍធនធានមនុស្ស ស្របតាមនវានុវត្តន៍អន្តរជាតិ
- សហការជាមួយដៃគូអភិវឌ្ឍន៍ សិក្សា និងឆ្ពោះទៅការកសាងផែទឹកជ្រៅ ស្របតាមទស្សនវិស័យ និងកំណើនកុងតឺន័រឆ្លងកាត់
- ជម្រុញ និងពង្រឹងគោលការណ៍ ជាកំពង់ផែសម្រាប់ទាំងអស់គ្នា ។

# គុណតម្លៃ

- ទីតាំងភូមិសាស្ត្រល្អបំផុត
- ការបំពេញចិត្តជូនអតិថិជន
- ភាពបរិសកម្ម និងនវានុវត្តន៍
- សុចរិតភាព និងគណនេយ្យភាព
- ភាពរួសរាយរាក់ទាក់ និងការគោរព
- ការងារជាក្រុម និងគុណភាពសេវាកម្ម
- ភាពជឿទុកចិត្ត និងកំណើនប្រកបដោយចីរភាព

## **ព័ត៌មានហិរញ្ញវត្ថុសង្ខេប**

<table>
<tr><th colspan="2">ស្ថានភាពហិរញ្ញវត្ថុ</th><th>ឆ្នាំ២០២៥<br>(ពាន់រៀល)</th><th>ឆ្នាំ២០២៤<br>(ពាន់រៀល)</th><th>ឆ្នាំ២០២៣<br>(ពាន់រៀល)</th></tr>
<tr><td colspan="2">ទ្រព្យសកម្មសរុប</td><td>២.២៨៩.២៧៨.៣៨១</td><td>១.៧៧៣.៣២៤.៦១៧</td><td>១.៦០២.៨២៤.៩៤០</td></tr>
<tr><td colspan="2">បំណុលសរុប</td><td>១.០៦៤.២៧៧.០៧៦</td><td>៧០៣.៤២២.៨៤១</td><td>៦៣០.៧៨០.០៦៤</td></tr>
<tr><td colspan="2">មូលធនសរុប</td><td>១.២២៥.០០១.៣០៥</td><td>១.០៦៩.៩០១.៧៧៦</td><td>៩៧២.០៤៤.៨៧៦</td></tr>
<tr><th colspan="2">លទ្ធផលហិរញ្ញវត្ថុ</th><td></td><td></td><td></td></tr>
<tr><td colspan="2">ចំណូលសរុប</td><td>៦២១.៤៥៨.៥៤៦</td><td>៤៥៩.២១២.១៣៣</td><td>៣៦៤.៦៤០.៧៧១</td></tr>
<tr><td colspan="2">ចំណេញមុនបង់ពន្ធ</td><td>២១៧.៦៥៣.២២២</td><td>១៥៤.៥៨៨.០៥២</td><td>១៥៤.៣៩២.៥៤៤</td></tr>
<tr><td colspan="2">ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ</td><td>១៧១.៩៧៨.៩៤៧</td><td>១២៦.៧៣៣.៦២៩</td><td>១២១.៩៦៥.៤៩០</td></tr>
<tr><td colspan="2">លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ</td><td>១៧១.៩៧៨.៩៤៧</td><td>១១៣.៦៦៤.១៦៨</td><td>១២១.៩៦៥.៤៩០</td></tr>
<tr><th colspan="2">អនុបាតហិរញ្ញវត្ថុ</th><th>៣១ ធ្នូ ២០២៥</th><th>៣១ ធ្នូ ២០២៤</th><th>៣១ ធ្នូ ២០២៣</th></tr>
<tr><td colspan="2">អនុបាតសោធនភាព</td><td>២២,៤៧%</td><td>២៥,៧៤%</td><td>២៦,៩២%</td></tr>
<tr><td colspan="2">អនុបាតបំណុលធៀបនឹងមូលធន</td><td>០,៨៧</td><td>០,៦៦</td><td>០,៦៥</td></tr>
<tr><td rowspan="2">អនុបាត</td><td>អនុបាតចរន្ត</td><td>២,១៦</td><td>២,៣៨</td><td>១,៩៤</td></tr>
<tr><td>អនុបាតចរន្តលឿន</td><td>១,៩៥</td><td>២,០៦</td><td>១,៦៩</td></tr>
<tr><th colspan="2">អនុបាត ចំណេញភាព</th><th>ឆ្នាំ២០២៥</th><th>ឆ្នាំ២០២៤</th><th>ឆ្នាំ២០២៣</th></tr>
<tr><td rowspan="5">អនុបាត<br>ចំណេញភាព</td><td>ផលចំណេញក្នុងមួយ<br>ឯកតាទ្រព្យសកម្ម</td><td>៧,៥១%</td><td>៧,១៥%</td><td>៧,៦១%</td></tr>
<tr><td>ផលចំណេញក្នុងមួយ<br>ឯកតាមូលធន</td><td>១៤,០៤%</td><td>១១,៨៥%</td><td>១២,៥៥%</td></tr>
<tr><td>គំលាតចំណេញដុល</td><td>៣៤,៤០%</td><td>២៦,៤២%</td><td>៣៨,៥៥%</td></tr>
<tr><td>គំលាតចំណេញភាព</td><td>២៧,៦៧%</td><td>២៧,៦០%</td><td>៣៣,៤៥%</td></tr>
<tr><td>ចំណេញក្នុងមួយឯកតា<br>មូលបត្រកម្មសិទ្ធិ(រៀល)</td><td>២.០០៥,០៧</td><td>១.៤៧៧,៥៦</td><td>១.៤២១,៩៧</td></tr>
<tr><td colspan="2">អនុបាតលទ្ធភាពសងការប្រាក់</td><td>២៩,៣៩</td><td>២០,៧២</td><td>១៨,២៣</td></tr>
</table>

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









## ភាគហ៊ុនិករបស់ កសស

| ល.រ | ប្រភេទមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|---|
| ១ | មូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ "ក" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣៦៤.៥៣០.៨៦១ | ៨០,៩៥% |
| ២ | មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ | ១៤,២៩% |
| ៣ | មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "គ" | ឯកជន | ២១.៤៤២.៩៩២ | ៤,៧៦% |
| សរុប | | | ៤៥០.៣០២.៨២៨ | ១០០% |

## ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិប្រភេទ "គ" របស់ កសស

| ល.រ | ភាគហ៊ុនិក | ចំនួនមូលបត្រកាន់កាប់ | ភាគរយ |
|---|---|---|---|
| ១ | ESOP | ២.១៤៤.២៩៩ | ១០% |
| ២ | KAMIGUMI CO., LTD | ១១.១៥០.៣២៤ | ៥២% |
| ៣ | KOBE-OSAKA International Port Corporation | ២.១៤៤.៣០០ | ១០% |
| ៤ | ភាគហ៊ុនិកឯកជនដទៃទៀត | ៦.០០៤.០៦៩ | ២៨% |
| សរុប | | ២១.៤៤២.៩៩២ | ១០០% |



# បម្រែបម្រួលថ្លៃភាគហ៊ុន និងទំហំជួញដូរ






# ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ

| បរិយាយ | ឯកត្តា | ផែនការ ឆ្នាំ២០២៥ | ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| **បរិមាណទំនិញឆ្លងកាត់** | តោន | **១០.៥២១.០០០** | **១២.៣២៣.៤១៤** | **៩.៧៩៧.៤១៣** | **៧.៨៩៣.១៥៧** | **១៧,១៣%** | **២៥,៧៨%** | **៥៦,១៣%** |
| ជាកុងតឺន័រ | _ | | ៩.២៦២.៨២០ | ៧.១៥៦.០៩៩ | ៥.៦១១.២០៧ | | ២៩,៤៤% | ៦៥,០៨% |
| ទំនិញរាយ | _ | | ៧៧៨.០២៦ | ៤១៣.៦៣៤ | ២០៣.៣០៤ | | ៨៨,១០% | ២៨២,៦៩% |
| ជាប្រេង | _ | | ២.០៦៤.៥៣៤ | ២.០៧៧.៨៧៣ | ១.៩៣៩.៧២១ | | -០,៦៤% | ៦,៤៣% |
| ហ្គាស | _ | | ២១៨.០៣៤ | ១៤៩.៨០៧ | ១៣៨.៩២៤ | | ៤៥,៥៤% | ៥៦,៩៤% |
| **បរិមាណទំនិញនាំចូល** | _ | **៧.៩៥៣.០០០** | **៩.១២៨.០៨១** | **៧.៣៤៥.៤១២** | **៥.៨៤២.៩៨៩** | **១៤,៧៨%** | **២៤,២៧%** | **៥៦,២២%** |
| **បរិមាណទំនិញនាំចេញ** | _ | **២.៥៦៨.០០០** | **៣.១៩៥.៣៣៣** | **២.៤៥២.០០១** | **២.០៥០.១៦៨** | **២៤,៤៣%** | **៣០,៣២%** | **៥៥,៨៦%** |
| **បរិមាណទំនិញលើករៀប** | _ | **២២.៦៩១.០០០** | **២១.១៥៦.២៣០** | **២១.១០៨.១៦៩** | **១៧.១៦១.៩៣៨** | **-៦,៧៦%** | **០,២៣%** | **២៣,២៧%** |
| ប្រគល់ផ្ទាល់ | _ | ៣៨០.០០០ | ៧៧៨.០២៦ | ៣៧១.៧៨៣ | ១៦៩.១៧៣ | | ១០៩,២៧% | ៣៥៩,៩០% |
| ឆ្លងកាត់ឃ្លាំង និងទីលាន | _ | ២២.៣១១.០០០ | ២០.៣៧៨.២០៤ | ២០.៧៣៦.៣៨៥ | ១៦.៩៩២.៧៦៥ | | -១,៧៣% | ១៩,៩២% |
| **បរិមាណកុងតឺន័រឆ្លងកាត់** | TEUs | **១.១៣៧.០០០** | **១.៣៤៧.៧២៦** | **១.០៣២.១៩១** | **៧៩៧.៧៧៨** | **១៨,៥៣%** | **៣០,៥៧%** | **៦៨,៩៣%** |
| នាំចូល | _ | | ៧០១.៣៩២ | ៥៣៧.០១៧ | ៤០២.៦៣៣ | | ៣០,៦១% | ៧៤,២០% |
| នាំចេញ | _ | | ៦៤៦.៣៣៤ | ៤៩៥.១៧៤ | ៣៩៥.១៤៥ | | ៣០,៥៣% | ៦៣,៥៧% |
| **ចំនួននាវាចូលចត** | គ្រឿង | **១.៥៩៧** | **១.៧៧៥** | **១.៥៦៦** | **១.៥០៦** | **១១,១៥%** | **១៣,៣៥%** | **១៧,៨៦%** |
| **ចំណុះផ្ទុកនាវា** | តោន | **២០.៨២៧.០០០** | **២៦.១២៨.២១០** | **២០.២១១.៤៣៣** | **១៩.១០៥.៧០២** | **២៥,៤៥%** | **២៩,២៧%** | **៣៦,៧៦%** |

# សមាសភាពក្រុមប្រឹក្សាភិបាល



**ឯកឧត្តម លូ គឹមឈន់**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជាប្រធានអគ្គនាយក



**ឯកឧត្តម ឈួន ថិន**
តំណាងក្រសួងសាធារណការ
និងដឹកជញ្ជូន



**ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា**
តំណាងក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ



**ឯកឧត្តម គឹម ស៊ីថន**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ៊ុន មុន្នីវណ្ណ**
អភិបាលឯករាជ្យ



**លោក Hidetoshi KUME**
អភិបាលមិនប្រតិបត្តិ
តំណាងភាគហ៊ុនិកឯកជន



**លោក លូ លីខេង**
តំណាងនិយោជិតកម្មករ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ



# សេចក្តីថ្លែង
## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
## ទទួលបន្ទុកជាប្រធានអគ្គនាយក

តាងនាម ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវ របាយការណ៍លទ្ធផលអាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យកំពង់ផែស្វយ័តក្រុងព្រះសីហនុមានការអភិវឌ្ឍ ពង្រឹង និងពង្រីកសមត្ថភាពជាបន្តបន្ទាប់ ។ ជាមោទនភាព និងកិត្តិយសដ៏ធំធេង ទោះបីស្ថិតក្នុងកាលៈទេសៈប្រតិបត្តិការមានភាពមមាញឹកខ្លាំង និងលើសពីសមត្ថភាព ព្រមទាំងស្ថានភាពនៃការបិទព្រំដែនគោកកម្ពុជា-ថៃ ដោយនៅក្នុងឆ្នាំ២០២៥នេះ កសស សម្រេចបានបរិមាណកុងតឺន័រឆ្លងកាត់ខ្ពស់រហូតដល់ជាង ១,៣លាន TEUs ដែលជាប្រវត្តិសាស្ត្រពុំធ្លាប់មានពីមុនមក ។ ជាមួយគ្នានេះ យើងមានមោទនភាពដែលកំពង់ផែដើរតួនាទីជាច្រកទ្វារនាំទំនិញចេញ-ចូលដ៏សំខាន់ អាចជួយដោះស្រាយបញ្ហាប្រឈម ជម្រុញកំណើនសេដ្ឋកិច្ចជាតិ និងកំពុងអភិវឌ្ឍខ្លួនជាបណ្តើរៗស្របតាមចក្ខុវិស័យ និងគម្រោងអភិវឌ្ឍន៍ផែនការមេ ដើម្បីប្រែក្លាយកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទៅជាកំពង់ផែតំបន់ (Regional Port) និងមជ្ឈមណ្ឌលឡូជីស្ទិក (Logistics Hub) ជាទស្សនវិស័យដ៏ឈ្លាសវៃបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា និងគាំទ្រដោយរដ្ឋាភិបាលជប៉ុន ។

ដោយមានការគាំទ្រយ៉ាងមុតមាំពីរាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន) ប្រជាជន-រដ្ឋាភិបាលជប៉ុន សមត្ថកិច្ច-ភាគីពាក់ព័ន្ធ ក្រុមហ៊ុននាវា និងអ្នកប្រើប្រាស់ផែទាំងអស់ រួមទាំងបងប្អូនបុគ្គលិក កសស ដែលបានខិតខំបំពេញការងារប្រកបដោយភាពម្ចាស់ការ និងទំនួលខុសត្រូវខ្ពស់ ។ ជាលទ្ធផល បរិមាណកុងតឺន័រឆ្លងកាត់នៅក្នុងឆ្នាំ២០២៥ មានចំនួន ១.៣៤៧.៧២៦ TEUs កើនឡើង ៣០,៥៧% ទំនិញគិតជាតោនសរុបឆ្លងកាត់ មានចំនួន ១២.៣២៣.៤១៤ តោន កើនឡើង ២៥,៧៨% ចំណូលអាជីវកម្មសរុប មានចំនួន ៦២១.៤៥៨.៥៤៦.០០០ រៀល កើនឡើង ៣៥,៣៣% និងប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធក្នុងការិយបរិច្ឆេទមានចំនួន ១៧១.៩៧៨.៩៤៧.០០០ រៀល កើនឡើង ៣៥,៧០% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ដែលផ្អែកតាមលទ្ធផលដ៏ល្អនេះ ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិគឺមានចំនួន ២.០០៥,០៧ រៀល ។ ជាមួយគ្នានេះផងដែរ ចំនួននាវាឆ្លងកាត់ មានចំនួន ១.៧៧៥ គ្រឿង កើនឡើង ១៣,៣៥% ប៉ុន្តែចំណុះផ្ទុកនាវាមានដល់ ២៦.១២៧.២១១ តោន កើនឡើង ២៩,២៧% ។ ស្ថិតិនេះបានបញ្ជាក់ឱ្យឃើញអំពីនិន្នាការនាវាចូលចតផែកាន់តែមានទំហំធំ ជម្រៅទឹកជ្រៅ ធ្វើឱ្យថ្លៃដឹកជញ្ជូនតាមសមុទ្រកាន់តែមានភាពប្រកួតប្រជែង និងភាពទាក់ទាញនៃការវិនិយោគផ្សេងៗ ។

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ ក៏ដូចជាចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្លាយជាប្រទេសដែលមានចំណូលខ្ពស់ កសស ប្តេជ្ញាលើកកម្ពស់គុណភាពសេវាកម្មដោយបង្កើនការប្រើប្រាស់បរិវត្តកម្មឌីជីថល និងជម្រុញការតភ្ជាប់ (Connectivity) ដើម្បីប្រែក្លាយទៅជាច្រកទ្វារដ៏ចម្បងសម្រាប់ពាណិជ្ជកម្មអន្តរជាតិ និងទាក់ទាញការវិនិយោគនៅកម្ពុជា ។ ទន្ទឹមហ្នឹងនេះ កសស កំពុងបន្តពង្រឹងគុណភាពធនធានមនុស្ស តាមរយៈការពង្រឹងសមត្ថភាពជំនាញ ការបណ្តុះបណ្តាល និងការលើកទឹកចិត្ត ដើម្បីធានាបាននូវប្រសិទ្ធភាព គុណតម្លៃល្អប្រសើរ និងឆាប់រហ័សប្រកបដោយភាពប្រកួតប្រជែងជូនដល់អតិថិជនរបស់យើង ។ បន្ថែមលើនេះ កសស នឹងបន្តកិច្ចខិតខំប្រឹងប្រែងបំពេញការងារ និងផ្តល់សេវាកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីសម្រេចបានលទ្ធផលខ្ពស់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន ។

- ដើម្បីឆ្លើយតបនឹង កំណើនបរិមាណកុងតឺន័រឆ្លងកាត់ កសស ក៏ដូចជាតម្រូវការរបស់អតិថិជន កសស មានទិសដៅការងារចម្បង ដូចខាងក្រោម៖
  - ប្រតិបត្តិការ និងអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) តាមទិសដៅ និងតម្រូវការរបស់គោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា
  - អនុវត្តគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ដំហានទី១ ដំហានទី២ និងដំហាទី៣ ។ បន្ទាប់ពីគម្រោងនេះសាងសង់រួចរាល់ នឹងអនុញ្ញាតអោយនាវាមានផ្លូវដឹកជញ្ជូនក្នុងពិភពលោក ទៅ-មក កសស បានដោយផ្ទាល់ ពុំមានឧបសគ្គជម្រៅទឹកទៀតឡើយ និងធ្វើអោយតម្លៃដឹកជញ្ជូនតាមសមុទ្រមានតម្លៃប្រហាក់ប្រហែលជាមួយប្រទេសផ្សេងៗក្នុងតំបន់
  - បង្កើនគុណភាពសេវាកម្មឥតឈប់ឈរ តាមរយៈការជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងគ្រឿងចក្របន្ថែមទៀត, សហការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ផែ និងអភិវឌ្ឍធនធានមនុស្ស បច្ចេកវិទ្យា និងមធ្យោបាយលើកដាក់ទំនើបៗ ស្របតាមនវានុវត្តន៍អន្តរជាតិ
  - សហការជាមួយដៃគូអភិវឌ្ឍន៍ សិក្សាជាជំហានៗ និងមានផែនការច្បាស់លាស់កសាងផែទឹកជ្រៅ ស្របតាមទស្សនវិស័យ និងកំណើនកុងតឺន័រឆ្លងកាត់
  - ពង្រឹងគោលការណ៍ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាកំពង់ផែទាំងអស់គ្នា ចូលរួមលើកកម្ពស់ការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ
  - ចូលរួមក្នុងសកម្មភាពអភិវឌ្ឍសហគមន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ រាជរដ្ឋាភិបាលដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន) អាជ្ញាធរដែនដី អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមត្ថកិច្ចពាក់ព័ន្ធ ដែលជានិច្ចកាលតែងតែគាំទ្រ និងចូលរួមបំពេញភារកិច្ចរួមជាមួយនឹងកំពង់ផែផ្តល់នូវគុណភាព សេវាកម្មប្រកបដោយប្រសិទ្ធភាព និងការជឿទុកចិត្តពីក្រុមហ៊ុននាវា និងអតិថិជនរហូតសម្រេចបានលទ្ធផលល្អប្រសើរ ។

ជាចុងក្រោយនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃសុក្រ ៩ កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ខេត្តព្រះសីហនុ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ គឹមឈន់**

# មាតិកា


**ទស្សនវិស័យ បេសកកម្ម គុណតម្លៃ** ............ I

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ............ II

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប.** ............ III

**ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ.** ............ VI

**សមាសភាពក្រុមប្រឹក្សាភិបាល** ............ VII

**សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក** ............ VIII

**ផ្នែកទី១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងកំពង់ផែស្វយ័តក្រុងព្រះសីហនុ** ............ ០១

ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ ............ ០២

ខ- លក្ខណៈនៃធុរកិច្ច ............ ០២

គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ ............ ០៤

ឃ-ព្រឹត្តិការសំខាន់ៗប្រចាំឆ្នាំ. ............ ០៤

ង- ស្ថានភាពទីផ្សារ ............ ០៤

ច- ស្ថានភាពប្រកួតប្រជែង ............ ០៧

ឆ- ផែនការអនាគត ............ ០៨

ជ- កត្តាហានិភ័យ. ............ ១៣

**ផ្នែកទី២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ............ ១៤

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ............ ១៥

ខ- រចនាសម្ព័ន្ធចំណូល ............ ១៨

**ផ្នែកទី៣ : ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** ............ ១៩

ក- អង្គការលេខ ............ ២០

ខ- ក្រុមប្រឹក្សាភិបាល ............ ២១

គ- បុគ្គលិកជាន់ខ្ពស់ ............ ២១

**ផ្នែកទី៤ : ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ** ............ ២២

ក- ព័ត៌មានអំពីមូលបត្រ ............ ២៣

ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ............ ២៣

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ ............ ២៤

ឃ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន ............ ២៤

ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី)ឆ្នាំចុងក្រោយ ............ ២៤

**ផ្នែកទី៥ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ....... ២៥**

**ផ្នែកទី៦ : របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ........... ២៦**

**ផ្នែកទី៧ : ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍ ........................................................................................................ ២៧**

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ.២៨

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ........................................២៨

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធ នឹងការទិញ-លក់ ទ្រព្យសកម្ម និងសេវាកម្ម ..........................................................................................................២៨

ឃ-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ............................................២៨

ង- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីង របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ........................................................................................................២៨

ច- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល.......................................................................................................................២៨

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី កំពង់ផែស្វយ័តក្រុងព្រះសីហនុ.........................................................................................................២៨

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ..................................................២៨

**ផ្នែកទី៨ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ....................................... ២៩**

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ............................................................................... ៣០

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .......................................................... ៣៥

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល........................................................ ៣៦

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ.................................... ៣៦

ង- ផលប៉ះពាល់នៃអតិផរណា.................................................................................... ៣៦

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល .......................៣៧

**ផ្នែកទី៩ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន .............................. ៣៨**

**ហត្ថលេខាអភិបាលរបស់កំពង់ស្វយ័តក្រុងព្រះសីហនុ ............................................. ៤០**

**ឧបសម្ព័ន្ធ១ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង**

**ឧបសម្ព័ន្ធ២ : របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**ឧបសម្ព័ន្ធ៣ : របាយការណ៍អភិបាលកិច្ចសាជីវកម្ម ប្រចាំឆ្នាំ២០២៥**

# ផ្នែកទី១

# ព័ត៌មានពាក់ព័ន្ធនឹង
# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- អត្តសញ្ញាណកំពង់ផែស្វយ័តក្រុងព្រះសីហនុ

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | : | កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (ឡាតាំង) | : | PORT AUTONOME DE SIHANOUKVILLE "PAS" |
| ឈ្មោះក្រុមហ៊ុនជាអក្សរ (អង់គ្លេស) | : | SIHANOUKVILLE AUTONOMOUS PORT |
| លេខកូដស្តង់ដារ | : | KH1000060009 |
| អាសយដ្ឋាន | : | តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។ |
| លេខទូរស័ព្ទ | : | (៨៥៥) ៣៤ ៩៣៣ ៤១៦ / ៩៣៣ ៥១១ |
| ទំនាក់ទំនងវិនិយោគិន | : | (៨៥៥) ៧៨ ៤៩៦ ៧៨៩ |
| គេហទំព័រ | : | www.pas.gov.kh |
| អ៊ីម៉ែល | : | pasinfo@pas.gov.kh |

វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម : MOC-37805504 ពណ.ចបព

| | | |
|---|---|---|
| ចុះបញ្ជីក្រោមលេខ | : | 00074638 |
| កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម | : | ២១ កុម្ភៈ ២០១៧ |

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ : ០៥៨/១៧/គ.ម.ក/ស.ស.រ

| | | |
|---|---|---|
| កាលបរិច្ឆេទ | : | ០៩ ឧសភា ២០១៧ |
| ឈ្មោះតំណាងបុគ្គលបោះផ្សាយ | : | **ឯកឧត្តម លូ គឹមឈន់** |

## ខ- លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រទឹកជ្រៅដ៏សំខាន់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដីប្រតិបត្តិការប្រមាណ ១២៥ ហិកតា ។ កំពង់ផែស្ថិតនៅឆកកំពង់សោម ដែលជាកំពង់ផែទឹកជ្រៅស្ទួលសម្រួលដល់ការដឹកជញ្ជូនតាមសមុទ្រ ដែលទទួលបានភាពអនុគ្រោះពីធម្មជាតិ ដោយពុំមានគ្រោះរញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ និងមានជម្រៅទឹកជ្រៅ ហើយស្ថិតនៅចំទីតាំងដែលពុំតម្រូវឱ្យមានការបូមស្ការឃ្លងនាវាជាប្រចាំឡើយ ។

កសស ជាមជ្ឈមណ្ឌលចែកចាយ និងផ្គត់ផ្គង់ទំនិញ ដែលមានការប្រមូលផ្តុំប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទក្នុងការផ្តល់សេវាជូនអតិថិជន និងអ្នកប្រើប្រាស់ផែ តភ្ជាប់ទៅរាជធានីភ្នំពេញតាមផ្លូវគោក ដោយផ្លូវជាតិលេខ៤ មានប្រវែង ២២៦ គីឡូម៉ែត្រ ឬ តាមផ្លូវជាតិលេខ៣ កាត់តាមទីរួមខេត្តកំពត មានប្រវែង ២៤៤ គីឡូម៉ែត្រ ឬ ផ្លូវល្បឿនលឿនមានប្រវែង ១៨៧ គីឡូម៉ែត្រ ។ ក្រៅពីផ្លូវគោក កសស ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើង ភាគខាងត្បូងពីភ្នំពេញកាត់តាមខេត្តកំពត ដែលមានប្រវែង ២៦៤ គីឡូម៉ែត្រ និងតាមផ្លូវអាកាស តភ្ជាប់ពីខេត្តសៀមរាប រាជធានីភ្នំពេញ ប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសចិន មកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ។

ក្នុងនាមជាអាជ្ញាធរ និងប្រតិបត្តិករផែ កសស មានកម្មវត្ថុអាជីវកម្ម និងសេវាកម្ម ដូចខាងក្រោម៖

- កណ្ណជារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភារដល់នាវា
- លើកដាក់ ផ្ទេរ-ផ្ទុក ទំនិញ
- ស្តុកទំនិញ នៅឃ្លាំង និងទីលាន
- ដឹកជញ្ជូនទំនិញ
- តំបន់សេដ្ឋកិច្ចពិសេស
- សេវាផ្ទេរមធ្យោបាយដឹកជញ្ជូន "Transshipment"

កសស មានចំណតផែសរុបប្រវែង ១.៨៦០ ម៉ែត្រ ដោយចែកជា ១៣ ចំណតដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ | ប្រភេទទំនិញ | បណ្តោយ (ម៉ែត្រ) | ទទឹង (ម៉ែត្រ) | ចំណត |
|---|---|---|---|---|---|
| ១ | ស្ថានីយផែអ្នកដំណើរ (ចំណតផែចាស់) | អ្នកដំណើរ និងទំនិញរាយ | ២៩០ | ២៨ | លេខ១ និងលេខ៣៖ ជម្រៅទឹក ៩ ម៉ែត្រ ដល់ ១៣ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅ ៨,៥ ម៉ែត្រ ចូលចតបាន។ លេខ២ និងលេខ៤ជម្រៅ ៦,៥ ម៉ែត្រ ដល់ ៨ ម៉ែត្រ សម្រាប់នាវា ដែលមានជម្រៅក្រោម ៧ ម៉ែត្រ ចូលចតបាន ។ |
| ២ | ស្ថានីយផែបន្ថែម (ចំណតផែថ្មី) | កុងតឺន័រ | ៣៥០ | ៥០០ | លេខ៥ (ផ្នែកខាងលិច) ប្រវែង ៩៧ ម៉ែត្រ សម្រាប់នាវាទំនិញទូរទៅ និងលេខ៦ (ផ្នែកខាងកើត)៖ ប្រវែង ២៥៣ ម៉ែត្រ ជម្រៅទឹក ១០,៥ ម៉ែត្រ អនុញ្ញាតឱ្យនាវាកុងតឺន័រ មានជម្រៅទឹក ៩,៥ ម៉ែត្រ ចូលចតបាន ។ |
| ៣ | ស្ថានីយផែកុងតឺន័រ | កុងតឺន័រ | ៤០០ | ៣៥០ | លេខ៧ និងលេខ៨៖ ជម្រៅទឹក ១១,៥ ម៉ែត្រ អនុញ្ញាតឱ្យនាវាកុងតឺន័រ មានជម្រៅទឹក ១០,៥ ម៉ែត្រ ចូលចតបាន ។ |
| ៤ | ស្ថានីយផែពហុបំណង | អ្នកដំណើរ ទំនិញរាយ និងរុករកប្រេង | ៣៣០ | ២០០ | ផែពហុបំណង មានប្រវែង ៣៣០ ម៉ែត្រ និងជម្រៅទឹក ១៣,៥ ម៉ែត្រ សម្រាប់ ប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញទូទៅ ដែលអាចអនុញាតឱ្យ នាវាចំណុះ ៥០.០០០ DWT ចូលចតបាន និងចំណតផែមូលដ្ឋាន ផ្គត់ផ្គង់ការរុករករ៉ែប្រេងក្នុងដែនសមុទ្រ មានប្រវែង ២០០ ម៉ែត្រ និងជម្រៅទឹក ៧,៥ ម៉ែត្រ ដើម្បីបម្រើសេវាភស្តុភារកម្ម សម្រាប់ការរុករកប្រេង ក្នុងដែនសមុទ្រកម្ពុជា ។ |
| ៥ | ស្ថានីយផែថ្ម | ដឹកប្រេង | ៥៣ | ៥ | ចំណតផែប្រេង៖ ជម្រៅ ៤,៥ ម៉ែត្រ ហើយមានប្រវែងសរុបក្រោម ៨០ ម៉ែត្រ។ ឧបករណ៍ទាក់ពួរកែច្នៃ ត្រូវបានរៀបចំសម្រាប់នាវាប្រេង ដែលមានជម្រៅ បាតក្រោម ៦ ម៉ែត្រ និងប្រវែងក្រោម ១១០ ម៉ែត្រ ធ្វើការចូលចតបាន ។ |

- ស្ថានីយរថភ្លើងដឹកកុងតឺន័រ : ក្រៅពីចំណតផែខាងលើ កសស បានផ្តល់សេវាកម្មលើកដាក់កុងតឺន័រទៅលើ និងចុះពីរថភ្លើង ដោយមានកិច្ចសហការជាមួយក្រុមហ៊ុន Royal Railway Co., Ltd កសស ក្នុងការដឹកជញ្ជូនទំនិញ កុងតឺន័រ តាមប្រព័ន្ធផ្លូវដែក ទៅមកភ្នំពេញ-កសស ។
- តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ : បន្ថែមពីអាជីវកម្ម សេវាកម្មខាងលើ កសស ក៏មានប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ លើផ្ទៃដីទំហំប្រមាណ ៦៤ ហិកតា ស្ថិតនៅក្បែរនឹងកំពង់ផែ និងបានសាងសង់ឡើងស្របទៅតាមបទដ្ឋាន និងលក្ខណៈបច្ចេកទេសរបស់ប្រទេសជប៉ុន ។

## គ- សម្ព័ន្ធភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ

នៅក្នុងឆ្នាំ២០២៥ នេះ កសស មិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬ ក្រុមហ៊ុនពាក់ព័ន្ធដទៃទៀតទេ ។

## ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ២០២៥

នៅក្នុងឆ្នាំ២០២៥ នេះ កសស មានព្រឹត្តិការណ៍សំខាន់ៗ ដូចខាងក្រោម ៖

- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥ កសស បានប្រារព្ធពិធីសំណេះសំណាលជាមួយ ថ្នាក់ដឹកនាំ មន្ត្រី រាជការ បុគ្គលិក កម្មករនិយោជិត របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) នាឱកាសអបអរសាទរខួប អនុស្សាវរីយ៍លើកទី ១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានប្រារព្ធនៅចំណតផែពហុបំណង ។
- នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ កសស បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន អមដោយ **ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាតភាគហ៊ុនិកលើកទី៨ នៅសណ្ឋាគារ រ៉ាហ្វិល រ៉ូយ៉ាល់, រាជធានីភ្នំពេញ ។

## ង- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ កសស គឺផ្អែកសំខាន់ទៅលើបរិមាណកុងតឺន័រឆ្លងកាត់ ដោយនៅក្នុងឆ្នាំ២០២៥ នេះ បរិមាណកុងតឺន័រឆ្លងកាត់សរុបមានចំនួន ១.៣៤៧.៧២៦ TEUs កើនឡើង ៣១៥.៥៣៥ TEUs ស្មើនឹង ៣០,៥៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ និងកើនឡើង ៥៤៩.៩៤៨ TEUs ស្មើនឹង ៦៨,៩៣% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ។



បន្ថែមលើនេះ នៅក្នុងឆ្នាំ២០២៥ បរិមាណទំនិញឆ្លងកាត់សរុប (កុងតឺន័រ ទំនិញរាយ ប្រេងនិងហ្គាស) មានចំនួន ១២.៣២៣.៤១៤ តោន កើនឡើង ២.៥២៦.០០១ តោន ស្មើនឹង ២៥,៧៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ និងកើនឡើង ៤.៤៣០.២៥៧ តោន ស្មើនឹង ៥៦,១៣% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ។ ក្នុងនោះទំនិញជាកុងតឺន័រ កើនឡើង ២.១០៦.៧២១ តោន ស្មើនឹង ២៩,៤៤% ទំនិញរាយកើនឡើង ៣៦៤.៣៩២ តោន ស្មើនឹង ៨៨,១០% និងទំនិញជាប្រេង-ហ្គាស កើនឡើង ៥៤.៨៨៨ តោន ស្មើនឹង ២,៤៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។




ចាប់តាំងពីឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន មានកុងតឺន័រមួយចំនួនដឹកតាមរយៈរថភ្លើងឆ្លងកាត់ កសស ដែលបានជួយសម្រួលដល់ស្ថានភាពចរាចរណ៍ផ្លូវជាតិលេខ៤ ក៏ដូចជាផ្ដល់នូវជម្រើសសម្រាប់អតិថិជន ក្នុងការដឹកទំនិញចេញ-ចូលកំពង់ផែ។ នៅក្នុងឆ្នាំ២០២៥ នេះ បរិមាណកុងតឺន័រដឹកតាមរថភ្លើងឆ្លងកាត់ កសស មានចំនួន ៥៦.៩៤៧ TEUs ថយចុះ ១.៥៦៨ TEUs ស្មើនឹង ២,៦៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។



បរិមាណទំនិញនាំចេញសរុបនៅក្នុងឆ្នាំ២០២៥ មានចំនួន ៣.១៩៥.៣៣៣ តោន កើនឡើង ៧៤៣.៣៣២ តោន ស្មើនឹង ៣០,៣២% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ ទំនិញនាំចេញ ជាប្រភេទទំនិញទូទៅ នាំចេញបានច្រើនជាងគេ គឺមានចំនួន ១.២៨៣.៩៦៣ តោន ស្មើនឹង ៤០,១៨% ជាក្រណាត់-សំលៀកបំពាក់មានចំនួន ៨៣៤.៧៨២ តោន ស្មើនឹង ២៦,១៣% និងជាអង្ករ មានចំនួន ៧២៦.៦៩៩ តោន ស្មើនឹង ២២,៧៤% នៃទំនិញនាំចេញសរុប ។ ចំណែកទំនិញនាំចេញផ្សេងៗទៀតរួមមាន៖ ឈើកែច្នៃមានចំនួន ៧,៧៤% ផ្លែឈើមានចំនួន ១,៣៦% រថយន្ត ម៉ូតូ កង់ មានចំនួន ០,៩៥% ស្បែកជើង/ស្រោមជើងមានចំនួន ០,៦៦% គ្រឿងចក្រមានចំនួន ០,១៣% និងបារីមានចំនួន ០,១១% ។




ចំណែកបរិមាណទំនិញនាំចូលសរុបសម្រាប់ឆ្នាំ២០២៥ មានចំនួន ៩.១២៨.០៨១ តោន កើនឡើង ១.៧៨២.៦៦៩ តោន ស្មើនឹង ២៤,២៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ ទំនិញនាំចូល ជាប្រភេទទំនិញទូទៅ នាំចូលបានច្រើនជាងគេ គឺមានចំនួន ៥.៦០៦.៩៤១ តោន ស្មើនឹង ៦១,៤៣% និងប្រេងឥន្ធនៈ និងហ្គាស មាន ចំនួន ២.២៨២.៥៦៨ តោន ស្មើនឹង ២៥,០១% ។ ចំណែកទំនិញនាំចូលផ្សេងៗទៀតរួមមាន៖ ក្រណាត់ សំលៀកបំពាក់មានចំនួន ៤,១៤% ផ្សងថ្មមានចំនួន ១,៧៧% លោហៈធាតុមានចំនួន ៣,៥% គ្រឿងចក្រមានចំនួន ៣,០៥% រថយន្ត ម៉ូតូ កង់មានចំនួន ០,៧៣% និងបារីមានចំនួន ០,៣៨% ។



## ច- ស្ថានភាពប្រកួតប្រជែង

កសស នៅតែរក្សាបានឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដោយសារកត្តាមួយចំនួន ដូចខាងក្រោម៖

- **លក្ខណៈអំណោយផលនៃទីតាំងភូមិសាស្ត្រ**

  - កសស គឺជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងខេត្តព្រះសីហនុ ហើយមានទីតាំងនៅចំកណ្តាលក្នុងចំណោមប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនទៅកាន់ទីផ្សារអន្តរជាតិសំខាន់ៗ ។ ការដឹកជញ្ជូនពី កសស ទៅកាន់កំពង់ផែក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ពុំចាំបាច់ឆ្លងកាត់កំពង់ផែមេក្នុងតំបន់ឡើយ ពោលគឺការដឹកជញ្ជូនអាចធ្វើឡើងដោយផ្ទាល់ ។ ក្រៅពីការដឹកជញ្ជូនទៅកាន់កំពង់ផែក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ការដឹកជញ្ជូនទៅកាន់កំពង់ផែហុងកុង ឬសិង្ហបុរី ដែលជាច្រកទ្វារទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ក៏មានភាពងាយស្រួលផងដែរ ។
  - មានអំណោយផលល្អ ដោយពុំធ្លាប់មានផលប៉ះពាល់បណ្តាលមកពីគ្រោះធម្មជាតិ ដូចជា ខ្យល់ព្យុះ រញ្ជួយដី ឬទឹកជំនន់ ។
  - មិនតម្រូវឱ្យមានការចំណាយលើការបូមស្តារឃ្លងនាវាជាប្រចាំឡើយ ។

- **ហេដ្ឋារចនាសម្ព័ន្ធទំនើប**

  - កសស មាននូវហេដ្ឋារចនាសម្ព័ន្ធទំនើបៗ រួមទាំងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការកុងតឺន័រ ដូចជា៖ CTMS, SWSS, VTMS, PAS Mobile និងប្រព័ន្ធផ្សេងៗទៀត សម្រាប់បម្រើឱ្យអាជីវកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ និងភាពជឿទុកចិត្តបាន ។ បច្ចុប្បន្ន កសស មានចំណតផែកុងតឺន័រចំនួន ៣ និងគ្រឿងចក្រលើកដាក់ទំនើប ព្រមទាំងការបូមស្តារចំណតផែកុងតឺន័រទាំងបីចំណត ធ្វើឱ្យសមត្ថភាពផែសរុបកើនដល់ ១.០០០.០០០ TEUs/ឆ្នាំ អនុញ្ញាតឱ្យនាវាដឹកកុងតឺន័រមានជម្រៅទឹក ១០,៤ ម៉ែត្រ ចូលចតបាន (កើនឡើងពី ១៨% ទៅប្រមាណ ៣៨% នៃនាវាដែលធ្វើចរាចរក្នុងពិភពលោក ដោយឡែកសម្រាប់នាវាដែលមានផ្លូវរត់ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកកើនឡើងដល់ ៤៩,២៥%) ។

- **ប្រសិទ្ធភាពការងារ**

  - ការបន្តពង្រឹងប្រសិទ្ធភាពនៃការងារគ្រប់គ្រង និងការអនុវត្តអភិបាលកិច្ចល្អ ។
  - ការបណ្តុះបណ្តាលជាប្រចាំ និងការលើកទឹកចិត្ត មន្ត្រី បុគ្គលិក និងកម្មករ ដើម្បីអភិវឌ្ឍសមត្ថភាព ពង្រឹងស្មារតី និងផ្តល់កម្លាំងចិត្តក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញសេវាកម្មឱ្យល្អប្រសើរជូនអតិថិជន ។
  - ការអនុវត្តប្រតិបត្តិការលើកដាក់កុងតឺន័រជូនក្រុមហ៊ុននាវា និងអតិថិជន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការជឿទុកចិត្តបាន ។

- **តម្លៃសេវាកម្ម មានភាពប្រកួតប្រជែង**

  - កសស នៅតែរក្សាតម្លៃសេវាកម្មរបស់ខ្លួនឱ្យមានភាពប្រកួតប្រជែង ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងកិច្ចសម្រួលពាណិជ្ជកម្ម ដែលបានផ្តល់នូវអត្ថប្រយោជន៍ជូនដល់ក្រុមហ៊ុននាវា អតិថិជនវិនិយោគិន និងអ្នកប្រើប្រាស់ផែ ។

- **រក្សាទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ**

  - កសស បានរក្សាទំនាក់ទំនងល្អជាមួយអតិថិជនរបស់ខ្លួន ដោយព្យាយាមបំពេញតាមតម្រូវការរបស់អតិថិជន ទទួលយកមតិយោបល់ ដើម្បីស្វែងយល់អំពីចំណុចខ្វះខាត ក្នុងទិសដៅកែលម្អឱ្យកាន់តែប្រសើរបន្ថែមទៀត ។
  - កសស តែងតែរក្សាកិច្ចសហប្រតិបត្តិការជាមួយកំពង់ផែក្នុងតំបន់ និងអន្តរជាតិ ក្នុងការចែករំលែកបទពិសោធន៍ និងការបណ្តុះបណ្តាល ដើម្បីបង្កើនគុណភាពសេវាកម្មរបស់ខ្លួន ។

## ឆ- ផែនការអនាគត

### ផែនការអភិវឌ្ឍន៍ កសស រយៈពេល ៥ឆ្នាំ (២០២៥-២០៣០)

កសស មានផែនការអភិវឌ្ឍន៍រយៈពេលខ្លី និងមធ្យម ចាប់ពីឆ្នាំ២០២៥ ដល់ឆ្នាំ២០៣០ ដូចខាងក្រោម៖

- **គម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ជម្រៅ ១៤,៥ ម៉ែត្រ**

ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧ គឺជាគម្រោងអភិវឌ្ឍន៍ផែកុងតឺន័រថ្មី (ជំហានទី១) ប្រវែង ៣៥០ ម៉ែត្រ និងមានជម្រៅទឹក ១៤,៥ ម៉ែត្រ រួមបញ្ចូលទាំងការបំពាក់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប ប្រភេទ QC ចំនួន ៣ គ្រឿង និងប្រភេទ RTG ចំនួន ៩ គ្រឿង និងមធ្យោបាយលើកដាក់កុងតឺន័រមួយចំនួន។ ល។

គម្រោងនេះ ទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន (ទីភ្នាក់ងារ JICA) តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានចាប់អនុវត្តការងារសាងសង់នៅខែមេសា ឆ្នាំ២០២៤ ហើយគ្រោងបញ្ចប់ការងារសាងសង់ និងដាក់ឱ្យប្រតិបត្តិការនៅអំឡុងខែមីនា ឆ្នាំ២០២៧ ។

| សេចក្ដីសង្ខេបគម្រោង | |
|---|---|
| រយៈពេល | ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៧ |
| គោលបំណង | បង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅកំពង់ផែក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅសំខាន់របស់ប្រទេសកម្ពុជា និងប្រសិទ្ធភាពផ្នែកកស្តុការកម្ម ដោយការសាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក ១៤,៥ ម៉ែត្រ ព្រមទាំងអភិវឌ្ឍឍបបនីយកណ្ឌផែផ្សេងទៀត អាចអនុញ្ញាតឱ្យនាវាកុងតឺន័រ ដែលមានចំណុះផ្ទុក ៦០.០០០ DWT (៤.០០០ TEUs) ចូលចតបាន (ប្រមាណ ៩៣% នៃនាវាកុងតឺន័រក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក)។ ចំណតផែកុងតឺន័រថ្មីនេះ គ្រោងនឹងបញ្ចប់ការសាងសង់ និងដាក់ឱ្យដំណើរការនៅអំឡុងខែមីនា ឆ្នាំ២០២៧ ដែលចំណតនេះមានសមត្ថភាពឱ្យកុងតឺន័រឆ្លងកាត់បានប្រមាណ ៤៥០.០០០ TEUs/ឆ្នាំ ធ្វើឱ្យសមត្ថភាពសរុបផែកុងតឺន័រ កសស នឹងកើនឡើងដល់ ១.៤៥០.០០០ TEUs/ឆ្នាំ នៅឆ្នាំ២០២៧ ធ្វើឱ្យតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Cost) មានតម្លៃប្រហាក់ប្រហែលបណ្តាប្រទេសជិតខាង និងក្នុងតំបន់ ដែលអាចរួមចំណែកដល់ការជួយសម្រួលផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រនឹងឈានដល់ ១.៤៥០.០០០ TEUs/ឆ្នាំ នៅពេលដែលចំណតផែកុងតឺន័រនេះដាក់ឱ្យប្រតិបត្តិការនៅអំឡុងខែមីនា ឆ្នាំ២០២៧ ខាងមុខ ។ |
| ធាតុសំខាន់ៗ | - សាងសង់ចំណតផែកុងតឺន័រថ្មី ប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក ១៤,៥ ម៉ែត្រ ទីលានកុងតឺន័រ និងឋបនីយកណ្ឌផែ ព្រមទាំងការងារបូមស្អារអាងនាវា និងឃ្លងនាវាប្រវែង ៤,៣ គីឡូម៉ែត្រ និងជម្រៅ ១៣,៥ ម៉ែត្រ ។ ល។<br>- បំពាក់មធ្យោបាយលើកដាក់កុងតឺន័រធុនធ្ងន់ រួមមាន៖ QC ចំនួន ៣ គ្រឿង, RTG ចំនួន ៩ គ្រឿង Top Lifter ចំនួន ២ គ្រឿង, រថយន្តសណ្ដោងកុងតឺន័រចំនួន ១៦ គ្រឿង និងប្រព័ន្ធគ្រប់គ្រងចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម ។ ល។ |
| ទីតាំង | ស្ថិតនៅទល់មុខចំណតផែកុងតឺន័រដែលមានស្រាប់ ក្បែរទំនប់រលកចំងាយប្រមាណ ៣០០ ម៉ែត្រ ពីច្រាំងសមុទ្រ មានច្រកផ្លូវចូលភ្ជាប់ពីផ្លូវលេខ ១៤៨ ទៅកាន់ចំណតផែកុងតឺន័រថ្មី និងមានផ្ទៃដីសរុបទំហំ ១៧,៥ ហិកតា ។ |
| ទីភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA (លេខ៖ CP-P21) តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ២៣.៥០២.០០០.០០០ ប្រហាក់ប្រហែលនឹង USD ២០៣.០០០.០០០,០០ |

| | |
|---|---|
| ដំណាក់កាលនៃការអនុវត្តន៍គម្រោង | **ដំណាក់កាលទី១ ៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)**<br>-ជំហានទី១ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ក្រុមសិក្សា JICA បានចុះមកសិក្សា និងរៀបចំរបាយការណ៍ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែក្រុងព្រះសីហនុ ។<br>-ជំហានទី២ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧)៖ ទីភ្នាក់ងារ JICA បានចុះមកសិក្សា និងវាយតម្លៃផ្នែកហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយសម្រេចចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានលេខៈ CP-P21 នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសកុងស៊ុលតង់គម្រោង (ឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩)**<br>-ការងារជ្រើសរើសកុងស៊ុលតង់នេះត្រូវបានអនុវត្តតាមនីតិវិធី Single Source Selection (SSS)។ ក្នុងដំណាក់កាលនីមួយៗ ត្រូវមានការឯកភាពជាគោលការណ៍ពី ក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។ សេវាកុងស៊ុលតង់នេះរួមមាន ការងារសិក្សាគំនូរផ្នែកវិស្វកម្មសំណង់ស៊ីវិល និងការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងការងារត្រួតពិនិត្យ ក្នុងអំឡុងពេលសាងសង់ជាដើម ។<br>-ក្រុមហ៊ុន Nippon-Koei & Oriental Consultants Global JV (ក្រុមហ៊ុនជប៉ុន) ត្រូវបានចុះកិច្ចសន្យាជាមួយ កសស នៅខែសីហា ឆ្នាំ២០១៩ ។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូរប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់និងក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០)**<br>-<u>ជំហានទី១ (ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២០)៖</u> ការរៀបចំគំនូរប្លង់វិស្វកម្មសម្រាប់ ①ការងារសំណង់ស៊ីវិល (Package-1) និង ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Package-2) ។<br>-ក្រុមហ៊ុនកុងស៊ុលតង់ NK-OCG JV បានចាប់ដំណើរការការងារផ្នែកគំនូរប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃ សម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់តាំងពី ខែកក្កដា ឆ្នាំ២០១៩ ហើយបានដាក់ជូន កសស នៅខែកក្កដា ឆ្នាំ២០២០។ ប៉ុន្តែការងារផ្នែកគំនូរប្លង់វិស្វកម្មនេះ ត្រូវបានកែសម្រួលឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងផលប៉ះពាល់ជាសកលដោយសារជំងឺកូវីដ-១៩ បណ្តាលឱ្យមានការពន្យាពេលអនុវត្តគម្រោង និងបានដាក់ជូន កសស សារជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២៣ ។<br>-<u>ជំហានទី២ (ឆ្នាំ២០២៣ ដល់ ឆ្នាំ២០២៥)៖</u> ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រថ្មី (Package-1) (ឆ្នាំ២០២៤) និង ②ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (Package-2)(ឆ្នាំ២០២៥)។ ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាម នីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ហើយត្រូវមានការឯកភាពជាគោលការណ៍ពីក្រសួងអាណាព្យាបាលទាំងពីរ (MEF & MPWT) និងទីភ្នាក់ងារ JICA ។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រថ្មី និងផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ចុងឆ្នាំឆ្នាំ២០២៥ ដល់ចុងឆ្នាំ២០២៦)**<br>- <u>កញ្ចប់ទី១ (ឆ្នាំ២០២៤)៖</u> ការងារសាងសង់ចំណតផែកុងតឺន័រថ្មី គ្រោងនឹងចាប់ផ្តើមការងារសាងសង់នៅខែមីនា ឆ្នាំ២០២៤ ហើយបគ្រោងញ្ចប់ការងារនៅឆ្នាំ២០២៧ (៣៦ខែ) ។<br>- <u>កញ្ចប់ទី២ (ឆ្នាំ២០២៥ ដល់ ឆ្នាំ២០២៧)៖</u> ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់គ្រោងនឹងចាប់ផ្តើមនៅខែកុម្ភៈ ឆ្នាំ២០២៥ ហើយគ្រោងបញ្ចប់ការងារនៅខែមិថុនា ឆ្នាំ២០២៧ (២៨ខែ)។<br>**ដំណាក់កាលទី៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៧ ដល់ ឆ្នាំ២០២៨)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល ១ឆ្នាំ ដូចខាងក្រោម ៖<br>-ការងារសាងសង់ចំណតផែកុងតឺន័រថ្មី (ឆ្នាំ២០២៧ ដល់ ឆ្នាំ២០២៨)<br>-ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ (ឆ្នាំ២០២៧ ដល់ ឆ្នាំ២០២៨)។ |
| វឌ្ឍនភាពគម្រោង | កិច្ចព្រមព្រៀងប្រាក់កម្ចី បានចុះហត្ថលេខានៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី ចូលជាធរមាន នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។<br>-កិច្ចព្រមព្រៀងប្រាក់កម្ចី បញ្ចប់សុពលភាព នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ។ |

| | |
|---|---|
| | -កិច្ចសន្យាផ្នែកសេវាកុងស៊ុលតង់ រវាង កសស និងក្រុមហ៊ុន NK-OCG JV ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩។<br>-សេវាកុងស៊ុលតង់ផ្នែកគំនូរប្លង់វិស្វកម្ម និងរៀបចំឯកសារដេញថ្លៃសម្រាប់ជ្រើសរើសក្រុមហ៊ុនម៉ៅការសាងសង់ បានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០១៩ ហើយគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២០ ។ ប៉ុន្តែគម្រោងនេះ ត្រូវបានពន្យាពេលដោយសារផលប៉ះពាល់ជាសកល នៃជំងឺកូវីដ-១៩ និងការកែសម្រួលគំនូរប្លង់លំអិតឱ្យស្របតាមកិច្ចសម្រួលពាណិជ្ជកម្ម នោះឯកសារដេញថ្លៃកែសម្រួលថ្មី បានដាក់ជូន កសស សាជាថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២៣ ។<br>-នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ កសស បានចុះហត្ថលេខាជាមួយក្រុមហ៊ុនសាងសង់ TOA Corporation និងបានបើកសម្ពោធការដ្ឋានសាងសង់ចំណតផែកុងតឺន័រថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ និងចាប់ផ្តើមអនុវត្តការងារសាងសង់នៅពាក់កណ្តាល ខែមេសា ឆ្នាំ២០២៤ ហើយគ្រោងនឹងបញ្ចប់នៅខែមីនា ឆ្នាំ២០២៧ ខាងមុខ ។ |

**ទីតាំងគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី-ជំហានទី១ ប្រវែង ៣៥០ម៉ែត្រ ជម្រៅទឹក ១៤,៥ ម៉ែត្រ**




❖ **គម្រោងពង្រីកចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក ១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក ១៧,៥ ម៉ែត្រ) ដោយប្រើប្រាស់កម្ចីជប៉ុន**

ជាទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅស្តូលប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើឡើងនូវវិស័យឡូជិស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ នៅពេលចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ ដាក់ឱ្យដំណើរការ កសស នឹងអាចស្រូបទាញនាវាកុងតឺន័រធុនធំ ដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ប្រទេសកម្ពុជាដោយផ្ទាល់ ដោយពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលា ក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ។

កសស បាននឹងកំពុងប្រែក្លាយជាបណ្តើរៗ ទៅជាកំពង់ផែក្នុងតំបន់ដ៏មានសក្តានុពលមួយ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ហើយតភ្ជាប់ប្រទេសកម្ពុជាទៅកាន់តំបន់ និងពិភពលោក។

ហេតុដូច្នេះ កសស ត្រូវការជាបន្ទាន់នូវការពង្រីកចំណតផែកុងតឺន័រទឹកជ្រៅថ្មីទាំងពីរជំហានរួមគ្នាឱ្យបានរួចរាល់នៅឆ្នាំ២០២៩-២០៣០ ដែលជាជម្រើសសិក្សាដោយក្រុមសិក្សា JICA Survey Team ៖

១. ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ ម៉ែត្រ និងជម្រៅទឹក ១៦,៥ ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១២០.000DWT ផ្ទុកកុងតឺន័រជាមធ្យម ១០.000TEUs ចូលចតបាន និងការបំពាក់មធ្យោបាយលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។

២. ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ ម៉ែត្រ និងជម្រៅទឹក ១៧,៥ ម៉ែត្រ

- សមត្ថភាពនាវាចំណុះ ១៦០.000DWT ផ្ទុកកុងតឺន័រជាមធ្យម ១៥.000TEUs ចូលចតបាន និងការបំពាក់មធ្យោបាយលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់ មួយចំនួន ។

| **សេចក្តីសង្ខេបគម្រោង** | |
|---|---|
| រយៈពេល | ឆ្នាំ២០២៥ ដល់ឆ្នាំ២០៣០ |
| គោលបំណង | ដើម្បីចូលរួមគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម និងធុរកិច្ចនៅកម្ពុជាកាត់បន្ថយពេលវេលា និងតម្លៃឡូជីស្ទិក ដែលធានាបាននូវនិរន្តរភាព នៃលំហូរទំនិញចេញ-ចូលប្រកបដោយលក្ខណៈប្រកួតប្រជែងគុណភាពសេវា និងមិនកកស្ទះចរាចរទំនិញនាពេលអនាគត ឆ្លើយតបបាននូវគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ នោះ កសស ត្រូវការជាបន្ទាន់ និងសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ (ប្រវែង ៤០០ ម៉ែត្រ ជម្រៅទឹក ១៦,៥ ម៉ែត្រ) និងជំហានទី៣ (ប្រវែង ៤៣០ ម៉ែត្រ ជម្រៅទឹក ១៧,៥ ម៉ែត្រ) រួមគ្នាក្នុងទស្សនវិស័យ កសស នឹងអភិវឌ្ឍទៅជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ប្រកបដោយប្រសិទ្ធភាព និងជវភាព ដើម្បីចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវវិស័យឡូជីស្ទិក និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំណតផែកុងតឺន័រទឹកជ្រៅថ្មីនេះនឹងអាចស្រូបទាញនាវាកុងតឺន័រធុនធំ ដែលមានផ្លូវដឹកជញ្ជូនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក មកកាន់ប្រទេសកម្ពុជាដោយផ្ទាល់ ពុំចាំបាច់ ផ្ទេរ-ផ្ទុក នៅតាមបណ្តាកំពង់ផែផ្សេងៗ ហើយទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ច ពីការកាត់បន្ថយតម្លៃ និងការចំណេញពេលវេលាក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ។ ជាមួយនេះ កសស បាននឹងកំពុងប្រែក្លាយជាកំពង់ផែតំបន់ដ៏មានសក្តានុពល ជាពិសេសគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ហើយតភ្ជាប់ប្រទេសកម្ពុជាទៅកាន់តំបន់ និងពិភពលោក ។ |
| លទ្ធផលរំពឹងទុក | សមត្ថភាពលើកដាក់កុងតឺន័រឈានដល់ ២.៦៣៧.000TEUs/ឆ្នាំ នៅពេលដែលចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ និងជំហានទី៣ នេះដាក់ឱ្យប្រតិបត្តិការនៅឆ្នាំ២០៣០ ខាងមុខ ។ |
| ធាតុសំខាន់ៗ | **១-ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី២ ប្រវែង ៤០០ ម៉ែត្រ និងជម្រៅទឹក ១៦,៥ ម៉ែត្រ** (សមត្ថភាពនាវាចំណុះ ១២០.000DWT ផ្ទុកកុងតឺន័រជាមធ្យម ១០.000TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។<br>**២-ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី៣ ប្រវែង ៤៣០ ម៉ែត្រ និងជម្រៅទឹក ១៧.៥ ម៉ែត្រ**(សមត្ថភាពនាវាចំណុះ ១៦០.000DWT ផ្ទុកកុងតឺន័រជាមធ្យម ១៥.000TEUs ចូលចតបាន) និងការបំពាក់មធ្យោបាយលើកដាក់កុងតឺន័រធុនធ្ងន់ ព្រមទាំងប្រព័ន្ធប្រតិបត្តិការចំណតផែកុងតឺន័រស្វ័យប្រវត្តិកម្ម TOS ចាំបាច់មួយចំនួន ។<br>**៣-បំពាក់នាវាសណ្តោង សមត្ថភាព ៤.៤០០ សេះ ចំនួន ២ គ្រឿង និងនាវាបម្រើការងារផ្នែកកណ្តាលជារចំនួន ១ គ្រឿង ។** |

| | |
|---|---|
| ទីតាំង | បន្តពីចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ដំហានទី១ ប្រវែង ៣៥០ ម៉ែត្រ ស្ថិតលើផ្ទៃទឹកសមុទ្រក្បែរទំនប់រលក ចំងាយប្រមាណ ៦៥០ ម៉ែត្រ ពីច្រាំងសមុទ្រ, មានប្រកផ្លូវចូលភ្ជាប់ពីផ្លូវលេខ ១៤៨ ទៅទីលានចំណត ផែកុងតឺន័រថ្មី និងមានផ្ទៃដីសរុបទំហំ ៤២.៥ ហិកតា ។ |
| ភ្នាក់ងារអនុវត្តគម្រោង | កសស ជាទីភ្នាក់ងារអនុវត្តគម្រោង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាម្ចាស់គម្រោង (Employer) ។ |
| ប្រភពថវិកា និងចំនួនថវិកា | ប្រាក់កម្ចីពី JICA តាមរយៈប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ |
| តម្លៃប៉ាន់ស្មានគម្រោង | JPY ៦៤.៩៧៣.000.000 ស្មើនឹងប្រមាណ USD ៥៤៧.000.000,00<br>(បានទទួលប្រាក់កម្ចី JICA លើកទី១៖ ចំនួន JPY ៤១.៣៨៨.000.000 ស្មើនឹងប្រមាណ USD ៣៦0.000.000,00) |
| ដំណាក់កាលនៃគម្រោង | **ដំណាក់កាលទី១៖ ការសិក្សាបុរេសមិទ្ធិលទ្ធភាព និងការរៀបចំហិរញ្ញវត្ថុ (ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)**<br>-ឆ្នាំ២០២១ ដល់ឆ្នាំ២០២២)៖ ក្រុមសិក្សា JICA Survey Team បានកំពុងចុះសិក្សា និងរៀបចំរបាយការណ៍ ស្តីពីការសិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ដំហានទី២ និងដំហានទី៣ ព្រមទាំងធ្វើការវាយតម្លៃផ្នែកហិរញ្ញវត្ថុ លើគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រ ទឹកជ្រៅថ្មី ទាំងពីរដំហានរួមគ្នា ដើម្បីផ្តល់ប្រាក់កម្ចីសម្បទាន ។<br>**ដំណាក់កាលទី២៖ ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ (ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤)**<br>ការងារជ្រើសរើសក្រុមហ៊ុនកុងស៊ុលតង់ សម្រាប់គម្រោងពង្រីកចំណតផែកុងតឺន័រថ្មី-ដំហានទី២ និង ដំហានទី៣ ដោយត្រូវបានអនុវត្តតាមនីតិវិធីផ្តល់ឈ្មោះបញ្ជីខ្លីក្រុមហ៊ុនកុងស៊ុលតង់ (Shortlisted Consultants) ដោយដៃគូអភិវឌ្ឍន៍ ។ សេវាកុងស៊ុលតង់នេះ រួមមាន ការងារសិក្សាគំនូរប្លង់ផ្នែកវិស្វកម្ម សំណង់ស៊ីវិល សម្រាប់ NCT2 & NCT3 ជំនួយការរៀបចំឯកសារដេញថ្លៃ និងការងារត្រួតពិនិត្យលើការងារសាងសង់ សម្រាប់ការជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ សម្រាប់ NCT2 & NCT3 ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រធុនធ្ងន់ និងការងារផ្គត់ផ្គង់នាវាបម្រើប្រតិបត្តិការ ព្រមទាំងការងារត្រួតពិនិត្យក្នុងអំឡុងពេលជានារយៈពេលសាងសង់ជាដើម។<br>**ដំណាក់កាលទី៣៖ ការរៀបចំគំនូរប្លង់វិស្វកម្ម និងជំនួយការផ្នែកដេញថ្លៃជ្រើសរើសក្រុមហ៊ុនម៉ៅការសំណង់ និងក្រុមហ៊ុនផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតឺន័រទំនើប (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥)**<br>-ដំហានទី១ (ខែសីហាឆ្នាំ២០២៤ ដល់ ខែមីនា ឆ្នាំ២០២៥)៖ ការរៀបចំគំនូរប្លង់វិស្វកម្ម និងឯកសារដេញថ្លៃសម្រាប់ ①ការងារសំណង់ស៊ីវិលចំណតផែកុងតឺន័រថ្មី-ដំហានទី២ (Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3)។<br>-ដំហានទី២ (ខែមករា ឆ្នាំ២០២៥ ដល់ខែធ្នូ ឆ្នាំ២០២៥)៖ ការរៀបចំគំនូរប្លង់វិស្វកម្ម និងឯកសារដេញថ្លៃសម្រាប់ការងារសំណង់ស៊ីវិលចំណតផែកុងតឺន័រថ្មី-ដំហានទី៣ (Package-4) ។<br>-ដំហានទី៣ (ខែមេសា ឆ្នាំ២០២៥ ដល់ខែកញ្ញា ឆ្នាំ២០២៦)៖ ដំណើរការដេញថ្លៃ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់-ដំហានទី២ (Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ដំហានទី៤ (ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៦)៖ ៖ ដំណើរការដេញថ្លៃ ①ការជ្រើសរើសក្រុមហ៊ុនសាងសង់ចំណតផែកុងតឺន័រ-ដំហានទី៣ (Package-4) ។ ចំពោះនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនផ្គត់ផ្គង់ត្រូវអនុវត្តតាមនីតិវិធីនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ (ICB) ។<br>**ដំណាក់កាលទី៤៖ ដំណាក់កាលសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ដំហានទី២ និងដំហានទី៣ ការងារផ្គត់ផ្គង់មធ្យោបាយលើកដាក់កុងតឺន័រទំនើប និងការងារនាវាបម្រើប្រតិបត្តិការ (ឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០)** |

| | |
|---|---|
| | -ដំណាក់ទី១ (ខែកញ្ញា ឆ្នាំ២០២៦ ដល់ខែកញ្ញា ឆ្នាំ២០២៩) (៣៦ខែ)៖ ①ការងារសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ដំណាក់ទី២ (Package-1) ②ការងារផ្គត់ផ្គង់គ្រឿងចក្រលើកដាក់កុងតឺន័រទំនើប (Package-2) និង ③ការងារនាវាបម្រើប្រតិបត្តិការ (Package-3) ។<br>-ដំណាក់ទី២ (ឆ្នាំ២០២៧ ដល់ឆ្នាំ២០៣០) (៤២ខែ)៖ ការងារសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅថ្មី - ដំណាក់ទី៣ (Package-4) ។<br>**ដំណាក់កាលទី៥៖ រយៈពេលធានាជួសជុលថែទាំ (LDP) (ឆ្នាំ២០២៩ ដល់ឆ្នាំ២០៣០)**<br>រយៈពេលធានាជួសជុលថែទាំគម្រោងមានរយៈពេល ១ឆ្នាំ ។ |
| វឌ្ឍនភាពគម្រោង | រហូតមកដល់ដំណាច់ខែមករា ឆ្នាំ២០២៦នេះ វឌ្ឍនភាពការងារលទ្ធកម្មសម្រេចបាន៖<br>១. សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃសម្រាប់ Package-1: ការងារសាងសង់ចំណតផែកុងតឺន័រថ្មីដោយគ្រោង ខែវិច្ឆិកា ឆ្នាំ២០២៥ បានផ្សព្វផ្សាយលក់ឯកសារដេញថ្លៃនៅថ្ងៃទី១២ ដំណាក់ទី២-បញ្ចប់ការទទួលពាក្យដេញថ្លៃនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ (៣ខែ),<br>២. ចំណែក Package-2: ការងារលទ្ធកម្មគ្រឿងចក្រលើកដាក់ទំនិញសម្រាប់ NCT-2 & NTC-3 បានផ្សព្វផ្សាយលក់ឯកសារដេញថ្លៃនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ដោយគ្រោងបញ្ចប់ការទទួលពាក្យដេញថ្លៃនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ (៧៥ថ្ងៃ),<br>៣. ចំណែក Package-3: ការងារលទ្ធកម្មនាវាបម្រើការងារ បានផ្សព្វផ្សាយលក់ឯកសារដេញថ្លៃនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦ ដោយគ្រោងបញ្ចប់ការទទួលពាក្យដេញថ្លៃនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ (៦០ថ្ងៃ) និង<br>៤. រីឯ Package-4: ការងារសាងសង់ចំណតផែកុងតឺន័រថ្មី ដំណាក់ទី៣-ការងាររៀបចំគំនូសប្លង់លំអិត និងឯកសារដេញថ្លៃ បានបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០២៥ ហើយបានកំពុងត្រួតពិនិត្យដោយក្រុមបច្ចេកទេស មុននឹងដាក់ស្នើសុំគោលការណ៍ពីគណៈកម្មការ PRC ជាបន្ត។ |

## ៩- កត្តាហានិភ័យ

នៅក្នុងឆ្នាំ២០២៥ នេះ កសស បានពិនិត្យ និងពិភាក្សា អំពីកត្តាហានិភ័យ មួយចំនួន ដូចខាងក្រោម ៖

- កំណើននៃបរិមាណកុងតឺន័រឆ្លងកាត់ខ្ពស់ ដែលចាំបាច់ត្រូវពង្រីកហេដ្ឋារចនាសម្ព័ន្ធជាបន្ទាន់
- ការប្រតិបត្តិការលើសពីសមត្ថភាព ដែលចាំបាច់ត្រូវជម្រុញការងារសាងសង់ចំណតផែកុងតឺន័រថ្មីឱ្យបានទាន់ពេលវេលាតាមការគ្រោងទុក
- ការវិភាគទៅលើអត្រាចំណេញប្រតិបត្តិការ និងហានិភ័យបណ្តាលមកពីអត្រាប្តូរប្រាក់មិនទាន់សម្រេច ការរក្សាទីតាំងបម្រុងទុកសម្រាប់ការអភិវឌ្ឍស្របទៅតាមផែនការមេកំពង់ផែ (Master Plan) កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ការឆ្លើយតបទៅនឹងហានិភ័យនៃប្រព័ន្ធព័ត៌មានវិទ្យា ដែលចាំបាច់ត្រូវការធ្វើទំនើបកម្ម និងការការពារប្រព័ន្ធពីការវាយលុកផ្សេងៗ ។

# ផ្នែកទី២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| បរិយាយ | ឯកត្តា | ផែនការ ឆ្នាំ២០២៥ | ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ប្រៀបធៀប | | |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | (២-១)/១ | (២-៣)/៣ | (២-៤)/៤ |
| **បរិមាណទំនិញឆ្លងកាត់** | តោន | **១០.៥២១.០០០** | **១២.៣២៣.៤១៤** | **៩.៧៩៧.៤១៣** | **៧.៨៩៣.១៥៧** | **១៧,១៣%** | **២៥,៧៨%** | **៥៦,១៣%** |
| ដាកុងតឺន័រ | - | | ៩.២៦២.៨២០ | ៧.១៥៦.០៩៩ | ៥.៦១១.២០៧ | | ២៩,៤៤% | ៦៥,០៨% |
| ទំនិញរាយ | - | | ៧៧៨.០២៦ | ៤១៣.៦៣៤ | ២០៣.៣០៤ | | ៨៨,១០% | ២៨២,៦៩% |
| ប្រេង | | | ២.០៦៤.៥៣៤ | ២.០៧៧.៨៧៣ | ១.៩៣៩.៧២១ | | -០,៦៤% | ៦,៤៣% |
| ហ្គាស | - | | ២១៨.០៣៤ | ១៤៩.៨០៧ | ១៣៨.៩២៤ | | ៤៥,៥៤% | ៥៦,៩៤% |
| **បរិមាណទំនិញនាំចូល** | - | **៧.៩៥៣.០០០** | **៩.១២៨.០៨១** | **៧.៣៤៥.៤១២** | **៥.៨៤២.៩៨៩** | **១៤,៧៨%** | **២៤,២៧%** | **៥៦,២២%** |
| ដាកុងតឺន័រ | - | | ៦.១៩១.៧៧០ | ៤.៧០៧.៧៥១ | ៣.៥៧៤.១២៤ | | ៣១,៥២% | ៧៣,២៤% |
| ទំនិញរាយ | - | | ២.៩៣៦.៣១០ | ២.៦៣៧.៦៦១ | ២.២៦៨.៨៦៥ | | ១១,៣២% | ២៩,៤២% |
| **បរិមាណទំនិញនាំចេញ** | - | **២.៥៦៨.០០០** | **៣.១៩៥.៣៣៣** | **២.៤៥២.០០១** | **២.០៥០.១៦៨** | **២៤,៤៣%** | **៣០,៣២%** | **៥៥,៨៦%** |
| ដាកុងតឺន័រ | - | | ៣.០៧១.០៥០ | ២.៤៤៨.៣៤៧ | ២.០៣៧.០៨៣ | | ២៥,៤៣% | ៥០,៧៦% |
| ទំនិញរាយ | - | | ១២៤.២៨៤ | ៣.៦៥៣ | ១៣.០៨៥ | | ៣៣០១,៨១% | ៨៤៩,៨៤% |
| **បរិមាណទំនិញលើករៀប** | - | **២២.៦៩១.០០០** | **២១.១៥៦.២៣០** | **២១.១០៨.១៦៩** | **១៧.១៦១.៩៣៨** | **-៦,៧៦%** | **០,២៣%** | **២៣,២៧%** |
| ប្រគល់ផ្ទាល់ | - | ៣៨០.០០០ | ៧៧៨.០២៦ | ៣៧១.៧៨៣ | ១៦៩.១៧៣ | | ១០៩,២៧% | ៣៥៩,៩០% |
| ឆ្លងកាត់ឃ្លាំងនិងទីលាន | - | ២២.៣១១.០០០ | ២០.៣៧៨.២០៤ | ២០.៧៣៦.៣៨៥ | ១៦.៩៩២.៧៦៥ | | -១,៧៣% | ១៩,៩២% |
| **បរិមាណកុងតឺន័រឆ្លងកាត់** | TEUs | **១.១៣៧.០០០** | **១.៣៤៧.៧២៦** | **១.០៣២.១៩១** | **៧៩៧.៧៧៨** | **១៨,៥៣%** | **៣០,៥៧%** | **៦៨,៩៣%** |
| **នាំចូល** | - | | **៧០១.៣៩២** | **៥៣៧.០១៧** | **៤០២.៦៣៣** | | ៣០,៦១% | ៧៤,២០% |
| មានទំនិញ | - | | ៦៤៤.៩៦៣ | ៤៦៦.០៤៦ | ៣៦១.៣៧១ | | ៣៨,៣៩% | ៧៨,៤៨% |
| គ្មានទំនិញ | - | | ៥៦.៤២៩ | ៧០.៩៧១ | ៤១.២៦២ | | -២០,៤៩% | ៣៦,៧៦% |
| **នាំចេញ** | - | | **៦៤៦.៣៣៤** | **៤៩៥.១៧៤** | **៣៩៥.១៤៥** | | ៣០,៥៣% | ៦៣,៥៧% |
| មានទំនិញ | - | | ៣៦៥.៩៣០ | ២៩៧.៥៨៣ | ២៣៨.៦៣៣ | | ២២,៩៧% | ៥៣,៣៤% |
| គ្មានទំនិញ | - | | ២៨០.៤០៤ | ១៩៧.៥៩១ | ១៥៦.៥១២ | | ៤១,៩១% | ៧៩,១៦% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំនួននាវាចូលចត** | **គ្រឿង** | **១.៥៩៧** | **១.៧៧៥** | **១.៥៦៦** | **១.៥០៦** | **១១,១៥%** | **១៣,៣៥%** | **១៧,៨៦%** |
| **ចំណុះផ្ទុកនាវា** | **តោន** | **២០.៨២៧.០០០** | **២៦.១២៨.២១០** | **២០.២១១.៤៣៣** | **១៩.១០៥.៧០២** | **២៥,៤៥%** | **២៩,២៧%** | **៣៦,៧៦%** |
| នាវាដឹកកុងតឺន័រ | គ្រឿង | | ៩៨៣ | ៧៥៩ | ៧៥៦ | | ២៩,៥១% | ៣០,០៣% |
| ចំណុះនាវាដឹកកុងតឺន័រ | តោន | | ១៧.៤២៤.៩០៤ | ១២.៦៤៥.០៨០ | ១២.៤៩៨.៣៨២ | | ៣៧,៨០% | ៣៩,៤២% |
| នាវាដឹកប្រេង និងហ្គាស | គ្រឿង | | ៤៧៨ | ៥៤៤ | ៥២៩ | | -១២,១៣% | -៩,៦៤% |
| ចំណុះនាវាដឹកប្រេង និងហ្គាស | តោន | | ២.៦០៦.៨៤៥ | ២.៤៥១.១៤៤ | ២.៣៦៨.០៩៨ | | ៦,៣៥% | ១០,០៨% |
| នាវាដឹកទំនិញទូទៅ | គ្រឿង | | ២៩០ | ២៤០ | ២០០ | | ២០,៨៣% | ៤៥,០០% |
| ចំណុះនាវាដឹកទំនិញទូទៅ | តោន | | ៤.៧៣១.១៨១ | ៣.៩៧៩.១៤០ | ៣.២១៤.៣២១ | | ១៨,៩០% | ៤៧,១៩% |
| នាវាទេសចរណ៍ | គ្រឿង | | ២៤ | ២៣ | ២១ | | ៤,៣៥% | ១៤,២៩% |
| នាវាទេសចរណ៍ | តោន | | ១.៣៦៥.២៨០ | ១.១៣៦.០៦៩ | ១.០២៤.៩០១ | | ២០,១៨% | ៣៣,២១% |
| ចំនួនទេសចរ | នាក់ | | ១៨.៩៧៧ | ១៤.០៣៨ | ១២.៩០៦ | | ៣៥,១៨% | ៤៧,០៤% |


ចំណុះផ្ទុកនាវាចូលចត
២០០០០០០០
១៥០០០០០០
១០០០០០០០
៥០០០០០០
០
១៧.៤២៤.៩០៤
១២.៦៤៥.០៨០
១២.៤៩៨.៣៨២
២.៦០៦.៨៤៥
២.៤៥១.១៤៤
២.៣៦៨.០៩៨
៤.៧៣១.១៨១
៣.៩៧៩.១៤០
៣.២១៤.៣២១
១.៣៦៥.២៨០
១.១៣៦.០៦៩
១.០២៤.៩០១
នាវាកុងតឺន័រ
នាវាប្រេង
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២៥
ឆ្នាំ២០២៤
ឆ្នាំ២០២៣


ចំនួននាវាចូលចត
១២០០
១០០០
៨០០
៦០០
៤០០
២០០
០
៩៨៣
៧៥៩
៧៥៦
៤៧៨
៥៤៤
៥២៩
២៩០
២៤០
២០០
២៤
២៣
២១
នាវាកុងតឺន័រ
នាវាប្រេង&ហ្គាស
នាវាទំនិញទូទៅ
នាវាទេសចរណ៍
ឆ្នាំ២០២៥
ឆ្នាំ២០២៤
ឆ្នាំ២០២៣


កុងតឺន័រនាំចេញតាមបណ្តាប្រទេស
៧%
២៦%
៤៤%
៩%
៦%
១%
៨%
ចិន
អឺរ៉ុប
អាមេរិក
អាស៊ី
អង់គ្លេស
ជប៉ុន
ផ្សេងៗ




## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | | សម្រាប់ការិយបរិច្ឆេទ ២០២៤ | | សម្រាប់ការិយបរិច្ឆេទ ២០២៣ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ផ្ទេរ-ផ្ទុកពីនាវាទៅទីលាន | ២៩៦.៩០១.៤៣៤ | ៤៧,៧៧% | ២២៧.៦៤៣.១៥៥ | ៤៩,៥៧% | ១៧៧.៧៧៨.៨៩២ | ៤៨,៧៥% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ១៦០.០៧៦.៣២៥ | ២៥,៧៦% | ១២២.៩៨៤.៣១១ | ២៦,៧៨% | ៩៣.៣៩០.៤៨២ | ២៥,៦១% |
| ចំណូលពីសេវាកម្មនាវាចរ | ១០៤.៥៥០.៨០៨ | ១៦,៨២% | ៧៨.១៨៥.៦៣៥ | ១៧,០៣% | ៧៤.០៥៧.៧១៣ | ២០,៣១% |
| ចំណូលស្តុក ឃ្លាំងនិងទីលាន | ៤៧.២៣៩.៥៥៤ | ៧,៦០% | ២០.៧១៧.៧៥៧ | ៤,៥១% | ១៤.០៦៤.៥៣៦ | ៣,៨៦% |
| ចំណូលដឹកជញ្ជូន | ១២២.០៥៩ | ០,០២% | ១៣៦.៤០៩ | ០,០៣% | ១២៣.២៦៤ | ០,០៣% |
| ចំណូលនាវាទេសចរណ៍ | ៣០០.៥៩០ | ០,០៥% | ២២៧.៥០២ | ០,០៥% | ២០៩.៩៣២ | ០,០៦% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ៦.៦៥៧.៧៤៧ | ១,០៧% | ២.៩៥៧.៩៧០ | ០,៦៤% | ២.២៩៧.៦១៦ | ០,៦៣% |
| ចំណូលជួលទីតាំង | ១.៧៧៨.៥៩០ | ០,២៩% | ២.៤១៥.៩៨៦ | ០,៥៣% | ១.៩៣៨.៥៩៧ | ០,៥៣% |
| ចំណូលផ្សេងៗទៀត | ៣.៨៣១.៤៣៩ | ០,៦២% | ៣.៩៤៣.៤០៩ | ០,៨៦% | ៧៧៩.៧៣៩ | ០,២១% |
| **ចំណូលសរុប** | **៦២១.៤៥៨.៥៤៦** | **១០០,០០%** | **៤៥៩.២១២.១៣៣** | **១០០,០០%** | **៣៦៤.៦៤០.៧៧១** | **១០០,០០%** |

# ផ្នែកទី៣

# ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

# ក- អង្គការលេខ


ឧបសម្ព័ន្ធ នៃសេចក្ដីសម្រេចលេខ ០០៩ សសរ/កសស/រប.ធម
ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២០
អង្គការលេខ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ( កសស )
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងសាធារណការ និងដឹកជញ្ជូន
ក្រុមប្រឹក្សាភិបាល
ប្រធានអគ្គនាយក
គណៈកម្មាធិការ តែងតាំងនិងលាតការ
គណៈកម្មាធិការ សវនកម្ម
គណៈកម្មាធិការ គ្រប់គ្រងហានិភ័យ
អគ្គនាយករង រដ្ឋបាល-គ្រប់គ្រង
អគ្គនាយករង អាជីវកម្ម
អគ្គនាយករង បច្ចេកទេស
លេខាធិការដ្ឋាន
នាយកដ្ឋាន គ្រឿងចក្រ និងអគ្គិសនី
នាយកដ្ឋាន សំណង់-វិស្វកម្ម
នាយកដ្ឋាន បច្ចេកទេស-សម្ភារៈ
នាយកដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស
នាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ
នាយកដ្ឋាន ប្រតិបត្តិការទីលានកុងតឺន័រ
នាយកដ្ឋាន អាជីវកម្ម
នាយកដ្ឋាន ទីផ្សារ
នាយកដ្ឋាន សវនកម្មផ្ទៃក្នុង
នាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ
នាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ
នាយកដ្ឋាន ព័ត៌មានវិទ្យា
នាយកដ្ឋាន នាវាចរ-កណ្ដាលធារ
នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជាប្រធានអគ្គនាយក
លូ គីមឈន់

## ខ- ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់ អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម លូ គឹមឈន់ | ប្រធាន | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ២ | ឯកឧត្តម ឈួន វិន | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៣ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៤ | ឯកឧត្តម កឹម ស៊ីថន | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ២១-មិថុនា-២០២៤ | ២០-មិថុនា-២០២៨ |
| ៦ | លោក Hidetoshi KUME | សមាជិក | ២១-មិថុនា-២០២៤ | ២០-មិថុនា-២០២៨ |
| ៧ | លោក លូ លីខេង | សមាជិក | ០៥-ឧសភា-២០២៤ | ០៤-ឧសភា-២០២៨ |

## គ- បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះអភិបាល | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម លូ គឹមឈន់ | ប្រុស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ២ | លោក ណុំ ស៊ីនិត | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋ អមកំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៣ | លោក ថៃ ឬទ្ធី | ប្រុស | អគ្គនាយករង អាជីវកម្ម |
| ៤ | លោក ថោង វីរ៉ូ | ប្រុស | អគ្គនាយករង រដ្ឋបាល-គ្រប់គ្រង |
| ៥ | លោក ទី សាគុណ | ប្រុស | អគ្គនាយករង បច្ចេកទេស |
| ៦ | លោក រ័ត្ន សិលា | ប្រុស | ប្រធាននាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស |
| ៧ | លោក ពិត ប្រាកដ | ប្រុស | ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ |
| ៨ | លោក សូ សៀង | ប្រុស | ប្រធាននាយកដ្ឋាន ផែនការ លទ្ធកម្ម និងស្ថិតិ |
| ៩ | លោក អ៊ុក វណ្ណារ៉ា | ប្រុស | ប្រធាននាយកដ្ឋាន បច្ចេកទេស-សម្ភារៈ |
| ១០ | លោកស្រី ជ័យ សុគន្ធា | ស្រី | ប្រធាននាយកដ្ឋាន ទីផ្សារ |
| ១១ | លោក ជីវ ច័ន្ទសុផល | ប្រុស | ប្រធាននាយកដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស |
| ១២ | លោក ងួន រតនា | ប្រុស | ប្រធាននាយកដ្ឋាន អាជីវកម្ម |
| ១៣ | លោក ថៃ ម៉េងលី | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទីលានកុងតឺន័រ |
| ១៤ | លោក លូ លីខេង | ប្រុស | ប្រធាននាយកដ្ឋាន ប្រតិបត្តិការទំនិញទូទៅ |
| ១៥ | លោក ស៊ឹង សេណួ | ប្រុស | ប្រធាននាយកដ្ឋាន នាវាចរ-កណ្ណធារ |
| ១៦ | លោក គឹម ហោ | ប្រុស | ប្រធាននាយកដ្ឋាន គ្រឿងចក្រ និងអគ្គិសនី |
| ១៧ | លោក ម៉ែន ចាន់ | ប្រុស | ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង |
| ១៨ | លោក សោម ករណី | ប្រុស | ប្រធាននាយកដ្ឋាន ព័ត៌មានវិទ្យា |
| ១៩ | លោក មាន គឹង | ប្រុស | ប្រធាននាយកដ្ឋាន សំណង់-វិស្វកម្ម |
| ២០ | លោក ស៊ុក កុលចិន្តា | ប្រុស | ជំនួយការ ឯកឧត្តមប្រតិភូ មានឋានៈស្មើ ប្រធាននាយកដ្ឋាន |

# ផ្នែកទី៤

## ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក
## របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## ក- ព័ត៌មានអំពីមូលបត្រ

ឈ្មោះមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ : PAS (កសស)
ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ “គ”
តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ១.០០០ រៀល
ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ៥.០៤០ រៀល (១,២៥៩ ដុល្លារអាមេរិក)
បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ២១.៤៤២.៩៩២ មូលបត្រ
មូលធនូបនីយកម្មទីផ្សារ : ១០៨.០៧២.៦៧៩.៦៨០ រៀល (២៦.៩៩១.១៧៩ ដុល្លារអាមេរិក)
ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : ផ្សារមូលបត្រកម្ពុជា
កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ១១.៩០០ | ១១.៨៨០ | ១១.៩៤០ | ១១.៩៦០ | ១២.០០០ | ១២.៣៨០ | ១២.៣២០ | ១២.១៦០ | ១២.២០០ | ១២.២០០ | ១២.៣៦០ | ១៣.០៦០ |
| | អប្បបរមា | ១១.៦២០ | ១១.៦៤០ | ១១.៨០០ | ១១.៦៤០ | ១១.៧៨០ | ១១.៩៨០ | ១១.៨៨០ | ១១.៩២០ | ១២.០០០ | ១២.០៨០ | ១២.១២០ | ១២.៤៨០ |
| | មធ្យម | ១១.៧២៥ | ១១.៨២១ | ១១.៨៨៣ | ១១.៨៥៦ | ១១.៩១៩ | ១២.២១៤ | ១២.០២៦ | ១២.០៣០ | ១២.១០១ | ១២.១២៧ | ១២.២៨១ | ១២.៨២៥ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ១.៤០៨ | ២.៥០២ | ១.៣៦៥ | ១.០៧៥ | ១០.២៩៧ | ៣.២៩៤ | ១៩.២៧៩ | ១.២០៣ | ១.៨២៤ | ១.៨៨២ | ៨៦៨ | ៧.២៤២ |
| | អប្បបរមា | ១៩៤ | ១០៦ | ៧៦ | ៣០ | ១៦ | ៩៤ | ១៦៧ | ៧៦ | ២២ | ២៥ | ១៤២ | ១៦៧ |
| | មធ្យម | ៦០៥ | ៦៩៦ | ៤៩៨ | ៣៥៩ | ១.២៧៥ | ១.២៥៦ | ២.៤៩២ | ៥២៧ | ៣៩៩ | ៦៣៣ | ៤៧៦ | ១.២៦៩ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោត ចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| **សរុប** | | | **៦៤.៣២៨.៩៧៥** | **៧៥,០០%** |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធបោះឆ្នោតចំនួនច្រើន (ចាប់ពី៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | KAMIGUMI CO., LTD | ជប៉ុន | ១១.១៥០.៣២៤ | ១៣,០០% |
| **សរុប** | | | **១១.១៥០.៣២៤** | **១៣,០០%** |

## ខ- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|---|
| ចំណេញសុទ្ធ | ១២៦.៧៣៣.៦២៩.០០០ | ១២១.៩៦៥.៤៩០.០០០ | ៨៤.១៥៥.២១៥.០០០ |
| ភាគលាភជាសាច់ប្រាក់ | ១៦.៨៧៩.៤១៧.៥៦៨ | ១៥.៨០៧.២៦៧.៩៦៨ | ១៣.៧២១.៥៦០.៣៦៨ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | មិនមាន | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ (%) | ១៣,៣២% | ១២,៩៦% | ១៦,៣១% |
| ទិន្នផលភាគលាភ(%) | ១១,០០% | ១០,០០% | ៩,០០% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៥៥៤ រៀល | ៥០៤ រៀល | ៤៥៤ រៀល |

# ផ្នែកទី៥

## របាយការណ៍សវនកម្មរបស់
## សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ១

# ផ្នែកទី៦

## របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ

ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ២

# ផ្នែកទី៧

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគី
# ជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

**ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**គ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឃ- ប្រតិបត្តិការសំខាន់ៗ ជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ង- ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលកាន់មុខតំណែងណាមួយ នៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

**ជ- ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

នៅក្នុងឆ្នាំ២០២៥ នេះ មិនមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ កសស ទេ ។

# ផ្នែកទី៨

## ការពិភាក្សា និងការវិភាគ
## របស់គណៈគ្រប់គ្រង

## ក- និដ្ឋភាពទូទៅនៃប្រតិបត្តិការ

កសស គឺជាកំពង់ផែសមុទ្រទឹកជ្រៅស្វ័យ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដីប្រតិបត្តិការប្រមាណ ១២៥ ហិកតា ដែលមានទីតាំងស្ថិតនៅ តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចមានចែងក្នុង អនុក្រឹត្យលេខ ៥០ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ។

នៅក្នុងឆ្នាំ២០២៥ នេះ បរិមាណទំនិញឆ្លងកាត់ កសស មានចំនួន ១២.៣២៣.៤១៤ តោន កើនឡើង ២៥,៧៨% បរិមាណកុងតឺន័រឆ្លងកាត់ មានចំនួន ១.៣៤៧.៧២៦ TEUs កើនឡើង ៣០,៥៧% នាវាចូលចត មានចំនួន ១.៧៧៥ គ្រឿង កើនឡើង ១៣,៣៥% ចំណុះផ្ទុកនាវាចូលចត មានចំនួន ២៦.១២៨.២១០ តោន កើនឡើង ២៩,២៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ កសស និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យ សម្រាប់ឆ្នាំ២០២៥ និងឆ្នាំ២០២៤ ដូចបង្ហាញក្នុងឧបសម្ព័ន្ធ២ នៃរបាយការណ៍ឆ្នាំ២០២៥ នេះ ។

កសស មានប្រភពចំណូលសំខាន់ដូចខាងក្រោម ៖

- ចំណូលពីសេវាកម្មនាវាចរ (Port Charges for Vessel Services) គឺជាចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ចំណូលលើចំណុះផ្ទុក សំចតផែ ប្រឡាយ ថ្លៃឈ្នួលកណ្តាជារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលប្រមូលសំរាមពីនាវា
- ចំណូលពីសេវាកម្ម លើកដាក់ ផ្ទេរ-ផ្ទុក ពីនាវាទៅទីលាន (Stevedoring Charges) គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬ កុងតឺន័រ ផ្ទេរ-ផ្ទុក ពីនាវាមកគែមផែ
- ចំណូលពីសេវាកម្មលើកដាក់កុងតឺន័រនៅលើទីលាន (Lo-Lo Charges) គឺជាចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញរាយ ឬ កុងតឺន័រ នៅលើទីលាន
- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ ឬ កុងតឺន័រ (Storage Fees) គឺជាចំណូលដែលបានមកពីការស្តុកទំនិញរាយ ឬ កុងតឺន័រនៅក្នុងឃ្លាំង និងលើទីលាន ។
- ចំណូលដឹកជញ្ជូន (Transportation Charges) គឺជាចំណូលដែលបានមកពីសេវាកម្មដឹកជញ្ជូនទំនិញ ឬ កុងតឺន័រ
- ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone) គឺជាចំណូលដែលទទួលបានពីការជួលទីតាំងដីក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កសស កត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិ ចំណែកប្រតិបត្តិការដែលជារូបិយប័ណ្ណអន្តរជាតិផ្សេងៗ ត្រូវបានបង្ហាញជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ របស់ធនាគារជាតិនៃកម្ពុជា ទៅតាមកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ ។

## ១. ការវិភាគចំណូល

**តារាងប្រៀបធៀបប្រាក់ចំណូល សម្រាប់ការិយបរិច្ឆេទ ២០២៥ នឹងការិយបរិច្ឆេទ ២០២៤**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | សម្រាប់ការិយបរិច្ឆេទ ២០២៤ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ភាគរយ |
| ចំណូល | ៦២១.៤៥៨.៥៤៦ | ៤៥៩.២១២.១៣៣ | ១៦២.២៤៦.៤១៣ | ៣៥,៣៣% |

នៅក្នុងឆ្នាំ២០២៥ នេះ ចំណូលរបស់ កសស កើនឡើងចំនួន ១៦២.២៤៦.៤១៣.០០០ រៀល ស្មើនឹង ៣៥,៣៣% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ ការកើននៃចំណូលសរុបនេះ បណ្ដាលមកពីការកើនឡើងនៃចំណូលសេវាកម្មលើកដាក់ ផ្ទេរ-ផ្ទុក ពីនាវាទៅទីលាន ចំណូលសេវាកម្មលើកដាក់កុងតឺន័រនៅទីលាន ចំណូលពីសេវាកម្មនាវាចរ និងចំណូលថ្លៃឈ្នួលស្តុកទំនិញ ឬ កុងតឺន័រនៅឃ្លាំង និងទីលាន ។

## ២. ការវិភាគចំណូលតាមផ្នែក

**តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែក ទៅនឹងប្រាក់ចំណូលសរុប សម្រាប់ការិយបរិច្ឆេទ ២០២៥ និងការិយបរិច្ឆេទ ២០២៤**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | | សម្រាប់ការិយបរិច្ឆេទ ២០២៤ | |
|---|---|---|---|---|
| | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប | ពាន់រៀល | ភាគរយធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ពីនាវាទៅទីលាន (Stevedoring) | ២៩៦.៩០១.៤៣៤ | ៤៧,៧៧% | ២២៧.៦៤៣.១៥៥ | ៤៩,៥៧% |
| ចំណូលលើកដាក់លើទីលាន (LOLO) | ១៦០.០៧៦.៣២៥ | ២៥,៧៦% | ១២២.៩៨៤.៣១១ | ២៦,៧៨% |
| ចំណូលពីសេវាកម្មនាវាចរ | ១០៤.៥៥០.៨០៨ | ១៦,៨២% | ៧៨.១៨៥.៦៣៥ | ១៧,០៣% |
| ចំណូលស្តុក ឃ្លាំង និងទីលាន | ៤៧.២៣៩.៥៥៤ | ៧,៦០% | ២០.៧១៧.៧៥៧ | ៤,៥១% |
| ចំណូលដឹកជញ្ជូន | ១២២.០៥៩ | ០,០២% | ១៣៦.៤០៩ | ០,០៣% |
| ចំណូលនាវាទេសចរណ៍ | ៣០០.៥៩០ | ០,០៥% | ២២៧.៥០២ | ០,០៥% |
| ចំណូលពីតំបន់សេដ្ឋកិច្ចពិសេស | ៦.៦៥៧.៧៤៧ | ១,០៧% | ២.៩៥៧.៩៧០ | ០,៦៤% |
| ចំណូលជួលទីតាំង | ១.៧៧៨.៥៩០ | ០,២៩% | ២.៤១៥.៩៨៦ | ០,៥៣% |
| ចំណូលផ្សេងៗទៀត | ៣.៨៣១.៤៣៩ | ០,៦២% | ៣.៩៤៣.៤០៩ | ០,៨៦% |
| **ចំណូលសរុប** | **៦២១.៤៥៨.៥៤៦** | **១០០,០០%** | **៤៥៩.២១២.១៣៣** | **១០០,០០%** |

ផ្អែកតាមតារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកខាងលើ ប្រាក់ចំណូលចំនួន ៤ ប្រភេទ រួមមាន ៖

១. ចំណូលលើកដាក់ ផ្ទេរ-ផ្ទុក ពីនាវាទៅទីលាន

២. ចំណូលលើកដាក់នៅទីលាន

៣. ចំណូលពីសេវាកម្មនាវាចរ

៤. ចំណូលថ្លៃឈ្នួលស្តុកនៅឃ្លាំង និងទីលាន បានរួមចំណែកយ៉ាងសំខាន់រហូតដល់ប្រមាណ ៩៨% នៃចំណូលអាជីវកម្ម (សេវាកម្ម) សរុបរបស់ កសស ។

**តារាងប្រៀបធៀបប្រាក់ចំណូលតាមផ្នែកសំខាន់ៗ សម្រាប់ការិយបរិច្ឆេទ ២០២៥ និងការិយបរិច្ឆេទ ២០២៤**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | សម្រាប់ការិយបរិច្ឆេទ ២០២៤ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ភាគរយ |
| ចំណូលលើកដាក់ ផ្ទេរ-ផ្ទុក ពីនាវាទៅទីលាន | ២៩៦.៩០១.៤៣៤ | ២២៧.៦៤៣.១៥៥ | ៦៩.២៥៨.២៧៩ | ៣០,៤២% |
| ចំណូលលើកដាក់នៅទីលាន | ១៦០.០៧៦.៣២៥ | ១២២.៩៨៤.៣១១ | ៣៧.០៩២.០១៤ | ៣០,១៦% |
| ចំណូលពីសេវាកម្មនាវាចរ | ១០៤.៥៥០.៨០៨ | ៧៨.១៨៥.៦៣៥ | ២៦.៣៦៥.១៧៣ | ៣៣,៧២% |
| ចំណូលថ្លៃឈ្នួលស្តុកនៅឃ្លាំង និងទីលាន | ៤៧.២៣៩.៥៥៤ | ២០.៧១៧.៧៥៧ | ២៦.៥២១.៧៩៧ | ១២៨,០១% |

ចំណូលពីការលើកដាក់ ផ្ទេរ-ផ្ទុក ពីនាវាទៅទីលាន កើនឡើងចំនួន ៦៩.២៥៨.២៧៩.០០០ រៀល ស្មើនឹង ៣០,៤២% និងចំណូលពីការលើកដាក់នៅទីលាន កើនឡើងចំនួន ៣៧.០៩២.០១៤.០០០ រៀល ស្មើនឹង ៣០,១៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ ចំណូលធំៗទាំងពីរនេះ កើនឡើងស្របទៅតាមកំណើនបរិមាណកុងតឺន័រឆ្លងកាត់ កសស មានចំនួន ៣០,៥៧ % ។

សម្រាប់ចំណូលផ្សេងទៀតដូចជា ចំណូលពីសេវាកម្មនាវាចរ គឺអាស្រ័យលើចំនួននាវា និងចំណុះផ្ទុកនាវា ហើយនៅក្នុងឆ្នាំ២០២៥ នេះ នាវាសរុបដែលឆ្លងកាត់ កសស កើនឡើងចំនួន ២០៩ នាវា ស្មើនឹង ១៣,៣៥% និងចំណុះផ្ទុកនាវា កើនឡើងចំនួន ៥.៩១៦.៧៧៧ តោន ស្មើនឹង ២៩,២៧% នាំឱ្យចំណូលពីសេវាកម្មនាវាចរ កើនឡើងចំនួន ២៦.៣៦៥.១៧៣.០០០ រៀល ស្មើនឹង ៣៣,៧២% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ ជាមួយគ្នានេះ ចំណូលពីសេវាកម្មស្តុក ឃ្លាំង និងទីលាន កើនឡើងចំនួន ២៦.៥២១.៧៩៧.០០០ រៀល ស្មើនឹង ១២៨,០១% មកពីមានការកែប្រែរយៈពេលអនុគ្រោះថ្លៃស្តុកសម្រាប់កុងតឺន័រនាំចេញ និងនាំចូល ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ក្នុងគោលបំណងចូលរួមដោះស្រាយ ដើម្បីបង្កើនប្រសិទ្ធភាព និងទប់ស្កាត់ការស្ទះចរាចរណ៍នាវា-រថយន្តនៅ កសស ស្របពេលដែលមានកំណើនខ្ពស់នៃបរិមាណកុងតឺន័រឆ្លងកាត់ ។

## ៣. ការវិភាគគំលាតចំណេញដុល

កសស បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមយថាប្រភេទ ដូចនេះពុំមានការបង្ហាញឱ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការបានដោយទទួលបានពីចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ ។

ចំណាយប្រតិបត្តិការនឹងលើកមកធ្វើការវិភាគនៅផ្នែកខាងក្រោមគឺ ចំណុច ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ចំណេញ/(ខាត) មុនបង់ពន្ធ គឺជាលទ្ធផលដែលទទួលបានពី ចំណូលសរុប ដកនឹងចំណាយប្រតិបត្តិការ និងចំណេញ (ឬខាត) ផ្សេងៗ-សុទ្ធ ដូចខាងក្រោម ៖

**តារាងប្រៀបធៀប ចំណេញ/(ខាត) មុនបង់ពន្ធសម្រាប់ការិយបរិច្ឆេទ ២០២៥ និងការិយបរិច្ឆេទ ២០២៤**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | សម្រាប់ការិយបរិច្ឆេទ ២០២៤ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ភាគរយ |
| **ចំណូលសរុប** | **៦២១.៤៥៨.៥៤៦** | **៤៥៩.២១២.១៣៣** | **១៦២.២៤៦.៤១៣** | **៣៥,៣៣%** |
| ចំណាយសម្ភារៈផ្គត់ផ្គង់ | (១២៤.២៩៨.៤៣០) | (១០៨.១៥៩.០៦៩) | ១៦.១៣៩.៣៦១ | ១៤,៩២% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | (១៧៤.៨៥៦.៩១៩) | (១៣៧.៨២៦.៥០៤) | ៣៧.០៣០.៤១៥ | ២៦,៨៧% |
| ចំណាយរំលស់(ទ្រព្យសម្បត្តិនិងបរិក្ខារ និងទ្រព្យសកម្មអរូបី) | (៦៧.១២៦.៥៦១) | (៥៤.៣២២.៨៧១) | ១២.៨០៣.៦៩០ | ២៣,៥៧% |
| ចំណាយជួសជុល និងថែទាំ | (១.៨៩៥.០០២) | (២.១១៦.៧៩៤) | (២២១.៧៩២) | -១០,៤៨% |
| ចំណាយផ្សេងៗ | (៤៨.០៦៨.៦១០) | (៣៦.០៦០.៨៨៤) | ១២.០០៧.៧២៦ | ៣៣,៣០% |
| ចំណេញ/(ខាត)ផ្សេងៗ-សុទ្ធ | ៨.៥៦៣.៥៨៩ | ៥៩៥.៣២៣ | ៧.៩៦៨.២៦៦ | ១.៣៣៨,៤៨% |
| (ចំណាយ)/ចំណូលហិរញ្ញវត្ថុ-សុទ្ធ | ៣.៨៧៦.៦០៩ | ៣៣.២៦៦.៧១៨ | (២៩.៣៩០.១០៩) | -៨៨,៣៥% |
| **ចំណេញមុនបង់ពន្ធ** | **២១៧.៦៥៣.២២២** | **១៥៤.៥៨៨.០៥២** | **៦៣.០៦៥.១៧០** | **៤០,៨០%** |

ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ កើនឡើងចំនួន ២៦,៨៧% គឺបណ្តាលមកពីកំណើនខ្ពស់នៃបរិមាណកុងតឺន័រឆ្លងកាត់ ធ្វើឱ្យកើនឡើងនូវប្រាក់បៀវត្ស និងប្រាក់រង្វាន់សរសើរ (ប្រាក់ខែទី១៣, ១៤ និង១៥) នៅក្នុងឆ្នាំ២០២៥ នេះ ។

ចំណាយរំលស់ (រំលស់ទ្រព្យសម្បត្តិនិងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី) កើនឡើងចំនួន ២៣,៥៧% គឺបណ្តាលមកពីការពង្រីកហេដ្ឋារចនាសម្ព័ន្ធផែ និងការបំពាក់គ្រឿងចក្រទំនើបៗ ដើម្បីឆ្លើយតបទៅនឹងកំណើនបរិមាណកុងតឺន័រឆ្លងកាត់ កសស ។

ចំពោះចំណាយផ្សេងៗ កើនឡើងចំនួន ៣៣,៣០% គឺបណ្តាលមកពីការកើនឡើង នៃចំណាយវិភាគទាន និងអំណោយ ។

ចំណេញ/(ខាត) ផ្សេងៗ-សុទ្ធ (Realized Foreign Exchange Gain-Losses) គឺសំដៅលើការចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទសម្រេច ដែលនៅក្នុងឆ្នាំ២០២៥ នេះ ចំណេញពីការប្តូររូបិយប័ណ្ណ កើនឡើងក្នុងការិយបរិច្ឆេទសម្រេចចំនួន ១.៣៣៨,៤៨% ។

ចំណែក ចំណូល/(ចំណាយ)ហិរញ្ញវត្ថុ-សុទ្ធ (Unrealized Foreign Exchange Gain-Loss ) គឺសំដៅលើការចំណេញ ឬ(ខាត) ពីការប្តូររូបិយប័ណ្ណក្នុងការិយបរិច្ឆេទមិនទាន់សម្រេច ដោយនៅក្នុងឆ្នាំ២០២៥ នេះមានការថយចុះនៃចំណូលហិរញ្ញវត្ថុចំនួន ៨៨,៣៥% ។ កត្តាសំខាន់បណ្តាលឱ្យមានបម្រែបម្រួល ចំណូល/(ចំណាយ) ហិរញ្ញវត្ថុ-សុទ្ធ គឺដោយសារការថយចុះនៃការចំណេញពីការប្តូររូបិយវត្ថុមិនទាន់សម្រេចរបស់ប្រាក់កម្ចី (ប្រាក់យ៉េនជប៉ុន) ។

ជាសរុប ចំណេញមុនបង់ពន្ធនៅក្នុងឆ្នាំ២០២៥ របស់ កសស កើនឡើងប្រមាណ ៤០,៨០% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។

## ៥. ការវិភាគចំណេញ/(ខាត) ក្រោយបង់ពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្ម។ ហេតុដូចនេះ ក្នុងវិស័យពន្ធដារ និងអាករ កសស មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា ២០% ។

បន្ទាប់ពីចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ កសស ទទួលបានការលើកទឹកចិត្តពន្ធដារ ក្នុងវិស័យមូលបត្រចំនួន ៣ឆ្នាំ (ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩) ។ ដូចនេះ ចាប់ពីឆ្នាំ២០២០ កសស បានបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួនក្នុងអត្រា ២០% ។

**តារាងប្រៀបធៀបចំណេញ/(ខាត)ក្រោយបង់ពន្ធ សម្រាប់ការិយបរិច្ឆេទ ២០២៥ និងការិយបរិច្ឆេទ ២០២៤**

| បរិយាយ | សម្រាប់ការិយបរិច្ឆេទ ២០២៥ | សម្រាប់ការិយបរិច្ឆេទ ២០២៤ | បំរែបំរួល | |
|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ភាគរយ |
| ចំណេញមុនបង់ពន្ធ (ក) | ២១៧.៦៥៣.២២២ | ១៥៤.៥៨៨.០៥២ | ៦៣.០៦៥.១៧០ | ៤០,៨០% |
| ចំណាយពន្ធលើប្រាក់ចំណូល (ខ) | (៤៥.៦៧៤.២៧៥) | (២៧.៨៥៥.៤២៣) | ១៧.៨១៩.៨៥២ | ៦៣,៩៧% |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **១៧១.៩៧៨.៩៤៧** | **១២៦.៧៣៣.៦២៩** | **៤៥.២៤៥.៣១៨** | **៣៥,៧០%** |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ០ | (១៣.០៦៩.៤៦១) | (១៣.០៦៩.៤៦១) | -១០០,០០% |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | **១៧១.៩៧៨.៩៤៧** | **១១៣.៦៦៤.១៦៨** | **៥៨.៣១៤.៧៧៩** | **៥១,៣០%** |
| **អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណូល (ខ)/(ក)** | **២០,៩៨%** | **១៨,០២%** | | |

កសស ចំណេញក្នុងការិយបរិច្ឆេទចំនួន ១៧១.៩៧៨.៩៤៧.០០០ រៀល នៅក្នុងឆ្នាំ២០២៥ កើនឡើងចំនួន ៤៥.២៤៥.៣១៨.០០០ រៀល ស្មើនឹង ៣៥,៧០% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ។ កត្តាដែលធ្វើឱ្យចំណេញក្នុងការិយបរិច្ឆេទមានការកើនឡើងនេះ គឺបណ្តាលមកពីការកើនឡើងនៃចំណូល និងចំណេញពីអត្រាប្តូរប្រាក់យ៉េនជប៉ុនសម្រេច ។

បើសង្កេតទៅលើអត្រាពន្ធលើប្រាក់ចំណូល នៅក្នុងឆ្នាំ២០២៥ មានការកើនឡើងពី ១៨,០២% សម្រាប់ឆ្នាំ២០២៤ ទៅ ២០,៩៨% សម្រាប់ឆ្នាំ២០២៥ គឺដោយសារការកើនឡើងនៃចំណេញមុនបង់ពន្ធ ។

## ៦. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កត្តាមួយចំនួនអាចមានឥទ្ធិពលលើស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ កសស ដូចជា៖

- កម្រិតនៃការជួញដូរក្នុងតំបន់ និងពិភពលោក ៖ ដោយសារតែប្រភពចំណូលចម្បងរបស់ កសស បានមកពីចរាចរណ៍ទំនិញឆ្លងកាត់ធ្វើពាណិជ្ជកម្មជាអន្តរជាតិ ដូចនេះកត្តានានាដែលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ នោះនឹងមានឥទ្ធិពលទៅលើអាជីវកម្មរបស់ កសស ។ កត្តាទាំងនោះមានដូចជាស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក ស្ថេរភាពសង្គម បញ្ហាសន្តិសុខ ឬកិច្ចសហប្រតិបត្តិការនាវាចរតាមសមុទ្រ ។ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,២% សម្រាប់ឆ្នាំ២០២៥ ចំណែកសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៤,៩% យោងតាម ASIAN DEVELOPMENT BANK (ADB) ។ តួលេខនេះបានបង្ហាញថាស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅតែមានភាពធន់ និងរឹងមាំ ដែលជាកត្តាវិជ្ជមានសម្រាប់ អាជីវកម្មកំពង់ផែ ។

- សមត្ថភាព និងប្រសិទ្ធភាពប្រតិបត្តិការរបស់ កសស ៖ បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់ចំណតផែកុងតឺន័របន្ថែមប្រវែង ២៥៣ ម៉ែត្រ ជាមួយនឹងការបំពាក់មធ្យោបាយលើកដាក់កុងតឺន័រ ការបូមស្តារចំណតផែទាំង៣ និងពង្រីកបន្ថែមផ្ទៃទីលាន នាំឱ្យសមត្ថភាពផែសរុបស្មើនឹង ១.០០០.០០០ TEUs ក្នុងមួយឆ្នាំ។ កត្តានេះ ធ្វើឱ្យកើនឡើងសមត្ថភាពផែ ផលិតភាពប្រតិបត្តិការ និងប្រសិទ្ធភាពនៃការលើកដាក់ សម្រាប់បំពេញតម្រូវការរបស់អតិថិជន និងកំណើនបរិមាណកុងតឺន័រឆ្លងកាត់ កសស ។
- ស្ថានភាពបណ្តាញដឹកជញ្ជូនក្នុងស្រុក ៖ កសស ត្រូវបានតភ្ជាប់ជាមួយនឹងបណ្តាញដឹកជញ្ជូនក្នុងប្រទេស តួយ៉ាង ផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៣ និងផ្លូវល្បឿនលឿន ដែលតភ្ជាប់ កសស ទៅកាន់ផ្ទៃក្នុងប្រទេសដោយរលូន ។ ចំណែកឯការដឹកជញ្ជូនតាមផ្លូវដែកបច្ចុប្បន្ន ដោយមានកិច្ចសហការជាមួយក្រុមហ៊ុន Royal Railway បានធ្វើឱ្យការដឹកជញ្ជូនតាមផ្លូវដែកមានចំនួនពី ៦ជើង ទៅ ៧ជើង ក្នុងមួយសប្តាហ៍ ដើម្បីនាំទំនិញចេញ-ចូល ហើយការដឹកជញ្ជូនតាមផ្លូវដែកនេះ ក៏ប្រព្រឹត្តទៅដោយរលូនតាមធម្មតាមិនមានបញ្ហាធ្វើឱ្យខកខានដំណើរនោះទេ ។
- កិច្ចសហការរវាង កសស ជាមួយកំពង់ផែនានា ៖ កសស មានកិច្ចសហការជាមួយកំពង់ផែនានា និងភាគហ៊ុនិកសក្តានុពលជប៉ុន ដើម្បីសម្រួលការនាំទំនិញចេញ-ចូលទៅកាន់ទីផ្សារពិភពលោក ។
- ការរំលស់ ៖ ដោយអាជីវកម្ម (សេវាកម្ម) កសស មានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រើន ចំណាយលើរំលស់លើហេដ្ឋារចនាសម្ព័ន្ធផែដូចជា ចំណតផែ គ្រឿងចក្រ អគារ មានទំហំធំដែលអាចប៉ះពាល់ដល់អាជីវកម្មរបស់ កសស ។ ដូចនេះ កសស ចាំបាច់ត្រូវមានការត្រួតពិនិត្យលើគោលនយោបាយរំលស់ឱ្យបានសមស្រប និងធ្វើការកែតម្រូវ តាមការចាំបាច់រៀងរាល់ការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ ។ នៅក្នុងឆ្នាំ២០២៥ នេះ ពុំមានការកែសម្រួល ឬការស្នើឱ្យមានការកែសម្រួលគោលនយោបាយរំលស់នេះពីសវនកររងករាជ្យឡើយ ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សកម្មភាពអាជីវកម្មរបស់ កសស មានទំនាក់ទំនងដោយផ្ទាល់ជាមួយសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចសាកលលោក ។ ជាពិសេសនៅពេលសេដ្ឋកិច្ចជាតិមានបម្រែបម្រួលនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើអាជីវកម្ម សេវាកម្មកំពង់ផែ ពោលគឺនៅពេលសេដ្ឋកិច្ចជាតិកើនឡើងនាំឱ្យអាជីវកម្ម សេវាកម្ម កំពង់ផែក៏កើនឡើងស្របនឹងនេះផលចំណូលរបស់ កសស ក៏មានកំណើនដូចគ្នា ផ្ទុយទៅវិញ បើសេដ្ឋកិច្ចជាតិថយចុះនឹងមានផលអវិជ្ជមានទៅលើផលចំណូល កសស ផងដែរ ។ យោងតាម ASIAN DEVELOPMENT BANK (ADB) សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រារំពឹងទុកប្រមាណ ៤,៩% ចំណែកសេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ ៣,២% (IMF) នៅក្នុងឆ្នាំ២០២៥ នេះ។ ទោះយ៉ាងណាក៏ដោយ កសស អាចមានកត្តាផលប៉ះពាល់ទៅដល់តម្រូវការ និងការផ្គត់ផ្គង់ដោយសារស្ថានភាពសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងសង្គ្រាមអ៊ីស្រាអែល-ប៉ាលេស្ទីន និងវិបត្តិជាសកល ។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រេងឥន្ធនៈ ជាវត្ថុធាតុដើមចម្បងបំផុតក្នុងការបម្រើសេវាកម្មកំពង់ផែ ដោយជាតម្រូវការសំខាន់នៅក្នុងប្រតិបត្តិការគ្រឿងចក្រ ។ យ៉ាងណាមិញ កសស នៅតែរក្សាតម្លៃសេវារបស់ខ្លួន ទោះបីជា តម្លៃប្រេងឥន្ធនៈមានការកើនឡើង ឬថយចុះក៏ដោយ ។ ហេតុដូចនេះ កសស បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លៃរបស់វត្ថុធាតុដើមទាំងនេះមានភាពសមស្រប និងប្រកួតប្រជែងក្នុងតម្លៃទីផ្សារ ។

### ៣. ការវិភាគលើពន្ធ

កសស ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ហេតុដូចនេះ កសស មានកាតព្វកិច្ចត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន ។ កសស ត្រូវបង់ពន្ធអាករទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំ ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។ ចំពោះពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ចាប់តាំងពីឆ្នាំ២០២០ កសស បានបំពេញកាតព្វកិច្ចបង់ពន្ធក្នុងអត្រា ២០% វិញក្រោយពីទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្ររយៈពេលបីឆ្នាំកន្លងមក ចំណែកពន្ធផ្សេងៗ កសស បានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា ។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់ៗរបស់ កសស ដែលរួមមាន ចំណូលលើកដាក់ ផ្ទេរ-ផ្ទុក និងចំណូលពីសេវាកម្មផែ បានរួមចំណែកប្រមាណ ៩៨% នៃចំណូលសរុប របស់ កសស នៅក្នុង ឆ្នាំ២០២៥ ។ កត្តាចម្បង ដែលជម្រុញឱ្យមានការកើនឡើងនៃប្រាក់ចំណូល គឺកំណើននៃបរិមាណកុងតឺន័រឆ្លងកាត់កំពង់ផែ ។ ការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យសំណង់ និងវិស័យឧស្សាហកម្ម គឺបានឆ្លុះបញ្ចាំងនូវស្ថានភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ទន្ទឹមហ្នឹងនេះក៏មានឥទ្ធិពលជាផលវិជ្ជមានលើអាជីវកម្ម សេវាកម្ម និងផលចំណូលរបស់ កសស ផងដែរ ។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

### ១. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

កសស បានទទួលប្រាក់កម្ចីបន្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី JICA និង JBIC ដោយតម្រូវឱ្យសងប្រាក់ដើម និងការប្រាក់ ជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក នៅពេលដែលរូបិយវត្ថុមុខងាររបស់ កសស គឺជាប្រាក់រៀល ។ ដូចនេះ បម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបទៅនឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលធៀបទៅនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារធៀបទៅនឹងប្រាក់យ៉េនជប៉ុន មានផលប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ កសស ។

### ២. ផលប៉ះពាល់ពីអត្រាការប្រាក់

បច្ចុប្បន្ន កសស មិនមានកម្ចីណាដែលមានអត្រាការប្រាក់ប្រែប្រួលនោះទេ ។ កសស បានទទួលប្រាក់កម្ចីពីរដ្ឋាភិបាលជប៉ុន (JICA និង JBIC) តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងអត្រាការប្រាក់ចាប់ពី ២,៦៥% ដល់ ៣,៧០% ។ ដូចនេះ នៅក្នុងឆ្នាំ២០២៥ កសស ពុំមានផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នោះទេ ។

### ៣. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈនឹងមានផលប៉ះពាល់ទៅដល់លទ្ធផលប្រាក់ចំណេញរបស់ កសស ដោយប្រតិបត្តិការអាជីវកម្មកំពង់ផែ បានប្រើប្រាស់គ្រឿងចក្រលើកដាក់ ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រេងឥន្ធនៈ ។ ដូចនេះ កសស បន្តពង្រឹងប្រសិទ្ធភាពលើកដាក់ និងគ្រប់គ្រងទីលានកុងតឺន័រ ព្រមទាំងការតបណ្ដាញអគ្គិសនីតង់ស្យុងមធ្យម ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកម្ពស់គុណភាពសេវាកម្ម ។

## ង- ផលប៉ះពាល់នៃអតិផរណា

កសស បានរក្សានូវតម្លៃសេវាកម្មរបស់ខ្លួនថេរ ដោយមិនធ្វើការប្រែប្រួល ឬកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុបានយ៉ាងប្រសើរ ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

គោលនយោបាយ សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើអាជីវកម្ម របស់ កសស ដោយសារគោលនយោបាយនេះមានទិសដៅគាំទ្រ និងលើកស្ទួយវិស័យពាណិជ្ជកម្មអន្តរជាតិ ដែលផ្តល់ផលវិជ្ជមានដល់អាជីវកម្មរបស់ កសស ។ គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន៖

- គោលនយោបាយលើកស្ទួយវិស័យឧស្សាហកម្ម៖ រាជរដ្ឋាភិបាលបានរៀបចំផែនការមេ ដើម្បីប្រែក្លាយខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា(IDP) ឆ្នាំ២០១៥-២០២៥ ។
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក៖ រាជរដ្ឋាភិបាលកម្ពុជាមានទស្សនៈវិស័យ និងឆន្ទៈមោះមុតក្នុងការសាងសង់ព្រែកជីកហ្វូណនតេជោ សម្រាប់ឯករាជ្យភាព ពង្រីកការដឹកជញ្ជូនឡូជីស្ទីកតាមផ្លូវទឹក ទៅកាន់កំពង់ផែសមុទ្រអន្តរជាតិរបស់ប្រទេសកម្ពុជា ។
- គោលនយោបាយជម្រុញការដឹកជញ្ជូនតាមផ្លូវល្បឿនលឿនពី ភ្នំពេញ-ខេត្តព្រះសីហនុ ចំណេញពេលវេលា និងចំណាយផ្សេងៗ ។
- គោលនយោបាយជម្រុញការនាំចេញអង្ករ និងផលិតផលកសិ-ឧស្សាហកម្ម ទៅទីផ្សារក្រៅប្រទេស កំពុងផ្តល់ផលវិជ្ជមានដល់ កសស ។
- គោលនយោបាយលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ ដោយខិតខំកាត់បន្ថយឧបសគ្គនានា ចំពោះការធ្វើពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសជាដៃគូក្នុងសាកលលោក ។
- រាជរដ្ឋាភិបាលតាមរយៈធនាគារជាតិ បានអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈយន្តការទីផ្សារប្តូរប្រាក់សេរី តែស្ថិតនៅក្រោមអន្តរាគមន៍ ដើម្បីរក្សាស្ថេរភាពរូបិយប័ណ្ណជាតិ ហើយលំនឹងរូបិយវត្ថុនេះ បានរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលបានកសាងទំនុកចិត្តចំពោះវិនិយោគិន និងជម្រុញការធ្វើអាជីវកម្មវិស័យឯកជន ។
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាន នឹងកំពុងជម្រុញឱ្យសហគ្រាសរដ្ឋ និងក្រុមហ៊ុនឯកជន ចូលទីផ្សារមូលបត្រកាន់តែច្រើន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

# ផ្នែកទី៩

## ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់
## ការពារវិនិយោគិន

នៅក្នុងឆ្នាំ២០២៥ នេះ កសស មានព័ត៌មានចាំបាច់មួយចំនួនសម្រាប់ការពារវិនិយោគិន ដូចខាងក្រោម ៖

- គម្រោងរៀបចំផែនការមេ រហូតដល់ឆ្នាំ២០៥០ នៃការអភិវឌ្ឍប្រែក្លាយ កំពង់ផែស្វយ័តក្រុងព្រះសីហនុជាកំពង់ផែតំបន់ និងមជ្ឈមណ្ឌលឡូជីស្ទិកដែលមិនត្រឹមតែសម្រាប់ប្រទេសកម្ពុជាប៉ុណ្ណោះទេ គឺសម្រាប់អនុតំបន់ទន្លេមេគង្គ និងលើសពីនេះទៀត ដែលជាទស្សនវិស័យដ៏ឈ្លាសវៃបំផុតរបស់ **សម្តេចតេជោ ហ៊ុន សែន** បន្តដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងគាំទ្រពីរដ្ឋាភិបាលជប៉ុន ។
- ខែមករា ឆ្នាំ២០២៥៖ គម្រោងអភិវឌ្ឍន៍ផែនការមេនេះ ទទួលបានគោលការណ៍ឯកភាពជាផ្លូវការពីរដ្ឋាភិបាល ជប៉ុន តាមរយៈការស្នើសុំរបស់ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ។
- ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥៖ រដ្ឋាភិបាលជប៉ុន បានបញ្ជូនក្រុមបេសកកម្ម JICA ដើម្បីសិក្សាផែនការលម្អិត នៃគម្រោងអភិវឌ្ឍន៍ផែនការមេនេះ ដោយបានជួបពិភាក្សាការងារជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និង កសស សម្រេចបានលទ្ធផលប្រកបដោយជោគជ័យ ហើយភាគីទាំងពីរបានឈានដល់ការចុះហត្ថលេខាលើកំណត់ហេតុអង្គប្រជុំ "Minutes of Meeting" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ។

# ហត្ថលេខាអភិបាលរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**លូ គឹមឈន់**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកប្រធានអគ្គនាយក

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**ឈួន វិន**
អភិបាល

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**ផាន់ ផល្លា**
អភិបាល

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**គឹម ស៊ីថន**
អភិបាល

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ុន មុន្នីវណ្ណ**
អភិបាល

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
KUME Hidetoshi
អភិបាល

---

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦
បានអាន និងឯកភាព

ហត្ថលេខា
**លូ លីខេង**
អភិបាល

# ឧបសម្ព័ន្ធ១

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង

# លើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍សវនកម្ម
# ស្តីពីការអនុវត្ត ការត្រួតពិនិត្យផ្ទៃក្នុង
# សម្រាប់ការិយបរិច្ឆេទ ២០២៥

## ផ្នែក ក: ខ្លឹមសារសង្ខេប

### ១. សាវតារ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានធ្វើសវនកម្មលើសកម្មភាពគ្រប់គ្រងប្រតិបត្តិការ អនុលោមភាព និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលដំណើរការដោយ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ សម្រាប់ការិយបរិច្ឆេទ ២០២៥ ដែលជាផ្នែកមួយនៃផែនការសកម្មភាពសវនកម្មឆ្នាំ ២០២៥ ក្នុងកម្មវិធីសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០២៥-២០២៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។ របាយការណ៍នេះ ឆ្លុះបញ្ចាំងអំពីលទ្ធផលសវនកម្ម អនុសាសន៍របស់សវនករ និងវិធានការកែលម្អរបស់សវនដ្ឋាន ។

### ២. ហានិភ័យគន្លឹះ

**ជាទូទៅហានិភ័យរួមមាន៖**

- **ហានិភ័យប្រតិបត្តិការ** : ជាហានិភ័យលើការបាត់បង់ ដែលជាលទ្ធផលបរាជ័យនៃដំណើរការអនុវត្តរបស់មនុស្ស និងប្រព័ន្ធគ្រប់គ្រង ឬ ពីហេតុការណ៍ខាងក្រៅ;
- **ហានិភ័យហិរញ្ញវត្ថុ** : ជាលទ្ធភាពដែលព័ត៌មានផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងមិនត្រឹមត្រូវ ធ្វើឱ្យការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពុំសមស្រប;
- **ហានិភ័យអនុលោមភាព** : ជាលទ្ធភាពដែលសកម្មភាពអនុវត្ត មិនអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

ដោយឡែក ការធ្វើសវនកម្មនៅតាមសវនដ្ឋានខាងលើ សវនករបានកំណត់ហានិភ័យគន្លឹះមួយចំនួនដូចខាងក្រោម៖

- លទ្ធភាពប៉ះពាល់លើគុណភាពនៃការផ្តល់សេវាកម្មសាធារណៈ;
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងបុគ្គលិក វិន័យ និងប្រសិទ្ធភាពការងារ;
- លទ្ធភាពប៉ះពាល់ដល់អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន; និង
- លទ្ធភាពប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

### ៣. វិសាលភាពសវនកម្ម

ដំណើរការសវនកម្មនេះ គ្របដណ្តប់លើសកម្មភាពគ្រប់គ្រង និងកិច្ចប្រតិបត្តិការដែលអនុវត្តដោយនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ណជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ សម្រាប់ការិយបរិច្ឆេទ ២០២៥ ។ ការប្រមូលព័ត៌មានសវនកម្មនិងការធ្វើសវនកម្ម ត្រូវបានធ្វើឡើងនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ **កសស** ។ ក្រុមការងារសវនកម្មនឹងរាយការណ៍តែអំពីចំណុចខ្វះខាត និងចំណុចដែលត្រូវផ្តល់អនុសាសន៍កែលម្អប៉ុណ្ណោះ ។

របាយការណ៍សវនកម្មជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងពីរបាយការណ៍សវនកម្មជាភាសាខ្មែរ ។ ក្នុងករណីមានភាពខុសប្លែកគ្នារវាងភាសាទាំងពីរ របាយការណ៍សវនកម្មជាភាសាខ្មែរ ត្រូវមានអាទិភាពក្នុងការបកស្រាយ។

## ៤. គោលបំណងសវនកម្ម

គោលបំណងក្នុងការធ្វើសវនកម្មនេះ គឺដើម្បីវាយតម្លៃនិងធ្វើឱ្យប្រសើរឡើង នូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អក្នុងទីសវនកម្ម ដែលស្ថិតក្នុងវិសាលភាពសវនកម្ម។

ជាទូទៅ ការងារសវនកម្មផ្តោតសំខាន់លើការបញ្ជាក់ថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្តល់នូវការធានាសមហេតុផល ដើម្បីសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- **គោលបំណងប្រតិបត្តិការ** : ការសម្រេចបានប្រកបដោយប្រសិទ្ធភាព នូវគោលបំណងប្រតិបត្តិការការងារជាក់ស្តែង;
- **គោលបំណងព័ត៌មានហិរញ្ញវត្ថុ** : ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ;
- **គោលបំណងអនុលោមភាព** : ការអនុលោមតាមច្បាប់ គោលការណ៍ និងនីតិវិធីជាធរមាន។

ក្នុងការធ្វើសវនកម្មនេះ សវនករបានកំណត់គោលបំណងសវនកម្មសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលការងារ;
- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពគ្រប់គ្រង និងសុវត្ថិភាពឯកសារអាជីវកម្ម;
- ពង្រឹងអនុលោមភាព និងសុវត្ថិភាពបើកបររថយន្តដឹកកុងតឺន័ររបស់ **កសស**;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពគ្រប់គ្រងរថយន្ត និងគ្រឿងចក្ររបស់ **កសស**;
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងទំនិញ នៅក្នុងឃ្លាំងនិងទីលានទំនិញទូទៅ;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពអនុវត្តជំនាញបច្ចេកទេស;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់ របស់ **កសស**;
- ពង្រឹងអនុលោមភាព និងប្រសិទ្ធភាពគ្រប់គ្រងឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់
- ពង្រឹងការគ្រប់គ្រងសណ្តាប់ធ្នាប់ បរិស្ថាន និងថែរក្សាទ្រព្យសម្បត្តិរបស់ **កសស**;
- ពង្រឹងប្រសិទ្ធភាពអនុវត្ត និងបង្ការការកកស្ទះប្រព័ន្ធប្រឡាយបង្ហូរទឹកនៅក្នុង **តសព**;
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងប្រសិទ្ធផលការងារនៅក្នុង **តសព**;
- ពង្រឹងប្រសិទ្ធភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យា ក្នុងប្រតិបត្តិការលើកដាក់កុងតឺន័រ;
- ពង្រឹងគ្រប់គ្រង និងប្រសិទ្ធភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **កសស**;
- ពង្រឹងប្រសិទ្ធភាពអនុវត្តប្រព័ន្ធបច្ចេកវិទ្យា និងការផ្សព្វផ្សាយព័ត៌មាននៅក្នុងគេហទំព័ររបស់ **កសស**;
- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពនិងគុណភាពសេវាកម្មរបស់ **កសស**;
- ពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងបណ្តាញអគ្គិសនីរបស់ **កសស**; និង
- ពង្រឹងអនុលោមភាព ប្រសិទ្ធភាពគ្រប់គ្រង និងសុវត្ថិភាពឯកសារ។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតសំខាន់លើដំណើរការមានហានិភ័យ ដែលត្រូវបានប្រើប្រាស់ក្នុងការងារសវនកម្មនេះ ។ អភិក្រមសវនកម្មរាប់បញ្ចូល៖

- ការកត់ត្រាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង តាមរយៈការត្រួតពិនិត្យឯកសារពាក់ព័ន្ធ និងការសម្ភាសន៍មន្រ្តី;
- ការកំណត់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគន្លឹះ និងប្រៀបធៀបជាមួយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលបានរំពឹងទុក; និង
- ការធ្វើតេស្តសវនកម្មអំពីប្រសិទ្ធភាពប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ។

តាមរយៈនេះ ក្រុមការងារសវនកម្ម បានសហការជាមួយថ្នាក់ដឹកនាំសវនដ្ឋាន ដើម្បីកំណត់ការរំពឹងទុក ។

## ៦. សង្ខេបលទ្ធផលគន្លឹះ

**ក្រុមការងារសវនកម្ម បានសង្កេតឃើញចំណុចខ្វះចន្លោះមួយចំនួន តាមរយៈការពិនិត្យ៖**

១- វិក្កយបត្រអាកររបស់ **កសស**;
២- ទីកន្លែងរក្សាទុកឯកសារទន់និងឯកសាររឹង របស់នាយកដ្ឋានអាជីវកម្ម;
៣- បណ្ណបើកបរនិងវគ្គបណ្តុះបណ្តាល សម្រាប់អ្នកបើកបរថយន្តដឹកកុងតឺន័រ;
៤- តារាងត្រួតពិនិត្យគ្រឿងចក្រ;
៥- របាយការណ៍គ្រប់គ្រងឃ្លាំង និងទីលានទំនិញទូទៅ;
៦- វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសប្រតិបត្តិការទំនិញទូទៅ;
៧- របាយការណ៍ស្តីពីវឌ្ឍនភាពការងារ របស់នាយកដ្ឋាននាវាចរ-កណ្តូជារ;
៨- បូឡាដពាក់ពួរនាវា នៅចំណតលេខ VI, VII, VIII, IX, XI និង XII;
៩- ការគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់របស់ **កសស**;
១០- ស្ថានភាពឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់;
១១- ស្ថានភាពទីលានកុងតឺន័ររបស់ **កសស**;
១២- ស្ថានភាពបរិស្ថានក្នុងបរិវេណអ៊ូនាវា;
១៣- ប្រព័ន្ធបង្ហូរទឹក (ប្រឡាយ) នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស;
១៤- កំណត់ហេតុប្រជុំសេវាអតិថិជនប្រចាំខែ;
១៥- ការគ្រប់គ្រង ត្រួតពិនិត្យ និងថែទាំបណ្តាញ Network នៅក្នុងក្របខ័ណ្ឌ **កសស**;
១៦- ការបណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន **កសស**;
១៧- ការធ្វើបច្ចុប្បន្នភាពវីដេអូផ្សព្វផ្សាយអំពី **កសស**;
១៨- របាយការណ៍លទ្ធផលនៃដំណើរការទស្សនកិច្ចសិក្សាស្រាវជ្រាវ និងស្វែងយល់ពីក្រុមហ៊ុន អ្នកប្រើប្រាស់ផែ និងភាគីពាក់ព័ន្ធរបស់ **កសស** សម្រាប់ខែឧសភា-មិថុនា ឆ្នាំ ២០២៥;
១៩- របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី;
២០- ការផ្គត់ផ្គង់ និងគ្រប់គ្រងបណ្តាញអគ្គិសនីរបស់ **កសស**;
២១- ការអនុវត្តវិធានការសន្តិសុខឋបនីយកណ្ឌផែ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**);
២២- ការតាមដាន ត្រួតពិនិត្យ ការអនុវត្តបទបញ្ជាផ្ទៃក្នុង-សុវត្ថិភាពពលកម្ម និងការងារបណ្តុះបណ្តាលមន្ត្រី-និយោជិត កម្មករ របស់ **កសស**;
២៣- បង្កាន់ដៃទទួលប្រាក់អេឡិចត្រូនិក (PAS E-Receipt) របស់ **កសស**;
២៤- មុខងារផ្លាស់ប្តូរប្រភេទទទួលប្រាក់ (Payment Type) និងមុខងារបញ្ចូលវិក្កយបត្រចូលក្នុងកន្ត្រកបង់ប្រាក់សម្រាប់ប្រព័ន្ធ SWSS;
២៥- ការគ្រប់គ្រង និងរក្សាទុកទិន្នន័យអាជីវកម្ម; និង
២៦- របាយការណ៍វឌ្ឍនភាពការងារ គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំហានទី ១ ប្រចាំខែធ្នូ ឆ្នាំ ២០២៥។

## ៧. សេចក្ដីសន្និដ្ឋានរួម

ផ្អែកតាមលទ្ធផលសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០២៥ នៅនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដាល ជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ ក្រុមការងារសវនកម្មបានពិនិត្យឃើញថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយចំនួនត្រូវបានរៀបចំបានល្អប្រសើរ និងមានកិច្ចសហការពីមន្ត្រី បុគ្គលិក កម្មករ គ្រប់ជាន់ថ្នាក់ ទោះបីជាការអនុវត្តមួយចំនួននៅមិនទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនៅពេលអនាគតក៏ដោយ។ ក្រុមការងារសវនកម្មបានកត់សម្គាល់ឃើញថា ចំណុចខ្វះខាតខាងលើពាក់ព័ន្ធនឹងអនុលោមភាពតាមច្បាប់ ប្រសិទ្ធភាពអនុវត្ត និងប្រសិទ្ធផលនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើការពង្រឹងនិងកែលម្អជាបន្តបន្ទាប់ ។

## ៨. វិធានការកែលម្អ

អនុសាសន៍ដែលបានផ្ដល់ជូន ក្នុងគោលបំណងដើម្បីធ្វើឱ្យល្អប្រសើរឡើង នូវការអនុវត្តដំណើរការធុរកិច្ច និងការគ្រប់គ្រងរបស់សវនដ្ឋាន ត្រូវបានបញ្ចូលក្នុងលទ្ធផលលម្អិត (**ផ្នែក ខ**)។ អនុសាសន៍អំពីការខ្វះចន្លោះមួយចំនួនត្រូវបានឯកភាព ជាមួយថ្នាក់ដឹកនាំសវនដ្ឋាននីមួយៗជាលាយលក្ខណ៍អក្សរ ។ លទ្ធផលលម្អិត (**ផ្នែក ខ**) ក៏បានរំលេចអំពីការឆ្លើយតបរបស់ថ្នាក់ដឹកនាំសវនដ្ឋាន ចំពោះអនុសាសន៍របស់សវនករ និងចំណុចខ្វះខាតផងដែរ។

វិធានការរបស់ថ្នាក់ដឹកនាំសវនដ្ឋាន ត្រូវបានរំលេចនៅក្នុងផែនការកែលម្អដូចមានចែងនៅក្នុង **ឧបសម្ព័ន្ធ ទី ២** ដែលបានភ្ជាប់មកជាមួយ ។

## ៩. អំណរគុណ

ក្រុមការងារសវនកម្មដែលដឹកនាំដោយលោក **ម៉ែន ចាន់** សូមថ្លែងអំណរគុណចំពោះលោកនាយក លោកស្រីនាយិកា នៃនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្ដាលជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ ព្រមទាំងសហការីដែលបានសហការផ្ដល់ព័ត៌មាន ឯកសារនិងមតិយោបល់ដ៏មានតម្លៃ ដើម្បីជួយជំរុញឱ្យការងារសវនកម្មនេះអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក ។

# ផ្នែក ខ: លទ្ធផលសវនកម្មលម្អិត

## ១. សមាសភាពចូលរួម និងខណ:គោល

### ១.១ សមាសភាពក្រុមការងារសវនកម្មផ្ទៃក្នុង

| | | |
|---|---|---|
| - លោក ម៉ែន ចាន់ | នាយក | ប្រធានក្រុម |
| - លោក ជីវ ច័ន្ទសុភាព | នាយករង | អនុប្រធាន |
| - លោក ហោ សុធី | នាយករង | អនុប្រធាន |
| - លោក មាស សុវណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ទូច វណ្ណា | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី រ័ត្ន និមល | ប្រធានការិយាល័យ | សមាជិក |
| - លោកស្រី ខន សុខុម | បុគ្គលិក | សមាជិក |
| - លោកស្រី ឈុន ហឿនរីណា | បុគ្គលិក | សមាជិក |
| - លោក ភាព ម៉េងស្រៀន | បុគ្គលិក | សមាជិក |
| - លោកស្រី តេង សុវណ្ណស្រីរ័ត្ន | បុគ្គលិក | សមាជិក |

### ១.២ សមាសភាពចូលរួមរបស់សវនដ្ឋាន

#### ១.២.១ នាយកដ្ឋានអាជីវកម្ម

| | | |
|---|---|---|
| - លោក ងួន រតនា | នាយក | សវនដ្ឋាន |
| - លោក ស៊ូ ឡុងស៊្រីន | នាយករង | សវនដ្ឋាន |

#### ១.២.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ

| | | |
|---|---|---|
| - លោក ថៃ ម៉េងលី | នាយក | សវនដ្ឋាន |
| - លោក ហ៊ាង សុផល | នាយករង | សវនដ្ឋាន |
| - លោក សេក សុវណ្ណារ៉ា | នាយករង | សវនដ្ឋាន |

#### ១.២.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ

| | | |
|---|---|---|
| - លោក លូ លីខេង | នាយក | សវនដ្ឋាន |
| - លោក អ៊ុក សុវណ្ណារិទ្ធិ | នាយករង | សវនដ្ឋាន |
| - លោក យឹង កុយ | នាយករង | សវនដ្ឋាន |

#### ១.២.៤ នាយកដ្ឋាននាវាចរ-កណ្តាប់ដៃ

| | | |
|---|---|---|
| - លោក ស៊ឹង សេណូ | នាយក | សវនដ្ឋាន |
| - លោក ចាន់ សុខា | នាយករង | សវនដ្ឋាន |
| - លោក សែន សុថា | នាយករង | សវនដ្ឋាន |

#### ១.២.៥ នាយកដ្ឋានបច្ចេកទេស-សម្ភារ

| | | |
|---|---|---|
| - លោក អ៊ុក វណ្ណារ៉ា | នាយក | សវនដ្ឋាន |
| - លោក ជា ចាន់ថន | នាយករង | សវនដ្ឋាន |
| - លោកស្រី សរ ម៉ាលីន | នាយិការង | សវនដ្ឋាន |

#### ១.២.៦ នាយកដ្ឋានសំណង់-វិស្វកម្ម

| | | |
|---|---|---|
| - លោក មាន គឹង | នាយក | សវនដ្ឋាន |
| - លោក ងឹម ញ៉ | នាយករង | សវនដ្ឋាន |
| - លោក ឈឹម ហ៊ា | នាយករង | សវនដ្ឋាន |

### ១.២.៧ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស

| | | |
|---|---|---|
| - លោក ជីវ ច័ន្ទសុផល | នាយក | សវនដ្ឋាន |
| - លោក ហេង សុខសាន្ត | នាយករង | សវនដ្ឋាន |
| - លោក ហាក់ ណារិទ្ធ | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.៨ នាយកដ្ឋានព័ត៌មានវិទ្យា

| | | |
|---|---|---|
| - លោក សោម ករណី | នាយក | សវនដ្ឋាន |
| - លោក សួន ប៊ុនសុង | នាយករង | សវនដ្ឋាន |

### ១.២.៩ នាយកដ្ឋានទីផ្សារ

| | | |
|---|---|---|
| - អ្នកស្រី ជ័យ សុគន្ធា | នាយិកា | សវនដ្ឋាន |
| - លោក យិន វី | ប្រធានការិយាល័យ | សវនដ្ឋាន |
| - លោក ម៉ៅ សាម៉ន | ប្រធានការិយាល័យ | សវនដ្ឋាន |

### ១.២.១០ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី

| | | |
|---|---|---|
| - លោក គីម ហោ | នាយក | សវនដ្ឋាន |
| - លោក គីម ហួន | នាយករង | សវនដ្ឋាន |

### ១.២.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស

| | | |
|---|---|---|
| - លោក រ័ត្ន សិលា | នាយក | សវនដ្ឋាន |
| - លោក សាន ឈន់ | នាយករង | សវនដ្ឋាន |

### ១.២.១២ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

| | | |
|---|---|---|
| - លោក ពិត ប្រាកដ | នាយក | សវនដ្ឋាន |
| - លោក អ៊ុក រតនា | នាយករង | សវនដ្ឋាន |

### ១.២.១៣ នាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ

| | | |
|---|---|---|
| - លោក សូ សៀង | នាយក | សវនដ្ឋាន |
| - លោក អ៊ុក សុមេធី | នាយករង | សវនដ្ឋាន |

## ១.៣ ខណៈគោល

**ខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្ម៖**

| | |
|---|---|
| ➢ សេចក្តីព្រាងលើកទី ១ បានបញ្ចប់ | ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២៦ |
| ➢ ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៦ |
| ➢ ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំសវនដ្ឋាន | ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៦ |
| ➢ របាយការណ៍ស្ពាពរ | ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២៦ |

## ២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុង គឺដើម្បីជួយថ្នាក់ដឹកនាំសវនដ្ឋាន ក្នុងដំណើរការគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនិងអភិបាលកិច្ចល្អ ។ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងត្រូវបានអនុវត្ត ដោយថ្នាក់ដឹកនាំសវនដ្ឋាននិងមន្ត្រីមួយចំនួនទៀត ដើម្បីធានាឱ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ
- របាយការណ៍ហិរញ្ញវត្ថុដែលអាចទុកចិត្តបាន
- អនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន ។

ការធ្វើសវនកម្មនេះ ក៏ពិនិត្យលើការរៀបចំនិងប្រតិបត្តិការ នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផងដែរ ។

## ៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

ក្រុមការងារសវនកម្ម បានវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដោយផ្អែកលើសមត្ថភាពនៃដំណើរការគ្រប់គ្រងដើម្បីសម្រេចលក្ខណៈវិនិច្ឆ័យគ្រប់ចំនួន ៧ រួមមាន៖ ការផ្តល់សិទ្ធិ ភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព ការការពារសុវត្ថិភាពនិងសន្តិសុខរូបវន្ត ការដោះស្រាយកំហុសឆ្គងនិងការបែងចែកការងារ ស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ចរបស់ នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តួជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ ។

## ៤. ព័ត៌មានអំពីសវនដ្ឋាន

នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តួជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ ស្ថិតក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឡើងនិងការប្រព្រឹត្តិទៅនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) និងដំណើរការតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធនិងតួនាទី-ភារកិច្ច សម្រាប់នាយកដ្ឋាននីមួយៗ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **កសស** ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ និងសេចក្តីសម្រេចកែសម្រួលរចនាសម្ព័ន្ធ និងការបំពេញបន្ថែមតួនាទី-ភារកិច្ច ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២០ ។

### ៤.១ នាយកដ្ឋានអាជីវកម្ម (អជក)

នាយកដ្ឋានអាជីវកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៣ នាក់ ក្នុងនេះមានស្ត្រី ២ នាក់ បុគ្គលិកកិច្ចសន្យា ១ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ២ រូប និងប្រធានការិយាល័យ ៥ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៦៤ សសរ/កសស/អជក ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០២០, សេចក្តីសម្រេចលេខ ២០៣, ៣៨១ និង ៣៨២ សសរ.តត/កសស/រប.ធម ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២១ និងថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២២៖

(១) ការិយាល័យអាជីវកម្ម និងសរុបរបាយការណ៍;
(២) ការិយាល័យប្រតិបត្តិការ និងកិច្ចសន្យា;
(៣) ការិយាល័យគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ;
(៤) ការិយាល័យស្រាវជ្រាវ-អភិវឌ្ឍន៍ និងគ្រប់គ្រងការដឹកជញ្ជូន; និង
(៥) ការិយាល័យតំណាង **កសស** ប្រចាំភ្នំពេញ ។

### ៤.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ (ប្រទក)

នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ៥៩៥ នាក់ ក្នុងនេះមានស្ត្រី ៥៣ នាក់ បុគ្គលិកកិច្ចសន្យា ៩៣ នាក់ និងត្រូវបាន ដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៣ រូប និងប្រធានការិយាល័យ ៨ រូបជាជំនួយការ ស្រប តាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៨ សសរ/កសស/ប្រទក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យទិន្នន័យ និងរបាយការណ៍;
(២) ការិយាល័យផែនការនាវា;
(៣) ការិយាល័យផែនការទីលាន;
(៤) ការិយាល័យប្រតិបត្តិការ;
(៥) ការិយាល័យគ្រប់គ្រងបុគ្គលិក;
(៦) ការិយាល័យគ្រឿងចក្រ;
(៧) ការិយាល័យទីលានសំបកកុងតឺន័រ (ECD) ; និង
(៨) ការិយាល័យឃ្លាំង (LCL) ។

### ៤.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ (ប្រទទ)

នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក សរុបចំនួន ២០២ នាក់ ក្នុងនេះមានស្ត្រី ១០ នាក់ បុគ្គលិកកិច្ចសន្យា ៨ នាក់ និងត្រូវបានដឹកនាំដោយ នាយក ១ រូប អមដោយនាយករង ២ រូប និងប្រធានការិយាល័យ ៦ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៩ សសរ/កសស/ប្រទទ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០។

(១) ការិយាល័យស្រាវជ្រាវ-អភិវឌ្ឍន៍ និងគ្រប់គ្រងសុវត្ថិភាព;
(២) ការិយាល័យគ្រប់គ្រង ឃ្លាំង-ទីលានទំនិញទូទៅ;
(៣) ការិយាល័យកត់ត្រា-ដញ្ជីង និងគ្រប់គ្រងព័ត៌មាននាវា;
(៤) ការិយាល័យគ្រប់គ្រងឯកសារ និងរបាយការណ៍;
(៥) ការិយាល័យគ្រឿងចក្រទំនិញទូទៅ; និង
(៦) ការិយាល័យលើកដាក់ទំនិញ ។

### ៤.៤ នាយកដ្ឋាននាវាចរ-កណ្ណធារ (នវកធ)

នាយកដ្ឋាននាវាចរ-កណ្ណធារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិក សរុបចំនួន ១១៩ នាក់ ក្នុងនេះមានស្ត្រី ២ នាក់ បុគ្គលិកកិច្ចសន្យា ៩ នាក់ និងត្រូវបានដឹកនាំដោយ នាយក ១ រូប អមដោយនាយករង ៤ រូប ប្រធានការិយាល័យ ៧ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ១៣៦ សសរ/កសស/នវកធ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២៥ ៖

(១) ការិយាល័យ កណ្ណធារ;
(២) ការិយាល័យ ទិន្នន័យ និងសរុប;
(៣) ការិយាល័យ នាវាចរ;
(៤) ការិយាល័យ VTMS និង បណ្តុះបណ្តាល;
(៥) ការិយាល័យ គ្រប់គ្រងមធ្យោបាយជើងទឹក;
(៦) ការិយាល័យ គ្រប់គ្រងអាងនាវាសណ្តោង; និង
(៧) ការិយាល័យ យន្តសាស្ត្រនាវាសណ្តោង ។

### ៤.៥ នាយកដ្ឋានបច្ចេកទេស-សម្ភារ (បទស)

នាយកដ្ឋានបច្ចេកទេស-សម្ភារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** មានមន្ត្រី បុគ្គលិកសរុបចំនួន ៧៣ នាក់ ក្នុងនេះមានស្ត្រី ៣ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៣ រូប និងប្រធានការិយាល័យ ៩ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០២៥ សសរ/កសស/បទស ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២៥។

(១) ការិយាល័យ សម្ភារបច្ចេកទេស-បន្ទាស់;
(២) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្ម;
(៣) ការិយាល័យ ឃ្លាំងសម្ភារបច្ចេកទេស-បន្ទាស់;
(៤) ការិយាល័យ ប្រេងឥន្ធនៈ-ប្រេងរំអិល;
(៥) ការិយាល័យ ស្រាវជ្រាវអភិវឌ្ឍន៍;
(៦) ការិយាល័យ ព័ត៌មានវិទ្យា;
(៧) ការិយាល័យ ជួសជុល-ថែទាំ មេកានិចគ្រឿងចក្រ ;
(៨) ការិយាល័យ យានដ្ឋាន; និង
(៩) ការិយាល័យ យន្តសាស្ត្រ កប៉ាល-នាវាសណ្តោង ។

### ៤.៦ នាយកដ្ឋានសំណង់-វិស្វកម្ម (សណវក)

នាយកដ្ឋានសំណង់-វិស្វកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ **(កសស)** មានមន្ត្រី បុគ្គលិកសរុបចំនួន ១២០ នាក់ ក្នុងនេះមានស្ត្រី ២ នាក់ បុគ្គលិកកិច្ចសន្យា ១៦ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៥ រូប និងប្រធានការិយាល័យ ១១ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០២៤ សសរ/កសស/សណវក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២០។

(១) ការិយាល័យ សំណង់-ជួសជុល និងថែទាំ;
(២) ការិយាល័យ អគ្គិសនី;
(៣) ការិយាល័យ ស្ថាបត្យកម្ម និងសិក្សាគម្រោង;
(៤) ការិយាល័យ ឃ្លាំងសម្ភារសំណង់;
(៥) ការិយាល័យ គ្រប់គ្រងឯកសារលទ្ធកម្មសំណង់;
(៦) ការិយាល័យ វិស្វកម្ម;
(៧) ការិយាល័យ វាស់ស្ទង់;
(៨) ការិយាល័យ សរុបនិងរបាយការណ៍;
(៩) ការិយាល័យ គ្រឿងចក្រសំណង់;
(១០) ការិយាល័យ ឃ្លាំងប្រេង;
(១១) ការិយាល័យ អ៊ូនាវា; និង
(១២) ការិយាល័យ ពោងសញ្ញា ។

### ៤.៧ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១២ នាក់ ក្នុងនេះមានស្ត្រី ១ នាក់ និងបុគ្គលិកកិច្ចសន្យា ១ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៣ រូប និងប្រធានការិយាល័យ ៣ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ៣៩៧ សសរ/កសស/តសព ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០៖

(១) ការិយាល័យ រដ្ឋបាល និងព័ត៌មានវិទ្យា;
(២) ការិយាល័យ ភ័ស្តុភារ និងស្រាវជ្រាវ-អភិវឌ្ឍន៍;
(៣) ការិយាល័យ សេវាអតិថិជន; និង
(៤) ការិយាល័យ ថែទាំនិងជួសជុល ។

### ៤.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

នាយកដ្ឋានព័ត៌មានវិទ្យា នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៨ នាក់ ក្នុងនេះមានស្ត្រី ១ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ១ រូប និងប្រធានការិយាល័យ ៣ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ១១៥ សសរ/កសស/ពម.វ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវ-អភិវឌ្ឍន៍ និងផ្សព្វផ្សាយ;
(២) ការិយាល័យ គ្រប់គ្រងបណ្តាញ; និង
(៣) ការិយាល័យ ប្រព័ន្ធព័ត៌មានវិទ្យា ។

### ៤.៩ នាយកដ្ឋានទីផ្សារ (ទផ)

នាយកដ្ឋានទីផ្សារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១២ នាក់ ក្នុងនេះមានស្ត្រី ៤ នាក់ បុគ្គលិកជាប់កិច្ចសន្យា ២ នាក់ និងត្រូវបានដឹកនាំដោយនាយិកា ១ រូប អមដោយប្រធានការិយាល័យ ៣ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ២២៧ សសរ/កសស/ទផ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០៖

(១) ការិយាល័យ ស្រាវជ្រាវទីផ្សារ និងអភិវឌ្ឍគុណភាពសេវាកម្ម;
(២) ការិយាល័យ ព័ត៌មានទីផ្សារ;
(៣) ការិយាល័យ ទំនាក់ទំនងអតិថិជន; និង
(៤) ការិយាល័យ សម្របសម្រួល ។

### ៤.១០ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី (គ្រច)

នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ៥៨ នាក់ ក្នុងនេះមានស្ត្រី ៣ នាក់ និងបុគ្គលិកកិច្ចសន្យា ១៤ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ២ រូប និងប្រធានការិយាល័យ ៦ រូបជាជំនួយការស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០២៦ សសរ/កសស/គ្រច ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២៥៖

(១) ការិយាល័យ ថែទាំ ជួសជុលគ្រឿងចក្រ;
(២) ការិយាល័យ ស្ថិតិគ្រឿងចក្រ;
(៣) ការិយាល័យ ស្ថានីយអគ្គិសនី;
(៤) ការិយាល័យ រោងជាងអគ្គិសនី;
(៥) ការិយាល័យ ជួសជុលបរិក្ខារអគ្គិសនី;និង
(៦) ការិយាល័យ ថែទាំ-ជួសជុលបបនីយភណ្ឌអគ្គិសនី។

### ៤.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស (រប.ធម)

នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៥១ នាក់ ក្នុងនេះមានស្ត្រី ៣៧ នាក់ បុគ្គលិកជាប់កិច្ចសន្យា ៦១ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៥ រូប ប្រធានការិយាល័យ ១២ រូប និងជំនួយការឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលឋានៈស្មើប្រធានការិយាល័យ ១ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ចដូចមានចែងនៅក្នុងសេចក្ដីសម្រេចលេខ ១៣៧ សសរ/កសស/រប.ធម ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៥ ។

(១) ការិយាល័យ ទំនាក់ទំនងសាធារណៈ;
(២) ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ;
(៣) ការិយាល័យ ថែទាំ និងជួសជុល;
(៤) ការិយាល័យ គ្រប់គ្រងឃ្លាំងសម្ភាររដ្ឋបាល;
(៥) ការិយាល័យ គ្រប់គ្រងមធ្យោបាយ និងប្រេងឥន្ធនៈ;
(៦) ការិយាល័យ ធនធានមនុស្ស និងព័ត៌មានវិទ្យា;
(៧) ការិយាល័យ ថែទាំសុខភាព;
(៨) ការិយាល័យ បរិស្ថាន និងអនាម័យ;
(៩) ការិយាល័យ គម្រោង;
(១០) ការិយាល័យ សន្តិសុខ និងសុវត្ថិភាព;
(១១) ការិយាល័យ រៀបចំសណ្ដាប់ធ្នាប់សាធារណៈ; និង
(១២) ការិយាល័យ ស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

### ៤.១២ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ (គណ.ហិ/វ)

នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ២១ នាក់ ក្នុងនេះមានស្ត្រី ៩ នាក់ និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ៣ រូប និងប្រធានការិយាល័យ ៧ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្ដីសម្រេចលេខ ០៦២ សសរ/កសស/គណ.ហវ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០២០ ។

(១) ការិយាល័យ បេឡា
(២) ការិយាល័យ គណនេយ្យ;
(៣) ការិយាល័យ អចលនទ្រព្យ;
(៤) ការិយាល័យ ទីផ្សារមូលបត្រ;
(៥) ការិយាល័យ ហិរញ្ញកិច្ច;
(៦) ការិយាល័យ គ្រប់គ្រងបំណុល; និង
(៧) ការិយាល័យ ទូទាត់ ។

### ៤.១៣ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ (ផលស)

នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានមន្ត្រី បុគ្គលិកសរុបចំនួន ១៤ នាក់ ក្នុងនេះមានស្ត្រី ៦ រូប និងត្រូវបានដឹកនាំដោយនាយក ១ រូប អមដោយនាយករង ២ រូប និងប្រធានការិយាល័យ ៤ រូបជាជំនួយការ ស្របតាមតួនាទី-ភារកិច្ច ដូចមានចែងនៅក្នុងសេចក្ដីសម្រេចលេខ ២២៦ សសរ/កសស/ផលស ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០ ។

(១) ការិយាល័យ ផែនការ-វិនិយោគ;
(២) ការិយាល័យ លទ្ធកម្មសាធារណៈ;
(៣) ការិយាល័យ ស្ថិតិ; និង
(៤) ការិយាល័យ គ្រប់គ្រងគម្រោង ។

# ៥. លទ្ធផលសវនកម្ម

## ៥.១ ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មរបស់ **កសស** ក្នុងគោលបំណងដើម្បីផ្តល់សេវាកម្ម ជូនអតិថិជននិងអ្នកប្រើប្រាស់ផែប្រកបដោយភាពរលូន និងឆាប់រហ័ស និងជួយជំរុញឱ្យសវនដ្ឋាននីមួយៗ អនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីកំណត់និងតម្រូវការរបស់អង្គភាព និងអនុលោមតាមលក្ខន្តិកៈបុគ្គលិករបស់ **កសស** ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ៥.២ លទ្ធផលនៃការអង្កេតវិជ្ជមាន

ក្រុមការងារសវនកម្មបានពិនិត្យឃើញថា នាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលជារ នាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ រួមទាំងការិយាល័យនិងផ្នែកពាក់ព័ន្ធ បាននិងកំពុងអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី-ភារកិច្ចដែល **កសស** បានកំណត់ និងបានយកចិត្តទុកដាក់អនុវត្តការងារតាមមុខជំនាញរៀងៗខ្លួន ក្នុងស្មារតីទទួលខុសត្រូវ និងសហការផ្តល់ឯកសារជូនសវនករ ដើម្បីជួយជំរុញឱ្យកិច្ចដំណើរការសវនកម្មផ្ទៃក្នុងរបស់ **កសស** អាចប្រព្រឹត្តទៅបានស្របតាមផែនការសកម្មភាពការងារសវនកម្ម និងប្រកបដោយភាពរលូន ។

## ៥.៣ លទ្ធផលនៃការអង្កេតអវិជ្ជមាន

### ៥.៣.១ នាយកដ្ឋានអាជីវកម្ម (អជក)

#### ៥.៣.១.១ វិក្កយបត្រអាកររបស់ កសស

យោងតាមការពិនិត្យវិក្កយបត្រអាកររបស់ **កសស** ដែលត្រូវបាននិងកំពុងអនុវត្តដោយនាយកដ្ឋានអាជីវកម្ម សវនករបានកត់សម្គាល់ឃើញមានការរៀបចំជា វិក្កយបត្រស្តង់ដាសមស្របសម្រាប់គិតប្រាក់ Port Charges for Vessel Services, Delivery of Import Cargo, Delivery of Import Container និង Container Export ដោយយោង Delivery Order/ Release Order រួមទាំងឯកសារ Booking/ប្រតិវេទន៍គយ និងលិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន។

ទោះជាយ៉ាងនេះក្តី សវនករបានសង្កេតឃើញថា សវនដ្ឋាននៅមានបញ្ហាប្រឈមខ្លះៗនិងពុំទាន់អាចដំណើរការវិក្កយបត្រអាករដោយរលូននៅឡើយ ពីព្រោះនៅពេល Print វិក្កយបត្រច្រើនក្នុងពេលតែមួយ ប្រព័ន្ធតែងតែ Error ជាហេតុបណ្តាលឱ្យរំលងលេខរៀងមួយចំនួន និងត្រូវធ្វើការផ្ទៀងផ្ទាត់ជាចាំបាច់ ទើបអាចយកលេខរៀងរំលងទាំងនោះមកប្រើវិញបាន។

ប្រការខាងលើ អាចបណ្តាលឱ្យការ Process ឯកសារ/វិក្កយបត្រអាករមានភាពយឺតយ៉ាវ និងពុំទាន់សមស្របតាមតម្រូវការរបស់អតិថិជន។

ករណីនេះ អាចបណ្តាលមកពីប្រព័ន្ធ ឬ ការ Print ឯកសារចេញដើម្បីយកលេខវិក្កយបត្រពី Computers ច្រើនគ្រឿងក្នុងពេលតែមួយ ជាពិសេសនៅថ្ងៃដែលមានអតិថិជនច្រើនមកគិតថ្លៃសេវា ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ការគិតតម្លៃ (អត្រាប្តូរប្រាក់) ក្នុងករណីមានការគិតប្រាក់ឆ្លងថ្ងៃ និងនៅពុំទាន់សមស្របតាមធុរកិច្ចឌីជីថល។

សវនដ្ឋាន គួរជូនដំណឹងទៅនាយកដ្ឋានជំនាញ និងសហការរកដំណោះស្រាយឱ្យបានឆាប់ ដើម្បីចៀសវាងការរាំងស្ទះដល់កិច្ចដំណើរការអាជីវកម្មរបស់ **កសស** ។

*នាយកដ្ឋានអាជីវកម្ម នឹងត្រៀមពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធដើម្បីឱ្យមានភាពរលូន។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

### ៥.៣.១.២ ទីកន្លែងរក្សាទុកឯកសារទន់និងឯកសាររឹង របស់នាយកដ្ឋានអាជីវកម្ម

យោងតាមការសម្ភាសន៍ ថ្នាក់ដឹកនាំសវនដ្ឋាននិងការចុះពិនិត្យស្ថានភាពជាក់ស្តែង សវនករបានសង្កេតឃើញសវនដ្ឋានរៀបចំ រក្សាទុកឯកសារទន់សំខាន់ៗនៅក្នុងប្រព័ន្ធ SWSS និងចម្លងទុកនៅក្នុង One Drive របស់នាយកដ្ឋាន រួមទាំង Servers ការពារសុវត្ថិភាពឯកសារទន់ (VEEAM Backup Server និង Offline/External Backup Server) ដែលគ្រប់គ្រងដោយនាយកដ្ឋានព័ត៌មានវិទ្យា។

ទោះជាយ៉ាងនេះក្តី សវនករបានពិនិត្យឃើញថាសវនដ្ឋាន នៅពុំទាន់មានឃ្លាំងរក្សាទុកឯកសាររឹងគ្រប់គ្រាន់និងសមស្របនៅឡើយ ។ ដោយបច្ចុប្បន្ន ឯកសាររឹងសំខាន់ៗត្រូវបានរក្សាទុកនៅក្នុងកុងតឺន័រ 20' ចំនួនពីរគ្រឿង ស្ថិតនៅក្រោយអគាររដ្ឋបាល និងមួយចំនួនទៀតនៅក្នុងឃ្លាំងអគាររដ្ឋបាលចាស់។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមបទបញ្ជាផ្ទៃក្នុង របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ដូចមានចែងនៅក្នុងចំណុចទី ៣. ប្រការ V. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារ មធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្សនៅឡើយ។

ករណីនេះ អាចកើតមានឡើងដោយសារក្នុងអំឡុងពេលចុះធ្វើសវនកម្ម ឯកសារត្រូវបានសើរើជាញឹកញាប់តាមតម្រូវការរបស់សវនករ និងអធិការកិច្ចមកពីបណ្តាក្រសួងផ្សេងៗ។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់/ខ្វះខាតទីកន្លែងរក្សាទុកឯកសាររឹង របស់សវនដ្ឋានដោយក្នុងរយៈពេលមួយឆ្នាំសវនដ្ឋានត្រូវការកុងតឺន័រ 20' ប្រហែលជាពីរគ្រឿង ដើម្បីរក្សាទុកឯកសាររឹងសម្រាប់រយៈពេល ១០ ឆ្នាំ តាមតម្រូវការច្បាប់។

សវនដ្ឋាន គួររាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** និងស្នើសុំទីកន្លែង/ឃ្លាំងរក្សាទុកឯកសាររឹងឱ្យបានសមស្រប។

*ដោយកុងតឺន័រមានកំណើនយ៉ាងឆាប់រហ័ស ដូចនេះនាំឱ្យឯកសារមានការកើនឡើងច្រើន ហេតុនេះធ្វើឱ្យខ្វះឃ្លាំងដាក់ឯកសារ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

## ៥.៣.២ នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ (ប្រទក)

### ៥.៣.២.១ បណ្ណបើកបរនិងវគ្គបណ្តុះបណ្តាល សម្រាប់អ្នកបើកបររថយន្តដឹកកុងតឺន័រ

យោងតាមរបាយការណ៍ និងការសម្ភាសន៍ប្រធានការិយាល័យគ្រឿងចក្រ នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ សវនករបានកត់សម្គាល់ឃើញថា ផ្នែករថយន្តដឹកកុងតឺន័រមានអ្នកបើកបរសរុបចំនួន ៩៩ នាក់ ក្នុងនេះ អ្នកបើកបរដែលមានបណ្ណបើកបរចំនួន ៨០ នាក់ និងគ្មានបណ្ណបើកបរ ១៩ នាក់ ។

ជាមួយគ្នានេះដែរ យោងតាមផែនការបណ្តុះបណ្តាលរបស់សវនដ្ឋានសម្រាប់ឆ្នាំ ២០២៥ សវនករបានពិនិត្យឃើញថា នៅពុំទាន់បានបើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេស និងជំនាញបើកបរផ្នែករថយន្តដឹកកុងតឺន័រនៅឡើយ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាម ព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៧ ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៥ និងផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ របស់ **កសស** ឆ្នាំ ២០២៥ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០២៤ ក្នុងឧបសម្ព័ន្ធទី ៧ ផែនការបណ្តុះបណ្តាលធនធានមនុស្ស ឆ្នាំ ២០២៥ ចំណុច ក-៤ ការហ្វឹកហ្វឺនបើកបរគ្រឿងចក្រធុនធ្ងន់។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីនិយោជិតក្នុងក្របខ័ណ្ឌសវនដ្ឋាន មានភាពមមាញឹកច្រើនក្នុងការបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** និងភាពខ្វះចន្លោះរបស់មន្ត្រីទទួលបន្ទុកការងារ ក្នុងការចុះត្រួតពិនិត្យបណ្ណបើកបររបស់និយោជិតកម្មករផ្នែករថយន្តដឹក។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា និងការអនុវត្តផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុរបស់ **កសស** ។

សវនដ្ឋាន គួររៀបចំឱ្យប្រតិបត្តិករ/អ្នកបើកបររបស់ **កសស** ប្រឡងយកបណ្ណបើកបរឱ្យបានគ្រប់គ្នា ស្របតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា និងគួរស្នើសុំបើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេស និងជំនាញបើកបរដល់ប្រតិបត្តិករ/អ្នកបើកបររថយន្តដឹកកុងតឺន័របន្ថែមទៀត។

*សម្រាប់បងប្អូន ១៩ នាក់ កំពុងស្នើឱ្យទៅរៀនបើកបរដើម្បីទទួលបានបណ្ណបើកបរ ។ សម្រាប់ ឆ្នាំកន្លងមក អ្នកបើកបររថយន្តកុងតឺន័រទាំងអស់ បានចូលរៀនវគ្គបណ្តុះបណ្តាលបច្ចេកទេសរួចហើយ នៅតែការធ្វើពិធីប្រគល់វិញ្ញាបនបត្រប៉ុណ្ណោះ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

### ៥.៣.២.២ តារាងត្រួតពិនិត្យគ្រឿងចក្រ

យោងតាមតារាងត្រួតពិនិត្យគ្រឿងចក្រ របស់នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ សវនករបានពិនិត្យឃើញគ្រឿងចក្រផ្នែករថស្ទូចចល័តនៅគែមផែ (QC) និងផ្នែករថស្ទូចចល័តនៅទីលាន (RTG) បានធ្វើតារាងត្រួតពិនិត្យ (Daily Checklist) ជាទៀងទាត់ ដោយឡែកផ្នែករថយន្តដឹកកុងតឺន័រ (Platform) សវនករបានពិនិត្យឃើញថា នៅពុំទាន់មានតារាងត្រួតពិនិត្យប្រចាំថ្ងៃនៅឡើយ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមសេចក្តីសម្រេចលេខ ២២៨ សសរ/កសស/ប្រទក ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២០ ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទី និងភារកិច្ចរបស់ការិយាល័យ នៃនាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ ក្នុងប្រការ ៧ ចំណុចទី ៧ បានចែងថាការិយាល័យ គ្រឿងចក្រមានភារកិច្ចត្រូវពិនិត្យគ្រឿងចក្រនីមួយៗ មុនពេលចេញប្រតិបត្តិការ (ទឹក អគ្គិសនី កង់ ប្រេងម៉ាស៊ីន) សម្រាប់ Reach stacker, Forklift និងរថយន្តដឹក ដោយឡែកសម្រាប់ QC និង RTG ត្រូវធ្វើ Checklist ឱ្យបានទៀងទាត់។

កត្តានេះ អាចបណ្តាលមកពីមន្ត្រីទទួលការងារមានភាពមមាញឹកក្នុងការរៀបចំចាត់ចែងកិច្ចប្រតិបត្តិការដឹកជញ្ជូនកុងតឺន័រដែលកំពុងកើនឡើង ។

ករណីនេះ អាចបណ្តាលឱ្យរថយន្តធាប់ខូច ខាតបង់ពេលវេលាជួសជុល ចំណាយច្រើន និងប៉ះពាល់ដល់ផលិតភាពប្រតិបត្តិការអាជីវកម្ម សេវាកម្ម របស់ **កសស** ។

សវនដ្ឋាន គួរចាត់ឱ្យប្រតិបត្តិករ/អ្នកបើកបរ រៀបចំធ្វើតារាងត្រួតពិនិត្យរថយន្តប្រចាំថ្ងៃ ដើម្បីតាមដានដំណើរការ លក្ខណៈបច្ចេកទេស ឬ ភាពមិនប្រក្រតីនៃរថយន្ត។

*សូមបញ្ជាក់ថា ជាបទដ្ឋានតារាង Checklist អនុវត្តតែ RTG និង QC ។ សម្រាប់ Reach Stacker, រថយន្តដឹកកុងតឺន័រ សវនដ្ឋានពុំទាន់មានតារាងត្រួតពិនិត្យប្រចាំថ្ងៃទេ ប៉ុន្តែសវនដ្ឋានមាន T.O ដែលបាននឹងកំពុងអនុវត្តរួចហើយ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

### ៥.៣.៣ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ (ប្រទទ)

#### ៥.៣.៣.១. របាយការណ៍គ្រប់គ្រងឃ្លាំង និងទីលានទំនិញទូទៅ

យោងតាមការឆ្លើយបំភ្លឺ ក្នុងកម្រងសំណួរត្រួតពិនិត្យផ្ទៃក្នុង និងការចុះពិនិត្យទីតាំងឃ្លាំងលេខ ២ លេខ ៣ ទីលានពហុបំណង ទីលានរង្វង់មូល និងទីលានផ្សងថ្ម សវនករបានសង្កេតឃើញថា សវនដ្ឋាននៅមានកង្វះខាតឃ្លាំងស្តុកទំនិញ និងសម្ភារដែលងាយទទួលរងការខូចខាតដោយសារទឹកភ្លៀង។ ក្នុងនេះ សវនករបានសង្កេតឃើញសម្ភារមួយចំនួនដូចជា កេស ដែកស័ង្កសី ដែករ៉ូឡូឡាំង ។ល។ ត្រូវបានរក្សាទុកដោយគ្របតង់នៅទីលានរង្វង់មូលជាបណ្តោះអាសន្ន។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមបទបញ្ជាផ្ទៃក្នុង របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ដូចមានចែងនៅក្នុងចំណុចទី ៣. ប្រការ V. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្សនៅឡើយ ។

ករណីនេះ អាចកើតមានឡើងដោយសារឃ្លាំងលេខ ២ និងលេខ ៣ ត្រូវបានកែសម្រួលសម្រាប់ស្តុកទំនិញកសិផលរួមមាន ចំណិតដំឡូងស្ងួត អង្ករ និងស្ករស ។ល។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទំនិញដែលងាយទទួលរងការខូចខាតដោយសារទឹកភ្លៀង និង/ឬ អាចនាំឱ្យបាត់បង់ទំនិញជាយថាហេតុ ។

សវនដ្ឋាន គួរចាត់មន្ត្រីជំនាញចុះពិនិត្យស្ថានភាពទីតាំងឃ្លាំង/ទីលានខាងលើ និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីចាត់វិធានការឆ្លើយតបឱ្យបានសមស្រប។

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំតាមពេលវេលាសមស្របជាក់ស្តែង។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

### ៥.៣.៣.២. វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសប្រតិបត្តិការទំនិញទូទៅ

យោងតាមការឆ្លើយបំភ្លឺ ក្នុងកម្រងសំណួរត្រួតពិនិត្យផ្ទៃក្នុង សវនករបានកត់សម្គាល់ឃើញថានៅខែមិថុនា ឆ្នាំ ២០២៣ សវនដ្ឋានបានបើកវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេស/គោលការណ៍ណែនាំសម្រាប់ក្រុមកម្មករ ស្រាយ/ចង កុងតឺន័រចំនួន ៣ វគ្គ និងបច្ចេកទេសប្រតិបត្តិការសម្រាប់អ្នកបើកបររថចូកចំនួន ១ វគ្គ ដូចបានរៀបរាប់ខាងក្រោម៖

- វគ្គទី១ នៅថ្ងៃទី ១៣ មិថុនា ២០២៣ និងបានអនុវត្តផ្ទាល់នៅថ្ងៃទី ១២ កក្កដា ២០២៣
- វគ្គទី២ នៅថ្ងៃទី ២២ មិថុនា ២០២៣ និងបានអនុវត្តផ្ទាល់នៅថ្ងៃទី ២៩ កក្កដា ២០២៣
- វគ្គទី៣ នៅថ្ងៃទី ២៧ មិថុនា ២០២៣ និងបានអនុវត្តផ្ទាល់នៅថ្ងៃទី ០៤ កក្កដា ២០២៣
- បច្ចេកទេសប្រតិបត្តិការរថចូក បានអនុវត្តផ្ទាល់នៅថ្ងៃទី ១៤ មិថុនា ២០២៣ ។

យោងតាមវគ្គបណ្តុះបណ្តាលខាងលើ សវនករបានសង្កេតឃើញថា ចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២៣ កន្លងទៅ សវនដ្ឋាននៅពុំទាន់បានរៀបចំផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសបន្ថែមទៀតនៅឡើយទេ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុរបស់ **កសស** ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០២៥ ក្នុងឧបសម្ព័ន្ធទី ៧ ៖ ផែនការបណ្តុះបណ្តាលធនធានមនុស្សឆ្នាំ ២០២៥ ចំណុច ក-៤ ការហ្វឹកហ្វឺនបើកបរគ្រឿងចក្រធន់ធ្ងន់ ក-៦ ការគ្រប់គ្រង និងប្រតិបត្តិការទំនិញទូទៅ និង ក-៧ ប្រតិបត្តិការស្តីពី ទំនិញគ្រោះថ្នាក់ ពេញលេញនៅឡើយ ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌសវនដ្ឋានមានភាពមមាញឹកច្រើន ក្នុងការបម្រើប្រតិបត្តិការអាជីវកម្ម សេវាកម្មរបស់ **កសស** ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្តផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុរបស់ **កសស** ។

សវនដ្ឋាន គួររៀបចំផែនការបណ្តុះបណ្តាល មន្ត្រី បុគ្គលិក កម្មករ និងប្រតិបត្តិករនូវមុខជំនាញបច្ចេកទេស សមស្របតាមតម្រូវការចាំបាច់របស់ខ្លួន ។

*នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នឹងធ្វើផែនការបណ្តុះបណ្តាលបុគ្គលិក-កម្មករ នូវជំនាញបច្ចេកទេស នៅពេលវេលាសមស្រប។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

### ៥.៣.៤ នាយកដ្ឋាននាវាចរ-កណ្ណធារ (នវកធ)

#### ៥.៣.៤.១ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ របស់នាយកដ្ឋាននាវាចរ-កណ្ណធារ

យោងតាមរបាយការណ៍ ស្តីពីវឌ្ឍនភាពការងាររបស់សវនដ្ឋាន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២៥ (ក្នុងចំណុចទី ៤-សំណូមពរជួសជុលដេហ្វង់ “Ship Fenders”) និងការចុះពិនិត្យស្ថានភាពជាក់ស្តែង នៅតាមចំណតផែទំនិញរាយនិងចំណតផែកុងតឺន័រ សវនករបានសង្កេតឃើញថា ចាប់ពីចំណតលេខ V ដល់លេខ X មានដេហ្វង់ (Ship Fenders) សរុបចំនួន ១០៥ គ្រឿង ដោយក្នុងនេះមានដេហ្វង់ចំនួន ៤ គ្រឿង នៅចំណតលេខ VII បានខូច ២ គ្រឿង និងបាក់/ដាច់ ២ គ្រឿង។ រហូតមកដល់ពេលនេះ នៅពុំទាន់បានជួសជុល និង/ឬ ផ្លាស់ប្តូរថ្មីនៅឡើយ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍ របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ពេញលេញនៅឡើយ ។

កត្តាខាងលើ អាចបណ្តាលមកពីអាយុកាលប្រើប្រាស់យូរឆ្នាំ ដែលធ្វើឱ្យធ្លាក់ចុះគុណភាព និង/ឬ ដោយសារមានការបុកត្រូវដោយកម្លាំងសង្កត់ ឬ គាបនៅពេលនាវាចូលចត។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់សុវត្ថិភាពនាវាចូលចត ដោយនាំឱ្យមានការប៉ះទង្គិចខូចខាតទាំងកំពង់ផែនិងនាវា រួមទាំងប្រសិទ្ធភាពប្រតិបត្តិការប្រចាំថ្ងៃ និងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ **កសស**។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចុះពិនិត្យស្ថានភាពជាក់ស្តែង និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំនាយកដ្ឋានជំនាញ ធ្វើការជួសជុល និង/ឬ ផ្លាស់ប្តូរដេហ្វង់ថ្មីឱ្យបានសមស្រប។

*ក្រុមជាងខាងអ៊ូនាវាកំពុងជួសជុលដេហ្វង់ទាំង ៤ គ្រឿង ប៉ុន្តែនៅពុំទាន់បានរួចរាល់។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

**៥.៣.៤.២ បូឡាដពាក់ព្ធួរនាវានៅចំណតលេខ VI, VII, VIII, IX, XI និង XII**

យោងតាមរបាយការណ៍ ស្តីពីវឌ្ឍនភាពការងាររបស់សវនដ្ឋាន ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០២៥ (ក្នុងចំណុចទី ៤-សំណូមពរជួសជុល និងលាបថ្នាំបូឡាដ “Bollards” នៅចំណតលេខ VII, VIII, IX, XI និង XII) និងការចុះពិនិត្យស្ថានភាពជាក់ស្តែង សវនករបានសង្កេតឃើញថា បូឡាដ (Bollards) ពាក់ព្ធួរនាវានៅចំណតលេខ VI មានលក្ខណៈតូចជាងនិងទាបជាងបូឡាដនៅចំណតលេខ VII និងលេខ VIII ជាហេតុនាំឱ្យមានការពិបាកក្នុងការដាក់/ពាក់ព្ធួរនាវារួមគ្នាឱ្យបានចំនួនប្រាំមួយខ្សែក្នុងពេលតែមួយ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/បេ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ពេញលេញនៅឡើយ។

ប្រការនេះ អាចបណ្តាលមកពីភាពសឹករេចរឹល នៃអាយុកាលប្រើប្រាស់យូរឆ្នាំដែលធ្វើឱ្យធ្លាក់ចុះគុណភាព និង/ឬ ដោយសារប្រភេទស្តង់ដា ឬ ខ្នាតទំហំបូឡាដខុសគ្នា។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់ដល់សុវត្ថិភាពនៃការពាក់ព្ធួរនាវា អាចធ្វើឱ្យកិច្ចប្រតិបត្តិការអាជីវកម្មមានភាពយឺតយ៉ាវ និងប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ **កសស**។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចុះពិនិត្យស្ថានភាពជាក់ស្តែង និងរាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំនាយកដ្ឋានជំនាញ ពិនិត្យលទ្ធភាពប្តូរខ្នាតទំហំបូឡាដឱ្យត្រូវគ្នា និងជួសជុល/លាបថ្នាំបូឡាដចាស់ៗ ឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។

*បូឡាដនៅចំណតលេខ VI ពិតជាតូចជាងនិងទាបជាងបូឡាដនៅចំណតលេខ VII និងចំណតលេខ VIII ប្រាកដមែន ដែលជាគម្រោងកែសម្រួលក្រោយការសាងសង់ចំណតលេខ VII និងចំណតលេខ VIII។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៥ នាយកដ្ឋានបច្ចេកទេស-សម្ភារ (បទស)

#### ៥.៣.៥.១ ការគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់របស់ កសស

យោងតាមការឆ្លើយបំភ្លឺ ក្នុងកម្រងសំណួរត្រួតពិនិត្យផ្ទៃក្នុង ស្តីពីការគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់ ដែលស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានបច្ចេកទេស-សម្ភារនៃ **កសស** និងការចុះពិនិត្យស្ថានភាពគ្រប់គ្រងសន្និធិសម្ភារ ក្នុងឃ្លាំងសម្ភារ - បច្ចេកទេសបន្លាស់ សវនករបានសង្កេតឃើញមានមុខទំនិញចម្រុះ នៅក្នុងបញ្ជីសន្និធិសម្ភារ-បន្លាស់ចំនួន ១៤៩២ មុខ។ ក្នុងនេះសវនដ្ឋានប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីកត់ត្រាគ្រប់មុខទំនិញរួមទាំងសន្និធិដើមគ្រា ចុងគ្រា និងសមតុល្យ ដោយនៅពុំទាន់មានកម្មវិធី/ប្រព័ន្ធគ្រប់គ្រងសន្និធិសម្ភារសមស្របនៅឡើយ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមតម្រូវការប្រើប្រាស់ជាក់ស្តែង និងការគ្រប់គ្រងសន្និធិសម្ភារតាមប្រព័ន្ធឌីជីថលនៅឡើយ។

ករណីនេះ អាចបណ្តាលមកពីសវនដ្ឋាន កំពុងសិក្សាអំពីតម្រូវការប្រើប្រាស់ឱ្យបានសមស្របតាមទំហំសន្និធិសម្ភារបច្ចុប្បន្ន និងអនាគត។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃការអនុវត្តប្រព័ន្ធគ្រប់គ្រងសន្និធិតាមបែបឌីជីថល ប្រសិទ្ធភាពគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់ និងនាំឱ្យមានភាពយឺតយ៉ាវក្នុងការរៀបចំឯកសារធ្វើបច្ចុប្បន្នភាពស្តុក។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការណ៍ជាមួយនាយកដ្ឋានជំនាញ សិក្សាអំពីតម្រូវការប្រើប្រាស់សមស្រប ដើម្បីរាយការណ៍ជូននិងស្នើសុំថ្នាក់ដឹកនាំ **កសស** រៀបចំកម្មវិធីអនុវត្តស្របតាមប្រព័ន្ធគ្រប់គ្រងសន្និធិសម្ភារបច្ចេកទេស-បន្លាស់ តាមបែបឌីជីថល។

*នាយកដ្ឋានបច្ចេកទេស-សម្ភារ នឹងធ្វើការសហការណ៍ជាមួយនាយកដ្ឋានជំនាញ ដើម្បីកែសម្រួល និងកែលម្អកម្មវិធី Microsoft Excel ជាជំហានៗឱ្យបានសមស្របតាមបរិមាណសន្និធិសម្ភារ-បន្លាស់ដែលមានចំនួនប្រហែល ១៥០០ មុខ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៥.២ ស្ថានភាពឃ្លាំងសម្ភារបច្ចេកទេស-បន្លាស់

យោងតាមការចុះពិនិត្យ ស្ថានភាពឃ្លាំងសម្ភារបច្ចេកទេស- បន្លាស់ ដែលស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានបច្ចេកទេស-សម្ភារនៃ **កសស** ក្នុងទំហំ ១៨ ម៉ែត្រ X ២៨ ម៉ែត្រ កម្ពស់ ៣,៧០ ម៉ែត្រ (ពីផ្ទៃបាតដល់ផ្ទៃពិដាន)សវនករបានសង្កេតឃើញថា ផ្ទៃឃ្លាំងមានសណ្តាប់ធ្នាប់ បរិស្ថានល្អ មានការរៀបចំផ្ទើស្តុកសម្ភារតាមទំហំ/ប្រភេទទំនិញ ដោយទុកចន្លោះផ្លូវសម្រាប់បញ្ចូល-បញ្ចេញទំនិញសមស្រប។ ទោះជាយ៉ាងណា សីតុណ្ហភាពក្នុងផ្ទៃឃ្លាំងមានសភាពក្តៅហប់ ដំបូលឃ្លាំងមានលក្ខណៈចាស់ និងមានស្នាមប្រេះ/ធ្លុះធ្លាយជាច្រើនកន្លែង ជាហេតុបណ្តាលឱ្យលិច/ជ្រាបទឹកភ្លៀងនៅតាមទរទឹក និងធ្វើឱ្យផ្នែកខ្លះនៃពិដានដាច់/បាក់ធ្លាក់ជាបន្តបន្ទាប់។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ពេញលេញនៅឡើយ។

ប្រការនេះ អាចបណ្តាលមកពីឃ្លាំងនេះ ជាប្រភេទអគារការិយាល័យចាស់ ដែលទទួលរងភាពសឹករេចរឹលដោយសារអាយុកាលប្រើប្រាស់យូរឆ្នាំ។

កត្តានេះ អាចបណ្តាលឱ្យបាត់បង់សោភណភាពក្នុងបរិវេណអគារ ខូចខាតសន្និធិសម្ភារដោយសារទឹកភ្លៀង និងប៉ះពាល់សុខភាពបុគ្គលិក កម្មករឃ្លាំង។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រីជំនាញចុះពិនិត្យស្ថានភាពជាក់ស្តែង និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំជួសជុលដំបូល ទរទឹក ពិដានឃ្លាំង និង/ឬ ពិនិត្យលទ្ធភាពបំពាក់ប្រព័ន្ធខ្យល់ដំបូល ដើម្បីសម្រួលសីតុណ្ហភាពក្នុងបរិវេណឃ្លាំង ក្នុងគោលបំណងធានាគុណភាព និងនិរន្តរភាពសន្និធិសម្ភារបន្លាស់។

*នាយកដ្ឋានបច្ចេកទេស-សម្ភារ នឹងលើកសំណើរសុំជួសជុលដំបូល ទរទឹក ពិដានឃ្លាំង បំពាក់ប្រព័ន្ធខ្យល់ដំបូល និងឧបករណ៍ ដើម្បីសម្រួលសីតុណ្ហភាពក្នុងបរិវេណឃ្លាំងក្នុងគោលបំណងធានាគុណភាព និងនិរន្តរភាពសន្និធិសម្ភារបន្លាស់។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

## ៥.៣.៦ នាយកដ្ឋានសំណង់-វិស្វកម្ម (សណវក)

### ៥.៣.៦.១. ស្ថានភាពទីលានកុងតឺន័ររបស់ កសស

យោងតាមការចុះពិនិត្យស្ថានភាពទីលានកុងតឺន័ររបស់ **កសស** សវនករបានសង្កេតឃើញមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចខាងក្រោម៖

- ផ្ទៃទីលាន BF ពីចំណុច B25 ដល់ B35 មានសភាពមិនរាបស្មើ (ជម្រាល) និងស្រុតដោយកន្លែង ជាពិសេសចាប់ពីចំណុច B31 ដល់ B33 ជាហេតុបណ្តាលឱ្យការលើករៀបស្តុកកុងតឺន័រមិនបានច្រើនជាន់ និងធ្វើឱ្យ RTG ពិបាកចល័តចូល;
- ផ្ទៃទីលាន CB ក្នុងចំណុច B57 មានស្ថានភាពស្រុតខ្លាំង បណ្តាលឱ្យដក់ទឹកនិងអាចបណ្តាលឱ្យទឹកជ្រាបចូលក្នុងកុងតឺន័រ ក្នុងករណីមានភ្លៀងធ្លាក់ខ្លាំង;
- ក្នុង Lane CB ចាប់ពី B15 ដល់ B39 មានស្ថានភាពស្រុតខ្លាំង និងទឹកដក់; និង
- ក្នុង Lane CA ចាប់ពី B17 ដល់ B35 នៅមានជម្រាលធ្វើឱ្យ RTG ពិបាកចាប់កុងតឺន័រដោយទើសស្លាបព្រាភ្ជាប់ RAM និងត្រូវរំកិលជើងពីព្រោះមុំកែងមិនស្មើគ្នា។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្ស ពេញលេញនៅឡើយ។

ករណីខាងលើ អាចបណ្តាលមកពីអាយុកាលប្រើប្រាស់យូរឆ្នាំ ដែលធ្វើឱ្យធ្លាក់ចុះគុណភាព និងដោយសារសកម្មភាពប្រតិបត្តិការលើកដាក់ ផ្ទេរ-ផ្ទុកកុងតឺន័រមានភាពមមាញឹកខ្លាំង។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់សមត្ថភាពស្តុករបស់ទីលានកុងតឺន័រ និងធ្វើឱ្យមានការពិបាកក្នុងការចល័តគ្រឿងចក្រ រៀបចំស្តុកនិងប្រតិបត្តិការលើកដាក់កុងតឺន័រ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រីជំនាញចុះពិនិត្យស្ថានភាពជាក់ស្តែង និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ **កសស** ដើម្បីស្នើសុំជួសជុលឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។

*១- ទីលាន BF ពីចំណុច B25-B35 កំណើនកុងតឺន័រច្រើនមិនអាចធ្វើកើត។*

*២- ទីលាន CB ក្នុងចំណុច B57 រង់ចាំដល់រដូវប្រាំង។*

*៣- Lane CB ចាប់ពី B15-B39 និង Lane CA ចាប់ពី B17 ដល់ B35 រង់ចាំរដូវប្រាំង។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៦.២. ស្ថានភាពបរិស្ថានក្នុងបរិវេណអ៊ូនាវ៉ា

តាមការចុះពិនិត្យទីតាំងអ៊ូនាវ៉ា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសំណង់-វិស្វកម្ម សវនករបានសង្កេតឃើញ ចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចខាងក្រោម៖

- មានសំណល់/កម្ទេចកម្ទីចម្រុះមុខជាច្រើន ដូចជាដែក សំបកកង់រថយន្តចាស់ៗ ធុងហ្គាស បំពង់ខ្យល់អុកស៊ីសែន ដីខ្សាច់ សំបកដបទឹកសុទ្ធ ស្បោងប្លាស្ទិក ។ល។ និងសម្ភារប្រើប្រាស់ចាស់ៗជាច្រើនផ្សេងទៀត ស្ថិតនៅក្នុងបរិវេណអ៊ូនាវ៉ាដោយពុំសូវមានសណ្តាប់ធ្នាប់។
- ឧបករណ៍ពន្លត់អគ្គិភ័យ ត្រូវបានចាក់សោរក្សាទុកនៅក្នុង បន្ទប់សម្ភារមួយដោយឡែក ក្រៅពីបន្ទប់បុគ្គលិកប្រចាំការ បន្ទប់សម្ភារបច្ចេកទេសពោងសញ្ញា បន្ទប់សម្ភារបច្ចេកទេសអ៊ូនាវ៉ា រោងជាងការិយាល័យអ៊ូនាវ៉ា-ពោងសញ្ញា និងកន្លែងជួសជុលនាវ៉ាសណ្តោង **កោះតាង** ជាហេតុនាំឱ្យមានការពិបាកយកមកប្រើប្រាស់ ក្នុងករណីមានគ្រោះអគ្គិភ័យកើតមានឡើងជាយថាហេតុ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមគោលនយោបាយគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថាន របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១១ ពេញលេញនៅឡើយ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីទទួលបន្ទុកការងារ មានភាពមមាញឹកច្រើនក្នុងការបំពេញការងារស្នូលរបស់ខ្លួន ជាហេតុនាំឱ្យមានការខ្វះចន្លោះក្នុងការពិនិត្យ រៀបចំទុកដាក់សម្ភារប្រើប្រាស់និងបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យឱ្យបានសមស្របតាមទីកន្លែងចាំបាច់។

កត្តានេះ អាចបណ្តាលឱ្យប៉ះពាល់បរិស្ថាន បាត់បង់សណ្តាប់ធ្នាប់ និងសោភណភាពនៅក្នុងបរិវេណអ៊ូនាវ៉ា ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថាន របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រីទទួលបន្ទុកការងារ រៀបចំសម្អាតបរិស្ថាន ទុកដាក់សម្ភារប្រើប្រាស់ឱ្យមានសណ្តាប់ធ្នាប់ល្អ និងបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ នៅតាមទីកន្លែងដែលចាំបាច់ប្រើប្រាស់ ស្របតាមគោលនយោបាយគ្រប់គ្រង សុវត្ថិភាព សុខភាព និងបរិស្ថាន របស់ **កសស** ។

*យោងតាមស្ថានភាពនៅការិយាល័យអ៊ូនាវ៉ានិងពោងសញ្ញា នឹងមានការរៀបចំសណ្តាប់ធ្នាប់ឡើងវិញឱ្យមានសោភណភាព។ ពាក់ព័ន្ធនឹងបំពង់ពន្លត់អគ្គិភ័យនឹងរៀបចំទៅតាមស្តង់ដារ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៧ នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស (តសព)

#### ៥.៣.៧.១ ប្រព័ន្ធបង្ហូរទឹក (ប្រឡាយ) នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

យោងតាមលិខិតលេខ ០៥៧ តសព/២៥ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០២៥ សវនករបានពិនិត្យឃើញសវនដ្ឋាន ស្នើសុំចាក់គម្របបេតុងប្រឡាយបង្ហូរទឹក និងជំឡើងចំនួន ៤០ គម្របដើម្បីយកមកផ្លាស់ប្ដូរគម្របបេតុងប្រឡាយបង្ហូរទឹក ដែលត្រូវបានបែកបាក់នៅតាមបណ្ដោយផ្លូវចាប់ពីច្រកចូលរហូតដល់រង្វង់មូល នៅក្នុង **តសព** កំពង់ផែក្រុងព្រះសីហនុ។ ប៉ុន្តែតាមការចុះពិនិត្យស្ថានភាពជាក់ស្ដែង សវនករបានសង្កេតឃើញគម្របប្រឡាយបង្ហូរទឹក ដែលបែកបាក់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន ១៨៩ ផ្ទាំង និងមានដីហូរចូលប្រឡាយបង្ហូរទឹក នៅក្នុងបរិវេណទីតាំងផ្ទុកគំនរដីនិងអគារស្ថានីយ៍ស្តុកទំនិញកុងតឺន័រថ្មី (New Container Freight Station)។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមបទបញ្ជាផ្ទៃក្នុង របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) លេខ ០០១ បបផក/កសស/រប.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ ដូចមានចែងនៅក្នុងចំណុចទី III. ប្រការ V. ស្តីពីការប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិ សម្ភារមធ្យោបាយ ឬ ឧបករណ៍របស់ **កសស** ដោយសន្សំសំចៃ ប្រុងប្រយ័ត្ន សំអាតថែរក្សា និងទុកដាក់ឱ្យបានគង់វង្សនៅឡើយ។

ករណីខាងលើ អាចបណ្ដាលមកពីរថយន្តដឹកទំនិញ/កុងតឺន័រ បើកកិនក្នុងប្រតិបត្តិការដឹកជញ្ជូនទំនិញនិងកុងតឺន័រ។

កត្តានេះ អាចបណ្តាលឱ្យសំរាម និងដីធ្លាក់/ហូរចូលប្រឡាយបង្ហូរទឹក និងបង្កឱ្យមានការកកស្ទះប្រឡាយ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រីទទួលបន្ទុកការងារ ឱ្យចុះពិនិត្យគម្របបេតុងប្រឡាយបង្ហូរទឹក និងស្ថានភាពប្រឡាយជាក់ស្តែង ដើម្បីជៀសវាងកង្វះគម្របបេតុង ដែលបានស្នើសុំ និង/ឬ គួរស្នើសុំត្រៀមបម្រុងទុកមួយចំនួនដើម្បីប្រើប្រាស់នៅពេលក្រោយ។

- ***តសព*** *បានធ្វើលិខិតសុំចាក់បេតុងគម្របប្រឡាយទឹក មួយខ្សែចាប់ពីច្រកចូលផ្លូវមេ រហូតដល់រង្វង់មូល ខែ ៨ ឆ្នាំ ២០២៥ ចំនួន ៤០ គម្រប។*
- ***តសព*** *ធ្វើលិខិតចាក់គម្របបេតុងប្រឡាយបែក ចាប់រង្វង់មូល រហូតដល់អាងទឹកស្អាត ចំនួន ១៤៩ គម្រប ក្នុងខែ ១១ ថ្ងៃទី១៤ ឆ្នាំ ២០២៥។*
- ***តសព*** *បានធ្វើលិខិតស្នើសុំស្តារប្រឡាយទឹក កាត់មែកឈើ និងសំអាតដីក្នុងប្រឡាយ មានបីទីតាំង ថ្ងៃទី ១៤ ខែ ១១ ឆ្នាំ ២០២៥។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៧.២ កំណត់ហេតុប្រជុំសេវាអតិថិជនប្រចាំខែ

យោងតាមកំណត់ហេតុប្រជុំសេវាអតិថិជនប្រចាំខែ ប្រចាំត្រីមាសទី ៤ ឆ្នាំ ២០២៤ សវនករបានពិនិត្យឃើញថា កន្លងមកសវនដ្ឋានបានរៀបចំកិច្ចប្រជុំសេវាអតិថិជនជារៀងរាល់ខែ ដោយមានការចូលរួមពីគ្រប់តំណាងអតិថិជន និងភាគីពាក់ព័ន្ធនៅក្នុង **តសព** ។ ប៉ុន្តែចាប់ពីត្រីមាសទី ៤ ឆ្នាំ ២០២៤ រហូតដល់បច្ចុប្បន្ន សវនដ្ឋាននៅពុំទាន់បានរៀបចំកិច្ចប្រជុំសេវាអតិថិជនបន្តទៀតនៅឡើយ។

ប្រការខាងលើ នៅពុំទាន់សមស្របតាមសេចក្តីសម្រេចលេខ ៣៩៧សសរ/កសស/តសព ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន តួនាទីនិងភារកិច្ចរបស់ការិយាល័យ នៃនាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស ដូចមានចែងនៅក្នុងប្រការ ៤ ស្តីពីការចុះជួបតាមរោងចក្រ និងរៀបចំប្រជុំប្រចាំខែជាមួយអតិថិជន សំដៅពង្រឹងគុណភាពនិងប្រសិទ្ធភាពសេវាកម្មក្នុង **តសព**។

កត្តានេះ អាចបណ្តាលមកពីសវនដ្ឋានមានការមមាញឹកច្រើន និង/ឬ មានការធ្វើទំនាក់ទំនងទូលាយតាមប្រព័ន្ធព័ត៌មានសង្គម។

កត្តានេះ អាចបណ្តាលឱ្យទំនាក់ទំនងការងារអាជីវកម្ម ឬ បញ្ហានានាដែលអាចកើតមានឡើងនៅក្នុង **តសព** ពុំត្រូវបានរួមគ្នាដោះស្រាយសមស្រប និងទាន់ពេលវេលា។

ថ្នាក់ដឹកនាំសវនដ្ឋាន គួររៀបចំកិច្ចប្រជុំសេវាអតិថិជនប្រចាំខែជាបន្តទៀត ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពសេវាកម្មនៅក្នុង **តសព**។

- ***តសព*** *បានសាកសួរអតិថិជន ដោយពេលខ្លះគាត់ជាប់រវល់ក្នុងប្រតិបត្តិការមិនបានចូលរួមប្រជុំ*
- ***តសព*** *បានចុះតាមរោងចក្រដើម្បីទទួលព័ត៌មាន ឬសំណើផ្សេងៗរបស់អតិថិជន*
- *សរុបមក* ***តសព*** *បានផ្តល់អាទិភាពជូនអតិថិជនដើម្បីសម្រេច ប្រសិនបើមានការស្នើសុំ* ***តសព*** *នឹងរៀបចំប្រជុំអតិថិជនឡើងវិញ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

## ៥.៣.៨ នាយកដ្ឋានព័ត៌មានវិទ្យា (ពមវ)

### ៥.៣.៨.១ ការគ្រប់គ្រង ត្រួតពិនិត្យ និងថែទាំបណ្ដាញ Network នៅក្នុងក្របខ័ណ្ឌ កសស

យោងតាមការពិនិត្យរបាយការណ៍ ស្ដីពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ កក្កដា និង ខែសីហា ឆ្នាំ ២០២៥ និងការសម្ភាសន៍មន្ត្រីជំនាញនៅនាយកដ្ឋានព័ត៌មានវិទ្យា សវនករបានកត់សម្គាល់ឃើញថា **កសស** បានបំពាក់ប្រព័ន្ធ MDT (Mobile Data Terminal) ចំនួន ៣៦ គ្រឿង រួមមាន៖ គ្រឿងចក្រផ្ទេរផ្ទុកលើគែមផែ (QC) ចំនួន ០៧ គ្រឿង គ្រឿងចក្រចល័តលើទីលាន (RTG) ២៤ គ្រឿង និងរថយន្តលើកដាក់កុងតឺន័រ (Reach Stackers) ០៥ គ្រឿង។

ក្នុងចំណោម MDT (Mobile Data Terminal) ដែលបានបំពាក់លើគ្រឿងចក្រទាំង ៣៦ គ្រឿង សវនករបានសង្កេតឃើញ MDT ដែលបានបំពាក់លើរថយន្តលើកដាក់កុងតឺន័រ (Reach Stackers) មានភាពអាក់អួល នៅពេលបំពេញប្រតិបត្តិការលើកដាក់កុងតឺន័រនៅចំណតលេខ ៦ និងនៅទីលានសំបកកុងតឺន័រក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាហេតុបណ្ដាលឱ្យស្ទះកុងតឺន័រក្នុងប្រព័ន្ធ CTMS ចំនួន ៦១៤ ទូ គិតចាប់ពីថ្ងៃទី ១៨ ខែសីហា ដល់ ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០២៥។

ប្រការខាងលើ នៅពុំទាន់ឆ្លើយតបពេញលេញតាមតម្រូវការជាក់ស្ដែងក្នុងប្រព័ន្ធ CTMS នៅឡើយ។

ករណីខាងលើ អាចបណ្ដាលមកពីការផ្ញើ Confirmation យឺត ឬ អាចបណ្ដាលមកពីប្រព័ន្ធអ៊ីនធឺណេត ឬ Wireless Access Points និងឧបករណ៍ (MDT Devices) នៅឆ្ងាយពីបណ្ដាញ ដែលជាហេតុបណ្ដាលឱ្យ WiFi Signal ចុះខ្សោយនិងគ្មានស្ថិរភាព ជាពិសេសនៅទីលានសំបកកុងតឺន័រក្នុងតំបន់សេដ្ឋកិច្ចពិសេស នៅពុំទាន់បានបំពាក់ប្រព័ន្ធអ៊ីនធឺណេតនៅឡើយ។

កត្តាខាងលើ អាចប៉ះពាល់ដល់ផលិតភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **កសស** ដែលប្រើប្រាស់បណ្ដាញអ៊ីនធឺណេតរួម។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរចាត់មន្ត្រីជំនាញចុះពិនិត្យប្រព័ន្ធ MDT និងទីតាំងជាក់ស្ដែង ដើម្បីពិនិត្យលទ្ធភាព បំពាក់ខ្សែបណ្ដាញប្រព័ន្ធអ៊ីនធឺណេតបន្ថែម នៅត្រង់ចំណតលេខ ៦ និងនៅទីលានសំបកកុងតឺន័រ ឬ ទីតាំងផ្សេងៗទៀតដែលមាន WiFi Signal ចុះខ្សោយ ឬ គ្មានស្ថិរភាព ដើម្បីជៀសវាងការរាំងស្ទះដល់ ដំណើរការប្រតិបត្តិការអាជីវកម្ម-សេវាកម្មរបស់ **កសស** ។

*នាយកដ្ឋានព័ត៌មានវិទ្យាបានធ្វើការ Survey នៅចំណុចដែលមានសេវាខ្សោយ ប៉ុន្តែត្រង់ចំណុចនោះត្រូវធ្វើការទិញថែមនូវឧបករណ៍ WiFi និងតំឡើងបង្គោលបន្ថែម។*

*ដូច្នេះ នាយកដ្ឋានព័ត៌មានវិទ្យានឹងធ្វើការស្នើសុំថ្នាក់ដឹកនាំដើម្បីដំឡើងបង្គោល និងទិញឧបករណ៍ WiFi បន្ថែម។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

**៥.៣.៨.២ ការបណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កសស**

យោងតាមលិខិតលេខ ២៥២ IT/០៩២៥ ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០២៥ សវនករបានកត់សម្គាល់ឃើញថា សវនដ្ឋានបានស្នើសុំចាត់បញ្ជូនបុគ្គលិកចំនួន ៤ រូប ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី Web Security Essential (SWSE) ដែលគ្របដណ្តប់លើសុវត្ថិភាពបណ្តាញ Website ការការពារទិន្នន័យនិងព័ត៌មានសម្ងាត់ ការពង្រឹងសមត្ថភាពបុគ្គលិក IT ការលើកកម្ពស់ការយល់ដឹងទូទៅរបស់ Website និងការបង្ការការវាយប្រហារជាមុនរបស់ក្រុម Hacker។ ប៉ុន្តែគិតមកដល់ត្រីមាសទី ៣ ឆ្នាំ ២០២៥ នេះ សវនករបានសង្កេតឃើញថា សវនដ្ឋាននៅពុំទាន់បានបើកវគ្គបណ្តុះបណ្តាល អំពីនីតិវិធីដំណើរការ សុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការធ្វើតេស្តលើការយល់ដឹងអំពីការប្រើប្រាស់ប្រព័ន្ធ Mobile Data Terminal (MDT) និង Radio Handy Terminal (RHT) ដល់បុគ្គលិកអ្នកប្រើប្រាស់ និងប្រតិបត្តិករ របស់ **កសស** នៅឡើយ។

ប្រការខាងលើ នៅពុំទាន់អនុលោមតាមគោលការណ៍ ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ ២០២១ ក្នុងផ្នែក ខ ចំណុច ៧.១១. ការយល់ដឹង និងការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់៖ បុគ្គលិកទាំងអស់របស់អង្គភាព និងអ្នកពាក់ព័ន្ធគួរតែទទួលការអប់រំ និងបណ្តុះបណ្តាលគ្រប់គ្រាន់សមស្របជាប្រចាំលើគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនឹងមុខងារភារកិច្ចរបស់ខ្លួន ព្រមទាំងលើសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការគំរាមកំហែង ភាពងាយរងគ្រោះ ឬ ក្របខ័ណ្ឌសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាព ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ១០១២ សហវប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញ ក្នុងក្របខ័ណ្ឌសវនដ្ឋានមានការមមាញឹកច្រើនក្នុងការបំពេញតួនាទី និងភារកិច្ចស្នូល របស់សវនដ្ឋាន។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាពអនុវត្ត និង/ឬ អ្នកប្រើប្រាស់ប្រព័ន្ធ និងក្របខ័ណ្ឌសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ **កសស** ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរស្នើសុំបើកវគ្គបណ្តុះបណ្តាល ដល់បុគ្គលិកអ្នកប្រើប្រាស់ និង/ឬ ប្រតិបត្តិករ អំពីនីតិវិធី ដំណើរការ សុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការប្រើប្រាស់ប្រព័ន្ធ Mobile Data Terminal (MDT) និង Radio Handy Terminal (RHT) ។ល។ ស្របតាមប្រកាសលេខ ១០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង បច្ចេកវិទ្យាព័ត៌មាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

*នាយកដ្ឋានព័ត៌មានវិទ្យានឹងរៀបចំជា Testing Environment មួយ ដើម្បីប្រើប្រាស់ Testing Environment នោះ នៅក្នុងការបើកវគ្គបណ្តុះបណ្តាល ដោយវគ្គបណ្តុះបណ្តាលមិនអាចយកប្រព័ន្ធដាក់ស្តែងទៅបណ្តុះបណ្តាលបានទេ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៩ នាយកដ្ឋានទីផ្សារ (ទផ)

#### ៥.៣.៩.១. ការធ្វើបច្ចុប្បន្នភាពវីដេអូផ្សព្វផ្សាយអំពី កសស

យោងតាមការពិនិត្យរបាយការណ៍ប្រចាំខែ សីហា ឆ្នាំ ២០២៥ និងផែនការអនុវត្តខែកញ្ញា ឆ្នាំ ២០២៥ របស់ការិយាល័យព័ត៌មានទីផ្សារនិងផ្សព្វផ្សាយ និងការសម្ភាសន៍មន្ត្រីជំនាញ សវនករបានសង្កេតឃើញសវនដ្ឋាន រៀបចំបង្កើតនិងរចនាប្រតិទិន និងសៀវភៅ (Brochure) ដើម្បីផ្សព្វផ្សាយអំពីសេវាកម្មរបស់ **កសស** ជូនអតិថិជន ភាគីពាក់ព័ន្ធ និងអ្នកប្រើប្រាស់ផែ។ ប៉ុន្តែគិតចាប់ពីឆ្នាំ ២០១៨ រហូតដល់បច្ចុប្បន្ន សវនដ្ឋាននៅពុំទាន់បានធ្វើបច្ចុប្បន្នភាព និង/ឬ ផលិតវីដេអូផ្សព្វផ្សាយថ្មីៗពាក់ព័ន្ធនឹងសេវាកម្ម សកម្មភាពការងារ សមិទ្ធផលសម្រេចបាន ក៏ដូចជាផែនការអភិវឌ្ឍកំពង់ផែ ដើម្បីផ្សព្វផ្សាយអំពីសក្តានុពលទីផ្សារ ការលក់ ឧត្តមភាពប្រកួតប្រជែង និងផលប្រយោជន៍នៃការប្រើប្រាស់សេវាកម្មរបស់ **កសស** នៅក្នុងគេហទំព័រផ្លូវការរបស់កំពង់ផែ ឬ ប្រព័ន្ធបណ្តាញសង្គមរបស់ **កសស** ស្របតាមសេដ្ឋកិច្ចឌីជីថលនៅឡើយ។

ប្រការខាងលើ នៅពុំទាន់ឆ្លើយតបពេញលេញតាមតម្រូវការ ការសិក្សា និងការរៀបចំយុទ្ធសាស្ត្រទីផ្សារឌីជីថល ក៏ដូចជាការវាស់វែងប្រសិទ្ធភាពនៃការផ្សព្វផ្សាយស្តង់ដា នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗនៅឡើយ។

ករណីនេះ អាចបណ្តាលមកពីភាពខ្វះចន្លោះ របស់មន្ត្រីទទួលបន្ទុកការងារក្នុងក្របខ័ណ្ឌការិយាល័យព័ត៌មានទីផ្សារ និងការផ្សព្វផ្សាយនៃនាយកដ្ឋានទីផ្សារ។

កត្តាខាងលើ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាព នៃការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ **កសស** នៅក្នុងគេហទំព័រ ឬ បណ្តាញសង្គមរបស់ **កសស**។

យោងបរិបទខាងលើ ថ្នាក់ដឹកនាំសវនដ្ឋាន គួរណែនាំការិយាល័យជំនាញដែលទទួលបន្ទុកព័ត៌មានទីផ្សារនិងផ្សព្វផ្សាយ ឱ្យបន្តពិនិត្យ សិក្សា រៀបចំឯកសារនិងរូបភាពសំខាន់ៗ ដើម្បីផលិតវីដេអូឡើងវិញ និងធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធនឹងសកម្មភាព សមិទ្ធផលការងារនិងការអភិវឌ្ឍដែលបានផ្សព្វផ្សាយក្នុងគេហទំព័រ និងបណ្តាញសង្គមរបស់ **កសស** ក្នុងរយៈពេលកន្លងមកឱ្យបានសមស្របនិងទាន់ពេលវេលា។

*នាយកដ្ឋានទីផ្សារបានដំណើរការ ការផលិតវីដេអូផ្សព្វផ្សាយរបស់ **កសស** ដោយបានដាក់ឯកសារជូនថ្នាក់ដឹកនាំសម្រេច និងណែនាំរួចហើយ គ្រោងនឹងចាប់ផ្តើមផលិតឆាប់ៗ និងអាចបញ្ចប់នៅខែ មករា ឬ ខែ កុម្ភៈ ឆ្នាំ ២០២៦ ខាងមុខ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.៩.២. របាយការណ៍ លទ្ធផលនៃដំណើរការទស្សនកិច្ចសិក្សាស្រាវជ្រាវ និងស្វែងយល់ពីក្រុមហ៊ុន អ្នកប្រើប្រាស់ផែ និងភាគីពាក់ព័ន្ធរបស់ កសស សម្រាប់ខែឧសភា-មិថុនា ឆ្នាំ ២០២៥

យោងតាមរបាយការណ៍លទ្ធផល នៃដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីក្រុមហ៊ុន អ្នកប្រើប្រាស់ផែ និងភាគីពាក់ព័ន្ធរបស់ **កសស** សម្រាប់ខែឧសភា-មិថុនា ឆ្នាំ ២០២៥ សវនករបានសង្កេតឃើញសវនដ្ឋានជួបពិភាក្សាការងារជាមួយក្រុមហ៊ុនៈ ១) តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SSEZ) ២) តំបន់សេដ្ឋកិច្ចពិសេស ចេ ជាំងហ្គូជី (Zhe Jiang Gouji SEZ) ៣) ក្រុមហ៊ុនផែស្ងួត អ៊ុយ ញ៉ុង (Union Dry Port) ៤) ក្រុមហ៊ុនផែស្ងួត ហុង ឡេងហួរ (HLH Dry Port) ៥) សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) និង ៦) តំបន់សេដ្ឋកិច្ចពិសេស អាយ អេស អាយ (ISI-SEZ) និងទទួលបានលទ្ធផលស្តីពីស្ថានភាពអាជីវកម្ម រួមទាំងបញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងសេវាកម្មរបស់ **កសស** ដូចខាងក្រោមៈ

**១. តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SSEZ)**

- ក្រុមហ៊ុននឹងមានការប្រឈមចំពោះការនាំចេញ-ចូល ប្រសិនបើមានការអនុវត្តយកពន្ធទៅមក (Reciprocal tariff) ដែលសហរដ្ឋអាមេរិកប្រកាសដាក់ពន្ធលើទំនិញនាំចូលពីកម្ពុជា ៤៩% ដែលអាចប៉ះពាល់ដល់ដំណើរការផលិត និងការនាំទំនិញចេញទៅកាន់សហរដ្ឋអាមេរិក។ បច្ចុប្បន្ន តំបន់សេដ្ឋកិច្ចពិសេស (SSEZ) កំពុងរង់ចាំលទ្ធផលនៃការចរចាររវាងថ្នាក់ដឹកនាំកម្ពុជា និងសហរដ្ឋអាមេរិក;
- ក្នុងអំឡុងចុងឆ្នាំ ២០២៣ និងដើមឆ្នាំ ២០២៤ កន្លងទៅ មានរោងចក្រផលិតបន្ទះសូឡានិងគ្រឿងបង្គុំបន្ទះសូឡាគ្រប់ប្រភេទ បានប្តូរទីតាំងទៅផលិតនៅប្រទេសផ្សេងពីកម្ពុជា ដោយសារសហរដ្ឋអាមេរិកបានអនុវត្តពន្ធនាំចូលខ្ពស់ លើទំនិញប្រភេទបន្ទះសូឡាពីកម្ពុជា។ ទំនិញប្រភេទបន្ទះសូឡា និងគ្រឿងបង្គុំបន្ទះសូឡានេះមានចំនួនកុងតឺន័រនាំចេញ-ចូលប្រមាណជា ៣០% នៃចំនួនកុងតឺន័រសរុបប្រចាំឆ្នាំរបស់ SSEZ ។

**២. ក្រុមហ៊ុនផែស្ងួត អ៊ុយ ញ៉ុង**

- មានការកកស្ទះនៅច្រកចូល-ចេញ នៅអំឡុងថ្ងៃចុងសប្តាហ៍ (សុក្រ-អាទិត្យ)
- រថយន្តនាំចូលទូកុងតឺន័រដល់ទីលានហើយ តែគ្រឿងចក្រមានបញ្ហា (ខូចម្តងម្កាល)
- មានការកកស្ទះនៅទីលានរថភ្លើង នៅពេលត្រូវដឹកទូកុងតឺន័រនាំចេញពីទីលានរថភ្លើងទៅទីលាននាំចេញ និងមានបញ្ហាចរាចរណ៍នៅក្នុងទីលាន ក្នុងចំណុចដែលកំពុងជួសជុល។

ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន ក្នុងនាម **កសស** នាយកដ្ឋានទីផ្សារនឹងខិតខំសម្របសម្រួល ក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនគុណភាពសេវាកម្មរបស់ **កសស** បន្ថែមទៀត។

ករណីខាងលើ អាចបណ្ដាលមកពីបញ្ហាសេដ្ឋកិច្ចសកល ដែលមានភាពមិនច្បាស់លាស់។ ចំពោះបញ្ហាចរាចរណ៍ គឺអាចបណ្ដាលមកពីកំណើនកុងតឺន័រនាំចូល-នាំចេញ ដែលបច្ចុប្បន្ននេះ ទំនិញនិងកុងតឺន័រឆ្លងកាត់ **កសស** កំពុងកើនឡើងលើសពីសមត្ថភាពរបស់កំពង់ផែ។

កត្តាខាងលើ អាចប៉ះពាល់ប្រសិទ្ធភាពនៃការផ្ដល់សេវាកម្មរបស់ **កសស**។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរខិតខំសម្របសម្រួលការងារខាងលើ ជាមួយនាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ និងសមត្ថកិច្ចពាក់ព័ន្ធដើម្បីរកដំណោះស្រាយជូន អតិថិជននិងអ្នកប្រើប្រាស់ផែឱ្យបានសមស្របនិងទាន់ពេលវេលា។

*នាយកដ្ឋានទីផ្សារបានតាមដានស្ថានការណ៍ជាមួយអតិថិជនពីខែ មិថុនា ដល់ ខែ តុលា ឆ្នាំ ២០២៥ ហើយបានកត់សម្គាល់ឃើញថា ស្ថានភាពបានប្រសើរឡើងជាទូទៅ ដោយសារកត្តាសំខាន់ៗចំនួន ៣៖*

*១ លំហូរចរាចរណ៍៖ ការកកស្ទះនៅច្រកចេញ-ចូលផែបានធូរស្បើយ បន្ទាប់ពីការរៀបចំស្លាកសញ្ញា គំនូសគន្លង និងការជួយសម្រួលចរាចរណ៍ពីសន្តិសុខផែ។*

*២ ដំណើរការគ្រឿងចក្រ៖ គ្រឿងចក្រលើកដាក់ដូចជា RTG ដំណើរការល្អជាងមុន និងមានបញ្ហាខូចខាតតិចតួច។*

*៣ ប្រសិទ្ធភាពទីលាន៖ ការប្រើប្រាស់ទីលានរថភ្លើងកាន់តែមានប្រសិទ្ធភាព បន្ទាប់ពីទីលានត្រូវបានពង្រីក និងជួសជុលបង្ហាប់ទំហំប្រមាណ ៣ ហិកតា។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

## ៥.៣.១០ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី (គ្រច)

### ៥.៣.១០.១. របាយការណ៍វឌ្ឍនភាពការងាររបស់នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី

យោងតាមរបាយការណ៍ស្ដីពីវឌ្ឍនភាពការងារ របស់នាយកដ្ឋានគ្រឿងចក្រនិងអគ្គិសនី ប្រចាំខែកក្កដា ឆ្នាំ ២០២៥ សវនករពិនិត្យឃើញសវនដ្ឋាន សម្រេចបានលទ្ធផលការងារសំខាន់ៗ ជាច្រើនពាក់ព័ន្ធនឹងផ្នែកជួសជុលបន្ទាន់ ការងារគ្រឿងចក្រធុនធ្ងន់ ផ្នែកថែទាំបង្ការការងារគ្រឿងចក្រធុនធ្ងន់ ផ្នែកស្ថានីយអគ្គិសនី និងផ្នែករោងជាងអគ្គិសនី។ ប៉ុន្តែសវនដ្ឋាននៅមានបញ្ហាមួយចំនួនពាក់ព័ន្ធនឹង៖

- ការថែទាំបបនីយកណ្ឌអគ្គិសនី ដែលកំពុងប្រើប្រាស់នៅក្នុងតំបន់កំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស នៅពុំទាន់មានស្ថិរភាព;
- ភាពយឺតយ៉ាវក្នុងការអនុវត្ត គម្រោងអភិវឌ្ឍបបនីយកណ្ឌអគ្គិសនីថ្មី ដែលកំពុងមានការកើនឡើងជាបន្តបន្ទាប់;
- ការត្រៀមសមត្ថភាពគ្រប់គ្រងនិងជួសជុល គ្រឿងចក្រធុនធ្ងន់ដែលនឹងមានការកើនឡើងយ៉ាងឆាប់នៅពេលខាងមុខ។

ប្រការខាងលើ អាចបណ្ដាលឱ្យមានភាពរអាក់រអួលដល់ សកម្មភាពអាជីវកម្មរបស់ **កសស** ជាយថាហេតុ។

ករណីនេះ អាចបណ្ដាលមកពីអ្នកជំនាញបច្ចេកទេសក្នុងក្របខ័ណ្ឌសវនដ្ឋាន ជាប់បំពេញការងារអាទិភាពរបស់ **កសស**។

កត្តានេះ អាចបណ្ដាលឱ្យមានភាពរអាក់រអួលដល់សកម្មភាពអាជីវកម្មរបស់ **កសស**។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរជំរុញការបណ្ដុះបណ្ដាលអ្នកជំនាញបច្ចេកទេសបន្ថែម និងរៀបចំផែនការគ្រប់គ្រងបបនីយកណ្ឌអគ្គិសនី នៅក្នុងតំបន់កំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេសឱ្យបានសមស្រប។

*នាយកដ្ឋានគ្រឿងចក្រនិងអគ្គិសនី នឹងព្យាយាមបណ្ដុះបណ្ដាលអ្នកជំនាញបច្ចេកទេសបន្ថែមតាមរយៈការអនុវត្តការងារជាក់ស្ដែង និង/ឬ នៅខាងក្រៅ ហើយនឹងខិតខំប្រឹងប្រែងពង្រឹងការងារគ្រប់គ្រងផ្នែកគ្រឿងចក្រនិងអគ្គិសនី ទៅតាមសមត្ថភាពនិងធនធានរបស់ខ្លួន។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.១០.២. ការផ្គត់ផ្គង់ និងគ្រប់គ្រងបណ្តាញអគ្គិសនីរបស់ កសស

យោងតាមការឆ្លើយបំភ្លឺនៅក្នុងកម្រងសំណួរ ស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់នាយកដ្ឋានគ្រឿងចក្រនិងអគ្គិសនី សវនករបានសង្កេតឃើញមានភាពខ្វះចន្លោះមួយចំនួនដូចខាងក្រោមៈ

- ការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅមានភាពរអាក់រអួលម្តងម្កាល ដោយសារក្រុមការងារកំពុងធ្វើបច្ចុប្បន្នភាពបរិក្ខារអគ្គិសនីចាស់ៗពុំទាន់រួចរាល់;
- ការថែទាំបណ្តាញនៅពុំទាន់មានពេលវេលាគ្រប់គ្រាន់ ដោយសារសន្ទុះនៃការលើកដាក់ទំនិញ/កុងតឺន័រ នៅក្នុងកំពង់ផែកាន់តែមានភាពមមាញឹក;

ប្រការខាងលើអាចនាំឱ្យ **កសស** ជួបការលំបាកខ្លះៗក្នុងពេលបច្ចុប្បន្ន។

ករណីនេះ អាចបណ្តាលមកពីមន្ត្រីជំនាញក្នុងក្របខ័ណ្ឌសវនដ្ឋាន ជាប់បំពេញការងារអាទិភាពរបស់ **កសស** រួមទាំងភាពមមាញឹកនៃការលើកដាក់ទំនិញ/កុងតឺន័រនៅក្នុងកំពង់ផែ ជាហេតុធ្វើឱ្យសវនដ្ឋានរង់ចាំពេលវេលាសមស្រប។

កត្តាខាងលើ អាចបណ្តាលឱ្យមានផលប៉ះពាល់ដល់ប្រសិទ្ធភាព នៃការគ្រប់គ្រងបណ្តាញអគ្គិសនី និងសកម្មភាពអាជីវកម្មរបស់ **កសស**។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការផ្គត់ផ្គង់ថាមពលអគ្គិសនី និងការថែទាំបណ្តាញនៅក្នុងតំបន់ប្រតិបត្តិការរបស់ **កសស**។

*នាយកដ្ឋានគ្រឿងចក្រនិងអគ្គិសនី សូមទទួលយកអនុសាសន៍របស់សវនករ ហើយនឹងខិតខំប្រឹងប្រែងពង្រឹងការងារគ្រប់គ្រង និងរៀបចំផែនការថែទាំបណ្តាញផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យមានស្ថិរភាព ដើម្បីធានានិរន្តរភាពអាជីវកម្មរបស់* ***កសស****។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.១១ នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស(រប.ធម)

#### ៥.៣.១១.១ ការអនុវត្តវិធានការសន្តិសុខបបនីយកណ្ឋផែ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

តាមការចុះពិនិត្យការអនុវត្ត វិធានការសន្តិសុខបបនីយកណ្ឋផែ និងគោលដៅសន្តិសុខនៅក្នុងបរិវេណ **កសស** និងតំបន់សេដ្ឋកិច្ចពិសេស សវនករបានពិនិត្យឃើញនាយសន្តិសុខបបនីយកណ្ឋផែ រៀបចំផែនការត្រួតពិនិត្យច្រកចេញ-ចូល ចាត់ចែងកម្លាំងយាមប្រចាំការ រៀបចំសណ្តាប់ធ្នាប់ ចរាចរណ៍ និងដើរល្បាតនៅតាមចំណុចសំខាន់ៗនៅក្នុងបរិវេណ **កសស** និងតំបន់សេដ្ឋកិច្ចពិសេស និងចេញ Declaration of Security (DOS) ជូននាវាដែលបានចុះកិច្ចសន្យាជាមួយ **កសស** រួមមាននាវាកុងតឺន័រ នាវាទំនិញរាយ នាវាទេសចរណ៍ នាវាទ័ព និងនាវាថ្មីៗជាច្រើនផ្សេងទៀត។

ទោះជាយ៉ាងណា សវនករបានសង្កេតឃើញមានចំណុច គួរឱ្យកត់សម្គាល់មួយចំនួនដូចខាងក្រោម៖

១. **ការត្រួតពិនិត្យ:** ពុំមានការត្រួតពិនិត្យជាលក្ខណៈ Random Check នូវប័ណ្ណសម្គាល់ខ្លួននិយោជិត កម្មករកំពង់ផែ រួមទាំងលិខិតអនុញ្ញាតផ្សេងៗ សម្រាប់ភ្ញៀវជាតិនិងអន្តរជាតិចេញ-ចូលកំពង់ផែនៅតាមច្រកទ្វារ ដែលជាកត្តាសំខាន់ក្នុងការពង្រឹងការអនុវត្តវិធានការសន្តិសុខបបនីយកណ្ឋផែ។

២. **ការរៀបចំសណ្តាប់ធ្នាប់ ចរាចរណ៍:** សណ្តាប់ធ្នាប់ ចរាចរណ៍នៅក្នុងបរិវេណ **កសស** មានលក្ខណៈល្អប្រសើរច្រើន ប៉ុន្តែនៅខាងក្រៅបរិវេណ **កសស** មានការកកស្ទះខ្លះៗ ដោយសារកំណាត់ផ្លូវជាតិលេខ ៤ តភ្ជាប់មក **កសស** កំពុងត្រូវបានពង្រីកនិងជួសជុល។

៣. **ការដើរល្បាត:** មានការសង្កេតឃើញបុគ្គលិកសន្តិសុខ ដើរល្បាតនៅក្នុងបរិវេណ **កសស** និងតំបន់សេដ្ឋកិច្ចពិសេសពុំសូវបានទៀងទាត់ ជាពិសេសនៅពេលយប់។

៤. **ស្ថានភាពរបង (កសស-តសព):** របងនៅជុំវិញបរិវេណ **កសស** មានប្រវែងសរុប ២៨៦០ម x ២,៤០ម ស្របតាមស្តង់ដារបស់ International Ship and Port Facility Security (ISPS) Code និង **តសព** មានប្រវែងសរុប ៥៥៧០មx២,១០ម+០.៨០ម។ ក្នុងនេះ មានបង្គោលភ្លើងនិងដើមឈើនៅជាប់របង តាមបណ្តោយច្រកផ្លូវរថយន្តដឹកកុងតឺន័រឆ្លងកាត់ពី CY ទៅតំបន់សេដ្ឋកិច្ចពិសេស រួមទាំងផ្នែកខាងមុខអគាររដ្ឋបាល **កសស** និងពីការិយាល័យគយទៅច្រកផ្លូវរថភ្លើង។

៥. **របងគល់ស្ពានផែចាស់:** លួសបន្លារបងនៅសងខាងគល់ស្ពានផែចាស់ ត្រូវបានច្រែះស៊ីពុកផុយស្ទើរទាំងស្រុង។

៦. **ច្រកទ្វាររថភ្លើង:** ច្រកទ្វាររថភ្លើងឆ្លងកាត់មានចំនួន ២ (ពីរ)។ ក្នុងចំណោមនេះ មានច្រកទ្វារ ១ (មួយ) អាចបិទបើកនិងប្រើប្រាស់បានដោយប្រសិទ្ធភាព។ ច្រកទ្វារ ១ (មួយ) ទៀតពុំមានរនាំងដែក និងលួសបន្លារុំព័ទ្ធជុំវិញផ្នែកខាងលើ ដែលអាចឱ្យជនខិលខូចចេញ-ចូលបាន។

វិធានការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន លេខ ៤៣២ ប្រក.សក.ដជទ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីសន្តិសុខ ឋបនីយកណ្ឌផែ នៃព្រះរាជាណាចក្រកម្ពុជា នៅឡើយ។

កត្តាខាងលើ អាចបណ្តាលមកពីពុំមានឧបករណ៍សន្តិសុខគ្រប់គ្រាន់ កង្វះនីតិវិធីប្រតិបត្តិការ ចរាចរណ៍កើនឡើង កង្វះការបណ្តុះបណ្តាល ការប្រាស្រ័យទាក់ទង និង/ឬ បុគ្គលិកសន្តិសុខមិន គ្រប់គ្រាន់។

កត្តានេះ អាចនាំឱ្យមានហានិភ័យខ្ពស់នៃការបំពានសុវត្ថិភាពសន្តិសុខ ដែលអាចប៉ះពាល់ ដល់ប្រតិបត្តិការកំពង់ផែ បន្ថយការជឿជាក់របស់ភាគីពាក់ព័ន្ធ ប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្ត វិធានការសន្តិសុខឋបនីយកណ្ឌផែនៅ **កសស** និងប្រកាសស្តីពីសន្តិសុខឋបនីយកណ្ឌផែនៃព្រះ រាជាណាចក្រកម្ពុជា របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរធ្វើការវាយតម្លៃសុវត្ថិភាពសន្តិសុខ បង្កើនការគ្រប់គ្រងសណ្តាប់ធ្នាប់ ចរាចរណ៍ ស្នើសុំបន្ថែមឧបករណ៍សំខាន់ៗ និងចាត់កម្លាំងដើរល្បាតជាទៀងទាត់ ដើម្បីបង្កើនការ តាមដាន និងឆ្លើយតបនឹងឧប្បត្តិហេតុសន្តិសុខបានទាន់ពេល។ ការបង្កើតនីតិវិធីប្រតិបត្តិការ (SOP) ជាក់លាក់ និងការលើកកម្ពស់ការបណ្តុះបណ្តាលសន្តិសុខ នឹងធានាការឆ្លើយតបបន្ទាន់ដោយ ប្រសិទ្ធភាព។ ការហ្វឹកហាត់ជាប្រចាំ ការត្រួតពិនិត្យការអនុវត្ត ISPS Code និងការចូលរួមពីភាគី ពាក់ព័ន្ធនឹងអាចពង្រឹងសុវត្ថិភាពកំពង់ផែ និងកាត់បន្ថយហានិភ័យបាន។

*នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍ និងខិតខំអនុវត្តស្របតាម អនុសាសន៍សវនកម្ម។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាម ដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត។

### ៥.៣.១១.២ ការតាមដាន ត្រួតពិនិត្យ ការអនុវត្តបទបញ្ជាផ្ទៃក្នុង-សុវត្ថិភាពពលកម្ម និងការងារបណ្តុះបណ្តាល មន្ត្រី-និយោជិត កម្មករ របស់ កសស

តាមការចុះពិនិត្យការតាមដាន ការអនុវត្តបទបញ្ជាផ្ទៃក្នុង-សុវត្ថិភាពពលកម្ម និងការងារបណ្តុះបណ្តាល មន្ត្រី-និយោជិត កម្មករ របស់ **កសស** សវនករបានសង្កេតឃើញថាដោយអនុវត្តតាមគោលការណ៍ខាងលើ មន្ត្រី-និយោជិត កម្មករគ្រប់រូប បានខិតខំបំពេញការងារស្របតាមបទបញ្ជាផ្ទៃក្នុង-សុវត្ថិភាពពលកម្ម និងលក្ខន្តិកៈបុគ្គលិករបស់ **កសស** និងទទួលបានការបណ្តុះបណ្តាលតាមមុខជំនាញរៀងៗខ្លួន។ បន្ថែមលើនេះ បុគ្គលិកដែលបានជ្រើសរើសថ្មីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលតម្រង់ទិស មុននឹងអនុញ្ញាតឱ្យចូលបម្រើការងារ។

ទោះជាយ៉ាងណា សវនករបានកត់សម្គាល់ឃើញ នៅមានមន្ត្រី-និយោជិត កម្មករ មួយចំនួនបានអវត្តមានការងារ និង/ឬ ទទួលការអនុញ្ញាតច្បាប់ឈប់សម្រាកព្យាបាលជំងឺ តាមគោការណ៍របស់ **កសស** ប៉ុន្តែនៅមានការខ្វះចន្លោះ ដោយពុំមានការបញ្ជាក់អំពីមូលហេតុ និងស្ថានភាពជំងឺច្បាស់លាស់ ហើយបុគ្គលិក កម្មករ កម្មករសេរី មួយចំនួននៅពុំទាន់បានអនុវត្តខ្ជាប់ខ្ជួននូវសម្ភារការពារពលកម្ម (អាវ ស្បែកជើង មួក និងស្រោមដៃ) ក្នុងពេលប្រតិបត្តិការ។ បន្ថែមលើនេះ បុគ្គលិកដែលបានជ្រើសរើសថ្មី ត្រូវបន្តការបណ្តុះបណ្តាលជំនាញបន្ថែមទៀត (ថែទាំ ជួសជុល មធ្យោបាយគ្រឿងចក្រ និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ)។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញតាមអនុក្រឹត្យលេខ ៥៦.អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដូចមានចែងនៅក្នុងផ្នែកទី ២ មាត្រា ៨៖ មន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា ត្រូវមានវត្តមានបំពេញការងារជាទៀងទាត់តាមពេលវេលាកំណត់ និងការស្នើសុំច្បាប់អនុញ្ញាតឈប់សម្រាកត្រូវបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ដូចមានចែងនៅក្នុងមាត្រា ៥ និងមាត្រា ៦ នៃអនុក្រឹត្យនេះ និងជំពូក V ប្រការ ២៤ នៃលក្ខន្តិកៈបុគ្គលិករបស់ **កសស** ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៣ នៅឡើយ។

ករណីនេះ អាចបណ្តាលមកពីការតាមដាន និងការត្រួតពិនិត្យអំពីការប្រតិបត្តិការងារនៅក្នុងនាយកដ្ឋាននីមួយៗនៅមិនទាន់បានគ្រប់គ្រាន់។ បន្ថែមលើនេះ កម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់ ត្រូវជំរុញឱ្យបានខ្លាំងបន្ថែមទៀតលើគ្រប់មុខជំនាញ ជាពិសេស ការថែទាំ ជួសជុល មធ្យោបាយគ្រឿងចក្រ និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ។

កត្តានេះ អាចប៉ះពាល់ប្រសិទ្ធភាពអនុវត្តអនុក្រឹត្យលេខ ៥៦.អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា និងគោលការណ៍វិន័យ ដូចមានចែងនៅក្នុងជំពូក V ប្រការ ២៤ នៃលក្ខន្តិកៈបុគ្គលិករបស់ **កសស** ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៣ និងការមិនគោរពលក្ខខណ្ឌនានាដែលបានកំណត់នៅក្នុងកិច្ចសន្យា។

សវនដ្ឋានគួរអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃឱ្យបានសមស្រប ដើម្បីតាមដានវត្តមាន និងការប្រតិបត្តិការងាររបស់និយោជិត ដើម្បីឱ្យស្របតាមបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិករបស់ **កសស** ។ បន្ថែមលើនេះ គួរធ្វើការពិនិត្យ និងជំរុញការងារសុវត្ថិភាពពលកម្ម និងការងារបណ្តុះបណ្តាលលើគ្រប់មុខជំនាញបន្ថែមទៀត ដើម្បីឱ្យ **កសស** ទទួលបានគុណភាព ប្រសិទ្ធភាព និងផលិតភាពប្រតិបត្តិការខ្ពស់។

*នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស ទទួលយកអនុសាសន៍ និងខិតខំអនុវត្តស្របតាមអនុសាសន៍សវនកម្ម ។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

## ៥.៣.១២ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ (គណ.ហិ/វ)

### ៥.៣.១២.១ បង្កាន់ដៃទទួលប្រាក់អេឡិចត្រូនិក (PAS E-Receipt) របស់ កសស

តាមការចុះពិនិត្យជាក់ស្តែង និងការសាកសួរមន្ត្រីជំនាញ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សវនករបានកត់សម្គាល់ឃើញថា ចាប់តាំងពីការដាក់ឱ្យអនុវត្តន៍ ការទូទាត់ប្រាក់តាមប្រព័ន្ធ E-Payment នៅបញ្ជរបេឡារបស់ **កសស** កាលថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០២៤ ដល់បច្ចុប្បន្ននេះ ការទទួលប្រាក់ចំណូលនៅបញ្ជរបេឡា មានភាពឆាប់រហ័ស និងងាយស្រួលជាងមុនច្រើនពីព្រោះអតិថិជនមានជម្រើសក្នុងការបង់ប្រាក់ និងទូទាត់វិក្កយបត្រជូន **កសស** (សាច់ប្រាក់, KHQR, PAS App)។

ដោយប្រតិបត្តិការអាជីវកម្មរបស់ **កសស** មានបរិមាណកុងតឺន័រឆ្លងកាត់កើនឡើងខ្ពស់ ដូច្នេះចំនួនវិក័យបត្រ ក៏មានការកើនឡើងច្រើនដែរ ជាហេតុធ្វើឱ្យសវនដ្ឋាននៅមានការប្រឈមមួយចំនួនពាក់ព័ន្ធនឹងកំណើនវិក្កយបត្រ ពីព្រោះនៅពេលអតិថិជនបានបង់ប្រាក់នៅបញ្ជរបេឡា បេឡាករត្រូវបោះត្រា PAID លើគ្រប់សន្លឹកវិក្កយបត្រជូនគ្រប់អតិថិជន (៤សន្លឹក/វិក្កយបត្រ) ដែលករណីនេះបណ្តាលឱ្យមានការចំណាយពេលវេលា និងនាំឱ្យអតិថិជនរង់ចាំយូរ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ចុះខែសីហា ឆ្នាំ ២០២៣ ក្នុងបញ្ចកោណទី៥. ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ចំណុចមុំទី២. ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងប្រព័ន្ធនវានុវត្តន៍ឌីជីថល។

ករណីខាងលើ បណ្តាលមកពីបេឡាករត្រូវចំណាយពេលវេលា ក្នុងការបោះត្រា PAID របស់ **កសស** លើគ្រប់សន្លឹកវិក្កយបត្រដែលអតិថិជន បានបង់ប្រាក់រួចនៅតាមបញ្ជរបេឡា ចំនួន៤សន្លឹកក្នុងវិក្កយបត្រមួយ (២ សន្លឹកសម្រាប់អតិថិជន និង ២សន្លឹកទៀតសម្រាប់នាយកដ្ឋានអាជីវកម្មនិងនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ) ហើយជាមធ្យម **កសស** មានវិក្កយបត្រចំនួន ១,៣០០ សន្លឹក ក្នុង១ថ្ងៃ (១,៣០០ វិក្កយបត្រ x ៤ សន្លឹក) ស្មើនឹង ៥,២០០ វិក្កយបត្រ សម្រាប់ជូនអតិថិជន និងសម្រាប់ **កសស** រក្សាទុកជាឯកសារ។

កត្តានេះ អាចប៉ះពាល់ដល់ប្រសិទ្ធភាពអនុវត្ត និងធ្វើឱ្យការបម្រើសេវាកម្មផ្នែកបេឡាជូនអតិថិជនរបស់ **កសស** មានភាពយឺតយ៉ាវ និងពុំទាន់សមស្របតាមធុរកិច្ចឌីជីថល។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយនាយកដ្ឋានជំនាញ សិក្សាបន្ថែមមុខងារ Module របស់ប្រព័ន្ធ SWSS ឱ្យបានសមស្របតាមតម្រូវការកំណើននៃការចេញវិក្កយបត្រ ដោយបង្កើត/ចេញបង្កាន់ដៃទទួលប្រាក់ (PAS E-Receipt) ជាអេឡិចត្រូនិកសម្រាប់ **កសស** ដើម្បីបញ្ជាក់អំពីការបង់ប្រាក់រួចរបស់អតិថិជន។

*សវនដ្ឋាននឹងសហការណ៍ ជាមួយនាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីបន្ថែមនូវមុខងារ Module របស់ប្រព័ន្ធ SWSS ដើម្បីអាចចេញជាបង្កាន់ដៃទទួលប្រាក់ (PAS E-Receipt) ជាអេឡិចត្រូនិក ជំនួសឱ្យការបោះត្រា PAID លើគ្រប់វិក្កយបត្រ នៅបញ្ជរបេឡារបស់* ***កសស*** *។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

**៥.៣.១២.២ មុខងារផ្លាស់ប្តូរប្រភេទទទួលប្រាក់ (Payment Type) និងមុខងារបញ្ចូលវិក្កយបត្រចូលក្នុងកន្ត្រកបង់ប្រាក់សម្រាប់ប្រព័ន្ធ SWSS**

តាមការចុះពិនិត្យជាក់ស្តែង និងការសាកសួរមន្ត្រីជំនាញ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ សវនករបានកត់សម្គាល់ឃើញ៖

១- អតិថិជនជាច្រើន ដែលមកបង់ប្រាក់នៅបញ្ជរបេឡា (ក្នុងម្នាក់មានប្រហែលជា ៨០ លេខវិក្កយបត្រ ឬ លើសពីនេះ) នៅពេលបង់ប្រាក់ បុគ្គលិក **កសស** នៅបញ្ជរបេឡា តែងតែសាកសួរពីការជ្រើសរើសប្រភេទនៃការទូទាត់ (សាច់ប្រាក់ ឬ KHQR តាមរយៈធនាគារដៃគូ)។ ករណីដែលបេឡាករបានជ្រើសរើសប្រភេទ នៃការទូទាត់រួចហើយ ហើយអតិថិជនស្នើឱ្យផ្លាស់ប្តូរប្រភេទនៃការទូទាត់វិញ ចាំបាច់តម្រូវឱ្យបេឡាករធ្វើការ Cancel Paid Invoice ម្តងមួយលេខៗទាំងអស់ ហើយតម្រូវឱ្យធ្វើការ Scan Invoice បញ្ចូលម្តងមួយលេខៗជាថ្មីឡើងវិញទាំងអស់ ទើបអាចជ្រើសរើសប្រភេទនៃការទូទាត់ប្រាក់ (Payment Type) ជាថ្មីបាន។

២- អតិថិជនដែលបង់ប្រាក់តាម Cheque ឬ Bank Transfer ជាកញ្ចប់ក្នុងចំនួនលេខវិក្កយបត្រច្រើន (អតិថិជនដែលមានប្រាក់តម្កល់នៅ **កសស** នឹងអនុញ្ញាតឱ្យធ្វើការទូទាត់ ១ សប្តាហ៍ម្តង) តម្រូវឱ្យបេឡាករចំណាយពេលវេលាក្នុងការ Scan វិក្កយបត្រទាំងនោះបញ្ចូលម្តងមួយៗ ដើម្បីចុច Paid (វិក្កយបត្របានបង់ប្រាក់រួច) នៅក្នុងប្រព័ន្ធ SWSS ។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ចុះខែសីហា ឆ្នាំ ២០២៣ ក្នុងបញ្ចកោណទី៥. ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ចំណុចមុំទី២. ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងប្រព័ន្ធនវានុវត្តន៍ឌីជីថល។

ករណីខាងលើ អាចបណ្តាលមកពីអតិថិជន មានភាពមិនច្បាស់លាស់ក្នុងការកំណត់ការជ្រើសរើសប្រភេទនៃការទូទាត់ប្រាក់ជូន **កសស** ឬ អាចបណ្តាលមកពីបេឡាករធ្វើការជ្រើសរើសប្រភេទនៃការទូទាត់ប្រាក់ខុស។ បន្ថែមលើនេះ ការប្រើប្រាស់វិក្កយបត្រច្រើនសម្រាប់ធ្វើការទូទាត់ដោយ Cheque ឬ Bank Transfer នាំឱ្យមានការចំណាយរយៈពេលយូរពីព្រោះតម្រូវឱ្យបេឡាករដំណើរការ Scan វិក្កយបត្រនិងចុច Paid ម្តងមួយៗ។

កត្តានេះ អាចប៉ះពាល់ដល់ប្រសិទ្ធភាពការងារនៅបញ្ជរបេឡា ព្រោះក្នុងករណីជ្រើសរើសប្រភេទនៃការទូទាត់ប្រាក់ខុសម្តងៗ បេឡាករត្រូវស្នើសុំប្តូរ (Cancel) ប្រភេទនៃការទូទាត់ពីមន្ត្រីដែលមានសិទ្ធិទើបអាចធ្វើការ Scan វិក្កយបត្រម្តងមួយៗឡើងវិញបាន។ លើសពីនេះទៀតចំនួននៃការប្រើប្រាស់វិក្កយបត្រច្រើន អាចបណ្តាលឱ្យប៉ះពាល់ដល់ ប្រសិទ្ធភាពការងាររបស់បេឡាករ និងនាំឱ្យអតិថិជនត្រូវរង់ចាំយូរ។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរសហការជាមួយនាយកដ្ឋានជំនាញ ដើម្បីសិក្សាបន្ថែមមុខងារសម្រាប់ផ្លាស់ប្តូរ/កែប្រែប្រភេទនៃការទូទាត់នៅក្នុងប្រព័ន្ធ SWSS។ ការកែលម្អនេះ មិនត្រឹមតែបង្កើនការពេញចិត្តរបស់អតិថិជនប៉ុណ្ណោះទេ ប៉ុន្តែវានឹងអាចជួយកាត់បន្ថយកំហុសឆ្គងផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុ នៅក្នុងដំណើរការទូទាត់។

*សវនដ្ឋាននឹងសហការណ៍ជាមួយនាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីសិក្សាបន្ថែមនូវមុខងារ (Module) ក្នុងការកែសម្រួលប្រភេទនៃការទូទាត់ (Payment Type) របស់ប្រព័ន្ធ SWSS សម្រាប់បេឡាករនៅបញ្ជរបេឡា និងវិក្កយបត្រដែលមានចំនួនច្រើន ចូលទៅក្នុងកន្ត្រកសម្រាប់ចុច Paid Invoice នៅក្នុងប្រព័ន្ធ SWSS សម្រាប់អតិថិជនដែលមានប្រាក់តម្កល់នៅ **កសស**។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

## ៥.៣.១៣ នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ (ផលស)

### ៥.៣.១៣.១. ការគ្រប់គ្រង និងរក្សាទុកទិន្នន័យអាជីវកម្ម

តាមការពិនិត្យការងារគ្រប់គ្រង និងការរក្សាទុកទិន្នន័យអាជីវកម្ម នៅនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ សវនករបានសង្កេតឃើញទិន្នន័យពីគ្រប់នាយកដ្ឋានជំនាញ ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការអាជីវកម្ម រួមមានឯកសារឌីជីថលនិងឯកសាររឹង ត្រូវបានប្រមូលនិងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណា មានបញ្ហាមួយចំនួនធ្វើឱ្យការរួមបញ្ចូលទិន្នន័យមានការលំបាក និងកង្វះស្តង់ដាប្រព័ន្ធសម្រាប់ការប្រមូល និងរក្សាទុកទិន្នន័យ។ បញ្ហាទាំងនេះរួមមាន៖

១- **ការកំណត់ពេលបិទនៃការកត់ត្រាទិន្នន័យ**: នាយកដ្ឋានខ្លះយកពេលបិទនៃការកត់ត្រា ត្រឹមម៉ោង ២៤៖០០ រៀងរាល់ចុងខែនីមួយៗ នាយកដ្ឋានខ្លះយករយៈពេលតាមនាវាចូលចត ហើយនាយកដ្ឋានមួយចំនួនទៀត កត់ត្រាបញ្ចប់នៅពេលនាវាចាកចេញពីផែ។

២- **ការកំណត់នៃការបូកសរុប និងរាយការណ៍**: ស្ថាប័នខ្លះតម្រូវឱ្យនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ បូកសរុបយោងពីខែចាស់ មកត្រឹមថ្ងៃទី ២០ ឬ២៥ ឬចុងខែដែលកំពុងអនុវត្ត។

ប្រការខាងលើ នៅពុំទាន់អនុលោមពេញលេញ តាមយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី ១ ចុះខែសីហា ឆ្នាំ ២០២៣ ក្នុងបញ្ចកោណទី៥. ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ចំណុចមុំទី២. ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងប្រព័ន្ធនវានុវត្តន៍ឌីជីថល។

កត្តាខាងលើ អាចកើតមានឡើងដោយសារកង្វះវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងទិន្នន័យពីនាយកដ្ឋានជំនាញរបស់ **កសស** និងស្ថាប័នពាក់ព័ន្ធ។ កង្វះស្តង់ដានេះ អាចធ្វើឱ្យពិបាកក្នុងការបញ្ចូលព័ត៌មាន និងនាំឱ្យមានវិធីសម្រាប់ទទួល ប្រមូល និងរក្សាទុកទិន្នន័យផ្សេងៗពីគ្នា។

កត្តានេះ អាចធ្វើឱ្យរបាយការណ៍បូកសរុបលទ្ធផលអាជីវកម្ម សម្រាប់ប្រើប្រាស់នៅ **កសស** ពុំមានសង្គតិភាព ជាមួយរបាយការណ៍ផ្ញើទៅស្ថាប័នពាក់ព័ន្ធ (រដ្ឋបាលខេត្ត)។

ថ្នាក់ដឹកនាំសវនដ្ឋាន គួរបង្កើតវិធាននិងនីតិវិធីស្តង់ដា សម្រាប់គ្រប់គ្រងទិន្នន័យដែលទទួលបានពីគ្រប់នាយកដ្ឋានទាំងអស់ រួមទាំងការបណ្តុះបណ្តាលជាប្រចាំ ដើម្បីធានាថាបុគ្គលិកយល់ដឹងនិងអនុវត្តន៍នីតិវិធីទាំងនេះ។

*នាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ នឹងខិតខំសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើឱ្យការរៀបចំរបាយការណ៍មានសង្គតិភាព។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តបន្ទាប់ទៀត ។

### ៥.៣.១៣.២. របាយការណ៍វឌ្ឍនភាពការងារ គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំហានទី ១ ប្រចាំខែធ្នូ ឆ្នាំ ២០២៥

យោងតាមរបាយការណ៍វឌ្ឍនភាព គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំហានទី ១ ប្រចាំខែធ្នូ ឆ្នាំ ២០២៥ រួមមានៈ ប្រវែងចំណតផែ ៣៥០ ម៉ែត្រ (ជម្រៅទឹក -១៤.៥០ ម៉ែត្រ) ការងារបូមស្តារអាងនាវាអង្កត់ផ្ចិតប្រវែង ៦៤០ ម៉ែត្រ និងឃ្លងនាវាប្រវែង ៤,០០០ ម៉ែត្រ រហូតដល់ជម្រៅ -១៣.៥០ ម៉ែត្រ សមត្ថភាពទីលានស្តុកកុងតឺន័រ ១៧.៥០ ហិកតា សមត្ថភាពស្តុកកុងតឺន័រនៅទីលាន ៤៥០,០០០ TEUs/ឆ្នាំ ទីលានត្រួតពិនិត្យទំនិញដោយសមត្ថកិច្ចគយ ៨.០០ ហិកតា រួមទាំងការងារសាងសង់ផ្លូវចូលទីតាំងគម្រោងស្ពានចូលទីតាំងគម្រោង និងអគាររដ្ឋបាល ។ល។ ក្រោមកិច្ចព្រមព្រៀងឥណទានលេខៈ CP-P21 ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៧ កាលបរិច្ឆេទចុះកិច្ចសន្យាសាងសង់នៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០២៣ កាលបរិច្ឆេទចាប់ផ្តើមសាងសង់នៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២៤ និងកាលបរិច្ឆេទបញ្ចប់ការសាងសង់នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២៧ សវនករបានពិនិត្យឃើញការអនុវត្តគម្រោងសម្រេចបានលទ្ធផលជារួម ៥៤.៣៦ ភាគរយ។

ទោះជាយ៉ាងណា គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំហានទី ១ នៅមានបញ្ហាប្រឈមមួយចំនួន ដែលក្នុងនេះតម្លៃដេញថ្លៃកញ្ចប់ទី ១-ការងារសំណង់ស៊ីវិល និងតម្លៃដេញថ្លៃការងារកញ្ចប់ទី ២-ការងារគ្រឿងចក្រធុនធ្ងន់ លើសពីតម្លៃប៉ាន់ស្មានគម្រោង ដែលបណ្តាលឱ្យខ្វះខាតថវិកាគម្រោង ដោយសារការធ្លាក់ចុះប្រាក់យ៉េនជប៉ុន និងបញ្ហាសេដ្ឋកិច្ចសាកល។ បន្ថែមលើនេះ ដំណើរការដេញថ្លៃកញ្ចប់ទី ១ និងទី ២ មានការយឺតយ៉ាវជាងកម្មវិធីគ្រោងទុកដែលបណ្តាលឱ្យការអនុវត្តគម្រោង ត្រូវពន្យារពេលប្រមាណ ៣ ឆ្នាំ រហូតដល់ឆ្នាំ ២០២៨។

ប្រការខាងលើ បណ្តាលឱ្យមានការអូសបន្លាយពេលវេលាច្រើន និងពុំអាចឆ្លើយតបបានទាន់ពេលវេលានូវកំណើនបរិមាណកុងតឺន័រឆ្លងកាត់ **កសស** ដែលកំពុងមានការកើនឡើងយ៉ាងគំហុក។

ប្រការខាងលើ អាចបណ្តាលមកពីការឆ្លងរាលដាលនៃជម្ងឺ Covid-19 បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាន នៃការផ្តល់ហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន នៅថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ ជាហេតុនាំឱ្យមានការពន្យារពេល ដល់ការរៀបចំនីតិវិធីការងារ និងដំណើរការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ រួមទាំងការជ្រើសរើសក្រុមហ៊ុនសាងសង់ និងទីប្រឹក្សាគម្រោង។

ប្រការនេះ អាចបណ្តាលឱ្យប៉ះពាល់ប្រសិទ្ធភាព នៃការអនុវត្តសេចក្តីសម្រេចខាងលើ។

អង្គភាពគ្រប់គ្រងគម្រោង គួរស្នើសុំក្រសួងអាណាព្យាបាល ជួយសម្របសម្រួលនិងដោះស្រាយ កង្វះហិរញ្ញប្បទានប្រាក់គម្រោងឱ្យបានសមស្រប ដើម្បីជៀសវាងការពន្យារពេលក្នុងការសាងសង់គម្រោង NCT2 និង NCT3។

*ថ្នាក់ដឹកនាំគ្រប់គ្រងគម្រោង នឹងខិតខំសហការជាមួយអង្គការ JICA និងក្រសួងពាក់ព័ន្ធដើម្បីពន្លឿនការអនុវត្តគម្រោងឱ្យប្រព្រឹត្តទៅតាមផែនការដែលបានគ្រោងទុក។*

ក្រុមការងារសវនកម្ម បានកត់សម្គាល់ការឆ្លើយបំភ្លឺរបស់ថ្នាក់ដឹកនាំសវនដ្ឋាន និងបន្តតាមដានការអនុវត្តអនុសាសន៍សវនកម្ម ជាបន្តបន្ទាប់ទៀត ។

## ៦. សេចក្តីសន្និដ្ឋានរួម

នៅក្នុងអំឡុងពេលនៃការធ្វើសវនកម្មនេះ សវនករបានពិនិត្យឃើញសវនដ្ឋាននីមួយៗខិតខំប្រឹងប្រែង រៀបចំដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាព ផលិតភាពប្រតិបត្តិការនិងការទទួលខុសត្រូវ ។ ជាមួយគ្នានេះ ក្រុមការងារសវនកម្មបានសង្កេតឃើញថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកគ្រប់នាយកដ្ឋាន មានឆន្ទៈរួមសហការ និងយកចិត្តទុកដាក់បំពេញតួនាទី-ភារកិច្ចរបស់ខ្លួន ដោយអនុលោមតាមលក្ខន្តិកៈបុគ្គលិក **កសស** គោលការណ៍ច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

## ៧. ផែនការសកម្មភាពកែលម្អ

ដើម្បីជានាប្រសិទ្ធភាពអនុវត្ត និងកែលម្អតាមអនុសាសន៍ដែលសវនករបានផ្តល់ជូន ថ្នាក់ដឹកនាំនាយកដ្ឋានអាជីវកម្ម នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ នាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ នាយកដ្ឋាននាវាចរ-កណ្តាលនាយកដ្ឋានបច្ចេកទេស-សម្ភារ នាយកដ្ឋានសំណង់-វិស្វកម្ម នាយកដ្ឋានតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទីផ្សារ នាយកដ្ឋានគ្រឿងចក្រ និងអគ្គិសនី នាយកដ្ឋានរដ្ឋបាល-ធនធានមនុស្ស នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ-លទ្ធកម្មនិងស្ថិតិ បានឯកភាពតាមផែនការសកម្មភាពកែលម្អ ដូចបានកំណត់នៅក្នុងតារាងនៃ **ឧបសម្ព័ន្ធទី ២** ។

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ខេត្តព្រះសីហនុ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២៦

**បានឃើញ និងឯកភាព**
ខេត្តសៀមរាប ថ្ងៃទី...១៦...ខែ...កុម្ភៈ... ឆ្នាំ ២០២៦
**ប្រធានគណៈកម្មាធិការសវនកម្ម**

**ហ៊ុន មុន្នីវណ្ណ**

**នាយកសវនកម្មផ្ទៃក្នុង**

**ម៉ែន ចាន់**

# ឧបសម្ព័ន្ធ២

## របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំ

## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

| **មាតិកា** | **ទំព័រ** |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១ - ៤ |
| របាយការណ៍សវនករឯករាជ្យ | ៥ - ១២ |
| របាយការណ៍ហិរញ្ញវត្ថុ៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១៣ |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ១៤ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៥ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៦ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១៧ - ៧៧ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្ដីសោមនស្ស ក្នុងការដាក់ជូនរបាយការណ៍របស់ខ្លួន និង របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា 'កសស') សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

## អំពីក្រុមហ៊ុន

កសស គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានទីស្នាក់ការកណ្ដាលរបស់ខ្លួននៅខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

កសស គឺជានីតិអង្គភាពដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្ដល់ស្ថានភាពឱ្យក្រុមហ៊ុនជាគ្រឹះស្ថានស្វយ័តសាធារណៈ។

កសស បានចុះបញ្ជីពាណិជ្ជកម្មជាសហគ្រាសសាធារណៈរបស់រដ្ឋនៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ 'គ' របស់ កសស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា 'ផ.ម.ក') នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។

សកម្មភាពអាជីវកម្មចម្បងរបស់ កសស គឺពាក់ព័ន្ធនឹងការផ្ដល់ជូនសេវាកំពង់ផែសមុទ្រ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកំពង់ផែ ព្រមទាំងភតិសន្យាប្រតិបត្តិក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួន។

ទីស្នាក់ការចុះបញ្ជីរបស់ កសស មានទីតាំងស្ថិតនៅតិរវិថី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុរបស់ កសស ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និង លទ្ធផលលម្អិតផ្សេងៗ នៃរបាយការណ៍ហិរញ្ញវត្ថុនៅលើទំព័រទី ១៤។

ភាគលាភដែលបានប្រកាស និងបានបង់ក្នុងឆ្នាំត្រូវបានកំណត់ក្នុងសម្គាល់ ៣០.២ នៃរបាយការណ៍ហិរញ្ញវត្ថុ។



តិរវិថី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

## របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)

### ក្រុមប្រឹក្សាភិបាល

ចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយ ក្រុមប្រឹក្សាភិបាលរបស់ កសស មានសមាសភាគដូចខាងក្រោម៖

| | | |
|---|---|---|
| ឯកឧត្តម លូ គឹមឈន់ | ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តមបណ្ឌិត ផាន់ ផល្លា | តំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ឈួន រិន | តំណាងឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម គឹម ស៊ីថន | តំណាងឱ្យក្រសួងពាណិជ្ជកម្ម | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក លូ លីខេង | តំណាងនិយោជិត កសស | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក ហ៊ុន មុន្នីវណ្ណ | អភិបាលឯករាជ្យ | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក Hidetoshi Kume | អភិបាលមិនប្រតិបត្តិ | សមាជិកក្រុមប្រឹក្សាភិបាល |

### ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានកត់សម្គាល់ហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភាន់ច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ កសស នោះទេ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ កសស ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុមក ឬ

ខ. មិនមានបំណុលយថាហេតុណាមួយរបស់ កសស ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុមកក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវបានទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំហិរញ្ញវត្ថុ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ កសស ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

### ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានកែតម្រូវនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ កសស ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**
**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ កសស សម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ មិនមានរងនូវផលប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំហិរញ្ញវត្ថុ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ កសស ក្នុងឆ្នាំហិរញ្ញវត្ថុដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុដែលរៀបចំដោយគណៈគ្រប់គ្រង និងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាព-ហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា 'CIFRS')។ ក្នុងការរៀបចំរបាយ-ការណ៍ហិរញ្ញវត្ថុទាំងនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្របអនុលោមតាម CIFRS ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតិ-ភាព។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ CIFRS ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានភាពមិនសមស្របក្នុងការសន្មតថា កសស នឹងបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. គ្រប់គ្រងនិងដឹកនាំ កសស ឱ្យមានប្រសិទ្ធភាព និងចូលរួមក្នុងការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ កសស ហើយត្រូវធានាថាការសម្រេចចិត្តទាំងនេះ ត្រូវបានឆ្លុះបញ្ចាំង ត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា កសស បានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**

**ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ កសស គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ-ជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ចុះហត្ថលេខាតាងនាមក្រុមប្រឹក្សាភិបាល

ឯកឧត្តម លូ គីមឈន់
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធាន
ក្រុមប្រឹក្សាភិបាល និង ប្រធាននាយកប្រតិបត្តិ

លោក ពិត ប្រាកដ
នាយក គណនេយ្យ និងហិរញ្ញវត្ថុ

ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២៦



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

pwc

## របាយការណ៍សវនករឯករាជ្យ

ជូនភាគទុនិក កំពង់ផែស្វយ័តក្រុងព្រះសីហនុ

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា 'កសស') គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (ហៅកាត់ថា CIFRS)។

របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ កសស រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធន សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត និងព័ត៌មានពន្យល់ផ្សេងៗទៀត។

PricewaterhouseCoopers (Cambodia) Ltd.
P.O. Box 1147, 58C Sihanouk Blvd, Sangkat Tonle Bassac,
Khan Chamkarmon, Phnom Penh 120101
T: +855 (0)23/69 860 606

**មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា ស្តង់ដាសវនកម្ម)។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពី កសស ដែលអនុលោមទៅតាមតម្រូវការក្រមសីលធម៌ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករ និង សវនករកម្ពុជា (ហៅកាត់ថា ក្រមសីលធម៌ CPAA) រួមជាមួយនឹងវិធានឯករាជ្យរបស់ និយ័តករមូលបត្រកម្ពុជា (ហៅកាត់ថា នមក) ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមតម្រូវការនៃក្រមសីលធម៌ CPAA និង វិធានឯករាជ្យរបស់ នមក ។

**បញ្ហាសវនកម្មសំខាន់ៗ**

បញ្ហាសវនកម្មសំខាន់ៗគឺជាបញ្ហាទាំងឡាយណា ដែលនៅក្នុងការវិនិច្ឆ័យវិជ្ជាជីវៈរបស់យើងខ្ញុំ មានសារៈសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទ។ យើងខ្ញុំកំណត់បញ្ហាសវនកម្មសំខាន់មួយគឺ កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍។ បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងបរិបទនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងនៅក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ហើយយើងខ្ញុំមិនបញ្ចេញមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហានេះទេ។

| បញ្ហាសវនកម្មសំខាន់ៗ | នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| យោងទៅកំណត់សម្គាល់ ២.២១.៣ – សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត ស្តីពីកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍<br>កំណត់សម្គាល់ ៣ – ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ការសន្មត និងការវិនិច្ឆ័យ លើកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ និងកំណត់សម្គាល់ ១៦ – កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍។<br><br>គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ កសស មានសមតុល្យដែលនៅមិនទាន់ទូទាត់ នៃគម្រោងអត្ថប្រយោជន៍សោធននិវត្តន៍ចំនួន ៩៨.៨៥៣.៨២៦ ពាន់រៀល។<br><br>គណៈគ្រប់គ្រង បានវាយតម្លៃបំណុលកាតព្វកិច្ច អាស្រ័យទៅតាមទិន្នន័យប្រជាសាស្ត្រក្នុងគ្រាកន្លងមក ស្ថានភាពអាជីវកម្មក្នុងពេលបច្ចុប្បន្ន និងគោលការណ៍គណនេយ្យ។<br><br>ការវាយតម្លៃ កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ តម្រូវឱ្យមាន ការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រង និងអ្នកជំនាញបច្ចេកទេសក្នុងការអនុវត្តការសន្មតដែលសមស្រប។ បម្រែបម្រួលការសន្មតសំខាន់ៗ រួមមាន កំណើនប្រាក់បៀវត្សរ៍ អត្រាអប្បហារ និងអត្រាបម្រែបម្រួលបុគ្គលិកដែលអាចនាំឱ្យមានផលប៉ះពាល់ជាសារវន្តលើការគណនាបំណុល។ គណៈគ្រប់គ្រងក៏បានជួលក្រុមអ្នកជំនាញខាងក្រៅ ដើម្បីធ្វើការគណនាលម្អិតអំពីភាពស្មុគស្មាញនេះផងដែរ។ | នីតិវិធីសវនកម្មរបស់យើងខ្ញុំ ដែលទាក់ទិនទៅនឹងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង លើចំនួនទឹកប្រាក់បំណុល រួមមាន៖<br>• វាយតម្លៃអំពីសមត្ថភាព ឯករាជ្យ និងភាពម៉ឺងម៉ាត់ ព្រមទាំងវាយតម្លៃលក្ខណៈសម្បត្តិនៃអ្នកជំនាញរបស់គណៈគ្រប់គ្រង (ក្រុមអ្នកជំនាញខាងក្រៅ) និងពិនិត្យលើវិសាលភាពការងាររបស់ពួកគាត់ផងដែរ។<br>• វាយតម្លៃលើការសន្មតហានិភ័យ ដោយប្រៀបធៀបកំណើនប្រាក់បៀវត្សរ៍ ជាមួយនឹងកំណើនប្រាក់បៀវត្សរ៍ក្នុងគ្រាកន្លងមក និងគម្រោងនាពេលអនាគត ប្រៀបធៀបអត្រាអប្បហារជាមួយនឹងអត្រាការប្រាក់នៃប្រាក់បញ្ញើដែលមានប្រភេទរូបិយវត្ថុ/ កាលកំណត់ដូចគ្នា ព្រមទាំងអត្រាបម្រែបម្រួលបុគ្គលិក ទៅនឹងអត្រាបម្រែបម្រួលបុគ្គលិកកន្លងមក ហើយធ្វើការវាយតម្លៃភាពសមហេតុផលនៃកាតព្វកិច្ចអត្ថប្រយោជន៍។<br>• ផ្ទៀងផ្ទាត់បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ ជាមួយនឹងព័ត៌មានគាំទ្រមូលដ្ឋាន ដូចជា ចំណាយថ្លៃសេវានាពេលបច្ចុប្បន្ន ចំណាយការប្រាក់អត្ថប្រយោជន៍បានបង់ ការខាតបង់ពីការវាស់វែងឡើងវិញ និងការផ្ទៀងផ្ទាត់សមតុល្យដើមគ្រា និងសមតុល្យចុងគ្រា និងផ្ទៀងផ្ទាត់ និងគណនាចំនួនទឹកប្រាក់ ក្នុងរបាយការណ៍វាយតម្លៃអត្ថប្រយោជន៍ ជាមួយនឹងការកត់ត្រាគណនេយ្យ និង ប្រភពទិន្នន័យពីនាយកដ្ឋានធនធានមនុស្ស។ |

| **បញ្ហាសវនកម្មសំខាន់ៗ** | **នីតិវិធីដែលយើងខ្ញុំដោះស្រាយបញ្ហាសវនកម្មសំខាន់ៗ** |
|---|---|
| យើងខ្ញុំផ្តោតលើផ្នែកទាំងនេះ ដោយសារមានការពាក់ព័ន្ធយ៉ាងសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ដើម្បីធ្វើការវាយតម្លៃសមស្រប និងត្រឹមត្រូវ។ | ជាលទ្ធផលនៃនីតិវិធីទាំងនេះ យើងខ្ញុំកំណត់ថាការសន្មតសំខាន់ៗសម្រាប់ការប៉ាន់ស្មាននេះគឺមានមូលដ្ឋានសមហេតុផល។ |

**ព័ត៌មានផ្សេងៗ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល (ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ) ដែលយើងខ្ញុំបានទទួល មុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ និងព័ត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ដែលយើងខ្ញុំរំពឹងថានឹងទទួលបានបន្ទាប់ពីកាលបរិច្ឆេទនេះ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះ មានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

នៅពេលដែលយើងអានព័ត៌មានដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តនៃព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ពីបញ្ហានេះ ជូនអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ កសស ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ កសស ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ កសស។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនករដែលមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថា សវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដាសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

pwc

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យស្របតាមវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ដោយសារការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនាការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ កសស ទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យ ទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលអាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើលទ្ធភាពរបស់ កសស ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាវាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនករ ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាន នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនករនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យ កសស ឈប់បន្តនិរន្តរភាពអាជីវកម្ម។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និង កំណត់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារតាមផែនការ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏បានផ្តល់ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវសេចក្តីអះអាងថា យើងខ្ញុំបានអនុវត្តតាមតម្រូវការក្រមសីលធម៌ពាក់ព័ន្ធនឹងឯករាជ្យ ព្រមទាំងបានជូនដំណឹងពួកគេអំពីទំនាក់ទំនងទាំងអស់ និងបញ្ហាផ្សេងៗ ដែលយើងខ្ញុំយល់ឃើញថាមានផលប៉ះពាល់ចំពោះឯករាជ្យរបស់យើងខ្ញុំ រួមជាមួយនឹងវិធានការនានាដែលបានអនុវត្ត ដើម្បីលុបបំបាត់នូវការគំរាមកំហែង ឬ វិធីសាស្ត្រការពារដែលបានបំពេញ។

បន្ទាប់ពីបញ្ហានានាដែលយើងខ្ញុំបានផ្តល់ដំណឹងជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ច យើងខ្ញុំកំណត់ពីបញ្ហាទាំងឡាយណា ដែលមានផលប៉ះពាល់ខ្លាំងបំផុតចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងដែលជាបញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែបញ្ហាទាំងនេះត្រូវបានហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិនានា ក្នុងការលាតត្រដាងជាសាធារណៈ ឬនៅក្នុងករណីដ៏កម្របំផុតដែលយើងខ្ញុំកំណត់ថា បញ្ហានោះមិនគួរត្រូវបានបង្ហាញនៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារការបង្ហាញពីបញ្ហានេះនឹងបណ្តាលឱ្យមានផលវិបាកអវិជ្ជមាន ដែលត្រូវបានរំពឹងថានឹងបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

ជ. ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)

ឡាង ហ៊ី

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥ ពាន់រៀល | ២០២៤ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៥ | ១.៥៦៥.៤៥៦.៥៥៨ | ១.២១៤.៤២៣.៧០៥ |
| ទ្រព្យសម្បត្តិវិនិយោគ | ៦ | ២៧៣.២១៥.៦២០ | ២៤៧.០៩៨.១៩០ |
| ទ្រព្យសកម្មអរូបី | ៧ | ៩០៧.៩៤៥ | ១.៨០៦.៦៩៤ |
| ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | ៩ | ១០.៤១៨.២០០ | - |
| ប្រាក់បញ្ញើនៅធនាគារ | ១១ | - | ៦.៥០២.៩៣៣ |
| | | ១.៨៤៩.៩៩៨.៣២៣ | ១.៤៦៩.៨៣១.៥២២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៨ | ៤១.៨៩៨.១៣១ | ៤១.៣៤៦.៥២៤ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១០ | ២០២.៩៥៤.១១០ | ១១៧.៦៤៩.៤៦២ |
| ប្រាក់បញ្ញើនៅធនាគារ | ១១ | ៩២.២៧៥.៣៣៤ | ១១៧.៣១១.២៤២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១២ | ១០២.១៥២.៤៨៣ | ២៧.១៨៥.៨៦៧ |
| | | ៤៣៩.២៨០.០៥៨ | ៣០៣.៤៩៣.០៩៥ |
| **ទ្រព្យសកម្មសរុប** | | ២.២៨៩.២៧៨.៣៨១ | ១.៧៧៣.៣២៤.៦១៧ |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១៣ | ៥១៨.០១៨.០៦៣ | ៥១៨.០១៨.០៦៣ |
| ទុនបម្រុងផ្សេងៗ | ១៤ | ៧៤.៣៧៦.០០៦ | ៦១.៧០២.៦៤៤ |
| ចំណេញរក្សាទុក | | ៦៣២.៦០៧.២៣៦ | ៤៩០.១៨១.០៦៩ |
| **មូលធនសរុប** | | ១.២២៥.០០១.៣០៥ | ១.០៦៩.៩០១.៧៧៦ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៥ | ៦៣៦.១២៩.៩១៤ | ៣៧៧.៧២៧.១៧០ |
| ប្រាក់តម្កល់ដែលអាចបង្វិលសងពីភតិក: | | ១.០០៣.២៥០ | ១.០០៦.២៥០ |
| ប្រាក់រក្សាទុកត្រូវបង់ | | ២៧.៩៥០.៣៣៩ | ២.៧៥៣.៨៦៩ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៦ | ៩២.៧៩២.៦៧០ | ៩១.១៧៦.០៨៥ |
| កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ៩៩៥.៣៤០ | ១.២៣៦.៣០០ |
| ចំណូលពន្យារ | ១៧ | ១៤.៨៧២.៥៧៥ | ១៥.៩០៥.៥១៩ |
| សម្បទានពីរាជរដ្ឋាភិបាល | ១៨ | ៤០.៦៨១.៨៤៤ | ៤៣.៨៩៦.៧៧៤ |
| បំណុលពន្ធពន្យារ | ២៦(ខ) | ៤៦.១៦៣.៣៨៥ | ៤២.៤១២.៩០២ |
| | | ៨៦០.៥៨៩.៣១៧ | ៥៧៦.១១៤.៨៦៩ |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៩ | ១២៧.៤៨០.៨១៦ | ៧២.៥៥៧.៣៣១ |
| ប្រាក់កម្ចី | ១៥ | ២៧.២៥៨.៩៨៥ | ២៦.៥២៧.៧០៦ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៦ | ៦.០៦១.១៥៦ | ៥.១៦២.៤៤៣ |
| កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ១១៨.០៥៥ | ៥៩.១៧៥ |
| ចំណូលពន្យារ | ១៧ | ១.៦៨៧.៥១២ | ១.៣៣៦.៦៦១ |
| សម្បទានពីរាជរដ្ឋាភិបាល | ១៨ | ៣.២១៤.៩៣០ | ៣.២១៤.៩៣០ |
| បំណុលពន្ធលើប្រាក់ចំណូល | ២៦(គ) | ៣៧.៨៦៦.៣០៥ | ១៨.៤៤៩.៧២៦ |
| | | ២០៣.៦៨៧.៧៥៩ | ១២៧.៣០៧.៩៧២ |
| **បំណុលសរុប** | | ១.០៦៤.២៧៧.០៧៦ | ៧០៣.៤២២.៨៤១ |
| **មូលធន និងបំណុលសរុប** | | ២.២៨៩.២៧៨.៣៨១ | ១.៧៧៣.៣២៤.៦១៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥ ពាន់រៀល | ២០២៤ ពាន់រៀល |
|---|---|---|---|
| **ចំណូល** | | | |
| ចំណូលពីកិច្ចសន្យាជាមួយអតិថិជន | ២០ | ៦១៣.១៩៥.៣០៣ | ៤៥១.៥៦០.៩៤០ |
| ចំណូលពីការជួល | ៦ | ៥.០៩៨.៣១៣ | ៤.៤៣៦.២៦៣ |
| ចំណូលពីសម្បទាន | ១៨ | ៣.២១៤.៩៣០ | ៣.២១៤.៩៣០ |
| | | ៦២១.៥៥៨.៥៤៦ | ៤៥៩.២១២.១៣៣ |
| **ចំណាយ** | | | |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២១ | (១៧៤.៤៥៦.៩១៩) | (១៣៧.៤២៦.៥០៤) |
| ចំណាយសម្ភារផ្គត់ផ្គង់ | ២២ | (១២៤.២៩៨.៤៣០) | (១០៤.១៥៩.០៦៩) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ ទ្រព្យសម្បត្តិវិនិយោគ និងទ្រព្យសកម្មអរូបី | ២៣ | (៦៧.១២៦.៥៦១) | (៥៤.៣២២.៤៧១) |
| ចំណាយជួសជុល និងថែទាំ | | (១.៨៩៥.០០២) | (២.១១៦.៧៩៤) |
| ចំណាយផ្សេងៗ | ២៤ | (៤៤.០៦៤.៦១០) | (៣៦.០៦០.៤៨៤) |
| ចំណេញផ្សេងៗ – សុទ្ធ | | ៨.៥៦៣.៥៨៩ | ៥៩៥.៣២៣ |
| | | (៤០៧.៦៨១.៩៣៣) | (៣៣៧.៨៩០.៧៩៩) |
| ចំណេញប្រតិបត្តិការ | | ២១៣.៨៧៦.៦១៣ | ១២១.៣២១.៣៣៤ |
| ចំណូលហិរញ្ញវត្ថុ | | ១១.៩១៦.៣២៤ | ៥១.៧៨៥.៨៧៥ |
| ចំណាយហិរញ្ញវត្ថុ | | (៨.០៣៩.៧១៥) | (៨.៥១៩.១៥៧) |
| ចំណូលហិរញ្ញវត្ថុ – សុទ្ធ | ២៥ | ៣.៨៧៦.៦០៩ | ៣៣.២៦៦.៧១៨ |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | | ២១៧.៦៥៣.២២២ | ១៥៤.៥៨៨.០៥២ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៦ | (៤៥.៦៧៤.២៧៥) | (២៧.៨៥៤.៤២៣) |
| **ចំណេញក្នុងឆ្នាំ** | | ១៧១.៩៧៨.៩៤៧ | ១២៦.៧៣៣.៦២៩ |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | |
| ខាតពីការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ - ក្រោយកាត់ពន្ធ | | - | (១៣.០៦៩.៤៦១) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | ១៧១.៩៧៨.៩៤៧ | ១១៣.៦៦៤.១៦៨ |
| **ចំណេញត្រូវបែងចែកឱ្យភាគទុនិក** | | ១៧១.៩៧៨.៩៤៧ | ១២៦.៧៣៣.៦២៩ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ-ក្រោយកាត់ពន្ធ ដែលត្រូវបែងចែកឱ្យភាគទុនិក** | | ១៧១.៩៧៨.៩៤៧ | ១១៣.៦៦៤.១៦៨ |

ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគទុនិករបស់ កសស សម្រាប់ដំណាច់ឆ្នាំមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនគោល/ថយចុះ (រៀល) | ២៧ | ២.០០៥,០៧ | ១.៤៧៧,៥៦ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | | ដែលជារបស់ភាគទុនិក | | | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដើមទុន និង បុព្វលាភភាគហ៊ុន ពាន់រៀល | ទុនបម្រុងផ្សេងៗ ពាន់រៀល | ចំណេញរក្សាទុក ពាន់រៀល | សរុប ពាន់រៀល |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤** | | ៥១៨.០១៨.០៦៣ | ៤៩.៥០៦.០៩៤ | ៤០៤.៥២០.៧១៩ | ៩៧២.០៤៤.៨៧៦ |
| ចំណេញក្នុងឆ្នាំ | | - | - | ១២៦.៧៣៣.៦២៩ | ១២៦.៧៣៣.៦២៩ |
| ខាតពីការវាស់វែងឡើងវិញនៃកាតព្វកិច្ច អត្ថប្រយោជន៍សោធននិវត្តន៍ | | - | - | (១៣.០៦៩.៤៦១) | (១៣.០៦៩.៤៦១) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | - | - | ១១៣.៦៦៤.១៦៨ | ១១៣.៦៦៤.១៦៨ |
| ផ្ទេរទៅទុនបម្រុង | ១៤ | - | ១២.១៩៦.៥៥០ | (១២.១៩៦.៥៥០) | - |
| ការបែងចែកភាគលាភ | ៣០.២ | - | - | (១៥.៨០៧.២៦៨) | (១៥.៨០៧.២៦៨) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | ៥១៨.០១៨.០៦៣ | ៦១.៧០២.៦៤៤ | ៤៩០.១៨១.០៦៩ | ១.០៦៩.៩០១.៧៧៦ |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥** | | ៥១៨.០១៨.០៦៣ | ៦១.៧០២.៦៤៤ | ៤៩០.១៨១.០៦៩ | ១.០៦៩.៩០១.៧៧៦ |
| ចំណេញក្នុងឆ្នាំ | | - | - | ១៧១.៩៧៨.៩៤៧ | ១៧១.៩៧៨.៩៤៧ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | - | - | ១៧១.៩៧៨.៩៤៧ | ១៧១.៩៧៨.៩៤៧ |
| ផ្ទេរទៅទុនបម្រុង | ១៤ | - | ១២.៦៧៣.៣៦២ | (១២.៦៧៣.៣៦២) | - |
| ការបែងចែកភាគលាភ | ៣០.២ | - | - | (១៦.៨៧៩.៤១៨) | (១៦.៨៧៩.៤១៨) |
| | | - | ១២.៦៧៣.៣៦២ | (២៩.៥៥២.៧៨០) | (១៦.៨៧៩.៤១៨) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | ៥១៨.០១៨.០៦៣ | ៧៤.៣៧៦.០០៦ | ៦៣២.៦០៧.២៣៦ | ១.២២៥.០០១.៣០៥ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | | ២១៧.៦៥៣.២២២ | ១៥៤.៥៨៨.០៥២ |
| *និយ័តកម្ម៖* | | | |
| ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ២៥ | (៣.៨៧៦.៦០៩) | (៣៣.២៦៦.៧១៨) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ ទ្រព្យសម្បត្តិវិនិយោគ និងទ្រព្យសកម្មអរូបី | ២៣ | ៦៧.១២៦.៥៦១ | ៥៤.៣២២.៨៧១ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិវិនិយោគ | | (១២.២៥១.៧២៧) | - |
| កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ៦.២២២.២១៦ | ៥.៣៥៧.៤៥០ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៦ | ៨.១៣៣.៩៦៩ | ៦.៦៨៤.១៨៦ |
| ចំណូលសម្បទានពីរាជរដ្ឋាភិបាល | ១៨ | (៣.២១៤.៩៣០) | (៣.២១៤.៩៣០) |
| កត់ត្រាត្រឡប់មកវិញនូវសំវិធានធនសម្រាប់សន្និធិដំណើរការយឺត | | - | (៩.៧៦៧) |
| ប្រាក់រក្សាទុកត្រូវបង់ | | ២៥.១៩៦.៤៧០ | - |
| សំវិធានធនសម្រាប់ខាតឥណទានរំពឹងទុកលើប្រាក់បញ្ញើនៅធនាគារ | | ១.៥៩៣.០៥៩ | ១៥៨.០១៨ |
| កត់ត្រាត្រឡប់មកវិញនូវការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម | | (៧០.៦២៨) | (៤១.៧៤១) |
| ការជម្រះចេញពីបញ្ជីនូវទ្រព្យសម្បត្តិ និងបរិក្ខារ | | ៧២០.៨៤៣ | ៣០៥.៨២៤ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | (៥៥១.៦០៧) | (៦.៨៧២.៤២៦) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | | (១៨.០៣៥.២៦៥) | (៧១.៥៦០.៣០២) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | (២៥.៧១២.២៧៥) | ១៩.៤៨៤.៩៣៤ |
| ចំណូលពន្យារ | | (៦៨២.០៩៣) | ២.៧២៤.៩០៦ |
| | | ២៦២.២៥១.២៤៦ | ១២៨.៦៦០.៣៥៧ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍បានបង់ | | (៥.៦១៨.៦៧១) | (៤.៥៧៣.៤០៩) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៦.គ | (២២.៥០៧.២១៣) | (២៥.៤៧៥.២៩៣) |
| **លំហូរសាច់ប្រាក់ចូលសុទ្ធពីសកម្មភាពប្រតិបត្តិការ** | | ២៣៤.១២៥.៣៦២ | ៩៨.៦១១.៦៥៥ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៥ | (៣១៤.១៤៣.៩៩១) | (១៥៥.៧៧៧.៦៨៣) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៦ | (៥២.១៨២.៧៧៣) | (៥.៧៧៦.៨៦៧) |
| ការទិញទ្រព្យសកម្មអរូបី | ៧ | (៣១២.៩២០) | (១៥៤.៣៥៦) |
| ទឹកប្រាក់បានពីការលក់ទ្រព្យសម្បត្តិវិនិយោគ | | ១២.៨១៥.១៧៩ | - |
| ការដកប្រាក់បញ្ញើពីធនាគារ | | ១១៣.៥៧៦.៧៣៤ | ៤៨.៧៤៨.០៩៣ |
| ការដាក់ប្រាក់បញ្ញើនៅធនាគារ | | (៨៤.៦៥០.៧៤៩) | (១៦.៥៩១.៥៤១) |
| ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | | (១០.៤១៨.២០០) | - |
| បុរេប្រទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | | (៦៩.៧៧២.៧៣៦) | - |
| ការប្រាក់បានទទួល | | ៧.៧៩២.៧៧៥ | ៨.៦០៨.៨៤៤ |
| **លំហូរសាច់ប្រាក់ចេញសុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | (៣៩៧.២៩៦.៦៨១) | (១២០.៩៤៣.៥១០) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | ៣០.២ | (១៦.៨៧៩.៤១៨) | (១៥.៨០៧.២៦៨) |
| ការទូទាត់សងប្រាក់កម្ចី | ២៨ | (២៥.០៧២.៤១៣) | (២៥.៨៦០.៧០២) |
| ការទូទាត់សងឥណទានវិបារូបន៍ | | (៥២.០៨១.០០០) | (៧៨.៨៧៥.៧៥០) |
| ការប្រាក់លើប្រាក់កម្ចីបានបង់ | ២៨ | (៩.៤២៥.០២៧) | (៨.៩១៦.៤៣០) |
| ការប្រាក់លើឥណទានវិបារូបន៍បានបង់ | | (៣៧៣.៣០៤) | (៦៧៩.៦៥៤) |
| សាច់ប្រាក់ពីប្រាក់កម្ចី | ២៨ | ២៨៩.៩៣៨.០៩៧ | ១១១.៤៣០.៣៦៥ |
| សាច់ប្រាក់ពីឥណទានវិបារូបន៍ | | ៥២.០៣១.០០០ | ៤៨.៨៨៥.៣៤៧ |
| **លំហូរសាច់ប្រាក់ចូលសុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | ២៣៨.១៣៧.៩៣៥ | ៣០.១៧៥.៩០៨ |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៧៤.៩៦៦.៦១៦ | ៧.៨៤៤.០៥៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ២៧.១៨៥.៨៦៧ | ១៩.៣៤១.៨១៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១២ | ១០២.១៥២.៤៨៣ | ២៧.១៨៥.៨៦៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា កសស) គឺជាសហគ្រាសសាធារណៈស្វយ័ត ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានទីស្នាក់ការនៅខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

កសស គឺជានីតិអង្គភាពដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពឱ្យ ក្រុមហ៊ុនជាស្ថាប័នស្វយ័តសាធារណៈ។

កសស បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ ភាគហ៊ុនប្រភេទ 'គ' របស់ កសស ត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា ផ.ម.ក) នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។

បច្ចុប្បន្ននេះ កសស គឺជាកំពង់ផែសមុទ្រអន្តរជាតិទឹកជ្រៅ និងជាកំពង់ផែពាណិជ្ជកម្មស្នូល នៅព្រះរាជាណាចក្រកម្ពុជា។ ស្របតាមអនុក្រឹតសម្រាប់ការបង្កើតស្ថាប័ន កសស មានបេសកកម្មក្នុងការផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រ ដូចខាងក្រោម៖

- កណ្តាធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភ័ស្តុភារដល់នាវា
- លើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសស ដែលមានស្រាប់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង និង
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន

កសស ក៏មានប្រត្តិបត្តិការនៅតំបន់សេដ្ឋកិច្ចពិសេស ជាភតិបតីក្រោមប្រតិបត្តិការជាភតិសន្យា។

ក្នុងឋានៈជាស្ថាប័នស្វយ័តសាធារណៈ កសស ទទួលអំណាច និងកាតព្វកិច្ចទាំងឡាយពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន។

ទីស្នាក់ការចុះបញ្ជីរបស់ កសស មានទីតាំងស្ថិតនៅតីវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយអនុលោមតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

គោលការណ៍គណនេយ្យសំខាន់ៗ ដែលត្រូវបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងមានសង្គតិភាព លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ ហើយក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យរបស់ កសស ផងដែរ។ ការប្រែប្រួលនៃការសន្មត អាចបណ្តាលឱ្យមានផលប៉ះពាល់ជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំដែលមានការប្រែប្រួលនៃការសន្មតនោះ។ គណៈគ្រប់គ្រងជឿជាក់ថាការសន្មតជាមូលដ្ឋាន គឺមានភាពត្រឹមត្រូវ។

ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញកម្រិតខ្ពស់ ឬផ្នែកដែលមានការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

របាយការណ៍ហិរញ្ញវត្ថុជាភាសាអង់គ្លេសត្រូវបានរៀបចំឡើងចេញពី របាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ។ ក្នុងករណីមិនមានសង្គតិភាព ឬមានភាពខុសគ្នាក្នុងការបកស្រាយរវាងភាសាទាំងពីរ នោះត្រូវយករបាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរជាគោល។

ចំនួនទឹកប្រាក់ត្រូវបានបង្គត់ខ្ទង់ពាន់រៀល លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។

### ២.២ ស្តង់ដាគណនេយ្យថ្មី វិសោធនកម្មស្តង់ដាគណនេយ្យ និងបំណកស្រាយ

### (ក) វិសោធនកម្មស្តង់ដាគណនេយ្យ ដែល កសស បានអនុវត្ត

កសស បានអនុវត្តវិសោធនកម្មស្តង់ដាគណនេយ្យដូចខាងក្រោមជាលើកដំបូង សម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំរបស់ កសស ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥។

- កង្វះលទ្ធភាពក្នុងការផ្តោះប្តូរ (Lack of exchangeability) – វិសោធនកម្ម CIAS 21

វិសោធនកម្មខាងលើមិនមានផលប៉ះពាល់ណាមួយ លើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗទេ និងមិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តចំពោះការិយបរិច្ឆេទបច្ចុប្បន្ន ឬ អនាគតទេ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)
## ២.២ ស្តង់ដាគណនេយ្យថ្មី វិសោធនកម្មស្តង់ដាគណនេយ្យ និងបំណកស្រាយ (ត)
## (ខ) ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មស្តង់ដាគណនេយ្យ ដែល កសស មិនទាន់អនុវត្ត

ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មស្តង់ដាគណនេយ្យ មួយចំនួនដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចូលជាធរមានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ហើយ កសស មិនទាន់បានអនុវត្តមុនកាលកំណត់ទេ។

- វិសោធនកម្មចំពោះការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ – វិសោធនកម្ម CIFRS 9 និង CIFRS 7
- កិច្ចសន្យាដែលយោងទៅលើអគ្គិសនីដែលអាស្រ័យលើធម្មជាតិ – វិសោធនកម្ម CIFRS 9 និង CIFRS 7
- CIFRS 19 ការលាតត្រដាងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនមានការទទួលខុសត្រូវជាសាធារណៈ

ស្តង់ដាគណនេយ្យនិងវិសោធនកម្មស្តង់ដារគណនេយ្យខាងលើនេះ មិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តដល់ កសស សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទអនាគត និងប្រតិបត្តិការនាពេលឆាប់ៗខាងមុខនេះទេ លើកលែងតែះ

- ការបង្ហាញ និងការលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ – CIFRS 18

CIFRS 18 នឹងជំនួស CIAS 1 ស្តីពី ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលណែនាំនូវតម្រូវការថ្មីដែលនឹងជួយឱ្យសម្រេចបាននូវការប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាពស្រដៀងគ្នា និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ និងកាន់តែមានតម្លាភាពបន្ថែមទៀតដល់អ្នកប្រើប្រាស់។ ទោះបីជា CIFRS 18 មិនប៉ះពាល់ដល់ការទទួលស្គាល់ ឬការវាស់វែងខ្ទង់ផ្សេងៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏ដោយ តែការបង្ហាញ និងការលាតត្រដាង ត្រូវបានរំពឹងថានឹងមានការប៉ះពាល់ខ្លះៗជាពិសេសខ្ទង់ដែលពាក់ព័ន្ធនឹងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ និងការផ្តល់នូវវិធានការអនុវត្តដែលកំណត់ដោយគណៈគ្រប់គ្រង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងវាយតម្លៃផលប៉ះពាល់លម្អិត នៃការអនុវត្តស្តង់ដាថ្មីចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ កសស។

កសស នឹងអនុវត្តស្តង់ដាថ្មីចាប់ពីកាលបរិច្ឆេទចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៧។ ការអនុវត្តត្រឡប់ថយក្រោយត្រូវបានតម្រូវ ដូច្នេះព័ត៌មានប្រៀបធៀបសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៦ នឹងត្រូវរាយការណ៍ឡើងវិញ អនុលោមតាម CIFRS 18 ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.៣ ការប្តូររូបិយប័ណ្ណ

រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណក្នុងបរិយាកាសសេដ្ឋកិច្ចចម្បងដែល កសស ធ្វើប្រតិបត្តិការ (ហៅកាត់ថា រូបិយប័ណ្ណគោល)។ កសស រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញ។

ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រានាដំណាច់ឆ្នាំ ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត។ ចំណេញនិងខាតពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹង ឥណទាន និងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬខាត នៅផ្នែក 'ចំណូលហិរញ្ញវត្ថុ និងចំណាយហិរញ្ញវត្ថុ'។

### ២.៤ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសម្បត្តិទាំងអស់នោះ។

ចំណាយបន្តបន្ទាប់មកទៀតត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកតាមភាពសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូលមកក្នុង កសស ហើយចំណាយទាំងនោះអាចវាស់វែងបាន។ តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសឡើងវិញ ត្រូវបានឈប់កត់ត្រា។ ចំណាយទៅលើរាល់ការជួសជុល និងថែទាំផ្សេងៗ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ។ សំណង់កំពុងសាងសង់មិនត្រូវបានដករំលស់ទេ រហូតដល់ពេលដែលទ្រព្យសម្បត្តិ និងបរិក្ខារនោះ មានភាពរួចរាល់សម្រាប់ប្រើប្រាស់។ រំលស់លើទ្រព្យសកម្មផ្សេងៗ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឱ្យនៅត្រឹមតម្លៃសំណល់របស់វា លើអាយុកាលប្រើប្រាស់ប៉ាន់ស្មានដូចខាងក្រោម៖

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.៤ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | **ចំនួនឆ្នាំ** |
|---|---|
| ការកែលម្អដីធ្លី | ៧ឆ្នាំ ទៅ ៥០ឆ្នាំ |
| អគារ | ៧ឆ្នាំ ទៅ ៥០ឆ្នាំ |
| បរិក្ខារបច្ចេកទេស | ៥ឆ្នាំ ទៅ ៣០ឆ្នាំ |
| គ្រឿងសង្ហារិម និងបរិក្ខារភ្ជាប់ | ៣ឆ្នាំ ទៅ ១០ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៣ឆ្នាំ ទៅ ៥ឆ្នាំ |
| យានយន្ត | ៥ឆ្នាំ ទៅ ១៥ឆ្នាំ |
| បរិក្ខារកំពង់ផែសមុទ្រ | ២០ឆ្នាំ ទៅ ៣០ឆ្នាំ |
| ប៉ាឡែត (Palettes) | ១០ឆ្នាំ |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនិងកែតម្រូវតាមភាពសមស្រប នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

ចំណេញនិងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

### ២.៥ ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

ក្រុមហ៊ុនញាតិសម្ព័ន្ធគឺជាអង្គភាពទាំងឡាយណា ដែលស្ថិតនៅក្រោមឥទ្ធិពលជាសារវន្តរបស់ កសស ប៉ុន្តែមិនមានសិទ្ធិគ្រប់គ្រង ជាទូទៅមានភាគហ៊ុនចន្លោះពី ២០% ទៅ ៥០% នៃសិទ្ធិបោះឆ្នោត។ ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ត្រូវបានកត់ត្រាដោយប្រើវិធីសាស្ត្រគណនេយ្យមូលធន បន្ទាប់ពីត្រូវបានទទួលស្គាល់លើកដំបូងតាមថ្លៃដើម។

យោងតាមវិធីសាស្ត្រគណនេយ្យមូលធន ការវិនិយោគត្រូវបានទទួលស្គាល់លើកដំបូងតាមថ្លៃដើម និងបន្ទាប់មកត្រូវធ្វើនិយ័តកម្មដើម្បីទទួលស្គាល់អត្ថប្រយោជន៍ចំណេញឬខាតរបស់ កសស បន្ទាប់ពីការទិញ ក្នុងនាមជាអ្នកវិនិយោគ និងបម្រែបម្រួលអត្ថប្រយោជន៍របស់ កសស ក្នុងលទ្ធផលលម្អិតផ្សេងៗរបស់អ្នកវិនិយោគ ទៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ ភាគលាភបានទទួល ឬនឹងត្រូវទទួលពីក្រុមហ៊ុនញាតិសម្ព័ន្ធ ត្រូវបានទទួលស្គាល់ដោយកាត់បន្ថយតម្លៃយោងនៃការវិនិយោគ។

នៅពេលដែលចំណែកខាតរបស់ កសស ក្នុងការវិនិយោគដែលផ្អែកតាមគណនេយ្យមូលធន ស្មើគ្នា ឬលើសអត្ថប្រយោជន៍របស់ខ្លួនដែលនៅក្នុងក្រុមហ៊ុននោះ រួមទាំង ទឹកប្រាក់ត្រូវទទួលរយៈពេលវែងដែលមិនមានការធានា កសស មិនទទួលស្គាល់ការខាតបង់បន្ថែមទៀតទេ លុះត្រាតែ កសស មានកាតព្វកិច្ច ឬត្រូវទូទាត់ប្រាក់ជំនួសអង្គភាពផ្សេងៗ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.៥ ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (ត)

ចំណេញពីប្រតិបត្តិការមិនទាន់ទទួលស្គាល់ រវាង កសស និងក្រុមហ៊ុនញាតិសម្ព័ន្ធ ត្រូវបានលុបចោល ឱ្យនៅស្មើនឹងអត្ថប្រយោជន៍របស់ កសស ក្នុងអង្គភាពទាំងនេះ។ ខាតមិនទាន់ទទួលស្គាល់ក៏ត្រូវបានលុបចោលដែរ លុះត្រាតែប្រតិបត្តិការនោះផ្តល់នូវភ័ស្តុតាងពីការថយចុះតម្លៃនៃទ្រព្យសកម្មដែលបានផ្ទេរ។ គោលការណ៍គណនេយ្យនៃអ្នកវិនិយោគតាមវិធីសាស្រ្តគណនេយ្យមូលធន ត្រូវបានកែប្រែទៅតាមភាពចាំបាច់ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងគោលការណ៍គណនេយ្យដែល កសស បានអនុវត្ត។

ប្រសិនបើមានសញ្ញាណបង្ហាញថា ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ អាចនឹងមានការថយចុះតម្លៃ កសស នឹងត្រូវពិនិត្យលើតម្លៃយោងទាំងមូលនៃការវិនិយោគដើម្បីរកការថយចុះតម្លៃ។

## ២.៦ ទ្រព្យសម្បត្តិវិនិយោគ

ទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់សម្រាប់ការជួលរយៈពេលវែង ឬសម្រាប់បង្កើនដើមទុន ឬផ្សេងៗគ្នាទាំងពីរ ហើយមិនត្រូវបានប្រតិបត្តិដោយ កសស ទេ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិវិនិយោគ។ ទ្រព្យសម្បត្តិវិនិយោគក៏រួមបញ្ចូលនូវទ្រព្យសម្បត្តិដែលកំពុងសាងសង់ សម្រាប់អភិវឌ្ឍឱ្យក្លាយជាទ្រព្យសម្បត្តិវិនិយោគនាពេលអនាគត។ ទ្រព្យសម្បត្តិវិនិយោគត្រូវបានកត់ត្រាជាបឋម តាមថ្លៃដើម ដករំលស់បង្គរនិងការថយចុះតម្លៃ ប្រសិនបើមាន។ កសស ប្រើប្រាស់គំរូថ្លៃដើម និងគណនីសម្រាប់ទ្រព្យសម្បត្តិវិនិយោគ ដោយអនុលោមតាម CIAS 16 'ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ'។

ទ្រព្យសម្បត្តិវិនិយោគត្រូវបានផ្ទេរទៅជាសន្និធិ តែនៅពេលដែលមានការផ្លាស់ប្តូរក្នុងការប្រើប្រាស់ ដោយ មានភ័ស្តុតាងបង្ហាញពីការចាប់ផ្តើមការអភិវឌ្ឍ ក្នុងទស្សនវិស័យសម្រាប់ការលក់។ នៅពេលដែល កសស សម្រេចលក់ទ្រព្យសម្បត្តិវិនិយោគណាមួយចេញដែលមិនមានការអភិវឌ្ឍ កសស បន្តចាត់ទុកទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិវិនិយោគរហូតដល់ពេលឈប់កត់ត្រា និងលុបវាចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយមិនចាត់ទុកវាជាសន្និធិទេ។ ប្រសិនបើទ្រព្យសម្បត្តិវិនិយោគត្រូវបានគេអភិវឌ្ឍឡើងវិញ ដើម្បីប្រើប្រាស់បន្តក្នុងទ្រង់ទ្រាយជាទ្រព្យសម្បត្តិវិនិយោគ នោះទ្រព្យសម្បត្តិនោះនៅរក្សាទុកជាទ្រព្យសម្បត្តិវិនិយោគដដែល ហើយមិនត្រូវបានចាត់ថ្នាក់ឡើងវិញជាទ្រព្យសម្បត្តិដែលកាន់កាន់ដោយម្ចាស់ ក្នុងអំឡុងពេលការអភិវឌ្ឍឡើងវិញទេ។

នៅពេលលក់ទ្រព្យសម្បត្តិវិនិយោគណាមួយ ឬនៅពេលដែលទ្រព្យសម្បត្តិវិនិយោគណាមួយត្រូវបានដកចេញពីការប្រើប្រាស់ជាអចិន្ត្រៃយ៍ និងមិនមានការរំពឹងថានឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការលក់ទៀតទេ នោះវានឹងត្រូវបានគេឈប់កត់ត្រា (លុបចេញពីតារាងតុល្យការ)។ ចំនួនលម្អៀងរវាងសាច់ប្រាក់សុទ្ធដែលទទួលបានពីការលក់ និងតម្លៃយោង ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត ក្នុងការិយបរិច្ឆេទនៃការឈប់ប្រើ ឬលក់ចេញ។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ។ ការកែលម្អអគារ និង ដី ត្រូវបានធ្វើរំលស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាក្នុងរយៈពេលពី១០ឆ្នាំទៅ៥០ឆ្នាំ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីគណនេយ្យ និងប្រព័ន្ធប្រតិបត្តិការកំពង់ផែ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ កសស បានធ្វើរំលស់ទ្រព្យសកម្មអរូបីដែលនៅមានអាយុកាលប្រើប្រាស់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមរយៈពេលដូចខាងក្រោម៖

| | ចំនួនឆ្នាំ |
|---|---|
| កម្មវិធីគណនេយ្យ | ១០ឆ្នាំ |
| ប្រព័ន្ធប្រតិបត្តិការកំពង់ផែ | ១០ឆ្នាំ |

### ២.៨ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ កសស ត្រូវបានត្រួតពិនិត្យនាដំណាច់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់រកសញ្ញាណនៃការថយចុះតម្លៃ។ ការខាតពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមតម្លៃយោងរបស់ទ្រព្យសកម្ម ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃនៅអាចប្រើប្រាស់បានរបស់វា។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃនៃទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត សម្រាប់ទ្រព្យសកម្មដែលមានលក្ខណៈជាលំហូរសាច់ប្រាក់ដាច់ដោយឡែកធំៗ (ឯកតាបង្កើតសាច់ប្រាក់)។ ខាតពីការថយចុះតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។

ការកត់ត្រាត្រឡប់មកវិញនៃការខាតពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ទៅតាមចំនួនតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់ កាត់កងជាមួយនឹងរំលស់ ប្រសិនបើមិនបានទទួលស្គាល់ការខាតដែលបណ្តាលមកពីការថយចុះតម្លៃទ្រព្យសកម្មក្នុងឆ្នាំមុនៗ។ បន្ទាប់ពីការកត់ត្រាត្រឡប់មកវិញរួចហើយ រំលស់ត្រូវបានធ្វើនិយ័តកម្មសម្រាប់ការិយបរិច្ឆេទនាពេលអនាគត ដើម្បីបែងចែកតម្លៃយោងដែលបានកែប្រែរបស់ទ្រព្យសកម្ម ដកតម្លៃសំណល់ តាមមូលដ្ឋានជាប្រព័ន្ធ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់នៅសល់។

### ២.៩ សន្និធិ

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងគេ (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) ធៀបនឹងតម្លៃសុទ្ធដែលអាចលក់បាន។ តម្លៃសុទ្ធដែលអាចលក់បាន គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកចំណាយក្នុងការលក់ផ្សេងៗ។

សន្និធិរួមមាន សម្ភារប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិផ្សេងៗដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែង ក្នុងការយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណងដែលបានគ្រោងទុក ដកសំវិធានធនសម្រាប់សន្និធិខូចខាត សន្និធិប្រើប្រាស់លែងបាន និងសន្និធិដំណើរការយឺត ដោយប្រើមូលដ្ឋានចូលមុន-ចេញមុន។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១០ ឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុគឺជាកិច្ចសន្យាណាមួយ ដែលធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្មហិរញ្ញវត្ថុរបស់អង្គភាពមួយ និង បំណុលហិរញ្ញវត្ថុ ឬឧបករណ៍មូលធនរបស់អង្គភាពមួយទៀត ។

### ២.១១ ទ្រព្យសកម្មហិរញ្ញវត្ថុ

២.១១.១ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

កសស ធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ដោយបានវាស់វែងតាមថ្លៃដើមដករំលស់។ ការធ្វើចំណាត់ថ្នាក់គឺអាស្រ័យទៅតាមគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងរយៈពេលកិច្ចសន្យានៃលំហូរសាច់ប្រាក់។

កសស បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនផ្លាស់ប្តូរតែប៉ុណ្ណោះ។

គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ប្រាក់បញ្ញើនៅធនាគារ និងសាច់ប្រាក់ និងសាច់ប្រាក់សមមូល បានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃ 'ការទូទាត់តែប្រាក់ដើម និងការប្រាក់' (SPPI) ដោយសារលក្ខខណ្ឌក្នុងកិច្ចសន្យារបស់វា បានធ្វើឱ្យលំហូរសាច់ប្រាក់កើនឡើង ដែលចាត់ទុកបានជា SPPI ព្រមទាំងមានសង្គតិភាពជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីគោល។ វាក៏ត្រូវបានរៀបចំឡើងនៅក្នុងគំរូអាជីវកម្ម held-to-collect ដូចនេះវាត្រូវបានចាត់ថ្នាក់ និងត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

២.១១.២ ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

*ការទទួលស្គាល់*

នៅពេលកំណត់តម្លៃដំបូង កសស វាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកជាមួយនឹងចំណាយប្រតិបត្តិការដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនវាស់វែងតាម FVPL។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយនៅក្នុងចំណេញ-ខាត។ បម្រែបម្រួលតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុតាម FVPL ត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាតផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗតាមការជាក់ស្តែង។

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញ នាពេលបន្ទាប់ពីការចាត់ថ្នាក់លើកដំបូងរបស់វាទេ លើកលែងតែ កសស ផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលរងផលប៉ះពាល់ ត្រូវបានចាត់ថ្នាក់ឡើងវិញនៅថ្ងៃដំបូង នៃការិយបរិច្ឆេទរាយការណ៍ដំបូងដែលមានការផ្លាស់ប្តូរគំរូអាជីវកម្មនោះ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

### ២.១១.២ ការទទួលស្គាល់ និងការឈប់ទទួលស្គាល់ (ត)

*ការឈប់ទទួលស្គាល់*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬ បើអាចអនុវត្តបាន ផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬផ្នែកមួយនៃក្រុមទ្រព្យសកម្មហិរញ្ញវត្ថុស្រដៀងគ្នា) ត្រូវបានគេឈប់ទទួលស្គាល់ភាគច្រើន (ដូចជា ដកចេញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ កសស) នៅពេលដែលៈ

- សិទ្ធិទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ដែលបានផុតកំណត់ ឬ
- កសស បានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬបានសន្មតកាតព្វកិច្ចក្នុងការទូទាត់លំហូរសាច់ប្រាក់ដែលបានទទួលពេញលេញ ដោយគ្មានការពន្យារពេលជាសារវន្ត ទៅភាគីទីបីក្រោមការរៀបចំ 'ឆ្លងកាត់' (pass-through arrangement) និង (ក) កសស បានផ្ទេរហានិភ័យជាសារវន្ត និងផលតបស្នងទាំងអស់នៃទ្រព្យសកម្ម ឬ កសស មិនបានផ្ទេរ ឬនៅមានហានិភ័យជាសារវន្ត និងផលតបស្នងទាំងអស់នៃទ្រព្យសកម្ម ប៉ុន្តែបានផ្ទេរការគ្រប់គ្រងនៃទ្រព្យសកម្ម។

នៅពេល កសស បានផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ឬបានចូលរួមក្នុងកិច្ចព្រមព្រៀង កសស នឹងវាយតម្លៃថាតើ កសស នៅមានហានិភ័យ និងផលនៃភាពជាម្ចាស់កម្មសិទ្ធិបានដែរឬទេ និងក្នុងកម្រិតណា។ នៅពេលដែល កសស មិនបានផ្ទេរ ឬនៅមានហានិភ័យជាសារវន្ត និងផលតបស្នងទាំងអស់នៃទ្រព្យសកម្ម ឬមិនបានផ្ទេរការគ្រប់គ្រងលើទ្រព្យសកម្ម កសស បន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរនៅកម្រិតនៃការចូលរួមជាបន្តបន្ទាប់របស់វា។ ក្នុងករណីនោះ កសស ក៏ទទួលស្គាល់បំណុលពាក់ព័ន្ធផងដែរ។ ទ្រព្យសកម្មដែលបានផ្ទេរ និងបំណុលពាក់ព័ន្ធត្រូវបានវាស់វែងតាមមូលដ្ឋានមួយ ដែលឆ្លុះបញ្ចាំងពីសិទ្ធិ និងកាតព្វកិច្ចដែល កសស នៅមាន។

### ២.១១.៣ ការវាស់វែង

នៅពេលកំណត់តម្លៃលើកដំបូង កសស វាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របរបស់វា បូករួមទាំងចំណាយប្រតិបត្តិការផ្ទាល់ដែលកើតឡើងក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីទ្រព្យសកម្មហិរញ្ញវត្ថុមិនវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ-ខាត (FVPL)។ ការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើគំរូអាជីវកម្មរបស់ កសស ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

២.១១.៣ ការវាស់វែង (ត)

*ឧបករណ៍បំណុល*

ការវាស់វែងជាបន្តបន្ទាប់នៃឧបករណ៍បំណុល គឺអាស្រ័យលើគំរូអាជីវកម្មរបស់ កសស ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម។ កសស ចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ជាទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់។

ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានរក្សាទុកសម្រាប់ការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលលំហូរសាច់ប្រាក់ទាំងនោះសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះ ត្រូវបានធ្វើនិយ័តកម្មប្រសិនបើមានការទទួលស្គាល់សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក។ ចំណូលការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានរួមបញ្ចូលនៅក្នុងចំណូលហិរញ្ញវត្ថុ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

២.១១.៤ ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

កសស ទទួលស្គាល់សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក (ECLs) សម្រាប់ឧបករណ៍បំណុលទាំងអស់ដែលមិនត្រូវបានកំណត់តម្លៃតាមតម្លៃសមស្របក្នុងចំណេញ-ខាត។ ECLs គឺផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលត្រូវបង់ស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ទាំងអស់ដែល កសស រំពឹងថានឹងទទួលបាន ដោយត្រូវធ្វើអប្បហារប្រហាក់ប្រហែលនឹងអត្រាការប្រាក់មានប្រសិទ្ធភាពដើមដំបូង។ លំហូរសាច់ប្រាក់រំពឹងទុករួមបញ្ចូលនូវលំហូរសាច់ប្រាក់ពីការលក់ទ្រព្យបញ្ចាំដែលកាន់កាប់ ឬ ការកែលម្អឥណទានផ្សេងទៀត ដែលជាផ្នែកសំខាន់មួយនៃលក្ខខណ្ឌកិច្ចសន្យា។

ECLs ត្រូវបានទទួលស្គាល់ជាពីរដំណាក់កាល។ ចំពោះឥណទានដែលមិនមានហានិភ័យឥណទានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់លើកដំបូងមក ECLs ត្រូវបានកត់ត្រាសម្រាប់ការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍មិនទូទាត់ប្រាក់ដែលអាចកើតមានក្នុងរយៈពេល១២ខែបន្ទាប់ (ECL ១២ខែ)។ ចំពោះឥណទានទាំងឡាយណា ដែលមានហានិភ័យឥណទានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់លើកដំបូង តម្រូវឱ្យមានការកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកក្នុងរយៈពេលដែលនៅសល់ ដោយមិនគិតពីពេលវេលានៃការមិនទូទាត់ប្រាក់ (ECL ពេញមួយអាយុកាល)។

ចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ កសស អនុវត្តវិធីសាស្ត្រសាមញ្ញមួយក្នុងការគណនា ECLs។ ដូច្នេះ កសស មិនតាមដានការប្រែប្រួលនៃហានិភ័យឥណទានទេ ប៉ុន្តែផ្ទុយទៅវិញ ទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ ដោយផ្អែកលើ ECLs ពេញមួយអាយុកាល នាកាលបរិច្ឆេទរាយការណ៍នីមួយៗ។ កសស បានបង្កើតម៉ាទ្រីសសំវិធានធន ដែលផ្អែកលើបទពិសោធន៍នៃការខាតបង់ឥណទានក្នុងគ្រាកន្លងមករបស់ខ្លួន ដែលត្រូវបានកែតម្រូវទៅតាមកត្តារំពឹងមើលទៅអនាគតជាក់លាក់ចំពោះកូនបំណុល និងបរិយាកាសសេដ្ឋកិច្ច។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.១១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

២.១១.៤ ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

កសស ចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុក្នុងចំណាត់ថ្នាក់មិនសងប្រាក់ នៅពេលដែលការទូទាត់តាមកិច្ចសន្យាហួសកាលកំណត់សង១២០ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន កសស ក៏អាចពិចារណាមិនចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុក្នុងចំណាត់ថ្នាក់មិនសងប្រាក់ដែរ នៅពេលដែលព័ត៌មានផ្ទៃក្នុង ឬក្រៅបង្ហាញថា កសស ទំនងជាអាចទទួលបានចំនួនទឹកប្រាក់កិច្ចសន្យាដែលនៅសេសសល់ពេញលេញ មុនពេលពិចារណាអំពីការកែលម្អឥណទានណាមួយដែលកាន់កាប់ដោយ កសស។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានជម្រះចេញពីបញ្ជី នៅពេលមិនមានការរំពឹងទុកសមហេតុផលក្នុងការទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាមកវិញ។

កសស បានកំណត់ការមើលឃើញពីការខាតបង់ឥណទានរំពឹងទុក ដែលទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ដែលកត់ត្រាតាមថ្លៃដើមដករំលស់។ វិធីសាស្រ្តថយចុះតម្លៃដែលបានអនុវត្ត អាស្រ័យទៅលើថាតើមានកំណើនហានិភ័យឥណទានជាសារវន្តដែរឬទេ។

## ២.១២ គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ជាទឹកប្រាក់ដែលទទួលបានពីការផ្តល់សេវាកម្មផ្សេងៗ ដល់អតិថិជនក្នុងដំណើរការអាជីវកម្មធម្មតា។ គណនីអតិថិជនពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការប្រមូលប្រាក់កំណត់ក្នុងរយៈពេល១ឆ្នាំឬតិចជាង (ឬនៅក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មធម្មតា)។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង។

គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកត់ត្រាលើកដំបូងតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់មានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់ការថយចុះតម្លៃ និងការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ២.១១.៤)។

## ២.១៣ ប្រាក់បញ្ញើនៅធនាគារ

ប្រាក់បញ្ញើនៅធនាគារគឺជាប្រាក់បញ្ញើមានកាលកំណត់ដែលផ្ញើនៅធនាគារ និងមានរយៈពេល៦ខែទៅ២៤ខែ។ ចំណូលការប្រាក់ និងការប្រាក់ត្រូវទទួល ត្រូវបានទទួលស្គាល់ទៅតាមរយៈពេលនៃប្រាក់បញ្ញើ។

## ២.១៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ និងការវិនិយោគរយៈពេលខ្លី ដែលអាចបង្វិលទៅជាសាច់ប្រាក់បានភ្លាមៗ និងមានអាយុកាលបីខែ ឬតិចជាងបីខែ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១៥ បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់នៅពេលដែល កសស ក្លាយជាភាគីក្នុងបទប្បញ្ញត្តិកិច្ចសន្យានៃឧបករណ៍ណាមួយ។ បំណុលហិរញ្ញវត្ថុរបស់ កសស ដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ រួមមាន គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ ប្រាក់តម្កល់ដែលអាចបង្វិលពីភតិកៈ ប្រាក់រក្សាទុកត្រូវបង់ និងប្រាក់កម្ចី។

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការសម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ ដែលមិនបានកត់ត្រាតាមតម្លៃសមស្របក្នុងចំណេញ-ខាត។

បំណុលហិរញ្ញវត្ថុដែលមិនចាត់ថ្នាក់តាមតម្លៃសមស្រប ក្នុងចំណេញ-ខាត ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

បំណុលហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់ នៅពេលដែលវាត្រូវបានសងរំលស់អស់ ឬសងផ្តាច់អស់។

### ២.១៦ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលមានសិទ្ធិអនុវត្តតាមផ្លូវច្បាប់ ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ ហើយមានបំណងចង់ទូទាត់សងលើមូលដ្ឋានសុទ្ធ ឬទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់សងបំណុលក្នុងពេលដំណាលគ្នា។

### ២.១៧ ដើមទុន និងបុព្វលាភភាគហ៊ុន

ដើមទុនបានបង់ ត្រូវបានវាស់វែងតាមតម្លៃចារិកមួយសម្រាប់ភាគហ៊ុនទាំងអស់ដែលបានបោះផ្សាយ និងដែលនៅសេសសល់។ នៅពេលដែលភាគហ៊ុនត្រូវបានលក់តាមតម្លៃបុព្វលាភ ភាពខុសគ្នារវាងសាច់ប្រាក់ទទួលបាន និងតម្លៃចារិក ត្រូវបានបញ្ចូលទៅក្នុងបុព្វលាភភាគហ៊ុន។

ភាគហ៊ុនធម្មតាដែលមានភាគលាភទៅតាមឆន្ទានុសិទ្ធិ ត្រូវបានចាត់ថ្នាក់ជាមូលធន។ ការបែងចែកភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន ត្រូវបានកត់ត្រាជាបន្ទុកផ្ទាល់ នៅក្នុងមូលធន។

### ២.១៨ ភាគលាភ

ភាគលាភលើភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ជាបំណុលនៅពេលប្រកាសមុនកាលបរិច្ឆេទរាយការណ៍។ ភាគលាភដែលប្រកាសបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តឱ្យចេញផ្សាយ មិនត្រូវបានទទួលស្គាល់ជាបំណុល នាកាលបរិច្ឆេទរាយការណ៍ទេ។

សំវិធានធនត្រូវបានកត់ត្រាសម្រាប់ចំនួនភាគលាភណាមួយដែលបានប្រកាស ដែលត្រូវបានអនុម័តសមស្រប និងលែងស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់ កសស នៅថ្ងៃ ឬមុនដំណាច់ការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែមិនត្រូវបានបែងចែកនាដំណាច់ការិយបរិច្ឆេទរាយការណ៍។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.១៩ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលកើតឡើង ហើយបន្ទាប់មកវាត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់។ ភាពលម្អៀងរវាងសាច់ប្រាក់ (ដកចំណាយប្រតិបត្តិការ) និងទឹកប្រាក់ដែលបង្វិលសងវិញ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត លើរយៈពេលនៃប្រាក់កម្ចី ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

### ២.២០ បន្ទុកប្រាក់កម្ចី

បន្ទុកប្រាក់កម្ចីទូទៅនិងជាក់លាក់ ដែលបានចំណាយផ្ទាល់ក្នុងការទិញ ការសាងសង់ ហើយជាទ្រព្យសកម្មដែលត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់គេ ឬសម្រាប់លក់ត្រូវបានកត់ត្រាបន្ថែមទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលទ្រព្យសកម្មនោះមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬសម្រាប់លក់បាន។

ចំណូលលើការវិនិយោគដែលរកបានពីការវិនិយោគបណ្តោះអាសន្ននៃប្រាក់កម្ចីជាក់លាក់ ដែលមិនទាន់ជាចំណាយរបស់ទ្រព្យសម្បត្តិដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដកចេញពីបន្ទុកប្រាក់កម្ចីដែលត្រូវធ្វើមូលធនកម្ម។

បន្ទុកប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

### ២.២១ អត្ថប្រយោជន៍បុគ្គលិក

២.២១.១ អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី រួមមាន ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល ប្រាក់រង្វាន់ ប្រាក់បំណាច់អតីតភាពការងារ និងភាគទានក្នុងរបបសន្តិសុខសង្គម ត្រូវបានកត់ត្រាជាចំណាយក្នុងការិយបរិច្ឆេទ ដែលបុគ្គលិកបានបំពេញការងារឱ្យ កសស។

២.២១.២ ផ្នែករបបប្រាក់សោធន

កសស បង់ភាគទានប្រចាំខែជាប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច ទៅបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលជាផ្នែកសាធារណៈរដ្ឋបាលនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនក្នុងប្រទេសកម្ពុជា។ កសស មិនមានកាតព្វកិច្ចបង់ប្រាក់បន្ថែមទៀតទេ នៅពេលដែលបានបង់ភាគទាននេះរួច។ ភាគទានត្រូវបានកត់ត្រាជាចំណាយអត្ថប្រយោជន៍បុគ្គលិក នៅពេលដល់ថ្ងៃកំណត់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.២១ អត្ថប្រយោជន៍បុគ្គលិក (ត)

២.២១.៣ អត្ថប្រយោជន៍សោធននិវត្តន៍

កសស បានផ្តល់ឱ្យគម្រោងអត្ថប្រយោជន៍បុគ្គលិកចំនួនពីរ ដល់បុគ្គលិកនៅពេលដែលដល់អាយុចូលនិវត្តៈ

- កាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្ត
- ប្រាក់បំណាច់លើកទឹកចិត្ត

កសស អនុវត្តគម្រោងអត្ថប្រយោជន៍នេះដូចខាងក្រោម ៖

- វិភាគទានរបស់បុគ្គលិក ១០% នៃប្រាក់បៀវត្សរ៍គោលប្រចាំខែរបស់បុគ្គលិក
- វិភាគទានរបស់ កសស ១០% នៃប្រាក់បៀវត្សរ៍គោលប្រចាំខែរបស់បុគ្គលិក
- ក្រុមប្រឹក្សាភិបាលសម្រេចលើចំនួនបន្ថែមដែលត្រូវបញ្ចូលទៅក្នុងគម្រោងនេះ តាមមូលដ្ឋានប្រចាំឆ្នាំអាស្រ័យទៅតាមលទ្ធផលរបស់ កសស ក្នុងឆ្នាំ

ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះ បុគ្គលិកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ជាបុគ្គលិកអចិន្ត្រៃយ៍
- បានបំពេញការងារជូន កសស ចំនួន ២៥ ឆ្នាំ ឬ ច្រើនជាងនេះ
- បានចូលរួមវិភាគទុនក្នុងគម្រោងនេះ តាមការកំណត់
- មានប័ណ្ណបុគ្គលិក និង

ប្រសិនបើចូលនិវត្តមុនពេលដល់អាយុចូលនិវត្ត ការចូលនិវត្តនោះត្រូវមានការអនុម័តដោយប្រធានក្រុមប្រឹក្សា-ភិបាល និងអគ្គនាយក។

i) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

(ក) បុគ្គលិកដែលបានបម្រើការងាររយៈពេល២៥ឆ្នាំ ឬច្រើនឆ្នាំជាងនេះ មានជម្រើសពីរក្នុងការទទួលបានអត្ថប្រយោជន៍នេះ គឺបើកប្រាក់បង់ផ្តាច់តែមួយដងនៅពេលដល់អាយុចូលនិវត្ត ឬបើកប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណភាព។ ការបង់ប្រាក់ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ គឺអាស្រ័យទៅតាមប្រការ និងលក្ខខណ្ឌនានា ដូចខាងក្រោម៖

*ចំពោះការបង់ប្រាក់ផ្តាច់៖*

បុគ្គលិកដែលបានសម្រេចទទួលយកការបង់ប្រាក់ផ្តាច់នៅពេលដល់អាយុចូលនិវត្ត នឹងទទួលបាននូវចំនួនទឹកប្រាក់ស្មើនឹង ១២,៥ដង នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់បុគ្គលិក។

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត** (ត)

**២.២១ អត្ថប្រយោជន៍បុគ្គលិក** (ត)

២.២១.៣ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

i) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

*ចំពោះការបង់ប្រាក់ប្រចាំខែរហូតដល់ពេលទទួលមរណភាព៖*

ការបង់ប្រាក់ប្រចាំខែដែលត្រូវបង់ជូនបុគ្គលិកដែលសម្រេចជ្រើសរើសយកអត្ថប្រយោជន៍ប្រចាំខែ រហូតដល់ពេលទទួលមរណភាព គឺអាស្រ័យទៅតាមចំនួនឆ្នាំនៃអតីតភាពការងាររបស់បុគ្គលិក ដូចបានកំណត់ខាងក្រោម៖

| **អតីតភាពការងារ** | **អត្ថប្រយោជន៍** |
|---|---|
| ២៥ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់បុគ្គលិក |
| ២៦ឆ្នាំ - ៤០ឆ្នាំ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៧៥% នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់បុគ្គលិក បូកនឹង ១% បន្ថែម លើឆ្នាំនីមួយៗទៅលើរយៈពេល២៥ឆ្នាំខាងលើ។ |
| ៤០ឆ្នាំឡើងទៅ | ទទួលបានការបង់ប្រាក់ប្រចាំខែចំនួន ៩០% នៃប្រាក់បៀវត្សរ៍គោលខែចុងក្រោយរបស់បុគ្គលិក |

(ខ) បុគ្គលិកដែលបានបម្រើការងាររយៈពេលតិចជាង២៥ឆ្នាំ នៅពេលចូលនិវត្ត បញ្ឈប់ពីការងារ ឬទទួលមរណភាព គឺមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍នេះទេ ប៉ុន្តែពួកគេមានសិទ្ធិទទួលបានការបង់ប្រាក់មួយចំនួន ដូចខាងក្រោម៖

| **អតីតភាពការងារ** | **អត្ថប្រយោជន៍** |
|---|---|
| តិចជាង១០ឆ្នាំ | មិនទទួលបានអត្ថប្រយោជន៍ និងមិនទទួលបានវិភាគទានសរុបមកវិញទេ។ វិភាគទានសរុបនឹងក្លាយទៅជាចំណូលអត្ថប្រយោជន៍។ |
| ១០ឆ្នាំ - ២៤ឆ្នាំ | ទទួលបាន ២០០% នៃវិភាគទានសរុបពី កសស និងបុគ្គលិក។ |

ប្រសិនបើគម្រោងនេះត្រូវបានលុបចោលដោយមូលហេតុណាមួយ បុគ្គលិកអាចទាមទារនូវចំណែកបដិភាគរបស់គាត់ពីគម្រោងនេះវិញបាន អាស្រ័យទៅតាមលក្ខខណ្ឌជាក់ស្តែងរបស់គម្រោង ព្រមទាំងនីតិវិធីដែលបានចែងក្នុងគោលការណ៍។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.២១ អត្ថប្រយោជន៍បុគ្គលិក (ត)

២.២១.៣ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

i) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

(គ) អត្ថប្រយោជន៍ចូលនិវត្តមុនកំណត់

បុគ្គលិកដែលបានចូលនិវត្ត ឬត្រូវបណ្តេញចេញមុនពេលដល់អាយុចូលនិវត្ត នឹងទទួលបានអត្ថប្រយោជន៍ ដូចខាងក្រោម៖

| **អតីតភាពការងារ** | **អត្ថប្រយោជន៍** |
|---|---|
| តិចជាង១០ឆ្នាំ | មិនទទួលបានវិភាគទានសរុបរបស់បុគ្គលិកមកវិញទេ។ |
| ពី ១០ឆ្នាំ - ២០ឆ្នាំ | ១២០% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ។ |
| ពី ២១ឆ្នាំ - ៣០ឆ្នាំ | ១៣៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល២១ឆ្នាំ។ |
| ពី ៣១ឆ្នាំ - ៤០ឆ្នាំ | ១៥៥% នៃវិភាគទានសរុបរបស់បុគ្គលិក និង ១% បន្ថែម លើឆ្នាំនីមួយៗក្នុងរយៈពេល៣១ឆ្នាំ។ |
| ពី៤០ឆ្នាំឡើងទៅ | ១៦៤% នៃវិភាគទានសរុបរបស់បុគ្គលិក។ |

(ឃ) អត្ថប្រយោជន៍មរណភាព

បុគ្គលិកដែលទទួលមរណភាព នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង។ អត្ថប្រយោជន៍ដូចខាងក្រោមនេះ គឺអាស្រ័យទៅលើការចូលរួមវិភាគទានសរុបរបស់បុគ្គលិក និង អាស្រ័យទៅលើចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកនោះ ៖

| **អតីតភាពការងារ** | **មរណភាពទាក់ទងនឹងការងារ** | **មរណភាពមិនទាក់ទងនឹងការងារ** |
|---|---|---|
| តិចជាង១១ឆ្នាំ | ១២៥% | ១១៥% |
| ពី ១១ឆ្នាំ - ២០ឆ្នាំ | ១៤៥% | ១៣៥% |
| ពី ២១ឆ្នាំ - ៣០ឆ្នាំ | ១៥៥% | ១៤៥% |
| ពី៣០ឆ្នាំឡើងទៅ | ១៦៥% | ១៥៥% |

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)**

**២.២១ អត្ថប្រយោជន៍បុគ្គលិក (ត)**

២.២១.៣ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

i) កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

(ង) អត្ថប្រយោជន៍ពិការភាព៖

បុគ្គលិកដែលបានបម្រើការងារតិចជាង២៥ឆ្នាំ ហើយបានធ្លាក់ខ្លួនពិការ នឹងទទួលបានការបង់ប្រាក់ផ្តាច់តែមួយដង អាស្រ័យទៅតាមការចូលរួមវិភាគទានរបស់ កសស និងរបស់បុគ្គលិក ដូចខាងក្រោម៖

| **អតីតភាពការងារ** | **ពិការភាពបណ្តាលមកពីការងារ** | **ពិការភាពមិនបណ្តាលមកពីការងារ** |
|---|---|---|
| តិចជាង១១ឆ្នាំ | ១២៥% | ១១៥% |
| ពី១១ឆ្នាំ - ២៥ឆ្នាំ | ១២៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ | ១១៥% បូក ៣% លើឆ្នាំនីមួយៗក្នុងរយៈពេល១០ឆ្នាំ |
| ចាប់ពី២៥ឆ្នាំឡើងទៅ | | |
| ជម្រើសទី១ | ១៧០% | ១៦០% |
| ជម្រើសទី២ | អត្ថប្រយោជន៍សោធននិវត្តន៍ប្រចាំខែ | អត្ថប្រយោជន៍សោធននិវត្តន៍ប្រចាំខែ |

ii) ប្រាក់បំណាច់លើកទឹកចិត្ត

កសស ក៏បានផ្តល់គម្រោងអត្ថប្រយោជន៍បុគ្គលិកផ្សេងៗទៀត ដែលជាប្រាក់បំណាច់លើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារឱ្យ កសស រហូតដល់អាយុចូលនិវត្ត។

នៅពេលចូលនិវត្ត បុគ្គលិកនឹងទទួលបានប្រាក់បំណាច់លើកទឹកចិត្ត (គិតជាចំនួនទឹកប្រាក់) ដូចគណនាខាងក្រោម៖

*អត្រាអត្ថប្រយោជន៍ x ប្រាក់បៀវត្សរ៍គោលសុទ្ធដែលបានដកចុងក្រោយ x ចំនួនឆ្នាំអតីតភាពការងារ*

អត្រាអត្ថប្រយោជន៍អាស្រ័យលើចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិក ដែលបានចែងដូចខាងក្រោម៖

| **អតីតភាពការងារ** | **អត្រាអត្ថប្រយោជន៍** |
|---|---|
| រហូតដល់២៥ឆ្នាំ | ៧៥% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោលរបស់បុគ្គលិកនៅអាយុចូលនិវត្ត |
| ២៦ឆ្នាំ - ៤០ឆ្នាំ | ៧៥% បូមបន្ថែម១% សម្រាប់បន្ថែមឆ្នាំនីមួយៗដែលបានបម្រើការងាលើសពី២៥ឆ្នាំ នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោលរបស់បុគ្គលិក នៅអាយុចូលនិវត្ត |
| លើសពី៤០ឆ្នាំ | គិតត្រឹម ៩០% នៃប្រាក់បៀវត្សរ៍ខែចុងក្រោយគោលរបស់បុគ្គលិក នៅអាយុចូលនិវត្ត |

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.២១ អត្ថប្រយោជន៍បុគ្គលិក (ត)

២.២១.៣ អត្ថប្រយោជន៍សោធននិវត្តន៍ (ត)

ii) ប្រាក់បំណាច់លើកទឹកចិត្ត (ត)

បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទាក់ទងនឹងគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្តដែលបានកំណត់ គឺជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចបានកំណត់ គិតត្រឹមដំណាច់ការិយបរិច្ឆេទរាយការណ៍ ដកតម្លៃសមស្របនៃទ្រព្យតម្កល់ (ប្រសិនបើមាន)។ កាតព្វកិច្ចសោធននិវត្តន៍ត្រូវបានគណនាដោយប្រើវិធីសាស្ត្រប៉ាន់ស្មានឯកតាឥណទាន (projected unit credit)។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ ត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ នាកាលបរិច្ឆេទវាយតម្លៃ ដោយសារទីផ្សារសញ្ញាប័ណ្ណសាជីវកម្មមិនមានគុណភាពខ្ពស់ និងមិនមានសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំណេញ និងខាតពីការវាស់វែងឡើងវិញដែលកើតពីការធ្វើនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មត ត្រូវបានកត់ត្រាជាបន្ទុក ឬកត់ត្រាខាងខ្ទង់ឥណទានក្នុងលទ្ធផលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

ក៏ប៉ុន្តែ នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានធ្វើវិសោធនកម្មលើគោលការណ៍ ដោយបានកំណត់ចំនួនឆ្នាំអតីតភាពការងារ អតិបរិមាត្រឹម៤០ឆ្នាំ។

២.២១.៤ កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ

*ប្រាក់បំណាច់អតីតភាពការងាររំលឹក*

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានចេញប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ដល់សហគ្រាស គ្រឹះស្ថានទាំងអស់ និងបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ៨៩ (ថ្មី) នៃច្បាប់ការងារ រួមជាមួយនឹងសេចក្តីណែនាំអនុវត្តដែលចេញផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ ប្រកាសនេះតម្រូវឱ្យបង់ប្រាក់បំណាច់អតីតភាពការងាររំលឹក ដែលស្មើនឹង១៥ថ្ងៃក្នុងមួយឆ្នាំ សម្រាប់រយៈពេលអតិបរមាមិនលើសពី៦ខែ អាស្រ័យទៅតាមប្រាក់ឈ្នួលសុទ្ធជាមធ្យមសម្រាប់ឆ្នាំនីមួយៗ។ បុគ្គលិកមិនមានសិទ្ធិទទួលបានប្រាក់បំណាច់នេះទេ ប្រសិនបើពួកគេលាឈប់ពីការងារ មុនពេលទទួលបានប្រាក់បំណាច់នេះ។ ប្រាក់បំណាច់នឹងត្រូវបែងចែកជាពីរដំណាក់កាល ដោយចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០២១ ដូចខាងក្រោមៈ

- ស្មើនឹង៣ថ្ងៃ ដែលត្រូវបង់រៀងរាល់ខែធ្នូ និង
- ស្មើនឹង៣ថ្ងៃ ដែលត្រូវបង់រៀងរាល់ខែមិថុនា

ការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំលឹក មិនត្រូវលើសពី៦ខែនៃប្រាក់ឈ្នួលជាមធ្យមរបស់បុគ្គលិកនៃឆ្នាំនីមួយៗក្នុងអតីតកាលនោះទេ។ បុគ្គលិកមិនមានសិទ្ធិទទួលបានប្រាក់បំណាច់នេះទេ ប្រសិនបើពួកគេលាឈប់ពីការងារមុនពេលកំណត់។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ក្រសួងបានចេញសេចក្តីណែនាំស្តីពីការបង់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ ២០១៩ ដោយបញ្ជាក់ថាការបង់ប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ អាចត្រូវបានពន្យារពេលរហូតដល់ខែមិថុនា ឆ្នាំ២០២២។ ទោះជាយ៉ាងណាក៏ដោយ កសស បានចាប់ផ្តើមទូទាត់ប្រាក់បំណាច់អតីតភាពការងាររំលឹករបស់ខ្លួន ចាប់ពីខែធ្នូ ឆ្នាំ២០២១។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

## ២.២១ អត្ថប្រយោជន៍បុគ្គលិក (ត)

២.២១.៤ កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ (ត)

*ប្រាក់បំណាច់អតីតភាពការងាររំលឹក (ត)*

កសស ប៉ាន់ស្មានសំវិធានធនសម្រាប់ប្រាក់បំណាច់អតីតភាពការងារ ដោយប្រើតម្លៃបច្ចុប្បន្ននៃការទូទាត់រំពឹងទុកនាពេលអនាគត ដោយប្រើប្រាស់ការសន្មតជាក់លាក់មួយចំនួន ចំពោះអត្រាបម្រែបម្រួលបុគ្គលិក ដោយផ្អែកលើបទពិសោធន៍ថ្មីៗចុងក្រោយរបស់ កសស អត្រាមរណភាព និងអត្រាការប្រាក់ទីផ្សារ។

## ២.២២ សម្បទានពីរាជរដ្ឋាភិបាល

សម្បទានពីរាជរដ្ឋាភិបាលរបស់រដ្ឋាភិបាល ត្រូវបានទទួលស្គាល់នៅពេលដែលមានការធានាសមហេតុផលថាជំនួយនឹងត្រូវបានទទួល ហើយលក្ខខណ្ឌភ្ជាប់ទាំងអស់នឹងត្រូវអនុវត្តតាម។ នៅពេលដែលសម្បទានទាក់ទងនឹងធាតុចំណាយ នោះវាត្រូវបានទទួលស្គាល់ជាចំណូលតាមមូលដ្ឋានជាប្រព័ន្ធ ក្នុងរយៈពេលដែលការចំណាយពាក់ព័ន្ធដែលគ្រោងនឹងទូទាត់បង់ ត្រូវបានចំណាយ។ នៅពេលដែលសម្បទានទាក់ទងនឹងទ្រព្យសកម្មណាមួយ វាត្រូវបានទទួលស្គាល់ជាចំណូល ក្នុងចំនួនស្មើគ្នា ក្នុងរយៈពេលនៃអាយុកាលប្រើប្រាស់រំពឹងទុកនៃទ្រព្យសកម្មពាក់ព័ន្ធ។

នៅពេលដែល កសស ទទួលបានសម្បទានជាទ្រព្យសកម្មមិនមែនរូបិយវត្ថុ ទ្រព្យសកម្ម និងសម្បទានត្រូវបានកត់ត្រាតាមចំនួនកំណត់ ហើយកត់ត្រាបញ្ចេញទៅចំណេញ-ខាត ទៅតាមអាយុកាលប្រើប្រាស់រំពឹងទុករបស់ទ្រព្យសកម្ម ដោយផ្អែកលើគំរូនៃការប្រើប្រាស់អត្ថប្រយោជន៍នៃទ្រព្យសកម្មមូលដ្ឋាន ដោយបែងចែកប្រចាំឆ្នាំស្មើគ្នា។

## ២.២៣ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធសម្រាប់ការិយបរិច្ឆេទ រួមមាន ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ និងពន្ធពន្យារលើប្រាក់ចំណូល។ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។ ចំណាយពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ ត្រូវបានគណនាតាមមូលដ្ឋាននៃច្បាប់ពន្ធដារដែលត្រូវបានអនុម័តរួចជាស្ថាពរ ឬត្រូវបានអនុម័តមួយផ្នែកធំ នាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ។

គណៈគ្រប់គ្រងវាយតម្លៃជាបន្តបន្ទាប់ អំពីស្ថានភាពក្នុងលិខិតប្រកាសពន្ធ ជាមួយនឹងស្ថានភាពដែលត្រូវបកស្រាយបទប្បញ្ញត្តិពន្ធជាធរមាន និងកត់ត្រាសំវិធានធនទៅតាមភាពសមស្រប តាមមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលរំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធ។

ពន្ធពន្យារលើប្រាក់ចំណូលត្រូវបានធ្វើសំវិធានធនពេញលេញ ដោយប្រើវិធីសាស្ត្របំណុល លើចំនួនលម្អៀងបណ្តោះអាសន្នដែលកើតមានឡើង រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល ជាមួយនឹងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារត្រូវបានកំណត់ដោយប្រើអត្រាពន្ធ និងច្បាប់ពន្ធ ដែលត្រូវបានអនុម័តរួចជាស្ថាពរ ឬត្រូវបានអនុម័តរួចមួយផ្នែកធំនាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដែលត្រូវបានរំពឹងថាត្រូវអនុវត្តនៅពេលដែលពន្ធពន្យារលើប្រាក់ចំណូលត្រូវបានទទួលស្គាល់ ឬពន្ធពន្យារជាបំណុលលើប្រាក់ចំណូលត្រូវបានទូទាត់។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.២៣ ពន្ធលើប្រាក់ចំណូល (ត)

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវបានកាត់កង នៅពេលមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងពន្ធទ្រព្យសកម្មក្នុងឆ្នាំជាមួយនឹងបំណុលពន្ធក្នុងឆ្នាំ ហើយវាទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធក្នុងឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត លើកលែងតែវាទាក់ទងនឹងខ្ទង់ដែលទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬខ្ទង់ដែលទទួលស្គាល់ក្នុងមូលធន។ ក្នុងករណីនេះ ពន្ធក៏ត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬទទួលស្គាល់ផ្ទាល់ក្នុងមូលធនដែរ។

### ២.២៤ ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

កសស ទទួលស្គាល់ប្រាក់ចំណូល នៅពេលដែល កសស មានភាពប្រាកដចំពោះកាតព្វកិច្ចអនុវត្ត តាមរយៈការផ្ទេរទំនិញ ឬ សេវាដែលបានសន្យាទៅឱ្យអតិថិជន (នៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងលើទំនិញ ឬសេវានោះ)។ កាតព្វកិច្ចអនុវត្តគឺជាការសន្យាផ្ទេរទំនិញ ឬសេវាណាមួយឱ្យអតិថិជន។ ចំនួនទឹកប្រាក់ចំណូលដែលបានទទួលស្គាល់ គឺជាចំនួនទឹកប្រាក់ដែលបានបែងចែកទៅតាមកាតព្វកិច្ចអនុវត្តដែលមានភាពប្រាកដ។

*ចំណូលបានពីកំពង់ផែ*

ប្រាក់ចំណូលជាចម្បងរួមមាន កម្រៃដែលទទួលបានពីការដឹកជញ្ជូនទំនិញ (ការលើកដាក់ទំនិញពីនាវា/ចូលនាវា) ការលើកដាក់ទំនិញ (ការលើកដាក់ទំនិញពីយានយន្ត/ចូលយានយន្ត) សេវាកម្មច្រកចេញចូលកំពង់ផែ (ការបញ្ជានាវាចូលចំណត) ការរក្សាទុកកុងតឺន័រ និងសេវាផ្សេងៗទៀត។ ប្រាក់ចំណូលពីការផ្តល់សេវាទាំងនេះ ត្រូវបានកត់ត្រានៅពេលដែលបានបំពេញសេវាជូនអតិថិជន។

*ចំណូលពីការជួល - កសស គឺជាភាគីភតិបតី*

ភតិសន្យាដែលជាចំណែកនៃហានិភ័យដែលមានលក្ខណៈជាសារវន្ត និងភាពជាម្ចាស់ត្រូវបានរក្សាទុកដោយភាគីភតិបតី ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ចំណូលពីការជួលរបស់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាក្នុងរយៈពេលនៃភតិសន្យា តាមមូលដ្ឋានថេរ។

*ចំណូលផ្សេងៗ*

ចំណូលផ្សេងៗរួមមាន កម្រៃពីការចូលឡានធំៗ និងកម្រៃផ្សេងៗទៀត។ ចំណូលផ្សេងៗត្រូវបានកត់ត្រានៅពេលបានបំពេញសេវា។

*ចំណូលការប្រាក់*

ចំណូលការប្រាក់ត្រូវបានកត់ត្រាដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព និងរួមបញ្ចូលក្នុងចំណូលហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.២៥ ភតិសន្យាប្រតិបត្តិ - កសស ជាភាគីភតិបតី

ទ្រព្យសម្បត្តិជួលដែលស្ថិតក្រោមភតិសន្យាប្រតិបត្តិ ត្រូវបានរួមបញ្ចូលក្នុងទ្រព្យសម្បត្តិវិនិយោគ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (កំណត់សម្គាល់ ៦)។

### ២.២៦ ចំណេញក្នុងមួយភាគហ៊ុន

(i) ចំណេញក្នុងមួយភាគហ៊ុនគោល (Basic Earnings Per Share)

ចំណេញក្នុងមួយភាគហ៊ុនគោល ត្រូវបានគណនាដោយៈ

- យកចំណេញរបស់ភាគទុនិក កសស មិនរាប់បញ្ចូលចំណាយក្នុងការលក់ភាគហ៊ុន ក្រៅពីភាគហ៊ុនធម្មតា
- ចែកជាមួយនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលនៅសល់ ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ ដោយកែតម្រូវសម្រាប់ធាតុបន្ថែមនៅក្នុងភាគហ៊ុនធម្មតា ដែលបានបោះផ្សាយក្នុងអំឡុងឆ្នាំ និងមិនរាប់បញ្ចូលភាគហ៊ុនដែលអាចទិញយកមកវិញ (treasury shares) ប្រសិនបើមាន។

(ii) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (Diluted Earnings Per Share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ធ្វើនិយ័តកម្មតួលេខដែលបានប្រើប្រាស់ក្នុងការកំណត់ចំណេញក្នុងមួយភាគហ៊ុនគោល ដោយគិតទៅលើៈ

- ផលប៉ះពាល់លើការប្រាក់បន្ទាប់ពីដកពន្ធលើប្រាក់ចំណេញ និងចំណាយការប្រាក់ផ្សេងៗទៀត ដែលទាក់ទិននឹងភាគហ៊ុនធម្មតាដែលមានសក្តានុពល និង
- ចំនួនមធ្យមនៃភាគហ៊ុនធម្មតាបន្ថែម ដែលអាចត្រូវបានសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

### ២.២៧ សំវិធានធន និងបំណុលយថាភាព

សំវិធានធនត្រូវបានកត់ត្រានៅពេលដែល កសស មានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់កាតព្វកិច្ចនោះអាចប៉ាន់ស្មានគួរឱ្យទុកចិត្តបាន។ ប្រសិនបើផលប៉ះពាល់នៃតម្លៃពេលវេលានៃប្រាក់មានចំនួនជាសារវន្ត សំវិធានធនត្រូវបានធ្វើអប្បហារដោយប្រើអត្រាមុនពន្ធបច្ចុប្បន្ន ដែលឆ្លុះបញ្ចាំងពីហានិភ័យជាក់លាក់ចំពោះបំណុល ទៅតាមភាពសមស្រប។ ក្នុងករណីដែលអប្បហារត្រូវបានប្រើប្រាស់ ការកើនឡើងនៃសំវិធានធនដោយសារតែការកន្លងផុតទៅនៃពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.២៧ សំវិធានធន និងបំណុលយថាភាព (ត)

បំណុលយថាភាពមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ លុះត្រាតែលទ្ធភាពនៃការហូរចេញធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ចមានកម្រិតទាប។ ទ្រព្យសកម្មយថាភាពមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវបានបង្ហាញនៅពេលដែលលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចទំនងជាកើតមាន។ ទ្រព្យសកម្មយថាភាពត្រូវបានវាយតម្លៃជាបន្តបន្ទាប់ដើម្បីធានាថាការវិវឌ្ឍត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើមានភាពប្រាកដថាមានលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងកើតឡើង ទ្រព្យសកម្ម និងប្រាក់ចំណូលពាក់ព័ន្ធ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ។

### ២.២៨ ការរាយការណ៍តាមផ្នែក

ការរាយការណ៍តាមផ្នែកត្រូវបានរាយការណ៍ឱ្យមានសង្គតិភាព ជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (អគ្គនាយក)។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការគឺជាក្រុមគណៈគ្រប់គ្រង (រួមទាំងអគ្គនាយកនិងអគ្គនាយករងទាំងអស់) ដែលជាអ្នកធ្វើការសម្រេចចិត្តចំពោះការបែងចែកធនធាន និងជាអ្នកធ្វើការវាយតម្លៃលើលទ្ធផលនៃផ្នែកប្រតិបត្តិការ និងជាអ្នកដែលធ្វើការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រ។

## ៣. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ កសស ធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតពីអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ វាកម្រដូចគ្នាទៅនឹងលទ្ធផលពិតជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យធំ អាចបណ្តាលឱ្យមាននិយ័តកម្មជាសារវន្តលើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានបង្ហាញដូចខាងក្រោម៖

កាតព្វកិច្ចសោធននិវត្តន៍

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍គឺអាស្រ័យទៅតាមកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានដែលពាក់ព័ន្ធនឹងការគណនាហានិភ័យ ដោយប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយសុទ្ធសម្រាប់ប្រាក់សោធននិវត្តន៍ រួមមានអត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ និងអត្រាបម្រែបម្រួលបុគ្គលិក។ បម្រែបម្រួលណាមួយលើការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃយោងរបស់កាតព្វកិច្ចសោធននិវត្តន៍នេះ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ៤. ព័ត៌មានតាមផ្នែក

ការរាយការណ៍តាមផ្នែកមិនត្រូវបានបង្ហាញទេ ដោយសារភាគច្រើន កសស ពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មកំពង់ផែ ដូចជាសេវាកម្មកំពង់ផែសមុទ្រ និងសេវាកម្មផ្សេងទៀតទាក់ទងនឹងកំពង់ផែ និងភតិសន្យាប្រតិបត្តិនៃតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួន ដែលភាគច្រើនស្ថិតនៅក្នុងផ្នែកអាជីវកម្មតែមួយ ហើយវាមានសង្គតិភាពជាមួយនឹងការអនុវត្តបច្ចុប្បន្ននៃការរាយការណ៍ផ្ទៃក្នុងរបស់ខ្លួន។ កសស ធ្វើប្រតិបត្តិការតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។

ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ហៅកាត់ថា CODM) ដែលជាក្រុមគណៈគ្រប់គ្រង ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាផ្នែកកំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ CODM វាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកទៅលើទំហំប្រាក់ចំណូលដុល (កំណត់សម្គាល់ ២០)។ CODM ក៏ត្រួតពិនិត្យចំណេញមុនបង់ពន្ធ និងចំណេញសុទ្ធ ធៀបនឹងការិយបរិច្ឆេទមុនៗ។ លើសពីនេះ កសស ក៏មានទ្រព្យសម្បត្តិវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងទីតាំងផ្សេងទៀត ដែលកំពុងធ្វើប្រតិបត្តិការជាភាគីភតិបតី និងរកចំណូលបានពីការជួលផងដែរ (កំណត់សម្គាល់ ៦)។

ប្រាក់ចំណូលភាគច្រើនបានមកពីអតិថិជនខាងក្រៅរបស់ កសស។ កសស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយប្រាក់ចំណូលភាគច្រើន មានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

សេចក្តីលម្អិតនៃប្រាក់ចំណូល ដែលត្រូវបានបង្កើតពីអតិថិជនសំខាន់ក្នុងអំឡុងឆ្នាំ មានដូចក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| អតិថិជន ក | ៧៧.០៩០.៥៩០ | ៧០.៣២៨.៦៨២ |
| អតិថិជន ខ | ៨១.៥៩២.៤៦២ | ៥៧.៥០៣.១៥៨ |
| | ១៥៨.៦៨៣.០៥២ | ១២៧.៨៣១.៨៤០ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ៥. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីធ្លី ពាន់រៀល | ការកែលម្អ ដីធ្លី ពាន់រៀល | អគារ ពាន់រៀល | បរិក្ខារ បច្ចេកទេស ពាន់រៀល | គ្រឿងសង្ហារិម និងបរិក្ខារភ្ជាប់ ពាន់រៀល | កុំព្យូទ័រ និង បរិក្ខារ ការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារ កំពង់ផែសមុទ្រ ពាន់រៀល | ប៉ាឡែត ពាន់រៀល | សំណង់កំពុង សាងសង់ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | | | | | | |
| ថ្លៃដើម | ៣០៣.៣៨៨.១៣៦ | ៧៣.៩២២.៨៦៩ | ៣៨៩.៤៣១.១៤២ | ៦៩.០១៦.០៦៦ | ៣.៩០០.៤៣៤ | ១០.៦៧៣.២៤០ | ១០០.២០៧.៦៦៩ | ៤២០.៦៣៤.១៥០ | ១.៤២៧.៦៤១ | ១០១.១០៤.៥០១ | ១.៤៧៣.៧០៥.៨៤៨ |
| រំលស់បង្គរ | - | (១៦.៨៥១.៤៦៦) | (៧១.១៥៨.៧៧៧) | (២៧.៦២៤.២៥៧) | (២.១២៤.៤៧៧) | (៧.៣៥៨.៨០៣) | (២៨.៥៨៤.០៧០) | (១០៤.៤៩៦.០១២) | (១.០៨៤.២៨១) | - | (២៥៩.២៨២.១៤៣) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣០៣.៣៨៨.១៣៦ | ៥៧.០៧១.៤០៣ | ៣១៨.២៧២.៣៦៥ | ៤១.៣៩១.៨០៩ | ១.៧៧៥.៩៥៧ | ៣.៣១៤.៤៣៧ | ៧១.៦២៣.៥៩៩ | ៣១៦.១៣៨.១៣៨ | ៣៤៣.៣៦០ | ១០១.១០៤.៥០១ | ១.២១៤.៤២៣.៧០៥ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៣០៣.៣៨៨.១៣៦ | ៥៧.០៧១.៤០៣ | ៣១៨.២៧២.៣៦៥ | ៤១.៣៩១.៨០៩ | ១.៧៧៥.៩៥៧ | ៣.៣១៤.៤៣៧ | ៧១.៦២៣.៥៩៩ | ៣១៦.១៣៨.១៣៨ | ៣៤៣.៣៦០ | ១០១.១០៤.៥០១ | ១.២១៤.៤២៣.៧០៥ |
| ទិញបន្ថែម | - | ២០៧.៣៤៣ | ៨៤៩.៣១៩ | ៣.៥៨៥.១៣០ | ៩៤១.២៥០ | ២.៥១០.២១៩ | ២៥.២៨៧.០០៥ | - | ៣៥៦.៤៧៦ | ៣៥៨.៤២៩.៩៩៥ | ៣៩២.១៦៦.៧៣៧ |
| ផ្ទេរ | ៤.០៣៦.៣៦៣ | ២២.០៨៧.៩២១ | ៣.៣៣៥.៧២៧ | ២០.៨៤០.១៣១ | - | - | - | ២.២៥៧.១៣៦ | - | (៥២.៥៥៧.២៧៨) | - |
| ផ្ទេរពីទ្រព្យសម្បត្តិវិនិយោគ | ២១.៩៩២.៧២២ | - | - | - | - | - | - | - | - | - | ២១.៩៩២.៧២២ |
| ជម្រះចេញពីបញ្ជី | - | (១៤៥.៨០៧) | (៥៦៦.៤៦៨) | - | (៦.៨១០) | (១.៧៩៨) | - | - | - | - | (៧២០.៨៨៣) |
| រំលស់ | - | (៥.០៧៩.៩២០) | (១៣.១០៧.៨១៨) | (១០.៩៣៥.៨២៨) | (៨៧០.៤៨៦) | (១.៦៦៦.៩០៥) | (៨.៥៦១.១៩៨) | (២២.០៦៣.៨៦០) | (១១៩.៧០៨) | - | (៦២.៤០៥.៧២៣) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៣២៩.៤១៧.២២១ | ៧៤.១៤០.៩៤០ | ៣០៨.៧៨៣.១២៥ | ៥៤.៨៨១.២៤២ | ១.៨៣៩.៩១១ | ៤.១៥៥.៩៥៣ | ៨៨.៣៤៩.៤០៦ | ២៩៦.៣៣១.៤១៤ | ៥៨០.១២៨ | ៤០៦.៩៧៧.២១៨ | ១.៥៦៥.៤៥៦.៥៥៨ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | | | | | | | | | | |
| ថ្លៃដើម | ៣២៩.៤១៧.២២១ | ៩៥.៩៣៧.១៩៦ | ៣៩១.៧៩៨.២៨០ | ៩៣.៤៤១.៣២៧ | ៤.៦៩៧.០៥០ | ១២.៩៧៧.៩៦៥ | ១២៥.៤៩៤.៦៧៤ | ៤២២.៨៩១.២៨៦ | ១.៧៨៤.១១៧ | ៤០៦.៩៧៧.២១៨ | ១.៨៨៥.៤១៦.៣៣៤ |
| រំលស់បង្គរ | - | (២១.៧៩៦.២៥៦) | (៨៣.០១៥.១៥៥) | (៣៨.៥៦០.០៨៥) | (២.៨៥៧.១៣៩) | (៨.៨២២.០១២) | (៣៧.១៤៥.២៦៨) | (១២៦.៥៥៩.៨៧២) | (១.២០៣.៩៨៩) | - | (៣១៩.៩៥៩.៧៧៦) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣២៩.៤១៧.២២១ | ៧៤.១៤០.៩៤០ | ៣០៨.៧៨៣.១២៥ | ៥៤.៨៨១.២៤២ | ១.៨៣៩.៩១១ | ៤.១៥៥.៩៥៣ | ៨៨.៣៤៩.៤០៦ | ២៩៦.៣៣១.៤១៤ | ៥៨០.១២៨ | ៤០៦.៩៧៧.២១៨ | ១.៥៦៥.៤៥៦.៥៥៨ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ថ្លៃដើមទ្រព្យសម្បត្តិ និងបរិក្ខារដែលអស់រំលស់ទាំងស្រុង ប៉ុន្តែនៅតែប្រើប្រាស់មានចំនួន ៣៥.០៨៦.៣១០ ពាន់រៀល (២០២៤៖ ២១.០៣៨.៨០៩ ពាន់រៀល)។

**៥. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)**

ការផ្ទៀងផ្ទាត់ការទិញបន្ថែមជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ (ការទិញទ្រព្យសម្បត្តិ និង បរិក្ខារ) មានដូចខាងក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ទិញបន្ថែម | ៣៩២.១៦៦.៧៣៧ | ១៧០.៥៥៥.៩៨៦ |
| ការធ្វើមូលធនកម្មការប្រាក់ (*) | (២.៨៧៩.៤៣១) | (១.១១៨.៥៦១) |
| តំហយបុរេប្រទានឱ្យអ្នកផ្គត់ផ្គង់ | (២.៥៧៣.៩៨១) | - |
| កំណើនទឹកប្រាក់ត្រូវសងអ្នកផ្គត់ផ្គង់ | (៧២.៥៦៩.៣៣៤) | (១៣.៦៥៩.៧៤២) |
| **សាច់ប្រាក់បានប្រើក្នុងការទិញទ្រព្យសម្បត្តិ និងបរិក្ខារ** | ៣១៤.១៤៣.៩៩១ | ១៥៥.៧៧៧.៦៨៣ |

(*) អត្រាមូលធនកម្មដែលបានប្រើដើម្បីកំណត់ចំនួនប្រាក់កម្ចី ដែលត្រូវបានធ្វើមូលធនកម្ម គឺជាអត្រាការប្រាក់បានថ្លឹងមធ្យម ដែលត្រូវអនុវត្តចំពោះប្រាក់កម្ចីទូទៅរបស់ កសស ក្នុងអំឡុងឆ្នាំ ក្នុងករណីនេះគឺអត្រា ១,៤២% ក្នុងមួយឆ្នាំ (២០២៤ ៖ ១,៤៦% ក្នុងមួយឆ្នាំ)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ៦. ទ្រព្យសម្បត្តិវិនិយោគ

| | ដីធ្លី(*)<br>ពាន់រៀល | ការកែលម្អ<br>អគារ និងដី<br>ពាន់រៀល | សំណង់កំពុង<br>សាងសង់<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | |
| ថ្លៃដើម | ១២៦.៥៨៣.៦៦៥ | ១៧០.៧៧៥.៧២៦ | ២.៨៩៣.៧២៧ | ៣០០.២៥៣.១១៨ |
| រំលស់បង្គរ | - | (៥៣.១៥៥.៩២៨) | - | (៥៣.១៥៥.៩២៨) |
| តម្លៃចុះបញ្ជីសុទ្ធ | ១២៦.៥៨៣.៦៦៥ | ១១៧.៦២០.៧៩៨ | ២.៨៩៣.៧២៧ | ២៤៧.០៩៨.១៩០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១២៦.៥៨៣.៦៦៥ | ១១៧.៦២០.៧៩៨ | ២.៨៩៣.៧២៧ | ២៤៧.០៩៨.១៩០ |
| ទិញបន្ថែម | - | ៣៩៣.៣២៧ | ៥១.៧៨៩.៤៤៦ | ៥២.១៨២.៧៧៣ |
| ផ្ទេរ | ៥២.៥៥៧.២៣២ | ១.៦៤៥.៦៦៩ | (៥៤.២០២.៩០១) | - |
| ផ្ទេរទៅទ្រព្យសម្បត្តិ និងបរិក្ខារ | (២១.៩៩២.៧២២) | - | - | (២១.៩៩២.៧២២) |
| លក់ចេញ | (៥៦៣.៤៥២) | - | - | (៥៦៣.៤៥២) |
| រំលស់ | - | (៣.៥០៩.១៦៩) | - | (៣.៥០៩.១៦៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១៥៦.៥៨៤.៧២៣ | ១១៦.១៥០.៦២៥ | ៤៨០.២៧២ | ២៧៣.២១៥.៦២០ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | | | | |
| ថ្លៃដើម | ១៥៦.៥៨៤.៧២៣ | ១៧២.៨១៤.៧២២ | ៤៨០.២៧២ | ៣២៩.៨៧៩.៧១៧ |
| រំលស់បង្គរ | - | (៥៦.៦៦៤.០៩៧) | - | (៥៦.៦៦៤.០៩៧) |
| តម្លៃចុះបញ្ជីសុទ្ធ | ១៥៦.៥៨៤.៧២៣ | ១១៦.១៥០.៦២៥ | ៤៨០.២៧២ | ២៧៣.២១៥.៦២០ |

(*) ដីទាំងនេះរួមមាន ដីនៅតំបន់សេដ្ឋកិច្ចពិសេស (SEZ) និងដីផ្សេងទៀតដែល កសស បានទិញ។ សម្រាប់ដីនៅតំបន់សេដ្ឋកិច្ចពិសេស កសស បានធ្វើការដោះស្រាយ និងទូទាត់ និងធ្វើការឈូសឆាយ-ចាក់ដីតំបន់នៅជុំវិញ ជាលទ្ធផល កសស ទទួលបានដីសរុបចំនួន ៦៨ ហិកតា។ កសស បានកត់ត្រារាល់ការចំណាយលើការទូទាត់ក្នុងការដោះស្រាយ និងបានធ្វើមូលធនកម្ម ព្រមទាំងកត់ត្រាជាតម្លៃដីក្នុងបញ្ជីគណនេយ្យ និងទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ក្នុងឆ្នាំ២០១២។

## ៦. ទ្រព្យសម្បត្តិវិនិយោគ (ត)

សាច់ប្រាក់បានប្រើសម្រាប់ទិញទ្រព្យសម្បត្តិវិនិយោគ មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ការទិញក្នុងឆ្នាំ (សាច់ប្រាក់ និងមិនមែនសាច់ប្រាក់) | ៥២.១៨២.៧៧៣ | ៥.៦៨៨.១៣៧ |
| តំហយទឹកប្រាក់ត្រូវសងអ្នកផ្គត់ផ្គង់ | - | ៨៨.៧៣០ |
| **សាច់ប្រាក់បានប្រើក្នុងការទិញទ្រព្យសម្បត្តិវិនិយោគ** | ៥២.១៨២.៧៧៣ | ៥.៧៧៦.៨៦៧ |

*ដំណើរការវាយតម្លៃ (បច្ចេកទេស/ធាតុចូល) ប្រើក្នុងការកំណត់តម្លៃសមស្រប*

ទ្រព្យសម្បត្តិវិនិយោគត្រូវបានវាយតម្លៃ ដោយក្រុមហ៊ុនវាយតម្លៃដែលមានការទទួលស្គាល់ដោយ និយ័តករមូលបត្រកម្ពុជា។ គណៈគ្រប់គ្រងជឿជាក់ថា មិនមានការផ្លាស់ប្តូរសំខាន់ៗលើការវាយតម្លៃទេ គិតមិនត្រឹមកាលបរិច្ឆេទរាយការណ៍។

តម្លៃសមស្របកម្រិត៣ របស់ទ្រព្យសម្បត្តិវិនិយោគ ត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ សម្រាប់ដីធ្លី និងវិធីសាស្ត្រថ្លៃដើមសម្រាប់អគារ។ ដីធ្លីត្រូវបានវាយតម្លៃដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបការលក់ទៅនឹងដីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ តម្លៃទាំងនេះត្រូវបានកែតម្រូវសម្រាប់ភាពខុសគ្នា ក្នុងការសន្មតសំខាន់ៗ ដូចជា ទំហំ ទីតាំង ស្ថានភាព និងកត្តាពាក់ព័ន្ធផ្សេងទៀត។

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| តម្លៃដីធ្លី វាស់វែងតាមតម្លៃសមស្រប | ២.៩៦៣.៤១៤.៧០៣ | ២.៩៦៣.៤១៤.៧០៣ |
| តម្លៃអគារ វាស់វែងតាមតម្លៃសមស្រប | ១១៧.៨១១.៧៥០ | ១១៧.៨១១.៧៥០ |
| | ៣.០៨១.២២៦.៤៥៣ | ៣.០៨១.២២៦.៤៥៣ |

ចំនួនទឹកប្រាក់ដូចខាងក្រោមត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងដែលទទួលបានពីអាជីវកម្មលើទ្រព្យសម្បត្តិវិនិយោគ៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ចំណូលពីការជួល | ៥.០៩៨.៣១៣ | ៤.៤៣៦.២៦៣ |
| ចំណាយរំលស់ | (៣.៥០៩.១៦៩) | (៣.៨៦៤.៤៤៤) |
| ចំណាយប្រតិបត្តិការផ្ទាល់ ដែលកើតចេញពីទ្រព្យសម្បត្តិវិនិយោគ ដែលបង្កើតឱ្យមានចំណូលពីការជួល | (២.៣៥៤.៧០០) | (៣.៣៤២.៩៩៤) |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ៦. ទ្រព្យសម្បត្តិវិនិយោគ (ត)

ការទូទាត់ភតិសន្យានាពេលអនាគតក្នុងចំនួនអប្បបរមាចំពោះការជួលទ្រព្យសម្បត្តិវិនិយោគមានដូចខាងក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ក្នុងអំឡុង១ឆ្នាំ | ២៤.១៣៦.៥៩០ | ១៥.៤៥០.៣៦៥ |
| ចន្លោះពី១ឆ្នាំ ទៅ ២ឆ្នាំ | ៧.១០៣.០១០ | ៨.៣៧២.០០០ |
| ចន្លោះពី២ឆ្នាំ ទៅ ៣ឆ្នាំ | ៥.៥៦២.០១៨ | ៧.១២៤.២៥០ |
| ចន្លោះពី៣ឆ្នាំ ទៅ ៤ឆ្នាំ | ១.៥៩៧.១៧៤ | ៥.៥៧៨.៦៥០ |
| ចន្លោះពី៤ឆ្នាំ ទៅ ៥ឆ្នាំ | ១.៥៩៧.១៧៤ | ១.៦០១.៩៥០ |
| លើសពី៥ឆ្នាំ | ៤២.៦៦៧.២២៧ | ៣៤.៨១២.៤៣៤ |
| | ៨២.៦៦៣.១៩៣ | ៧២.៩៣៩.៦៤៩ |

## ៧. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ<br>ពាន់រៀល |
|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | |
| ថ្លៃដើម | ១១.៦៩៣.៧៣៧ |
| រំលស់បង្គរ | (៩.៨៨៧.០៤៣) |
| តម្លៃចុះបញ្ជីសុទ្ធ | ១.៨០៦.៦៩៤ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១.៨០៦.៦៩៤ |
| ទិញបន្ថែម | ៣១២.៩២០ |
| រំលស់ | (១.២១១.៦៦៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៩០៧.៩៤៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | |
| ថ្លៃដើម | ១២.០០៦.៦៥៧ |
| រំលស់បង្គរ | (១១.០៩៨.៧១២) |
| តម្លៃចុះបញ្ជីសុទ្ធ | ៩០៧.៩៤៥ |

## ៨. សន្និធិ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| សម្ភារប្រើប្រាស់ | ៣៨.០៧៦.៧៤៧ | ៣៧.៨៥០.៨២៨ |
| សម្ភារងាយឆេះ | ១.៧៥២.៦១០ | ១.១២២.៩២០ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន | ២.១៥៤.៤១១ | ២.៤៥៨.៤១៣ |
| | ៤១.៩៨៣.៧៦៨ | ៤១.៤៣២.១៦១ |
| សំវិធានធនសម្រាប់ការថយចុះតម្លៃសន្និធិ | (៨៥.៦៣៧) | (៨៥.៦៣៧) |
| | ៤១.៨៩៨.១៣១ | ៤១.៣៤៦.៥២៤ |

## ៩. ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

រាជរដ្ឋាភិបាលកម្ពុជាមានទស្សនៈវិស័យ និងឆន្ទៈមោះមុតក្នុងការសាងសង់ព្រែកជីកហ្វូណនតេជោ សម្រាប់ការពង្រីកការដឹកជញ្ជូនឡជីស្ទីកតាមផ្លូវទឹក ទៅកាន់កំពង់ផែសមុទ្រអន្តរជាតិរបស់ប្រទេសកម្ពុជា ដោយបានសម្ពោធការសាងសង់គម្រោងព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤ ។ ទន្ទឹមគ្នានោះ រាជរដ្ឋាភិបាលបានចង្អុលបង្ហាញអោយសហគ្រាសសាធារណៈរបស់រដ្ឋចំនួនពីរ (កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញ) ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ដែលក្នុងនោះ កសស មានទុនវិនិយោគចំនួន ២៦% ហើយបានចុះកិច្ចព្រមព្រៀងបណ្តាក់ទុនរួមគ្នាជាមួយក្រុមហ៊ុន Funan Techo Inland Waterways and Logistics Company Limited (FTIWL)។ FTIWL បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៃប្រទេសកម្ពុជា ហើយសមាមាត្រនៃផលប្រយោជន៍កម្មសិទ្ធិគឺដូចគ្នាទៅនឹងសមាមាត្រនៃសិទ្ធិបោះឆ្នោតដែលបានកាន់កាប់។ FTIWL ដំណើរការព្រែកជីកហ្វូណនតេជោ ដើម្បីពង្រីកការដឹកជញ្ជូនឡជីស្ទីកផ្លូវទឹកក្នុងប្រទេស ទៅកាន់កំពង់ផែសមុទ្រអន្តរជាតិ។ ព្រែកជីកហ្វូណនតេជោនឹងចូលរួមយ៉ាងសំខាន់សម្រាប់គាំទ្រ កសស អោយមានលក្ខណៈ Multimodal Transport ក្នុងការដឹកជញ្ជូនកាន់តែសម្បូរបែប រួមមាន ផ្លូវគោក ផ្លូវអាកាស ផ្លូវទឹក ផ្លូវដែក ដើម្បីអោយ កសស ឆាប់ឈានសម្រេចបានមាត្រដ្ឋានសេដ្ឋកិច្ចមួយដែលអាចប្រកួតប្រជែងខ្ពស់ និងទាក់ទាញនាវាធំៗអោយចូលចត ដោយពុំបាច់ផ្ទេរ-ផ្ទុកនៅកំពង់ផែមេ ក្នុងតំបន់នៃប្រទេសផ្សេង។ លក្ខណៈសម្បត្តិនៃការបណ្តាក់ទុន គឺជាការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។ កសស បានចាប់ផ្តើមបង់ដើមទុននៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ FTIWL កំពុងស្ថិតក្នុងដំណាក់កាលចាប់ផ្តើម និងមិនមានសកម្មភាពអាជីវកម្មជាដុំកំភួនទេ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១០. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | ២០២៥ ពាន់រៀល | ២០២៤ ពាន់រៀល |
|---|---:|---:|
| គណនីអតិថិជនពាណិជ្ជកម្ម | ៦៦.១២៩.៩២៩ | ៤៧.៩៥៣.៣៣០ |
| សំវិធានធនសម្រាប់ខាតឥណទានរំពឹងទុក | (១៧៤.៧៨៥) | (១០៤.១៥៧) |
| **គណនីអតិថិជនពាណិជ្ជកម្ម - សុទ្ធ** | ៦៥.៩៥៥.១៤៤ | ៤៧.៨៤៩.១៧៣ |
| | | |
| បុរេប្រទានឱ្យអ្នកផ្គត់ផ្គង់ | ៦៥.៩១៩.៤៩២ | ៦៨.៤៩៣.៤៧៣ |
| បុរេប្រទានឱ្យភាគីពាក់ព័ន្ធ (ក) | ៦៩.៧៧២.៧៣៦ | - |
| បុរេប្រទានឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (ខ) | ១.២២១.៣០៣ | ១.២២១.៣០៣ |
| ចំណាយបង់មុន | ៨៥.៤៣៥ | ៨៥.៥១៣ |
| **គណនីអតិថិជនផ្សេងៗ** | ១៣៦.៩៩៨.៩៦៦ | ៦៩.៨០០.២៨៩ |
| | | |
| | ២០២.៩៥៤.១១០ | ១១៧.៦៤៩.៤៦២ |

អតិថិជនរបស់ កសស គឺជាភ្នាក់ងារដឹកជញ្ជូនជាតិ និងអន្តរជាតិនានា។ គណនីអតិថិជនពាណិជ្ជកម្មគឺជាគណនីមានរយៈពេលខ្លី។

(ក) នេះគឺបុរេប្រទានឱ្យក្រុមហ៊ុន ហ្វូណន តេជោ ខាណែល អ៊ិនវេសម៉ិន ឯ.ក ។ បុរេប្រទាននេះមិនមានការធានាទេ និងត្រូវទទួលបានមកវិញ តាមតម្រូវការ។

(ខ) នេះគឺជាសមតុល្យបុរេប្រទានសាច់ប្រាក់នៅសល់ ដែលត្រូវប្រគល់ឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (ហៅកាត់ថា MoPWT) យោងទៅតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។ ប្រាក់បុរេប្រទានត្រូវបានប្រើប្រាស់ សម្រាប់ការសាងសង់អគារការិយាល័យរបស់ MoPWT ។

## ១១. ប្រាក់បញ្ញើនៅធនាគារ

| | ២០២៥ ពាន់រៀល | ២០២៤ ពាន់រៀល |
|---|---:|---:|
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ៩១.៤៥៦.១៣៩ | ១២០.៣៨២.១២៣ |
| បង្គរការប្រាក់ត្រូវទទួល | ២.៥៩៦.៩៤៩ | ៣.៦១៦.៧៤៧ |
| | ៩៤.០៥៣.០៨៨ | ១២៣.៩៩៨.៨៧០ |
| | | |
| សំវិធានធនសម្រាប់ខាតឥណទានរំពឹងទុក | (១.៧៧៧.៧៥៤) | (១៨៤.៦៩៥) |
| | ៩២.២៧៥.៣៣៤ | ១២៣.៨១៤.១៧៥ |

## ១១. ប្រាក់បញ្ញើនៅធនាគារ (ត)

ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ គឺជាប្រាក់បញ្ញើមានកាលកំណត់ ដែលបានផ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងរយៈពេលពី៦ខែ ទៅ ២៤ខែ (២០២៤ ៖ ៦ខែ ទៅ ២៤ខែ) ហើយទទួលបានការប្រាក់ចន្លោះពី ៣,២៥% ទៅ ៦,៧៥% ក្នុងមួយឆ្នាំ (២០២៤ ៖ ៤,00% ទៅ ៦,៧៥% ក្នុងមួយឆ្នាំ)។

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| រយៈពេលខ្លី | ៩២.២៧៥.៣៣៤ | ១១៧.៣១១.២៤២ |
| រយៈពេលវែង | - | ៦.៥០២.៩៣៣ |
| | ៩២.២៧៥.៣៣៤ | ១២៣.៨១៤.១៧៥ |

## ១២. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ២៨៨.៩៦៦ | ១៧៦.១៩៨ |
| សាច់ប្រាក់នៅធនាគារ | ១០១.៨៦៣.៥១៧ | ២៧.០០៩.៦៦៩ |
| | ១០២.១៥២.៤៨៣ | ២៧.១៨៥.៨៦៧ |

សាច់ប្រាក់នៅធនាគារគឺសាច់ប្រាក់ក្នុងគណនីចរន្ត ដែលមានអត្រាការប្រាក់ចាប់ពី 0% ទៅ ៤,00% ក្នុងមួយឆ្នាំ (២០២៤ ៖ គ្មាន) និងផ្ញើនៅធនាគារពាណិជ្ជក្នុងស្រុក។

## ១៣. ដើមទុន និងបុព្វលាភភាគហ៊ុន

| | **ភាគហ៊ុនប្រភេទ ‘ក’ (*)** | | **ភាគហ៊ុនប្រភេទ ‘ខ’ (**)** | | **ភាគហ៊ុនប្រភេទ ‘គ’ (***)** | | **បុព្វលាភភាគហ៊ុន** | **សរុប** |
|---|---|---|---|---|---|---|---|---|
| | **ចំនួនភាគហ៊ុន** | **ពាន់រៀល** | **ចំនួនភាគហ៊ុន** | **ពាន់រៀល** | **ចំនួនភាគហ៊ុន** | **ពាន់រៀល** | **ពាន់រៀល** | **ពាន់រៀល** |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | ៥១៨.០១៨.០៦៣ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ៣៦៤.៥៣០.៨៦១ | ៣៦៤.៥៣០.៨៦១ | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ | ៦៧.៧១៥.២៣៥ | ៥១៨.០១៨.០៦៣ |

(*) យោងតាមមាត្រា ១១ នៃលក្ខន្តិកៈ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ដែលត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ដើមទុនចំនួន ៤៥០.៣០២.៨២៨.០០០ រៀល ត្រូវបានបែងចែកទៅជាភាគហ៊ុនប្រភេទ ‘ក’ ចំនួន ៣៦៤.៥៣០.៨៦១ ហ៊ុន ភាគហ៊ុនប្រភេទ ‘ខ’ ចំនួន ៦៤.៣២៨.៩៧៥ ហ៊ុន និងភាគហ៊ុនប្រភេទ ‘គ’ ចំនួន ២១.៤៤២.៩៩២ ហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ទាំងភាគហ៊ុនប្រភេទ ‘ក’ ភាគហ៊ុនប្រភេទ ‘ខ’ ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគហ៊ុនប្រភេទ ‘គ’ ត្រូវបានកាន់កាប់ដោយវិនិយោគិនសាធារណៈ។ ភាគហ៊ុនប្រភេទ ‘ក’ មិនទទួលបានភាគលាភទេ ហើយក៏មិនមានសិទ្ធិបោះឆ្នោតដែរ លើកលែងតែលក្ខខណ្ឌមួយចំនួនដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈ។ ភាគហ៊ុនប្រភេទ ‘ខ’ និងភាគហ៊ុនប្រភេទ ‘គ’ មានសិទ្ធិបោះឆ្នោត និងទទួលភាគលាភ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១៣. ដើមទុន និងបុព្វលាភភាគហ៊ុន (ត)

(**) សេចក្តីលម្អិតនៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងអ្នកកាន់កាប់ មានដូចខាងក្រោម៖

| | ភាគរយ | ចំនួនភាគហ៊ុន | គិតជាពាន់រៀល |
|---|---|---|---|
| ភាគហ៊ុនប្រភេទ 'ខ' កាន់កាប់ដោយ | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ៧៥,០០% | ៦៤.៣២៨.៩៧៥ | ៦៤.៣២៨.៩៧៥ |
| ភាគហ៊ុនប្រភេទ 'គ' (***) ៖ | | | |
| ក្រុមហ៊ុន Kamigumi Co., Ltd. | ១៣,០០% | ១១.១៥០.៣២៤ | ១១.១៥០.៣២៤ |
| ក្រុមហ៊ុន KOBE-OSAKA International Port Corporation | ២,៥០% | ២.១៤៤.៣០០ | ២.១៤៤.៣០០ |
| គម្រោងភាគហ៊ុនរបស់បុគ្គលិក | ២,៥០% | ២.១៤៤.២៩៩ | ២.១៤៤.២៩៩ |
| វិនិយោគិនសាធារណៈ | ៧,០០% | ៦.០០៤.០៦៩ | ៦.០០៤.០៦៩ |
| | ២៥,០០% | ២១.៤៤២.៩៩២ | ២១.៤៤២.៩៩២ |
| | ១០០,០០% | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |

(***) ភាគហ៊ុនប្រភេទ 'គ'ដែលបានបោះផ្សាយ មានចំនួន ២១.៤៤២.៩៩២ ដែលមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ 'គ'ដែលបានបោះផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់។

## ១៤. ទុនបម្រុងផ្សេងៗ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា | ៦១.៧០២.៦៤៤ | ៤៩.៥០៦.០៩៤ |
| បន្ថែម៖ ទុនបម្រុងទូទៅ | ៦.៣៣៦.៦៨១ | ៦.០៩៨.២៧៥ |
| បន្ថែម៖ ទុនបម្រុងស្របច្បាប់ | ៦.៣៣៦.៦៨១ | ៦.០៩៨.២៧៥ |
| | ១២.៦៧៣.៣៦២ | ១២.១៩៦.៥៥០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | ៧៤.៣៧៦.០០៦ | ៦១.៧០២.៦៤៤ |

មាត្រា៦៥ នៃលក្ខន្តិកៈចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ បានចែងថា ប្រាក់ចំណេញប្រចាំឆ្នាំរបស់ កសស បន្ទាប់ពីទូទាត់ការខាតយោងរួច (ប្រសិនបើមាន) ត្រូវបានបែងចែកទៅក្នុងទុនបម្រុងទូទៅចំនួន ៥% និងទុនបម្រុងតាមច្បាប់ចំនួន ៥% ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ១៥. ប្រាក់កម្ចី

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P3 (i) | ២២.៦៤៧.៣១៦ | ២៧.២០៧.៦៩៤ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 (i) | ៦៦.៨៦៩.០១៨ | ៧៤.៥១៦.៣០៧ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 (i) | ៣.៤៨១.៧២៥ | ៣.៧៧៥.៨២២ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 (i) | ៦៦.៨២៥.៣៣៧ | ៦៩.១១៤.៦៩០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P10 (i) | ១២៧.៣៨៥.៤៧០ | ១៣៤.៩៤៦.៩២៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P21 (i) | ២៨៥.៨៣០.៨១៥ | ៩៤.៦៩៣.៤៣៤ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P27 (i) | ១៩.៩៧១.៨៤៥ | - |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ប្រាក់កម្ចីរយៈពេលវែង (ii) | ៧០.៣៧៧.៣៧៣ | - |
| | ៦៦៣.៣៨៨.៨៩៩ | ៤០៤.២៥៤.៨៧៦ |

(i) ប្រាក់កម្ចី MoEF – (JBIC) និង (JICA)

រាជរដ្ឋាភិបាលកម្ពុជា (RGC) តំណាងដោយ MoEF បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចី ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និង Japan Bank for International Cooperation (JBIC) ដើម្បីគាំទ្រដល់គម្រោងពង្រីកអាជីវកម្មរបស់ កសស ។ កសស បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីដាច់ដោយឡែកពីគ្នាជាមួយ RGC តំណាងដោយ MoEF ជាមួយនឹងការរៀបចំដែល JICA និង JBIC នឹងធ្វើការទូទាត់ដោយផ្ទាល់ទៅឱ្យអ្នកផ្គត់ផ្គង់របស់ កសស។ ការទូទាត់សងប្រាក់កម្ចីធ្វើឡើងដោយ កសស ត្រូវទូទាត់សងទៅ MoEF តាមកាលវិភាគសងប្រាក់។

(ii) ប្រាក់កម្ចីពី MoEF

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ប្រាក់កម្ចីឱ្យ កសស ដើម្បីវិនិយោគលើក្រុមហ៊ុន ហ្វូណន តេជោ ខាណែល អ៊ិនវេសមិន ឯ.ក ក្នុងគោលបំណងគាំទ្រ និងចូលរួមក្នុងគម្រោងព្រែកជីកហ្វូណនតេជោ។

## ១៥. ប្រាក់កម្ចី (ត)

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះ មានដូចខាងក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| **រយៈពេលខ្លី** | | |
| មិនលើសមួយឆ្នាំ | ២៧.២៥៨.៩៨៥ | ២៦.៥២៧.៧០៦ |
| **រយៈពេលវែង** | | |
| ពីមួយឆ្នាំ ទៅពីរឆ្នាំ | ៣២.០៤៨.៩៩៨ | ២៤.៣៧៥.២៧២ |
| ពីពីរឆ្នាំ ទៅបីឆ្នាំ | ៣១.៥០៥.២៩៥ | ២៤.៣៧៥.២៧២ |
| ពីបីឆ្នាំ ទៅបួនឆ្នាំ | ៣១.៥០៥.២៩៥ | ២៤.៣៧៥.២៧២ |
| ពីបួនឆ្នាំ ទៅប្រាំឆ្នាំ | ២៧.០៤៤.៩៩៧ | ២៤.៣៧៥.២៧២ |
| លើសប្រាំឆ្នាំឡើងទៅ | ៥១៤.០២៥.៣២៩ | ២៨០.២២៦.០៨២ |
| | ៦៣៦.១២៩.៨១៤ | ៣៧៧.៧២៧.១៧០ |
| | ៦៦៣.៣៨៨.៧៩៩ | ៤០៤.២៥៤.៨៧៦ |

តម្លៃសមស្របត្រូវបានគណនាអាស្រ័យទៅតាមលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានាពេលអនាគត ដែលត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាប្រាក់កម្ចីនាពេលបច្ចុប្បន្ន។ វាត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតទី៣ ក្នុងកម្រិតតម្លៃសមស្រប ដោយសារមានការរួមបញ្ចូលនូវធាតុចូលដែលមិនអាចសង្កេតបាន រួមមាន ហានិភ័យឥណទានរបស់ភាគីដៃគូជាដើម។

តម្លៃយោងនៃប្រាក់កម្ចី គឺមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃប៉ាន់ស្មានសមស្របប៉ាន់ស្មាន ដោយសារធាតុទាំងនេះមិនមានភាពប្រែប្រួលជាសារវន្ត ទៅតាមការប្រែប្រួលអត្រាការប្រាក់ទីផ្សារ។

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណគោល មានដូចខាងក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ប្រាក់យ៉េនជប៉ុន (JPY) | ៥២៦.១៤៤.៤២៥ | ៣២៩.៧៣៨.៥៦៩ |
| ប្រាក់ដុល្លារអាមេរិក (US$) | ១៣៧.២៤៤.៤៧៤ | ៧៤.៥១៦.៣០៧ |
| | ៦៦៣.៣៨៨.៨៩៩ | ៤០៤.២៥៤.៨៧៦ |

## ១៥. ប្រាក់កម្ចី (ត)

អត្រាការប្រាក់ប្រចាំឆ្នាំ មានដូចខាងក្រោម៖

| | **២០២៥** | **២០២៤** |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P3 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ៣,៧០% | ៣,៧០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៣,០០% | ៣,០០% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ២,៦៥% | ២,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P10 | ១,៦៥% | ១,៦៥% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P21 | ១,២៦% | ១,២៦% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P27 | ១,៣៦% | - |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ប្រាក់កម្ចីរយៈពេលវែង | ២,០០% | - |

## ១៦. ភាគពុកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ ក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ៩៦.៣៣៨.៥២៨ | ៧៧.៨៩០.៩២៥ |
| ចំណាយលើអត្ថប្រយោជន៍បច្ចុប្បន្ន | ៣.០២៧.២២៤ | ១.៨១៨.០៨៨ |
| ចំណាយហិរញ្ញវត្ថុ | ៥.១០៦.៧៤៥ | ៤.៨៥៧.៨១៥ |
| ចំណាយលើអត្ថប្រយោជន៍អតីតភាពការងារ | - | ៨.២៨៣ |
| អត្ថប្រយោជន៍បានបង់ | (៥.៦១៨.៦៧១) | (៤.៥៧៣.៤០៩) |
| ខាតពីការវាយតម្លៃឡើងវិញ ដែលកើតពីបម្រែបម្រួលការសន្មតនៃការវាយតម្លៃ និង បទពិសោធន៍នៃការធ្វើនិយ័តកម្ម | - | ១៦.៣៣៦.៨២៦ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ៩៨.៨៥៣.៨២៦ | ៩៦.៣៣៨.៥២៨ |

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| រយៈពេលខ្លី | ៦.០៦១.១៥៦ | ៥.១៦២.៤៤៣ |
| រយៈពេលវែង | ៩២.៧៩២.៦៧០ | ៩១.១៧៦.០៨៥ |
| | ៩៨.៨៥៣.៨២៦ | ៩៦.៣៣៨.៥២៨ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១៦. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ ដែលត្រូវបានទទួលស្គាល់នៅក្នុងគណនីប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និង ចំណាយពាក់ព័ន្ធ និងគណនីការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ឡើងវិញ នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ចំណាយលើអត្ថប្រយោជន៍បច្ចុប្បន្ន | ៣.០២៧.២២៤ | ១.៨១៨.០៨៤ |
| ចំណាយការប្រាក់ | ៥.១០៦.៧៤៥ | ៤.៨៥៧.៨១៥ |
| ចំណាយលើអត្ថប្រយោជន៍អតីតភាពការងារ | - | ៨.២៨៣ |
| ចំនួនទឹកប្រាក់ទទួលស្គាល់នៅក្នុង ចំណេញ-ខាត (កំណត់សម្គាល់ ២១) | ៨.១៣៣.៩៦៩ | ៦.៦៨៤.១៨៦ |

ការសន្មតសំខាន់ជាចម្បង មានដូចខាងក្រោម៖

| | **២០២៥** | **២០២៤** |
|---|---|---|
| អត្រាអប្បហារក្នុងមួយឆ្នាំ | ៥,៥% | ៥,៥% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ក្នុងមួយឆ្នាំ | ៥,០% | ៥,០% |
| អត្រាបម្រែបម្រួលបុគ្គលិកក្នុងមួយឆ្នាំ | 0,៥% | 0,៥% |
| អត្រាមរណៈ | ១០០% នៃតារាងមរណភាពធម្មតា ឆ្នាំ ២០១៧ របស់ប្រទេសថៃ | ១០០% នៃតារាងមរណភាពធម្មតា ឆ្នាំ ២០១៧ របស់ប្រទេសថៃ |
| អត្រាពិការភាព | ១០% នៃអត្រាមរណៈមុនពេលចូលនិវត្ត | ១០% នៃអត្រាមរណៈមុនពេលចូលនិវត្ត |

តារាងខាងក្រោមនេះបង្ហាញពីបម្រែបម្រួលនៃកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ ចំពោះការប្រែប្រួលការសន្មតការគណនា ដូចខាងក្រោម៖

| **២០២៥** | **ការសន្មត** | **គិតជាពាន់រៀល** |
|---|---|---|
| *អត្រាអប្បហារ* | | |
| ការសន្មតជាមូលដ្ឋាន | ៥,៥០% | ៩៧.៤០០.៦២១ |
| +១,00% | ៦,៥០% | ៨៦.៩៩៧.២៩៧ |
| -១,00% | ៤,៥០% | ១១០.២០២.៨១០ |
| | | |
| *អត្រាកំណើនប្រាក់បៀវត្សរ៍* | | |
| ការសន្មតជាមូលដ្ឋាន | ៥,00% | ៩៧.៤០០.៦២១ |
| +១,00% | ៦,00% | ១០២.៥២៦.៧៤៦ |
| -១,00% | ៤,00% | ៩២.៩៦០.៩៨៤ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១៦. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

| **២០២៤** | **ការសន្មត** | **គិតជាពាន់រៀល** |
|---|---|---|
| *អត្រាអប្បហារ* | | |
| ការសន្មតជាមូលដ្ឋាន | ៥,៥០% | ៩៦.៣៣៨.៥២៨ |
| +១,០០% | ៦,៥០% | ៨៦.២៤៣.៤២៣ |
| -១,០០% | ៤,៥០% | ១០៨.៧៣០.៩៣១ |
| | | |
| *អត្រាកំណើនប្រាក់បៀវត្សរ៍* | | |
| ការសន្មតជាមូលដ្ឋាន | ៥,០០% | ៩៦.៣៣៨.៥២៨ |
| +១,០០% | ៦,០០% | ១០០.៧២៩.៧៥៦ |
| -១,០០% | ៤,០០% | ៩២.៥១១.១០៧ |

## ១៧. ចំណូលពន្យារ

កសស បានជួលទ្រព្យសម្បត្តិវិនិយោគរបស់ខ្លួន ដែលមានរយៈពេលជួលចន្លោះពី២ឆ្នាំ ទៅ៥០ឆ្នាំ និងមាន រយៈពេលអនុគ្រោះ១៦ខែ។ ការបង់ប្រាក់ជាមុនត្រូវបានកត់ត្រាខាងខ្វង់ឥណទាន នៅក្នុងរបាយការណ៍ចំណេញ-ខាត និង លទ្ធផលលម្អិតផ្សេងៗ តាមមូលដ្ឋានថេរ ក្នុងរយៈពេលជួល។

បម្រែបម្រួលនៃប្រាក់ចំណូលពន្យារក្នុងឆ្នាំ មានដូចខាងក្រោម៖

| | **២០២៥ ពាន់រៀល** | **២០២៤ ពាន់រៀល** |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ១៧.២៤២.១៨០ | ១៤.៥១៧.២៧៤ |
| ទឹកប្រាក់បានទទួលអំឡុងឆ្នាំ | ១.៨៧៣.៩១៩ | ៦.១៧៣.៧៦៨ |
| បានទទួលស្គាល់ជាចំណូលបានពីការជួល | (២.៤៩៨.៦៦០) | (៣.២០៥.៩៨៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណបរទេស | (៥៧.៣៥២) | (២៤២.៨៧៩) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | ១៦.៥៦០.០៨៧ | ១៧.២៤២.១៨០ |
| | | |
| រយៈពេលខ្លី | ១.៦៨៧.៥១២ | ១.៣៣៦.៦៦១ |
| រយៈពេលវែង | ១៤.៨៧២.៥៧៥ | ១៥.៩០៥.៥១៩ |
| | ១៦.៥៦០.០៨៧ | ១៧.២៤២.១៨០ |

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ១៨. សម្បទានពីរាជរដ្ឋាភិបាល

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---:|---:|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ៤៧.១១១.៧០៤ | ៥០.៣២៦.៦៣៤ |
| កត់ត្រាបញ្ចេញទៅជាចំណេញ-ខាត | (៣.២១៤.៩៣០) | (៣.២១៤.៩៣០) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | ៤៣.៨៩៦.៧៧៤ | ៤៧.១១១.៧០៤ |
| | | |
| រយៈពេលខ្លី | ៣.២១៤.៩៣០ | ៣.២១៤.៩៣០ |
| រយៈពេលវែង | ៤០.៦៨១.៨៤៤ | ៤៣.៨៩៦.៧៧៤ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | ៤៣.៨៩៦.៧៧៤ | ៤៧.១១១.៧០៤ |

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ កសស បានទទួលសំណង់អគារនៃស្ថានីយដឹកទំនិញកុងតឺន័រ ដែលតម្លៃសំណង់មានចំនួន ៥.១៥៦.៣៣៩ ពាន់រៀល (ស្មើនឹង ១.២៧១.៩១៤ ដុល្លារអាមេរិក) ពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ជាសម្បទានក្រោមគោលបំណងរួមចំណែកដល់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ កសស បានទទួលស្គាល់សំណង់អគារនៃស្ថានីយដឹកទំនិញកុងតឺន័រ ជាអគារដែលស្ថិតក្រោមគណនីទ្រព្យសម្បត្តិ និងបរិក្ខារ និងគណនីសម្បទានពីរាជរដ្ឋាភិបាលពន្យារ ទៅតាមតម្លៃសំណង់។ រំលស់ស្ថានីយដឹកទំនិញកុងតឺន័រ និងចំណូលសម្បទានដែលពាក់ព័ន្ធ នឹងត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មក្នុងរយៈពេល៣០ឆ្នាំ។ មិនមានលក្ខខណ្ឌដែលមិនបានបំពេញ ឬ យថាភាពភ្ជាប់ទៅនឹងសម្បទាននោះទេ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ កសស បានទទួលបរិក្ខារកំពង់ផែសមុទ្រជារថលើកដាក់ចល័ត នៅគែមផែចំនួនពីរគ្រឿង ដែលមានតម្លៃ ៤៥.៦៤៥.៧៧៣ ពាន់រៀល (ស្មើនឹង ១១.០៧៩.០៧១ ដុល្លារអាមេរិក) ពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ដែលជាជំនួយឥតសំណង ក្នុងគោលបំណងចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ កសស បានទទួលស្គាល់រថលើកដាក់ចល័តនៅគែមផែជាបរិក្ខារកំពង់ផែសមុទ្រ ដែលស្ថិតក្រោមគណនីទ្រព្យសម្បត្តិ និងបរិក្ខារ និងសម្បទានពីរាជរដ្ឋាភិបាលពន្យារ ទៅតាមតម្លៃរបស់ឧបករណ៍។ រំលស់នៃរថលើកដាក់ចល័តនៅគែមផែ និងចំណូលសម្បទានដែលពាក់ព័ន្ធ នឹងត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មក្នុងរយៈពេល១៥ឆ្នាំ។ មិនមានលក្ខខណ្ឌដែលមិនបានបំពេញ ឬ យថាភាព ភ្ជាប់ទៅនឹងសម្បទាននោះទេ។

យោងតាម 'លិខិតប្តូរសារ' រវាងរាជរដ្ឋាភិបាលកម្ពុជា (ភាគីទទួល) និងរាជរដ្ឋាភិបាលជប៉ុន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ផលិតផល និង/ឬ សេវាកម្មដែលផ្តល់ឱ្យក្រោមសម្បទាន ត្រូវបានរក្សាទុក និងប្រើប្រាស់យ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាព សម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម និងមិនសម្រាប់គោលបំណងយោធា។ លើសពីនេះ ផលិតផល និង/ឬ សេវាកម្មក្រោមជំនួយត្រូវបានប្រើប្រាស់ជាគោលការណ៍ ដោយអ្នកប្រើប្រាស់ចុងក្រោយដែលរួមទាំងភាគីទទួលផងដែរ សម្រាប់គោលបំណងមិនមែនពាណិជ្ជកម្ម។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

## ១៩. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---:|---:|
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | ២.២៦៧.៤៥០ | ៥.៨៤១.២៧២ |
| ទឹកប្រាក់ត្រូវបង់ឱ្យក្រុមហ៊ុនម៉ៅការ | ៦៦.៣៨១.១៤០ | ១៩.៧៧០.៥៨១ |
| ប្រាក់រង្វាន់បង្គរ | ៣៤.៧៤៦.៣៨១ | ២៤.៦៥២.៦២៥ |
| ការចូលបរិច្ចាគក្នុងមូលនិធិសង្គមបង្គរ | ១៣.០១៧.៦៩៧ | ១៤.៧៧៨.៥៨២ |
| ពន្ធអាករលើតម្លៃបន្ថែមចេញ - សុទ្ធ | ៤.១៨៤.៨៤៥ | ២.៦៨៥.១៦៥ |
| ប្រាក់តម្កល់របស់អតិថិជនដែលអាចបង្វិលសង | ២.៤៥៤.៧៥២ | ១.៩៩៨.៧៣៤ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ១.១០៩.៩៤៦ | ៦៨៥.៣៣០ |
| ប្រាក់រក្សាទុកត្រូវបង់ | ៧៦២.៣០៥ | - |
| បុរេប្រទានទទួលបានពីអតិថិជន | ២៦០.០៤៣ | ៣៦៤.០៨៤ |
| ពន្ធផ្សេងៗត្រូវបង់ | ៨៨៥.២៣១ | - |
| ផ្សេងៗ | ១.៤១១.០៦៦ | ១.៧៨០.៩៥៨ |
| | ១២៧.៤៨០.៨១៦ | ៧២.៥៥៧.៣៣១ |

## ២០. ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---:|---:|
| ចំណូលលើកដាក់ពីនាវា | ២៩៦.៩០១.៤៣៤ | ២២៧.៦៤៣.១៥៥ |
| ចំណូលលើកដាក់លើទីលាន (LO-LO) និងការរក្សាទុកកុងតឺន័រ | ២០៧.៣១៥.៨៧៩ | ១៤៣.៧០២.០៦៨ |
| ចំណូលពីសេវាកម្មផែ | ១០៤.៥៥០.៨០៨ | ៧៨.១៨៥.៦៣៥ |
| ចំណូលផ្សេងៗ | ៤.៣៧៧.១៨២ | ២.០៣០.០៨២ |
| | ៦១៣.១៤៥.៣០៣ | ៤៥១.៥៦០.៩៤០ |
| ពេលវេលានៃការទទួលស្គាល់ចំណូល៖ | | |
| ទទួលស្គាល់នៅពេលតែមួយ | ៥៦៤.១២៧.១៥៨ | ៤២៩.៩០៥.៤៩០ |
| ទទួលស្គាល់តាមដំណាក់កាល | ៤៩.០១៨.១៤៥ | ២១.៦៥៥.៤៥០ |
| | ៦១៣.១៤៥.៣០៣ | ៤៥១.៥៦០.៩៤០ |

## ២១. ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សរ៍បុគ្គលិក | ១១៣.៨៣១.០១០ | ៩១.៥៨១.៨៨២ |
| ប្រាក់រង្វាន់ | ៣៤.៧៤៦.៣៨១ | ២៤.៦៥២.៦២៥ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (កំណត់សម្គាល់ ១៦) | ៨.១៣៣.៩៦៩ | ៦.៦៨៤.១៨៦ |
| ប្រាក់បំណាច់អតីតភាពការងារ | ៦.២២២.២១៦ | ៥.៣៥៧.៤៥០ |
| ចំណាយសន្តិសុខសង្គម | ១.៨៥៧.៤៤០ | ១.៦០៨.០៣៤ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ១.៣៩៦.៨០០ | ១.៣៩៦.៨០០ |
| ប្រាក់ឈ្នួលសម្រាប់ក្រុមហ៊ុនម៉ៅការ | ១២៩.៦៤៦ | ១២៣.០០០ |
| ចំណាយផ្សេងៗ | ៨.៥៣៩.៤៩៧ | ៦.៤២២.៥២៧ |
| | ១៧៤.៨៥៦.៩១៩ | ១៣៧.៨២៦.៥០៤ |

## ២២. ចំណាយសម្ភារផ្គត់ផ្គង់

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ចំណាយលើសម្ភារងាយឆេះ | ៥២.៥៣០.១១៦ | ៤៧.៣១២.១៧៤ |
| គ្រឿងបន្លាស់ | ២៩.២៥៨.១១៣ | ២៩.៧០៦.៨០៤ |
| សម្ភារផ្គត់ផ្គង់ឃ្លាំង | ២៨.១៣៦.៨០៩ | ១៩.៤៩៥.៦៣៤ |
| ប្រេងរំអិល និងប្រេងម៉ាស៊ីន | ៦.២៨៨.៣៣៤ | ៤.៨៧៦.៤១២ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ៥.២០៩.៨៩៧ | ៥.១២៣.៣៦១ |
| ផ្សេងៗ | ២.៨៧៥.១៦១ | ១.៦៤៤.៦៨៤ |
| | ១២៤.២៩៨.៤៣០ | ១០៨.១៥៩.០៦៩ |

## ២៣. ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ ទ្រព្យសម្បត្តិវិនិយោគ និងរំលស់ទ្រព្យសកម្មអរូបី

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ចំណាយរំលស់លើៈ | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ៥) | ៦២.៤០៥.៧២៣ | ៤៩.២៧២.៧៣៨ |
| ទ្រព្យសម្បត្តិវិនិយោគ (កំណត់សម្គាល់ ៦) | ៣.៥០៩.១៦៩ | ៣.៨៦៤.៤៤៤ |
| ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ៧) | ១.២១១.៦៦៩ | ១.១៨៥.៦៤៩ |
| | ៦៧.១២៦.៥៦១ | ៥៤.៣២២.៨៧១ |

## ២៤. ចំណាយផ្សេងៗ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| វិភាគទាន និងការបរិច្ចាគ | ២៣.១០៩.៤៧១ | ១៥.៣២៤.៩១០ |
| ទឹកភ្លើង | ៦.៩៧៥.២៧០ | ៦.៣៤០.៥២១ |
| បេសកម្ម | ២.៥១២.៣៦២ | ១.៩១៥.៦៨១ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ២.៤៤១.៦៥៩ | ២.៤៧៩.១៩១ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ២.៣៥៤.៧០០ | ៣.៣៤២.៩៩៤ |
| កម្រៃសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ២.២២៧.៩៣៦ | ១.៨០៣.១៩១ |
| សំវិធានធនសម្រាប់ខាតឥណទានរំពឹងទុក | ១.៦៦៣.៦៨៦ | ១១៦.២៧៦ |
| ការបោះផ្សាយ | ១.៦៣៧.៩៦០ | ១.៤២៣.៤២៣ |
| សម្ភារផ្គត់ផ្គង់ | ១.៤៩១.៨៩៦ | ៨៨៦.៦៧៨ |
| ការទូទាត់សំណងសម្រាប់ការខូចខាតទំនិញ | ១.៣៦២.៧២០ | ២៧៥.០១៤ |
| ការបណ្តុះបណ្តាល និងសិក្ខាសាលា | ៩២៦.៣៧៥ | ១.១៦១.៩២៩ |
| ទំនាក់ទំនង | ៤០៧.៨៨៥ | ៣៩៩.២៦១ |
| សម្ភារថែទាំសុខភាព | ១៩១.៧០៤ | ១៩០.២៣៨ |
| ចំណាយផ្សេងៗ | ៧៦៤.៩៨៦ | ៤០១.៥៧៧ |
| | ៤៨.០៦៨.៦១០ | ៣៦.០៦០.៨៨៤ |

## ២៤. ចំណាយផ្សេងៗ (ត)

កម្រៃខាងក្រោមបានបង់ ឬនឹងត្រូវបង់ឱ្យក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)។ ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា) មិនមែនជាក្រុមហ៊ុនសវនកម្មរបស់ កសស សម្រាប់ឆ្នាំ២០២៤ ទេ។

| | ២០២៥<br>ពាន់រៀល |
|---|---:|
| ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុតាមច្បាប់ | ៤៤២.៨៩៥ |
| សេវាកម្មផ្សេងៗ | គ្មាន |

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---:|---:|
| ចំណូលហិរញ្ញវត្ថុ ៖ | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ៥.៦៨០.៥៩៤ | ៧.១៩២.១២៣ |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស (គ) | ៦.២៣៥.៧៣០ | ៣៤.៥៩៣.៧៥២ |
| | ១១.៩១៦.៣២៤ | ៤១.៧៨៥.៨៧៥ |
| ចំណាយហិរញ្ញវត្ថុ ៖ | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (៧.៦៦៦.៤១១) | (៧.៨៣៩.២៣៨) |
| ចំណាយការប្រាក់លើឥណទានវិបារូបន៍ | (៣៧៣.៣០៤) | (៦៧៩.៩១៩) |
| | (៨.០៣៩.៧១៥) | (៨.៥១៩.១៥៧) |
| ចំណូលហិរញ្ញវត្ថុ - សុទ្ធ | ៣.៨៧៦.៦០៩ | ៣៣.២៦៦.៧១៨ |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗដែលផ្ញើនៅក្នុងធនាគារក្នុងស្រុកក្នុងអំឡុងការិយបរិច្ឆេទ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចីដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការធ្វើហិរញ្ញប្បទានដោយ JICA និង JBIC (កំណត់សម្គាល់ ១៥ និង ២៨)។

(គ) កសស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក (កំណត់សម្គាល់ ១៥)។ ដោយសារតែការឡើងចុះនៃតម្លៃប្រាក់រៀល ធៀបនឹងប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក បណ្តាលឱ្យមានការខាត/ចំណេញជាសារវន្ត លើការប្តូររូបិយប័ណ្ណលើប្រាក់កម្ចីរបស់ កសស។ អត្រាប្តូររូបិយប័ណ្ណ គឺផ្អែកលើអត្រាប្តូររូបិយប័ណ្ណដែលត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា នាដំណាច់ការិយបរិច្ឆេទរាយការណ៍។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ២៥. ចំណូលហិរញ្ញវត្ថុ - សុទ្ធ (ត)

| | **២០២៥** | **២០២៤** |
|---|---|---|
| ប្រាក់យ៉េនជប៉ុន/ប្រាក់រៀល | ២៥,៨៧០ | ២៥,៦១៥ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.០១៣ | ៤.០២៥ |

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល

យោងតាមបទប្បញ្ញត្តិពន្ធកម្ពុជា កសស មានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០%។

## ក. ចំណាយពន្ធលើប្រាក់ចំណូល

សមាសធាតុសំខាន់ៗនៃចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំ មានដូចខាងក្រោមៈ

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| *ចំណាយពន្ធលើប្រាក់ចំណូលទទួលស្គាល់ក្នុងចំណេញក្នុងឆ្នាំ* | | |
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ៤៤.១១៧.១៧៩ | ២០.៩៤៦.១៩២ |
| សំវិធានធនលើសនៃពន្ធលើប្រាក់ចំណេញរបស់ឆ្នាំមុន | (២.១៩៣.៣៨៧) | (៦.៨៤៦.៨៦៦) |
| | ៤១.៩២៣.៧៩២ | ១៤.០៩៩.៣២៦ |
| ពន្ធពន្យារ | ៣.៧៥០.៤៨៣ | ១៣.៧៥៥.០៩៧ |
| **ចំណាយពន្ធលើប្រាក់ចំណូល** | ៤៥.៦៧៤.២៧៥ | ២៧.៨៥៤.៤២៣ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ២៦. ចំណាយពន្ធលើប្រាក់ចំណូល (ត)

### ក. ចំណាយពន្ធលើប្រាក់ចំណូល (ត)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណូលដែលគណនាតាមអត្រាពន្ធលើប្រាក់ចំណូលតាមច្បាប់ ២០% ដូចបានលាតត្រដាងនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ចំណេញតាមគណនេយ្យមុនពន្ធលើប្រាក់ចំណេញ | ២១៧.៦៥៣.២២២ | ១៥៤.៥៨៨.០៥២ |
| ចំណាយពន្ធលើប្រាក់ចំណូលគណនាតាមអត្រា ២០% | ៤៣.៥៣០.៦៤២ | ៣០.៩១៧.៦១០ |
| ផលប៉ះពាល់ពន្ធនៃចំណាយមិនអាចកាត់កង | ៥.៥៨៤.១៦៦ | ១០.៧០២.៤២៩ |
| ផលប៉ះពាល់នៃចំណូលមិនជាប់ពន្ធ | (១.២៤៧.១៤៦) | (៦.៩១៨.៧៥០) |
| សំវិធានធនលើសនៃពន្ធលើប្រាក់ចំណេញរបស់ឆ្នាំមុន | (២.១៩៣.៣៨៧) | (៦.៨៤៦.៨៦៦) |
| **ចំណាយពន្ធលើប្រាក់ចំណូល** | ៤៥.៦៧៤.២៧៥ | ២៧.៨៥៥.៤២៣ |

### ខ. ពន្ធពន្យារជាចំណូល - សុទ្ធ

ពន្ធពន្យារជាទ្រព្យសកម្មនិងបំណុលត្រូវបានកាត់កង នៅពេលដែល កសស មានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងពន្ធទ្រព្យសកម្មក្នុងឆ្នាំជាមួយនឹងបំណុលពន្ធក្នុងឆ្នាំ និងនៅពេលដែលពន្ធពន្យារទាក់ទងនឹងអាជ្ញាធរពន្ធដារតែមួយ។ ចំនួនត្រូវកាត់កង មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ពន្ធពន្យារជាទ្រព្យសកម្ម | ២៦.២៩១.៨៩០ | ២៤.៣៤៤.៤៥៧ |
| ពន្ធពន្យារជាបំណុល | (៧២.៤៥៥.២៧៥) | (៦៦.៧៥៧.៣៥៩) |
| **ពន្ធពន្យារជាចំណូល - សុទ្ធ** | (៤៦.១៦៣.៣៨៥) | (៤២.៤១២.៩០២) |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ២៦. ចំណាយពន្ធលើប្រាក់ចំណូល (ត)

### ខ. ពន្ធពន្យារជាចំណូល - សុទ្ធ (ត)

បម្រែបម្រួលពន្ធពន្យារជាបំណុលសុទ្ធ មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា | (៤២.៤១២.៩០២) | (៣១.៩២៥.១៧០) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៣.៧៥០.៤៨៣) | (១៣.៧៥៥.០៩៧) |
| កត់ត្រាខាងខ្ទង់ឥណទានក្នុងលទ្ធផលលម្អិត | - | ៣.២៦៧.៣៦៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ** | (៤៦.១៦៣.៣៨៥) | (៤២.៤១២.៩០២) |

បម្រែបម្រួលនៃពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ក្នុងអំឡុងឆ្នាំ ដោយមិនគិតពីការទូទាត់សមតុល្យក្នុងយុត្តាធិការដូចគ្នា មានដូចខាងក្រោម៖

### ពន្ធពន្យារជាទ្រព្យសកម្ម៖

| | ភាគពុកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍<br>ពាន់រៀល | ចំណូលពន្យារ<br>ពាន់រៀល | សម្បទានពីរាជរដ្ឋាភិបាល<br>ពាន់រៀល | ភាគពុកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ<br>ពាន់រៀល | សំវិធានធនសម្រាប់ខាតឥណទានរំពឹងទុក<br>ពាន់រៀល | សំវិធានធនសម្រាប់ការថយចុះតម្លៃសន្និធិ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|---|
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | ១៥.៥៧៨.១៨៥ | ២.៩០៣.៤៥៣ | ៩.០៨៥.៦២៣ | ២៤៧.០៣៦ | ៤៦.៧២០ | ១៩.០៨១ | ២៧.៨៨០.០៩៨ |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | ៣.៦៨៩.៥២១ | ១.៥៤៩.១៤០ | (៨.៨០៧.៦៦២) | ១២.០៥៩ | ២៣.២៥៥ | (១.៩៥៤) | (៣.៥៣៥.៦៤១) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ១៩.២៦៧.៧០៦ | ៤.៤៥២.៥៩៣ | ២៧៧.៩៦១ | ២៥៩.០៩៥ | ៦៩.៩៧៥ | ១៧.១២៧ | ២៤.៣៤៤.៤៥៧ |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ | ១៩.២៦៧.៧០៦ | ៤.៤៥២.៥៩៣ | ២៧៧.៩៦១ | ២៥៩.០៩៥ | ៦៩.៩៧៥ | ១៧.១២៧ | ២៤.៣៤៤.៤៥៧ |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | ៥០៣.០៥៩ | ១.៦៣៨.៥៦៨ | (១៣៤.៩៦៥) | (៣៦.៤១៦) | (២២.៨១៣) | - | ១.៩៤៧.៤៣៣ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | ១៩.៧៧០.៧៦៥ | ៦.០៩១.១៦១ | ១៤២.៩៩៦ | ២២២.៦៧៩ | ៤៧.១៦២ | ១៧.១២៧ | ២៦.២៩១.៨៩០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ២៦. ចំណាយពន្ធលើប្រាក់ចំណូល (ត)

## ខ. ពន្ធពន្យារជាបំណុល - សុទ្ធ (ត)

**ពន្ធពន្យារជាបំណុលៈ**

| | រំលស់ពន្លឿន<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | (៥៩.៨០៥.២៦៨) | (៥៩.៨០៥.២៦៨) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៦.៩៥២.០៩១) | (៦.៩៥២.០៩១) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | (៦៦.៧៥៧.៣៥៩) | (៦៦.៧៥៧.៣៥៩) |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ | (៦៦.៧៥៧.៣៥៩) | (៦៦.៧៥៧.៣៥៩) |
| កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | (៥.៦៩៧.៩១៦) | (៥.៦៩៧.៩១៦) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ | (៧២.៤៥៥.២៧៥) | (៧២.៤៥៥.២៧៥) |

## គ. បំណុលពន្ធលើប្រាក់ចំណូល

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ១៨.៤៤៩.៧២៦ | ២៩.៨២៥.៦៩៣ |
| ចំណាយពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ៤៤.១១៧.១៧៩ | ២០.៩៤៦.១៩២ |
| សំវិធានធនលើសនៃពន្ធលើប្រាក់ចំណេញរបស់ឆ្នាំមុន | (២.១៩៣.៣៨៧) | (៦.៨៤៦.៨៦៦) |
| ពន្ធលើប្រាក់ចំណូលបានបង់ | (២២.៥០៧.២១៣) | (២៥.៤៧៥.២៩៣) |
| | ៣៧.៨៦៦.៣០៥ | ១៨.៤៤៩.៧២៦ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ២៧. ចំណេញក្នុងមួយភាគហ៊ុន

### (i) ចំណេញក្នុងមួយភាគហ៊ុនគោល (basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនគោល ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់ កសស ចែកនឹងចំនួនភាគហ៊ុនធម្មតាមធ្យមដែលបានបោះផ្សាយក្នុងឆ្នាំ។

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (ពាន់រៀល) | ១៧១.៩៧៨.៩៤៧ | ១២៦.៧៣៣.៦២៩ |
| ចំនួនភាគហ៊ុនមធ្យម | ៨៥.៧៧១.៩៦៧ | ៨៥.៧៧១.៩៦៧ |
| **ចំណេញក្នុងមួយភាគហ៊ុនគោល** (**រៀល**) | ២.០០៥,០៧ | ១.៤៧៧,៥៦ |

### (ii) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយធ្វើនិយ័តកម្មចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមានដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ កសស មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ នាដំណាច់ឆ្នាំនេះ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនគោល។

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ

កសស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ ប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានចាត់ទុកថាជាប្រតិបត្តិការភាគីពាក់ព័ន្ធ។

## ក. សមតុល្យភាគីពាក់ព័ន្ធ

(i) ទឹកប្រាក់ជំពាក់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| MoEF – (JICA) | ៤៣៣.១៨៨.១៣០ | ២២៩.៦៤០.៣៦៣ |
| MoEF – (JBIC) | ១៥៩.៨២៣.៣៩៦ | ១៧៤.៦១៤.៥១៣ |
| MoEF | ៧០.៣៧៧.៣៧៣ | - |
| | ៦៦៣.៣៨៨.៨៩៩ | ៤០៤.២៥៤.៨៧៦ |

## ២៨. ប្រតិបត្តិការនាគីពាក់ព័ន្ធ (ត)

## ក. សមតុល្យនាគីពាក់ព័ន្ធ (ត)

(i) ទឹកប្រាក់ជំពាក់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ត)
បម្រែបម្រួលប្រាក់កម្ចីក្នុងអំឡុងឆ្នាំ មានដូចខាងក្រោមៈ

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| នាដើមឆ្នាំ | ៤០៤.២៥៤.៨៧៦ | ៣៥៦.៩៩១.៧១០ |
| ប្រាក់ដើមបន្ថែម | ២៨៩.៩៣៨.០៩៧ | ១១១.៤៣០.៣៦៥ |
| ប្រាក់ដើមដែលបានទូទាត់សង | (២៥.០៧២.៤១៣) | (២៥.៨៦០.៧០២) |
| ការប្រាក់កត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត | ៧.៦៦៦.៤១១ | ៧.៨៣៩.២៣៨ |
| ការធ្វើមូលធនកម្មការប្រាក់ | ២.៨៧៩.៤៣១ | ១.១១៨.៥៦១ |
| ការប្រាក់ដែលបានសង | (៩.៤២៥.០២៧) | (៨.៩១៦.៤៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | (៦.៨៥២.៤៧៦) | (៣៨.៣៤៧.៨៦៦) |
| នាដំណាច់ឆ្នាំ | ៦៦៣.៣៨៨.៨៩៩ | ៤០៤.២៥៤.៨៧៦ |

(ii) ទឹកប្រាក់ភាគីពាក់ព័ន្ធជំពាក់

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| បុរេប្រទានទៅឱ្យក្រុមហ៊ុន ហ្វូណន តេជោ ខាណែល អ៊ិនវេសម៉ិន ឯ.ក (កំណត់សម្គាល់ ១០) | ៦៩.៧៧២.៧៣៦ | - |
| បុរេប្រទានទៅឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (កំណត់សម្គាល់ ១០) | ១.២២១.៣០៣ | ១.២២១.៣០៣ |
| | ៧០.៩៩៤.០៣៩ | ១.២២១.៣០៣ |

## ២៨. ប្រតិបត្តិការភាគីពាក់ព័ន្ធ (ត)

### ខ. ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ឆ្នាំ មានដូចខាងក្រោម៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| រយៈពេលខ្លី | | |
| ក្រុមប្រឹក្សាភិបាល - កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | ៤.៦៩០.៦៣១ | ៣.៩៣៧.២២៩ |
| បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ - ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ | ១.៣៩៦.៨០០ | ១.៣៩៦.៨០០ |
| | ៦.០៨៧.៤៣១ | ៥.៣៣៤.០២៩ |
| រយៈពេលវែង | | |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (*) | ៣២៣.៥០៥ | ២៥៨.៣៩៨ |
| | ៦.៤១០.៩៣៦ | ៥.៥៩២.៤២៧ |

បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយក និងនាយក ដែលជាអ្នកសម្រេចចិត្តជាយុទ្ធសាស្ត្រ លើការដឹកនាំ លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ កសស ។

(*) គម្រោងអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានដាក់ឱ្យប្រតិបត្តិក្នុងអង្គភាពទាំងមូល ក្នុងនោះបុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ ក៏មានសិទ្ធិទទួលគម្រោងអត្ថប្រយោជន៍នេះ ដូចគ្នានឹងបុគ្គលិក កសស ដទៃទៀតដែរ។

## ២៩. កិច្ចសន្យា

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ កសស មានកិច្ចសន្យាលើការទិញទ្រព្យសកម្មដែលនៅមិនទាន់ទូទាត់ ចំនួន ១.៣៧៤.០៤៨លានរៀល សម្រាប់ការទិញសេវាសាងសង់ ទ្រព្យសម្បត្តិ និងបរិក្ខារ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤៖ ៦៥២.៤៦៣ លានរៀល)។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ

កសស អាចប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា ហានិភ័យទីផ្សារ (រួមបញ្ចូលហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ និងហានិភ័យការប្តូររូបិយប័ណ្ណ) ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។ កសស សន្មត និងគ្រប់គ្រងហានិភ័យទាំងនេះ ដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃភាគីដៃគូរបស់ខ្លួន អត្រាប្តូររូបិយប័ណ្ណ និង លំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ កសស មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---:|---:|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ៦៧.៣៨១.០៨២ | ៤៩.៣៧៦.៨៤០ |
| ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | ៩២.២៧៥.៣៣៤ | ១២៣.៨១៤.១៧៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០២.១៥២.៤៨៣ | ២៧.១៨៥.៨៦៧ |
| | ២៦១.៨០៨.៨៩៩ | ២០០.៣៧៦.៨៨២ |
| **បំណុលហិរញ្ញវត្ថុ** | | |
| ប្រាក់កម្ចី | ៦៦៣.៣៨៨.៨៩៩ | ៤០៤.២៥៤.៨៧៦ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៧១.៩៧២.៤០៣ | ២៥.០៤០.១៣២ |
| ប្រាក់រក្សាទុកត្រូវបង់ | ២៧.៩៥០.៣៣៩ | ២.៧៥៣.៨៦៩ |
| ប្រាក់តម្កល់ ដែលអាចបង្វិលសងពីភតិកៈ | ១.០០៣.២៥០ | ១.០០៦.២៥០ |
| | ៧៦៤.៣១៤.៨៩១ | ៤៣៣.០៥៥.១២៧ |

#### ហានិភ័យទីផ្សារ

*ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគត នឹងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ កសស។

កសស បានទទួលប្រាក់កម្ចី ក្នុងអត្រាការប្រាក់ថេរ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) និងធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JIBC) តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កសស មិនមានការផ្លោះប្តូរអត្រាការប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដើម្បីការពារហានិភ័យអត្រាការប្រាក់ទេ។ កសស មានផលប៉ះពាល់ដល់ហានិភ័យតម្លៃសមស្រប ទោះជាយ៉ាងណាក៏ដោយ គណៈគ្រប់គ្រងកំពុងពិនិត្យមើលយ៉ាងដិតដល់នូវការប្រែប្រួលទីផ្សារ ហើយនឹងឈានដល់ការផ្លោះប្តូរអត្រាការប្រាក់ ប្រសិនបើចាំបាច់។ ប្រាក់កម្ចីរបស់ កសស ត្រូវបានគណនាតាមថ្លៃដើមដករំលស់។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (ត)

**៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ** (ត)

**ហានិភ័យទីផ្សារ** (ត)

*ហានិភ័យតម្លៃ*

កសស មិនប្រឈមនឹងហានិភ័យតម្លៃទំនិញណាមួយឡើយ។ លើសពីនេះ កសស មិនប្រឈមនឹងហានិភ័យតម្លៃមូលបត្រទេ ព្រោះមិនមានឧបករណ៍ហិរញ្ញវត្ថុដែលរាយការណ៍តាមតម្លៃសមស្រប នាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ។

*ហានិភ័យការប្តូររូបិយប័ណ្ណ*

កសស ប្រឈមមុខនឹងហានិភ័យការប្តូររូបិយប័ណ្ណ ដែលសំខាន់ជាងគេគឺការប្តូរពីប្រាក់រៀល ទៅជាប្រាក់យ៉េនជប៉ុន និងទៅជាប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី JICA និងពី JIBC តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺទទួលបានជាប្រាក់យ៉េនជប៉ុន និងប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ កសស កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល។ បច្ចុប្បន្ននេះ កសស មិនប្រើប្រាស់ការការពារ ឬប្រើកិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត ដើម្បីការពារហានិភ័យនេះទេ។ ភាពប្រែប្រួលរបស់ កសស ចំពោះអត្រាប្តូររូបិយប័ណ្ណ ទៅលើឧបករណ៍ហិរញ្ញវត្ថុជាប្រាក់យ៉េនជប៉ុន និងឧបករណ៍ហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិក ត្រូវបានវិភាគដូចខាងក្រោម។ ឧបករណ៍ហិរញ្ញវត្ថុរបស់ កសស ភាគច្រើនជារូបិយប័ណ្ណបរទេសទាំងពីរនេះ។

ដោយផ្អែកលើការវិភាគរបស់ កសស លើការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេសជាមធ្យមក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ កសស បានចាត់ទុកថាការប្រែប្រួល ៦,៣១% (២០២៤៖១០,៣៣%) នៃអត្រាប្តូរប្រាក់យ៉េនជប៉ុន និង ០,៨៥% (២០២៤៖១,១០%) នៃអត្រាប្តូរប្រាក់ដុល្លារអាមេរិក គឺជាស្តង់ដាសមហេតុផល។

តារាងខាងក្រោមនេះបង្ហាញពីផលប៉ះពាល់ចំពោះចំណេញបន្ទាប់ពីពន្ធ ដែលជាលទ្ធផលនៃការប្រែប្រួលអត្រាប្តូរប្រាក់៖

| | | **២០២៥** |
|---|---|---|
| **ការប្រែប្រួល** | **ការប្រែប្រួលអត្រាប្តូរប្រាក់** | **ផលប៉ះពាល់ចំពោះចំណេញបន្ទាប់ពីពន្ធ ពាន់រៀល** |
| ប្រាក់យ៉េនជប៉ុន | ថយចុះ - ៦,៣១% | ៣១.៣៥៣.៩៥២ |
| | កើនឡើង + ៦,៣១% | (៣១.៣៥៣.៩៥២) |
| ប្រាក់ដុល្លារអាមេរិក | ថយចុះ - ០,៨៥% | (៧០៧.៣៣៩) |
| | កើនឡើង + ០,៨៥% | ៧០៧.៣៣៩ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)**

**ហានិភ័យទីផ្សារ (ត)**

*ហានិភ័យការប្តូររូបិយប័ណ្ណ (ត)*

| | ២០២៤ | |
|---|---|---|
| **ការប្រែប្រួល** | **ការប្រែប្រួលអត្រាប្តូរប្រាក់** | **ផលប៉ះពាល់ចំពោះចំណេញបន្ទាប់ពីពន្ធ ពាន់រៀល** |
| ប្រាក់យ៉េនជប៉ុន | ថយចុះ - ១០,៣៣% | ២៧.២៤៣.០០០ |
| | កើនឡើង + ១០,៣៣% | (២៧.២៤៣.០០០) |
| ប្រាក់ដុល្លារអាមេរិក | ថយចុះ - ១,១០% | (៧៥០.០០០) |
| | កើនឡើង + ១,១០% | ៧៥០.០០០ |

តារាងខាងក្រោមនេះគឺជាឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោង និងតាមប្រភេទរូបិយប័ណ្ណ ដោយមានតម្លៃសមមូលនឹងពាន់រៀល។

| | **សមមូលនឹងពាន់រៀល** | | | |
|---|---|---|---|---|
| | **ប្រាក់យ៉េនជប៉ុន** | **ប្រាក់ដុល្លារអាមេរិក** | **ប្រាក់រៀល** | **សរុប** |
| **២០២៥** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និង គណនីអតិថិជនផ្សេងៗ | - | ៦៦.២២០.៨០៥ | ១.១៦០.២៧៧ | ៦៧.៣៨១.០៨២ |
| ប្រាក់បញ្ញើនៅធនាគារ | - | ៨៥.៤០៨.៤០៤ | ៦.៨៦៦.៩៣០ | ៩២.២៧៥.៣៣៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ៩៥.៥១៥.១៧៤ | ៦.៦៣៧.៣០៩ | ១០២.១៥២.៤៨៣ |
| | - | ២៤៧.១៤៤.៣៨៣ | ១៤.៦៦៤.៥១៦ | ២៦១.៨០៨.៨៩៩ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៥២៦.១៤៤.៤២៥) | (១៣៧.២៤៤.៤៧៤) | - | (៦៦៣.៣៨៨.៨៩៩) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | (៦៧.១៤៣.៤៤៦) | (៤.៦៣៨.៧៣០) | (១៩០.២២៧) | (៧១.៩៧២.៤០៣) |
| ប្រាក់រក្សាទុកត្រូវបង់ | (២៧.៩៥០.៣៣៩) | - | - | (២៧.៩៥០.៣៣៩) |
| ប្រាក់តម្កល់ ដែលអាចបង្វិលសងពីភតិកៈ | - | (១.០០៣.២៥០) | - | (១.០០៣.២៥០) |
| | (៦២១.២៣៨.២១០) | (១៤២.៨៨៦.៤៥៤) | (១៩០.២២៧) | (៧៦៤.៣១៤.៨៩១) |
| **ស្ថានភាពសុទ្ធ** | (៦២១.២៣៨.២១០) | ១០៤.២៥៧.៩២៩ | ១៤.៤៧៤.២៨៩ | (៥០២.៥០៥.៩៩២) |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)
**ហានិភ័យទីផ្សារ (ត)**

*ហានិភ័យការប្តូររូបិយប័ណ្ណ (ត)*

| | សមមូលនឹងពាន់រៀល | | | |
|---|---|---|---|---|
| | ប្រាក់យ៉េនជប៉ុន | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | សរុប |
| **២០២៤** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម និង គណនីអតិថិជនផ្សេងៗ | - | ៤៧.៨៤៩.១៧៣ | ១.៥២៧.៦៦៧ | ៤៩.៣៧៦.៨៤០ |
| ប្រាក់បញ្ញើនៅធនាគារ | - | ១១៤.០០១.៥៨៤ | ៩.៨១២.៥៩១ | ១២៣.៨១៤.១៧៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | ២៦.៦៧៨.៧០៦ | ៥០៧.១៦១ | ២៧.១៨៥.៨៦៧ |
| | - | ១៨៨.៥២៩.៤៦៣ | ១១.៨៤៧.៤១៩ | ២០០.៣៧៦.៨៨២ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | (៣២៩.៧៣៨.៥៦៩) | (៧៤.៥១៦.៣០៧) | - | (៤០៤.២៥៤.៨៧៦) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | - | (២៥.០៤០.១៣២) | - | (២៥.០៤០.១៣២) |
| ប្រាក់រក្សាទុកត្រូវបង់ | (២.៧៥៣.៨៦៩) | - | - | (២.៧៥៣.៨៦៩) |
| ប្រាក់តម្កល់ ដែលអាចបង្វិលសងពីភតិកៈ | - | (១.០០៦.២៥០) | - | (១.០០៦.២៥០) |
| | (៣៣២.៤៩២.៤៣៨) | (១០០.៥៦២.៦៨៩) | - | (៤៣៣.០៥៥.១២៧) |
| **ស្ថានភាពសុទ្ធ** | (៣៣២.៤៩២.៤៣៨) | ៨៧.៩៦៦.៧៧៤ | ១១.៨៤៧.៤១៩ | (២៣២.៦៧៨.២៤៥) |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)

**ហានិភ័យឥណទាន**

កសស ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ប្រាក់បញ្ញើនៅធនាគារ និងសាច់ប្រាក់នៅធនាគារ ដែលវាស់វែងតាមថ្លៃដើមដករំលស់។

*ការគ្រប់គ្រងហានិភ័យ*

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ កសស តម្រូវឱ្យក្រុមហ៊ុនដឹកជញ្ជូនតាមនាវានីមួយៗ តម្កល់ប្រាក់កក់មុននឹងបំពេញសេវាណាមួយឱ្យក្រុមហ៊ុននោះ។ ចំពោះគ្រឹះស្ថានរបស់រដ្ឋាភិបាល មិនតម្រូវឱ្យមានប្រាក់កក់ទេ ដោយសារ កសស ជឿជាក់ថាខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុនៃគ្រឹះស្ថានរដ្ឋទាំងនោះ)។ ចំពោះក្រុមហ៊ុនដឹកជញ្ជូនតាមនាវាដែលមិនប្រើប្រាស់សេវារបស់ កសស ញឹកញាប់ ដូចជាដឹកជញ្ជូនគឺមិនតម្រូវឱ្យកក់ប្រាក់ទេ ដោយសារក្រុមហ៊ុនទាំងនោះតម្រូវឱ្យបង់ប្រាក់នៅពេលបំពេញសេវាតែម្តង។ កសស មានគោលការណ៍កាត់ប្រាក់កក់ ចំពោះអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេទៅតាមលក្ខខណ្ឌ និងកិច្ចសន្យាឥណទាន។ ហានិភ័យឥណទានរបស់ កសស ចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកំណត់ឱ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក ផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់ នាដំណាច់ឆ្នាំ។ មិនមានការប្រមូលផ្តុំហានិភ័យឥណទានជាសារវន្តទេ ទាំងហានិភ័យតាមរយៈអតិថិជនទោល វិស័យអាជីវកម្មជាក់លាក់ និង/ឬ តំបន់អាជីវកម្មជាក់លាក់។

ចំពោះប្រាក់បញ្ញើនៅធនាគារ និងសាច់ប្រាក់នៅធនាគារ ការដាក់ប្រាក់ត្រូវបានធ្វើឡើងតែជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលមានកេរ្តិ៍ឈ្មោះល្អតែប៉ុណ្ណោះ។

*ទ្រព្យធានា*

ចំពោះគណនីអតិថិជនពាណិជ្ជកម្មខ្លះ កសស ទទួលទ្រព្យធានាក្នុងទម្រង់ជាការតម្កល់ជាសាច់ប្រាក់ ដែលអាចស្នើឱ្យបង់ប្រាក់បាន ប្រសិនបើភាគីដៃគូខកខានមិនបានបង់ប្រាក់តាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង។

*ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ កសស រួមមាន សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដោយមិនរួមបញ្ចូលនូវសាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនៅធនាគារ និងគណនីអតិថិជនពាណិជ្ជកម្ម ដែលត្រូវអនុវត្តតាមគំរូការខាតឥណទានរំពឹងទុក។

*សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដោយមិនរួមបញ្ចូលនូវ សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនៅធនាគារ*

គណនីទាំងនេះត្រូវបានចាត់ទុកថាជាហានិភ័យឥណទានកម្រិតទាប។ ចំណាត់ថ្នាក់ឥណទាននៃទ្រព្យសកម្មទាំងនេះ ត្រូវបានតាមដានរកការថយចុះតម្លៃឥណទាន។ ការវាស់វែងរកការថយចុះតម្លៃ ត្រូវបានកំណត់ត្រឹមការខាតឥណទានរំពឹងទុករយៈពេល១២ខែ (កំណត់សម្គាល់ ១១)។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)

**ហានិភ័យឥណទាន** (ត)

*គណនីអតិថិជនពាណិជ្ជកម្ម*

កសស អនុវត្តវិធីសាស្ត្រដែលមានលក្ខណៈសាមញ្ញក្នុង CIFRS 9 ដើម្បីវាស់វែង ECL ដែលប្រើប្រាស់អាយុកាលសំវិធានធនខាតបង់រំពឹងទុក ចំពោះគណនីអតិថិជនពាណិជ្ជកម្មទាំងអស់។

ក្នុងការវាស់វែងការខាតបង់ឥណទានរំពឹងទុក គណនីអតិថិជនពាណិជ្ជកម្មត្រូវបានដាក់ជាក្រុម អាស្រ័យទៅតាមលក្ខណៈនៃហានិភ័យឥណទានជារួម និងចំនួនថ្ងៃផុតកំណត់។

ជាទូទៅ គណនីអតិថិជនពាណិជ្ជកម្មរបស់ កសស រួមមាន ទឹកប្រាក់ត្រូវទទួលពីកូនបំណុលចន្លោះពី ៣១ ទៅ ៣៧ នាក់ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៥។ យោងទៅតាមបទពិសោធន៍នៃការខាតបង់ឥណទានរបស់ កសស ក្នុងគ្រាកន្លងមក ចំពោះគណនីអតិថិជនពាណិជ្ជកម្ម គឺអតិថិជនបានសងប្រាក់ទៀងទាត់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ រាល់វិក្កិយបត្រទាំងអស់ត្រូវបានទូទាត់មិនលើសរយៈពេលមួយឆ្នាំទេ។

អត្រាការខាតបង់ក្នុងគ្រាកន្លងមក ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាននាពេលបច្ចុប្បន្ន និងព័ត៌មាននាពេលអនាគត ទៅលើកត្តាម៉ាក្រូសេដ្ឋកិច្ចផ្សេងៗ ដែលមានផលប៉ះពាល់ដល់លទ្ធភាពរបស់អតិថិជនក្នុងការទូទាត់សង។ កសស បានកំណត់អំពីអត្រាកំណើននៃផលិតផលសរុបដុលក្នុងស្រុករបស់ប្រទេសកម្ពុជា ដែល កសស កំពុងផ្តល់សេវារបស់ខ្លួន ត្រូវបានចាត់ទុកថាជាកត្តាដែលមានការពាក់ព័ន្ធ ក្នុងចំណោមកត្តាផ្សេងៗទៀត ដូចនេះហើយ កសស បានកែតម្រូវអត្រាខាតបង់ក្នុងគ្រាកន្លងមក អាស្រ័យទៅតាមបម្រែបម្រួលរំពឹងទុកនៃកត្តាទាំងអស់នេះ។

គណនីអតិថិជនពាណិជ្ជកម្មត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានការរំពឹងទុកសមហេតុផលណាមួយ ថាអាចប្រមូលបានមកវិញ។ សញ្ញាណដែលបង្ហាញថាមិនមានការរំពឹងទុកសមហេតុផល ក្នុងការប្រមូលបានមកវិញ រួមមានកត្តាមួយចំនួនក្នុងចំណោមកត្តាជាច្រើន ដូចជា ការខកខានរបស់កូនបំណុលក្នុងការសងប្រាក់តាមពេលវេលាកំណត់ និងការខកខានក្នុងការសងប្រាក់តាមកិច្ចសន្យាក្នុងរយៈពេលមួយ ដែលលើសពីចំនួនថ្ងៃផុតកំណត់ជាក់លាក់ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានដាក់បង្ហាញដោយការខាតពីការថយចុះតម្លៃសុទ្ធ ក្នុងចំណេញប្រតិបត្តិការ។ ការប្រមូលបានមកវិញនាពេលបន្ទាប់មក នៃចំនួនទឹកប្រាក់ដែលបានជម្រះចេញពីបញ្ជីរួចហើយ ត្រូវបានកត់ត្រាខាងខ្វង់ឥណទាន ក្នុងប្រភេទគណនីដូចគ្នា។

យោងតាមមូលដ្ឋាននេះ សំវិធានធនសម្រាប់ការខាតបង់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានកំណត់ដូចខាងក្រោម ចំពោះគណនីអតិថិជនពាណិជ្ជកម្មៈ

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)

**ហានិភ័យឥណទាន (ត)**

*គណនីអតិថិជនពាណិជ្ជកម្ម (ត)*

| | ២០២៥ | | |
|---|---|---|---|
| | អត្រាខាតរំពឹងទុក<br>% | តម្លៃយោងដុល<br>ពាន់រៀល | សំវិធានធន<br>សម្រាប់ ECL<br>ពាន់រៀល |
| រយៈពេលខ្លី | - | ៤០.៧៩០.៧០៩ | - |
| ហួសកាលកំណត់ពី១ថ្ងៃ - ៣០ ថ្ងៃ | - | ១៦.០៦៩.៧២៦ | - |
| ហួសកាលកំណត់ពី៣១ថ្ងៃ - ៦០ ថ្ងៃ | - | ១.១៤៣.៥៣៤ | - |
| ហួសកាលកំណត់ពី៦១ថ្ងៃ - ៩០ ថ្ងៃ | - | ៦៥១.៤០៧ | - |
| ហួសកាលកំណត់ពី៩១ថ្ងៃ - ១២០ ថ្ងៃ | - | ៣៨៨.៥០៥ | - |
| ហួសកាលកំណត់លើសពី១២០ ថ្ងៃ | (*) ២,៤៧% | ៧.០៨៦.០៤៨ | ១៧៤.៧៨៥ |
| | | ៦៦.១២៩.៩២៩ | ១៧៤.៧៨៥ |

| | ២០២៤ | | |
|---|---|---|---|
| | អត្រាខាតរំពឹងទុក<br>% | តម្លៃយោងដុល<br>ពាន់រៀល | សំវិធានធន<br>សម្រាប់ ECL<br>ពាន់រៀល |
| រយៈពេលខ្លី | 0% | ២០.០២៩.៤៧៤ | - |
| ហួសកាលកំណត់ពី១ថ្ងៃ - ៣០ ថ្ងៃ | 0% | ២១.៣៦៧.៧២៤ | - |
| ហួសកាលកំណត់ពី៣១ថ្ងៃ - ៦០ ថ្ងៃ | 0% | ២.៣៨៣.៩៤០ | - |
| ហួសកាលកំណត់ពី៦១ថ្ងៃ - ៩០ ថ្ងៃ | 0% | ៩៤៩.១៨២ | - |
| ហួសកាលកំណត់ពី៩១ថ្ងៃ - ១២០ ថ្ងៃ | 0% | ៣៦៩.៣៤១ | - |
| ហួសកាលកំណត់លើសពី១២០ ថ្ងៃ | (*) ៣,៦៥% | ២.៨៥៣.៦៦៩ | ១០៤.១៥៧ |
| | | ៤៧.៩៥៣.៣៣០ | ១០៤.១៥៧ |

(*) ផលប៉ះពាល់នៃការវាស់វែង ECL គឺដោយសារតែការផ្លាស់ប្តូរ ប្រូបាបនៃការមិនសងប្រាក់ (PD) ដែលកើតពីការកែតម្រូវសម្រាប់ពេលខាងមុន ទៅលើការព្យាករម៉ាក្រូសេដ្ឋកិច្ច។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)

### ហានិភ័យសាច់ប្រាក់ងាយស្រួល

កសស ប្រឈមនឹងហានិភ័យសាច់ប្រាក់ងាយស្រួល ដែលកើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសាច់ប្រាក់ងាយស្រួលរួមមានហានិភ័យដែលអាចធ្វើឱ្យ កសស មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឱ្យទាន់ពេលវេលា។

គោលការណ៍របស់ កសស គឺត្រូវរក្សាទុកសាច់ប្រាក់ឱ្យបានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទាន ជាមួយនឹងមូលនិធិផ្ទាល់ ដើម្បីបង់ការចំណាយវិនិយោគ។

កសស មានឥណទាន និងប្រាក់កម្ចីមិនទាន់ដកយកដូចខាងក្រោមនេះ នាដំណាច់ឆ្នាំ៖

| | **២០២៥**<br>**ពាន់រៀល** | **២០២៤**<br>**ពាន់រៀល** |
|---|---|---|
| **អត្រាការប្រាក់ថេរ** | | |
| ឥណទានវិបារូបន៍មិនទាន់ប្រើ (ផុតកំណត់ក្នុងរយៈពេល១ឆ្នាំ) | ៤០.១៣០.០០០ | - |
| ប្រាក់កម្ចីមិនទាន់ប្រើ (ផុតកំណត់ក្នុងរយៈពេលលើសពី១ឆ្នាំ) | ១.៣៧៤.០៤៨.១៩០ | ១.៥៦៨.១០៣.៨៤៥ |
| | ១.៤១៤.១៧៨.១៩០ | ១.៥៦៨.១០៣.៨៤៥ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

### ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
### ៣០.១ កត្តាហានិភ័យហិរញ្ញវត្ថុ (ត)
### ហានិភ័យសាច់ប្រាក់ខាយស្រួល(ត)

តារាងខាងក្រោមនេះវិភាគអំពីបំណុលហិរញ្ញវត្ថុរបស់ កសស តាមរយៈពេលដែលនៅសល់ រហូតដល់កាលបរិច្ឆេទផុតកំណត់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ។ ចំនួនដែលបានលាតត្រដាងនៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលមិនធ្វើអប្បហារ។

| | ក្នុងអំឡុង ១ ឆ្នាំ ពាន់រៀល | ពី ១-២ ឆ្នាំ ពាន់រៀល | ពី ២-៥ ឆ្នាំ ពាន់រៀល | លើសពី ៥ ឆ្នាំ ពាន់រៀល | លំហូរសាច់ប្រាក់តាមកិច្ចសន្យាសរុប ពាន់រៀល | បំណុលតម្លៃយោង ពាន់រៀល |
|---|---|---|---|---|---|---|
| **២០២៥** | | | | | | |
| ប្រាក់កម្ចី | ៣០.៩៣៨.៧១៨ | ៣០.២៨៣.៨៣៩ | ៨២.៥០៩.៩១៤ | ៥៦១.៥៨៤.៤១០ | ៧០៥.៣១៦.៨៨១ | ៦៦៣.៣៨៨.៨៩៩ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៧១.៩៧២.៤០៣ | - | - | - | ៧១.៩៧២.៤០៣ | ៧១.៩៧២.៤០៣ |
| ប្រាក់រក្សាទុកត្រូវបង់ | - | ២៧.៩៥០.៣៣៩ | - | - | ២៧.៩៥០.៣៣៩ | ២៧.៩៥០.៣៣៩ |
| ប្រាក់តម្កល់ ដែលអាចបង្វិលសងពីភតិក: | - | - | - | ១.០០៣.២៥០ | ១.០០៣.២៥០ | ១.០០៣.២៥០ |
| | ១០២.៩១១.១២១ | ៥៨.២៣៤.១៧៨ | ៨២.៥០៩.៩១៤ | ៥៦២.៥៨៧.៦៦០ | ៨០៦.២៤២.៨៧៣ | ៧៦៤.៣១៤.៨៩១ |
| **២០២៤** | | | | | | |
| ប្រាក់កម្ចី | ៣៣.១០០.៣៤៩ | ៣២.៤៤៨.៤០៨ | ៩៦.៨២៥.៤០៣ | ៣៣៦.៣០៧.១៩០ | ៤៩៨.៦៨១.៣៥០ | ៤០៤.២៥៤.៨៧៦ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២៥.០៤០.១៣២ | - | - | - | ២៥.០៤០.១៣២ | ២៥.០៤០.១៣២ |
| ប្រាក់រក្សាទុកត្រូវបង់ | - | - | ២.៧៥៣.៨៦៩ | - | ២.៧៥៣.៨៦៩ | ២.៧៥៣.៨៦៩ |
| ប្រាក់តម្កល់ ដែលអាចបង្វិលសងពីភតិក: | - | - | - | ១.០០៦.២៥០ | ១.០០៦.២៥០ | ១.០០៦.២៥០ |
| | ៥៨.១៤០.៤៨១ | ៣២.៤៤៨.៤០៨ | ៩៩.៥៧៩.២៧២ | ៣៣៧.៣១៣.៤៤០ | ៥២៧.៤៨១.៦០១ | ៤៣៣.០៥៥.១២៧ |

### ៣០.២ ការគ្រប់គ្រងហានិភ័យដើមទុន

ទិសដៅរបស់ កសស ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគទុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយចំណាយដើមទុន។

កសស មិនមានគោលការណ៍ជាក់លាក់ចំពោះអនុបាតបំណុលធៀបនឹងដើមទុននោះទេ។

## ៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣០.២ ការគ្រប់គ្រងហានិភ័យដើមទុន (ត)

*ភាគលាភ*

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភ ចំពោះប្រាក់ចំណេញសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដូចខាងក្រោម៖

| | ២០២៥<br>ពាន់រៀល | ២០២៤<br>ពាន់រៀល |
|---|---|---|
| ភាគលាភសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ចំនួន ៧៧,៧៣ រៀល (២០២៣ ៖ ៧៧,៧៣ រៀល) ក្នុងមួយភាគហ៊ុនប្រភេទ ខ | ៥.០០០.០០០ | ៥.០០០.០០០ |
| ភាគលាភសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ចំនួន ៥៥៤ រៀល (២០២៣ ៖ ៥០៤ រៀល) ក្នុងមួយភាគហ៊ុនប្រភេទ គ | ១១.៨៧៩.៤១៨ | ១០.៨០៧.២៦៨ |
| ភាគលាភបានបង់សរុប | ១៦.៨៧៩.៤១៨ | ១៥.៨០៧.២៦៨ |

កសស បានទូទាត់ភាគលាភនៃភាគហ៊ុនប្រភេទ ខ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ និងភាគហ៊ុនប្រភេទ គ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥។

### ៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់

វិធីសាស្ត្រ និងការសន្មត ដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

*(ក)* *សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើនៅធនាគារ* – តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

*(ខ)* *គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ* – តម្លៃយោងដកសំវិធានធនសម្រាប់ការថយចុះតម្លៃ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

*(គ)* *គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ*– តម្លៃយោងនៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ ត្រូវបានចាត់ទុកថាមានតម្លៃស្មើគ្នានឹងតម្លៃសមស្របរបស់វា ដោយសារវាមាន រយៈពេលខ្លី។

*(ឃ)* *ប្រាក់កម្ចី* – តម្លៃសមស្របត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយប្រើអត្រាការប្រាក់ទីផ្សារ ដែលមានចំនួនប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។

*(ង)* *ប្រាក់រក្សាទុកត្រូវបង់* – តម្លៃយោងនៃប្រាក់រក្សាទុកត្រូវបង់ មិនមានចំនួនខុសគ្នាជាសារវន្តពីតម្លៃសមស្របរបស់វាទេ យោងទៅតាមលក្ខខណ្ឌ និងកាលកំណត់របស់វា។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

**៣០. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**៣០.៣ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់ (ត)**

**កម្រិតតម្លៃសមស្រប**

កសស ប្រើប្រាស់កម្រិតដូចខាងក្រោម ដើម្បីកំណត់ និងលាតត្រដាងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុទៅតាមវិធីសាស្ត្រកំណត់តម្លៃខាងក្រោម៖

- តម្លៃដាក់លក់ក្នុងទីផ្សារសកម្ម ចំពោះទ្រព្យសកម្ម ឬបំណុលដូចគ្នា (កម្រិត ១)
- ធាតុចូលទាំងឡាយណាដែលពាក់ព័ន្ធនឹងធាតុចូលផ្សេងៗ ក្រៅពីតម្លៃដាក់លក់ក្នុងកម្រិត ១ ដែលអាចសង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (ជាតម្លៃ) ឬដោយប្រយោល (ទាញបានមកពីតម្លៃ) (កម្រិត ២) និង
- ធាតុចូលសម្រាប់ទ្រព្យសកម្ម ឬបំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុចូលដែលមិនអាចសង្កេតបាន) (កម្រិត ៣)។

មិនមានការផ្ទេររវាងការវាស់វែងតម្លៃសមស្របកម្រិត ១ និងកម្រិត ២ ទេ ហើយក៏មិនមានការផ្ទេរចូល និងផ្ទេរចេញពីការវាស់វែងតម្លៃសមស្របកម្រិត ៣ ដែរ។

**ការកាត់កងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ**

មិនមានការកាត់កងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំនេះទេ។

# ឧបសម្ព័ន្ធ៣

# របាយការណ៍អភិបាលកិច្ចសាជីវកម្ម

# ប្រចាំឆ្នាំ២០២៥

# ឧបសម្ព័ន្ធ

# នៃ

# របាយការណ៍ប្រចាំឆ្នាំ២០២៥
# របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# របាយការណ៍
# អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

# ផ្នែកទី១

# ភាគហ៊ុនិក

## ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២.៧៧៨ | ៣.៩០៣.៣៣៧ | ៤,៥៥% |
| | | នីតិបុគ្គល | ៥ | ៣.៣៣៧.០១០ | ៣,៨៩% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៤២៦ | ៥១៥.៨៧៣ | ០,៦០% |
| | | នីតិបុគ្គល | ៤ | ២.៥៣៦.៤៤៨ | ២,៩៦% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១១.១៥០.៣២៤ | ១៣,០០% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៦៤.៣២៨.៩៧៥ | ៧៥,០០% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៤ | ១៦៤.៣០៥ | ៧,៦៦% |
| បុគ្គលិកជាន់ខ្ពស់ | ១៥ | ៣១៣.១៤៥ | ១៤,៦០% |
| និយោជិត | ២០០ | ១.៦៦៦.៨៤៩ | ៧៧,៧៤% |
| **សរុប** | **២១៩** | **២.១៤៤.២៩៩** | **១០០,០០%** |

## ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

### ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិករបស់ កសស មានសិទ្ធិដូចខាងក្រោម ៖

- ភាគហ៊ុនិកប្រភេទ "ក"
  - សិទ្ធិបោះឆ្នោត ៖ ជាទូទៅភាគហ៊ុនិកប្រភេទ "ក" មិនមានសិទ្ធិបោះឆ្នោតឡើយ លើកលែងតែក្នុងករណីដែលមានកិច្ចប្រជុំសម្រេចលើបញ្ហាណាមួយ ដែលអាចប៉ះពាល់សិទ្ធិ និងផលប្រយោជន៍នៃភាគហ៊ុនិកប្រភេទ "ក" ក្នុងនោះមានជាអាទិ៍ដូចករណីខាងក្រោម ៖
    - ការកាត់បន្ថយចំនួន ឬ ការរិតត្បិតសិទ្ធិនៃភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក"
    - ការស្នើរួមបញ្ចូល ឬ ការបំបែក កសស
    - ការសម្រេចឱ្យរំលាយ និងជម្រះបញ្ជី កសស

ក្នុងករណីនេះ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបោះឆ្នោតដោយ ១ (មួយ) ភាគហ៊ុនស្មើនឹង ១ (មួយ) សំឡេង ។

- សិទ្ធិទទួលបានព័ត៌មាន ៖ ភាគហ៊ុនិកប្រភេទ "ក" មានសិទ្ធិទទួលបានព័ត៌មាន ដែលទាក់ទងនឹង កសស ស្របតាមច្បាប់ជាធរមាន ។
- សិទ្ធិទទួលបានទ្រព្យ ដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី៖ ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិរបស់ កសស ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី កសស មុនភាគហ៊ុនិកប្រភេទ "ខ" និង ប្រភេទ "គ" ដែលត្រូវបានកាន់កាប់គិតត្រឹមកាលបរិច្ឆេទនៃការរំលាយ និងការជម្រះបញ្ជី កសស ។

• ភាគហ៊ុនិកប្រភេទ "ខ"
  - សិទ្ធិបោះឆ្នោត ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ (មួយ) ភាគហ៊ុនស្មើនឹង ១ (មួយ) សំឡេង ។
  - សិទ្ធិទទួលបានភាគលាភ ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិទទួលបានភាគលាភនៅក្នុងឆ្នាំសារពើពន្ធណាមួយ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល កសស ។
  - សិទ្ធិទទួលបានព័ត៌មាន ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិទទួលបានព័ត៌មានរបស់ កសស ស្របតាមច្បាប់ជាធរមាន ។
  - សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី ៖ ភាគហ៊ុនិកប្រភេទ "ខ" ត្រូវទទួលទ្រព្យសម្បត្តិរបស់ កសស ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី កសស ប៉ុន្តែត្រូវគោរពតាមសិទ្ធិបុរិមាដែលបានផ្តល់ជូនភាគហ៊ុនិកប្រភេទ "ក" ។
  - សិទ្ធិបរិវត្តន៍ ៖ ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិបរិវត្តន៍ក្នុងការបំលែងភាគហ៊ុនរបស់ខ្លួនទៅជាភាគហ៊ុនប្រភេទ "គ" តាមសមាមាត្រមួយភាគហ៊ុនប្រភេទ "ខ" ទៅជាមួយភាគហ៊ុនប្រភេទ "គ" ដោយត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម ៖
    - ○ បន្ទាប់ពីផុតរយៈពេល ៣ (បី) ឆ្នាំ នៃការប្រកាស និងការធានាភាគលាភអប្បបរមាចំពោះភាគហ៊ុនប្រភេទ "គ" ។
    - ○ កសស មិនមានភាគលាភអប្បបរមាត្រូវបានធានា ដែលមិនទាន់បានបែងចែករួច ។
    - ○ ការធ្វើបរិវត្តន៍នៃភាគហ៊ុនប្រភេទ "ខ" នឹងមានអានុភាពនៅពេលមានការសម្រេចពីក្រុមប្រឹក្សាភិបាល កសស និងការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

• ភាគហ៊ុនិកប្រភេទ "គ"
  - សិទ្ធិបោះឆ្នោត ៖ ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ (មួយ) ភាគហ៊ុនស្មើនឹង ១ (មួយ) សំឡេង ។
  - សិទ្ធិទទួលភាគលាភ ៖ ភាគលាភដែលបែងចែកក្នុងចំណោមភាគហ៊ុនិកប្រភេទ "គ" ត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ កសស ក្នុងឆ្នាំសារពើពន្ធ និងត្រូវអនុម័តដោយមហាសន្និបាតភាគហ៊ុនិក។ ការបែងចែកភាគលាភ អាចជាសាច់ប្រាក់ ឬ ជាភាគហ៊ុន ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល កសស និងទទួលការអនុម័តពីមហាសន្និបាតភាគហ៊ុនិក ហើយនឹងផ្តល់ជូនភាគហ៊ុនិក ដែលបានកាន់កាប់ភាគហ៊ុនមុនថ្ងៃអិចឌីវិឌិនដ៍ (Ex-Dividend Day) ។
  - សិទ្ធិទទួលព័ត៌មាន ៖ ភាគហ៊ុនិកប្រភេទ "គ" មានសិទ្ធិទទួលបានព័ត៌មានរបស់ កសស ស្របតាមច្បាប់ជាធរមាន ។
  - សិទ្ធិទទួលបានទ្រព្យដែលនៅសល់ពីការរំលាយ និងការជម្រះបញ្ជី ៖ ភាគហ៊ុនិកប្រភេទ "គ" ត្រូវទទួលទ្រព្យសម្បត្តិរបស់ កសស ដែលនៅសល់បន្ទាប់ពីមានការរំលាយ និងការជម្រះបញ្ជី កសស ប៉ុន្តែត្រូវគោរពតាមសិទ្ធិបុរិមាដែលបានផ្តល់ជូនភាគហ៊ុនិកប្រភេទ "ក" និង ប្រភេទ "ខ" ។

## ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល និងអគ្គនាយក ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ កសស ហើយភាគហ៊ុនិកមានសិទ្ធិទទួលព័ត៌មានស្មើៗគ្នា ក្នុងពេលតែមួយមិនថាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនតិច ឬច្រើន ។ គ្រប់ភាគហ៊ុនិករបស់ កសស ទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមានសិទ្ធិក្នុងការសួរទៅលើលទ្ធផលប្រតិបត្តិការណ៍ ការអនុវត្ត និងផែនការអភិវឌ្ឍនានារបស់កំពង់ផែ ។ លើសពីនេះ សមាជិកក្រុមប្រឹក្សាភិបាល ក៏មានអភិបាលប្រតិបត្តិ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនដើម្បីការពារផលប្រយោជន៍ភាគហ៊ុនិកទាំងអស់ ។

## ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត

សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច ក៏ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយកដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ កសស ហើយភាគហ៊ុនិកទាំងនោះមានសិទ្ធិទទួលបានព័ត៌មានស្មើៗគ្នា និងក្នុងពេលតែមួយមិនថាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនតិច ឬច្រើន ។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមានសិទ្ធិក្នុងការសួរទៅលើ លទ្ធផលប្រតិបត្តិការ ការអនុវត្ត និងផែនការអភិវឌ្ឍន៍នានារបស់កំពង់ផែ ។

# គ. មហាសន្និបាតភាគហ៊ុនិក

## ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

- នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក
  - មហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើង ១ (មួយ) ឆ្នាំម្តង បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធស្របតាមកាលបរិច្ឆេទ និងរបៀបវារៈដែលត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល ។
  - មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ អាចប្រព្រឹត្តទៅបានក្នុងករណីមានសេចក្តីស្នើសុំដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនយ៉ាងតិចចំនួន ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនប្រភេទ "ខ" និងប្រភេទ "គ" ។
  - សេចក្តីស្នើសុំកោះប្រជុំរបស់ភាគហ៊ុនិក ត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាលយ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃមុនថ្ងៃប្រជុំ ដោយមានចុះហត្ថលេខា និងភ្ជាប់របៀបវារៈជាមួយផង ។
  - ប្រសិនបើមហាសន្និបាតភាគហ៊ុនិក ពុំអាចប្រព្រឹត្តិទៅបានតាមនីតិវិធីដូចចែងខាងលើ នោះសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកណាម្នាក់ដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក អាចស្នើសុំតុលាការ ឱ្យចាត់ចែងកោះប្រជុំមហាសន្និបាតភាគហ៊ុនិក តាមនីតិវិធី ណាមួយដែលតុលាការពិចារណាឃើញថាសមស្រប ។
  - មហាសន្និបាតភាគហ៊ុនិក ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយក ។ ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយកអវត្តមាន នោះសមាជិកក្រុមប្រឹក្សាភិបាល ដែលជាអាណត្តិគាហកៈតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើជាអធិបតី ។
  - ប្រធានមហាសន្និបាតភាគហ៊ុនិក មានសិទ្ធិបោះឆ្នោតលុះត្រាតែបានទទួលការផ្ទេរសិទ្ធិពីភាគហ៊ុនិកណាម្នាក់ ឬខ្លួនជាភាគហ៊ុនិក ។
  - មហាសន្និបាតភាគហ៊ុនិក ត្រូវប្រព្រឹត្តទៅនៅទីស្នាក់ការចុះបញ្ជីរបស់ កសស ឬនៅទីកន្លែងផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានកំណត់ដោយប្រធានក្រុមប្រឹក្សាភិបាល ។
  - សេចក្តីជូនដំណឹងស្តីពីមហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវផ្ញើទៅភាគហ៊ុនិកតាមរយៈលិខិត ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬតាមគ្រប់មធ្យោបាយសមស្របណាមួយដោយមានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈ ។

- សេចក្តីជូនដំណឹងត្រូវផ្ញើទៅភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោត ទៅអភិបាលរបស់ កសស មិនលើស ពី ២១ (ម្ភៃមួយ) ថ្ងៃ មុនកាលបរិច្ឆេទរបស់មហាសន្និបាតភាគហ៊ុនិក ។

- នីតិវិធីនៃការរៀបចំការបោះឆ្នោត
  - ដំណើរការនៃការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ កសស ត្រូវកំណត់ដូចខាងក្រោម ៖

<u>ការចុះវត្តមានអង្គបោះឆ្នោត និងកូរ៉ុម</u>

- ការចុះវត្តមាន ធ្វើនៅពេលមហាសន្និបាតភាគហ៊ុនិក ដោយភ្ជាប់មកជាមួយនូវលិខិតអញ្ជើញ ឬលេខអត្តសញ្ញាណវិនិយោគិន ។ ក្នុងករណីមានការផ្ទេរសិទ្ធិបោះឆ្នោត នោះអ្នកទទួលសិទ្ធិត្រូវភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិ និងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ ។
- អង្គបោះឆ្នោត គឺជាភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតទាំងអស់ មានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅថ្ងៃ កាលបរិច្ឆេទកំណត់ទុក (Record Date) ។
- ការបោះឆ្នោតអាចប្រព្រឹត្តទៅបាន លុះត្រាមានកូរ៉ុមវត្តមានភាគហ៊ុនិក តំណាងឱ្យចំនួនភាគហ៊ុនលើសពីពាក់កណ្តាលនៃភាគហ៊ុនសរុប ។

<u>ការប្រគល់សិទ្ធិ</u>

- ភាគហ៊ុនិក អាចប្រគល់សិទ្ធិឱ្យអ្នកតំណាងរបស់ខ្លួនចូលរួមបោះឆ្នោតជំនួសបាន។ ភាគហ៊ុនិកដែលប្រគល់សិទ្ធិឱ្យគេបោះឆ្នោតជំនួស មិនមានសិទ្ធិក្នុងការបោះឆ្នោតទៀតទេ ។
- អ្នកទទួលសិទ្ធិ ពុំចាំបាច់ជាម្ចាស់ភាគហ៊ុនទេ ។
- អ្នកទទួលសិទ្ធិ អាចទទួលបានការប្រគល់សិទ្ធិ ពីភាគហ៊ុនិកតែម្នាក់ប៉ុណ្ណោះ ។
- លិខិតប្រគល់សិទ្ធិ ត្រូវផ្តល់ជូនមកគណៈកម្មការរៀបចំការបោះឆ្នោត ឱ្យបានមុនពេលដំណើរការបោះឆ្នោត ។ ការប្រគល់សិទ្ធិ ត្រូវប្រកាសជាសាធារណៈក្នុងមហាសន្និបាតភាគហ៊ុនិក ។
- លិខិតប្រគល់សិទ្ធិ ត្រូវភ្ជាប់ជូនមកជាមួយនូវលិខិតអញ្ជើញ ។
- លិខិតប្រគល់សិទ្ធិ ត្រូវមានហត្ថលេខារបស់ភាគហ៊ុនិកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិ ។

<u>ការឃោសនាបោះឆ្នោត</u>

- ការឃោសនាបោះឆ្នោតមានរយៈពេល ១០នាទី សម្រាប់បេក្ខជនដើម្បីបង្ហាញ និងណែនាំពីសមត្ថភាព បទពិសោធន៍ការងារ និងទិសដៅការងារ ។
- ការឃោសនា ត្រូវធ្វើឡើងនៅក្នុងមហាសន្និបាតក្រោមរូបភាពដោយផ្ទាល់មាត់ ឬ/និង ដោយបទបង្ហាញជាស្លាយ (Power Point Slide) ។
- គ្រប់រូបភាព និងសកម្មភាពឃោសនា មិនត្រូវមានការវាយប្រហារិះគន់លើបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ឬសកម្មភាពការងាររបស់បេក្ខជនដទៃឡើយ ។ ក្នុងករណីមានការបំពាន គណៈកម្មការរៀបចំការបោះឆ្នោតមានសិទ្ធិបញ្ឈប់ការឃោសនារបស់បេក្ខជននោះភ្លាមៗ ។

<u>ការិយាល័យបោះឆ្នោត និងបន្ទប់សម្ងាត់</u>

- ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការរៀបចំការបោះឆ្នោត ។
- ការិយាល័យបោះឆ្នោត ត្រូវរៀបចំក្នុងសាលមហាសន្និបាត ។ ការិយាល័យបោះឆ្នោតត្រូវមានបន្ទប់សម្ងាត់តាមការចំបាច់សម្រាប់ភាគហ៊ុនិកចូលទៅបោះឆ្នោត ។
- ការិយាល័យបោះឆ្នោត ត្រូវមានសមាជិកគណៈកម្មការយ៉ាងតិច ៥ រូប រួមមានប្រធាន ១ រូប និងសមាជិកយ៉ាងតិចចំនួន ៤ រូប ។

- ប្រធានការិយាល័យបោះឆ្នោតទទួលពិនិត្យការងាររួម និងប្រកាសហៅឈ្មោះអ្នកបោះឆ្នោតតាមបញ្ជីចុះវត្តមាន ។ សមាជិក ២ រូប ទទួលបន្ទុកសណ្តាប់ធ្នាប់ខាងក្រៅការិយាល័យ និងចំនួន ២ រូបទៀតទទួលបន្ទុកសណ្តាប់ធ្នាប់ខាងក្នុងការិយាល័យ ។

<u>របៀបនៃការបោះឆ្នោត</u>

- របៀបនៃការបោះឆ្នោត ត្រូវធ្វើឡើងដោយការហៅឈ្មោះភាគហ៊ុនិក ដែលបានចុះបញ្ជីវត្តមាន ដោយក្នុងមួយលើកមានចំនួន ១០ រូប ។
- ប្រធានមហាសន្និបាត សមាជិកក្រុមប្រឹក្សាភិបាល បេក្ខជនឈរឈ្មោះ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតទាំងអស់ ត្រូវបានអនុញ្ញាតឱ្យឡើងធ្វើការបោះឆ្នោតមុន ។
- ភាគហ៊ុនិក ដែលអវត្តមានពេលប្រកាសហៅឈ្មោះ ត្រូវផ្តល់ឱកាសឱ្យឡើងបោះឆ្នោតបាននៅពេលភាគហ៊ុនិករូបនោះមានវត្តមានពេលកំពុងបោះឆ្នោត និងមុនពេលប្រកាសបិទការិយាល័យបោះឆ្នោតជាផ្លូវការ ។
- ភាគហ៊ុនិកដែលត្រូវបានហៅឈ្មោះឱ្យឡើងទៅបោះឆ្នោត ត្រូវចូលទៅបន្ទប់សម្ងាត់បោះឆ្នោត ដើម្បីទម្លាក់បណ្ណបោះឆ្នោតគាំទ្របេក្ខជនឈរឈ្មោះ ដែលខ្លួនពេញចិត្តនៅក្នុងហិបឆ្នោតដែលមានបិទឈ្មោះនិងរូបថតរបស់បេក្ខភាពជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

<u>ការបោះឆ្នោត</u>

- ការបោះឆ្នោតជ្រើសតាំងជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ និងតម្លាភាព ។
- ការបោះឆ្នោតជ្រើសតាំង ធ្វើឡើងតាមប្រព័ន្ធជាឯកត្តនាម ។
- ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ ធ្វើឡើងដោយភាគហ៊ុនិកសាធារណៈ និងភាគហ៊ុនិកឯកជន។
- ការបោះឆ្នោតជ្រើសតាំង អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ធ្វើឡើងដោយភាគហ៊ុនិកឯកជនតែប៉ុណ្ណោះ ដោយពុំអនុញ្ញាតឱ្យភាគហ៊ុនិកសាធារណៈចូលរួមបោះឆ្នោតឡើយ ។
- បេក្ខជនដែលឈរឈ្មោះហើយជាប់ឆ្នោត គឺជាបេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេ។
- ការបោះឆ្នោតជ្រើសតាំងជាអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ត្រូវធ្វើតែមួយលើក ។
- គណៈកម្មការរៀបចំការបោះឆ្នោត មានសមត្ថកិច្ចដោះស្រាយនូវរាល់បញ្ហា ដែលកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត ។

<u>បណ្ណបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល</u>

បណ្ណបោះឆ្នោតមាន ២ ប្រភេទ ៖

- ពណ៌ខៀវ សម្រាប់ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ
- ពណ៌ក្រហម សម្រាប់ការបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។
- បណ្ណបោះឆ្នោតនឹងត្រូវផ្តល់ជូននៅពេលដែលភាគហ៊ុនិក ឬអ្នកផ្ទេរសិទ្ធិចុះវត្តមាន។ បណ្ណបោះឆ្នោតមានបញ្ជាក់ពីលេខអត្តសញ្ញាណវិនិយោគិន និងចំនួនភាគហ៊ុនដែលភាគហ៊ុនិកកាន់កាប់ ។
- ភាគហ៊ុនិកត្រូវទម្លាក់បណ្ណបោះឆ្នោត ទៅក្នុងហិបឆ្នោតឱ្យបានត្រឹមត្រូវ តាមពណ៌នៃបណ្ណបោះឆ្នោត។ ការទម្លាក់បណ្ណបោះឆ្នោតខុសហិបឆ្នោត ឬគូសលើបណ្ណបោះឆ្នោត ឬសរសេរបន្ថែមដោយអ្នកបោះឆ្នោត ត្រូវចាត់ទុកជាបណ្ណបោះឆ្នោតឥតបានការ ។
- ភាគហ៊ុនិក អាចសុំជំនួយពីគណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីណែនាំពីរបៀបបោះឆ្នោតឱ្យបានត្រឹមត្រូវ ។

- ការរាប់ និងការបូកសរុបលទ្ធផលបោះឆ្នោត ត្រូវធ្វើតាមប្រព័ន្ធព័ត៌មានវិទ្យា (កុំព្យូទ័រ) ។
- ប្រធានការិយាល័យបោះឆ្នោតត្រូវពិនិត្យ និងលើកបង្ហាញបណ្ណបោះឆ្នោត ហើយសមាជិក ២ រូប ត្រូវកត់ត្រាតាមប្រព័ន្ធកុំព្យូទ័រ និង ២ រូបទៀត ត្រូវរៀបបណ្ណបោះឆ្នោតតាមពំនូកនូវបណ្ណបោះឆ្នោតបានការ និងមិនបានការ ។
- លទ្ធផលនៃការបោះឆ្នោតត្រូវប្រកាសដោយប្រធានមហាសន្និបាតភាគហ៊ុនិក ។

<u>ការប្ដឹងតវ៉ាចំពោះលទ្ធផលបោះឆ្នោត</u>

- គណៈកម្មការរៀបចំការបោះឆ្នោត មានសមត្ថកិច្ចដោះស្រាយបញ្ហានានាដែលកើតមាននៅក្រោយពេលបោះឆ្នោត ។
- បេក្ខជនដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិប្ដឹងតវ៉ាចំពោះលទ្ធផលបោះឆ្នោតបាន នៅចំពោះមុខគណៈកម្មការរៀបចំការបោះឆ្នោត ។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្ដីសម្រេច |
|---|---|---|---|---|---|
| ១ | ១៩ មិថុនា ២០២៥ | សាមញ្ញ | ៨២.០៧៤.៧៤៦ ភាគហ៊ុន ស្មើនឹង ៩៥,៦៩% នៃចំនួនភាគហ៊ុនសរុប | - របាយការណ៍ស្ដីពី លទ្ធផលអាជីវកម្ម-សេវាកម្មឆ្នាំ២០២៤<br>- របាយការណ៍ស្ដីពី លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០២៤ (បានធ្វើសវនកម្ម)<br>- ទិសដៅការងារឆ្នាំ២០២៥<br>- ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២៤ និងប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអមកសស សម្រាប់ឆ្នាំ២០២៥ | - ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២៤<br>• ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥.០០០.០០០.០០០ រៀល<br>• ភាគហ៊ុនិកប្រភេទ "គ" មានចំនួន ១១% នៃតម្លៃ IPO (៥.០៤០ រៀល) ស្មើនឹង ១១.៨៧៩.៤១៧.៥៦៨ រៀល<br>- ការអនុម័តលើប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋឆ្នាំ២០២៥ ។ |

# ឃ. ការបែងចែកភាគលាភ

## ១. គោលនយោបាយបែងចែកភាគលាភ

ដើម្បីជាការលើកទឹកចិត្តដល់វិនិយោគិន ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយភាគលាភ ដែលមានការធានាទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំស្មើនឹងចំនួន ៥% នៃទំហំវិនិយោគ ដោយគិតតាមថ្លៃបោះផ្សាយលក់មូលបត្រ (IPO) សម្រាប់រយៈពេល ៣ឆ្នាំ បន្ទាប់ពីការចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា ។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះ គឺនឹងផ្ដល់ជូនចំពោះមូលបត្រកម្មសិទ្ធដែលមានសិទ្ធបោះឆ្នោតប្រភេទ "គ" តែប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធមានសិទ្ធបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធគ្មានសិទ្ធបោះឆ្នោតប្រភេទ "ក" មិនទទួលបានការធានាភាគលាភទេ ។

ក្រោយពីផុតការធានារយៈពេល ៣ឆ្នាំ រួចមក ការបែងចែកភាគលាភត្រូវបានស្នើឡើងដោយក្រុមប្រឹក្សាភិបាល ហើយដាក់ឱ្យមហាសន្និបាតភាគហ៊ុនិកធ្វើការសម្រេច ។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ព្រឹត្តិការណ៍លម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ១៩-មិថុនា-២០២៥ | ២១-មិថុនា-២០២៤ | ០៩-មិថុនា-២០២៣ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ០៣-កក្កដា-២០២៥ | ០៥-កក្កដា-២០២៤ | ២០-មិថុនា-២០២៣ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ១៥-កក្កដា-២០២៥ | ១៦-កក្កដា-២០២៤ | ២៨-មិថុនា-២០២៣ |

# ផ្នែកទី២

# ក្រុមប្រឹក្សាភិបាល

## ក. ក្រុមប្រឹក្សាភិបាល

## ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម លូ គឹមឈន់ | ប្រធាន | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ២ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៣ | ឯកឧត្តម ឈួន រិន | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៤ | ឯកឧត្តម គឹម ស៊ីថន | សមាជិក | ២១-ឧសភា-២០២៤ | ២០-ឧសភា-២០២៨ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ២១-មិថុនា-២០២៤ | ២០-មិថុនា-២០២៨ |
| ៦ | លោក KUME Hidetoshi | សមាជិក | ២១-មិថុនា-២០២៤ | ២០-មិថុនា-២០២៨ |
| ៧ | លោក លូ លីខេង | សមាជិក | ០២-ឧសភា-២០២៤ | ០១-ឧសភា-២០២៨ |

## ២. ជីវប្រវត្តិសង្ខេបរបស់អភិបាល



### ឯកឧត្តម លូ គឹមឈន់
### ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

ឯកឧត្តម កើតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៥៦ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃកពោធិ៍ ឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

**<u>ប្រវត្តិនៃការសិក្សា</u>**

ឯកឧត្តមទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញវិស្វកម្មសំណង់ផ្លូវទឹក និងកំពង់ផែ ក្នុងឆ្នាំ១៩៨៦ ពីអតីតសហភាពសូវៀត សញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញពាណិជ្ជសាស្ត្រ ក្នុងឆ្នាំ២០០៦ និងសញ្ញាបត្រថ្នាក់ បណ្ឌិត ជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៨ ។

**<u>បទពិសោធន៍ការងារ</u>**

ក្នុងអំឡុងឆ្នាំ១៩៨៦ ឯកឧត្តមបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាបុគ្គលិកវិស្វករសំណង់ នៃនាយកដ្ឋានបច្ចេកទេសសម្ភារៈសំណង់ ។ ចាប់ពីឆ្នាំ១៩៩០ ដល់ ឆ្នាំ១៩៩២ ឯកឧត្តម ជាអនុប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។ ចាប់ពីឆ្នាំ១៩៩២ ដល់ ឆ្នាំ១៩៩៩ ឯកឧត្តម ជាប្រធានកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។ ចាប់ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៨ ឯកឧត្តម ជាប្រធានអគ្គនាយកកំពង់ផែក្រុងព្រះសីហនុ និងចាប់ពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។



# ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា

## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម កើតនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត សង្កាត់លេខ១ ក្រុងភ្នំពេញ ។

## ប្រវត្តិនៃការសិក្សា

ឯកឧត្តមទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រ ជំនាញរដ្ឋបាលពាណិជ្ជកម្ម ក្នុងឆ្នាំ១៩៩៦ នៅសាកលវិទ្យាល័យ Hawaii Pacific សហរដ្ឋអាមេរិក។ បន្ថែមលើនេះ ឯកឧត្តមទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញពាណិជ្ជកម្ម ក្នុងឆ្នាំ១៩៩៩ នៅសាកលវិទ្យាល័យ New South Wales និងទទួលបានសញ្ញាបត្រថ្នាក់ បណ្ឌិត ជំនាញសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤ នៅសាកលវិទ្យាល័យ Wollongong ប្រទេសអូស្ត្រាលី ។

## បទពិសោធន៍ការងារ

ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នៅអំឡុងឆ្នាំ២០០៤ ។ ឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) កម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំយុទ្ធសាស្ត្រជាតិនិងតាមវិស័យ យុទ្ធសាស្ត្រកៀរគរចំណូល ការវិភាគនិងគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញក្នុងបរិបទការរស់នៅជាមួយជំងឺកូវីដ-១៩ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ។ បច្ចុប្បន្ន ឯកឧត្តមជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាភិបាលធនាគារសហគ្រាសធុនតូចនិងមធ្យម និងជាប្រធានក្រុមប្រឹក្សាភិបាលមូលនិធិអភិវឌ្ឍន៍ជំនាញ ។



# ឯកឧត្តម ឈួន ទិន

## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ឯកឧត្តម កើតនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៨០ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ភូមិព្រៃកពោធិ៍ ឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

## ប្រវត្តិនៃការសិក្សា

ឯកឧត្តមទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំ១៩៩៧ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០១ នៅវិទ្យាស្ថានជាតិគ្រប់គ្រង និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគណនេយ្យ-ហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៤ នៅសាកលវិទ្យាល័យ Greenwich ប្រទេសអង់គ្លេស ។ បន្ថែមលើនេះ ឯកឧត្តមទទួលបានសញ្ញាបត្រមន្ត្រីជាន់ខ្ពស់ ជំនាន់អភិបាលកិច្ចល្អ ជំនាញគ្រប់គ្រង ដឹកនាំ និងរដ្ឋបាលសាធារណៈ ក្នុងឆ្នាំ២០០៧ នៅសាលាភូមិន្ទរដ្ឋបាល ប្រទេសកម្ពុជា ។

## បទពិសោធន៍ការងារ

នៅឆ្នាំ២០០៧ ឯកឧត្តមបានចូលបម្រើការងារជាមន្ត្រីនៅក្រសួងសាធារណការ និងដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាជំនួយការ និងជានាយកខុទ្ទកាល័យ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ ឯកឧត្តមជាអនុប្រធាននាយកដ្ឋាន និងចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ ឯកឧត្តមជាអគ្គនាយករង នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩ ឯកឧត្តមជាអនុរដ្ឋលេខាធិការ និងចាប់ពីឆ្នាំ២០១៩ ដល់បច្ចុប្បន្ន ឯកឧត្តមជា រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។



# ឯកឧត្តម គឹម ស៊ីថន
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងក្រសួងពាណិជ្ជកម្ម

ឯកឧត្តម កើតនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥០ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត សង្កាត់លេខ៥ ក្រុងភ្នំពេញ។

## ប្រវត្តិនៃការសិក្សា

ឯកឧត្តម ទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្ររង ជំនាញបច្ចេកទេសអគ្គិសនី ក្នុងឆ្នាំ១៩៨៦ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្រទេសកម្ពុជា និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រ ជំនាញសេដ្ឋកិច្ច ក្នុងឆ្នាំ១៩៩២ នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រទេសកម្ពុជា និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ១៩៩៧ នៅសាកលវិទ្យាល័យ London ប្រទេសអង់គ្លេស ។ បន្ថែមលើនេះ ឯកឧត្តមទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគោលនយោបាយសាធារណៈ ក្នុងឆ្នាំ២០០០ នៅសាកលវិទ្យាល័យ Saitama ប្រទេសជប៉ុន និងទទួលបានសញ្ញាបត្រថ្នាក់ បណ្ឌិត ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ក្នុងឆ្នាំ២០០៦ នៅមហាវិទ្យាល័យ Ashwood ។

## បទពិសោធន៍ការងារ

នៅអំឡុងឆ្នាំ១៩៧៩ ឯកឧត្តមបានចូលបម្រើការងារនៅសមាគមមិត្តភាព កម្ពុជា-វៀតណាម ។ ចាប់ពីឆ្នាំ ១៩៨០ ដល់ឆ្នាំ១៩៨១ ឯកឧត្តមបម្រើការងារនៅគណៈឃោសនាអប់រំមជ្ឈឹម ។ ចាប់ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៤ ឯកឧត្តមជាប្រធានការិយាល័យចាត់តាំង ចាប់ពីឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៦ ជាអនុប្រធាននាយកដ្ឋានចាត់តាំង និងចាប់ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៨ ជាប្រធាននាយកដ្ឋានគ្រប់គ្រងជំនាញការទូទាំងប្រទេស នៃក្រុមប្រឹក្សារដ្ឋមន្ត្រី ។ ចាប់ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩៧ ឯកឧត្តមជាប្រធាននាយកដ្ឋានបុគ្គលិក និងចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៨ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤ ឯកឧត្តមជាអនុរដ្ឋលេខាធិការ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៨ ជារដ្ឋលេខាធិការ និងចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងពាណិជ្ជកម្ម ។



# លោក ហ៊ុន មុន្នីវណ្ណ

## អភិបាលឯករាជ្យ

លោក ហ៊ុន មុន្នីវណ្ណ កើតនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៣ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

## ប្រវត្តិនៃការសិក្សា

ក្នុងឆ្នាំ១៩៩៧ លោកទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រគ្រប់គ្រង ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វេទមហាឥសី ប្រទេសកម្ពុជា និងក្នុងឆ្នាំ២០២៤ លោកទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រង នៅសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ប្រទេសកម្ពុជា រួមជាមួយការបណ្តុះបណ្តាលក្រៅប្រទេសពី Harvard Business School សហរដ្ឋអាមេរិក និងសាកលវិទ្យាល័យក្រុងឡុងដ៍ ចក្រភពអង់គ្លេស ។

## បទពិសោធន៍ការងារ

នៅអំឡុងឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩២ លោកបានចូលបម្រើការងារនៅអង្គភាពនយោបាយ T88 កងប្រដាប់អាវុធនៃកម្ពុជា មានតួនាទីជាជំនួយការប្រធានអង្គភាព ។ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០ លោកជាសវនករជាន់ខ្ពស់ នៃក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young រាជធានីភ្នំពេញ ។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ លោកជាមន្ត្រីរដ្ឋាភិបាលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨ លោកជាប្រធានហិរញ្ញវត្ថុ នៃសិប្បករអង្គរ ខ.,អិលធីឌី និងចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ លោកជាសមាជិកក្រុមប្រឹក្សាភិបាល តំណាងឱ្យបុគ្គលិកក្នុងក្រុមហ៊ុន ។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ លោកជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម នៃស្ថាបនាលីមីតធីត ។ ចាប់ពីឆ្នាំ២០០៦ ដល់បច្ចុប្បន្ន លោកបានចូលរួម និងបម្រើយ៉ាងសកម្ម ជាអ្នកសម្របសម្រួលមូលនិធិសម្រាប់គម្រោងសប្បុរសធម៌ផ្សេងៗ ។ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២២ លោកជាប្រធានក្រុមហ៊ុនធនធានមនុស្សឈានមុខគេមួយនៅកម្ពុជា ដែលគេស្គាល់ថា អេផ្លើស ឧនសាល់ធីង ឯ.ក ។ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ លោកជាប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្ម របស់ស្ថាបនា លីមីតធីត ។ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ លោកជាក្រុមប្រឹក្សាភិបាលនៃសមាគមសហគ្រិនវ័យក្មេងនៅកម្ពុជា (YEAC) ។ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០២៤ លោកជាអនុប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប និងខេត្តឧត្តមានជ័យ (SROCC) ។ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣ លោកជាប្រធានសមាគមអតីតនិស្សិត IATSS កម្ពុជា (CIAA) ។ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ លោកជាម្ចាស់ភាគហ៊ុន និងជានាយកប្រតិបត្តិក្រុមហ៊ុនអ៊ែកធីវ ប្រធីធី (ខេមបូឌា) ។ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ លោកជានាយកឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម នៃធនាគារស្ថាបនា ភីអិលស៊ី ។ ឆ្នាំ២០១៧ លោកជាអនុប្រធានសាលាពាណិជ្ជកម្ម LSi ។ ឆ្នាំ២០១៨ ដល់បច្ចុប្បន្ន លោកជាប្រធានក្រុមហ៊ុន អិមវីយូ អ៊ិនវេសម៉ិន ម.ក ។ ឆ្នាំ២០២១ ដល់បច្ចុប្បន្ន លោកជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនមេហ្គា លីស៊ីង ភីអិលស៊ី និងជាប្រធានក្រុមហ៊ុន អមរាឃៃភីថល ម.ក ។



# លោក KUME Hidetoshi

## អភិបាលមិនប្រតិបត្តិ
## តំណាងភាគហ៊ុនិកឯកជន

លោក KUME Hidetoshi កើតនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិ ជប៉ុន ។

**ប្រវត្តិនៃការសិក្សា**

លោក ទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រវិស្វករ ជំនាញវិស្វករប្រព្រឹត្តកម្មប្រព័ន្ធទឹកកខ្វក់ ក្នុងឆ្នាំ១៩៨០ ពីសាកលវិទ្យាល័យ Kyushu និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញវិស្វករប្រព្រឹត្តកម្មប្រព័ន្ធទឹកកខ្វក់ ក្នុងឆ្នាំ១៩៨២ ពីសាកលវិទ្យាល័យ Kyushu ប្រទេសជប៉ុន ។

**បទពិសោធន៍ការងារ**

នៅអំឡុងឆ្នាំ១៩៨២ លោកបានចូលបម្រើការងារជាមន្ត្រីបច្ចេកទេស ផ្នែកអភិវឌ្ឍន៍កំពង់ផែ និងសមុទ្រនៅក្រសួងដឹកជញ្ជូន (Ministry of Transport-MOT) ។ ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩០ លោកជាមន្ត្រីរៀបចំផែនការផ្នែកអភិវឌ្ឍន៍តំបន់ទីក្រុង (តំបន់ Kansai) និងចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩២ លោកមានតួនាទីជាប្រធានផ្នែករៀបចំផែនការ ទទួលបន្ទុកលើកិច្ចសហប្រតិបត្តិការបច្ចេកទេសដល់សិក្ខាកាមពីបរទេស ក្នុងវិស័យកំពង់ផែ និងអាកាសយានដ្ឋាន នៅវិទ្យាស្ថានស្រាវជ្រាវផ្នែកកំពង់ផែ និងនាវាចរ នៃក្រសួងដឹកជញ្ជូន (MOT) ។ ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ លោកមានតួនាទីជាលេខាធិការទី១ ផ្នែកសេដ្ឋកិច្ច ទទួលបន្ទុកលើជំនួយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលជប៉ុន ផ្តល់ជូនប្រទេសហ្វីលីពីន នៅស្ថានទូតជប៉ុនប្រចាំប្រទេសភីលីពីន ។ ចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ លោកមានតួនាទីជាប្រធានការិយាល័យសំណង់កំពង់ផែ និងអាកាសយានដ្ឋាន តាកាម៉ាតស៊ូ (Takamatsu) នៃនាយកដ្ឋានសំណង់កំពង់ផែភូមិភាគទី៣ នៃក្រសួងដឹកជញ្ជូន ។ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៩ លោកជាអ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកផែនការ ទទួលបន្ទុកលើការសិក្សាស្តីពី "ការសិក្សាអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍កំពង់ផែនៅក្នុងប្រទេសឥណ្ឌូនេស៊ី" ដែលជាគម្រោងកិច្ចសន្ទនាគោលនយោបាយលើកដំបូងរបស់ JICA ក្នុងវិស័យអភិវឌ្ឍន៍កំពង់ផែ នៅវិទ្យាស្ថានអភិវឌ្ឍន៍តំបន់ឆ្នេរក្រៅប្រទេស (OCDI) និងចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ លោកជាប្រធានការិយាល័យសំណង់កំពង់ផែ និងអាកាសយានដ្ឋានកាស៊ីម៉ា (Kashima) នៃនាយកដ្ឋានសំណង់កំពង់ផែភូមិភាគទី២ នៃក្រសួងដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ លោកជាទីប្រឹក្សាផ្នែកសាងសង់ នៃរដ្ឋបាលខេត្តអូគីណាវ៉ា ។ ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ លោកមានតួនាទីជាអនុប្រធាននាយកដ្ឋានបង្ការគ្រោះមហន្តរាយ និងជាអនុប្រធាននាយកដ្ឋានជម្រុញការចូលរួមពីវិស័យឯកជន នៃអគ្គនាយកដ្ឋានកំពង់ផែ និងនាវាចរ ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន (MLIT) ។ ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ លោកមានតួនាទីជាទីប្រឹក្សានាយកដ្ឋានកំពង់ផែ នៃរដ្ឋបាលក្រុងហ្វូគូអូកា (Fukuoka City Government) ។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ លោកមានតួនាទីជា អ្នកស្រាវជ្រាវជាន់ខ្ពស់ទទួលបន្ទុកគម្រោងស្រាវជ្រាវអន្តរជាតិ "ការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រដឹកជញ្ជូនអន្តរទីក្រុង" នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ លោកមានតួនាទីជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន Hokuriku Shinetsu នៅក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន (MLIT) និងចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ លោកមានតួនាទីជានាយកសិក្សាស្រាវជ្រាវ នៅវិទ្យាស្ថានការសិក្សាគោលនយោបាយដឹកជញ្ជូន ។ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ លោកជានាយកប្រតិបត្តិនៅមជ្ឈមណ្ឌលកែលម្អបរិស្ថានសមុទ្រតំបន់ឆ្នេរ Osaka Bay ។ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ លោកជាជំនាញការ JICA ទទួលបន្ទុកប្រឹក្សាគោលនយោបាយដឹកជញ្ជូន ប្រចាំនៅក្រសួងសាធារណការនិងដឹកជញ្ជូន ប្រទេសកម្ពុជា និងចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន លោកជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងជានាយកសមាគមដឹកជញ្ជូនកំពង់ផែជប៉ុន ។



# លោក លូ លីខេង
## សមាជិកក្រុមប្រឹក្សាភិបាល
## តំណាងនិយោជិត កសស

លោក លូ លីខេង កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត ឃុំឬស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

**ប្រវត្តិនៃការសិក្សា**

លោកទទួលបានសញ្ញាបត្រថ្នាក់ សញ្ញាបត្រវិស្វករ ជំនាញគីមីចំណីអាហារ ក្នុងឆ្នាំ១៩៩៦ ពីវិទ្យាស្ថានបច្ចេកទេសកម្ពុជា (សាលាតិចណូ) និងទទួលបានសញ្ញាបត្រថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញពាណិជ្ជសាស្ត្រ ក្នុងឆ្នាំ២០០៦ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជា ។

**បទពិសោធន៍ការងារ**

ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៣ លោកបានចូលបម្រើការងារជាមន្ត្រីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ នៅអំឡុងឆ្នាំ២០០៣ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាបុគ្គលិកផ្នែកកត់ត្រាទំនិញកុងតឺន័រពីទីលាន ។ ចាប់ពី ឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ លោកជាប្រធានផ្នែកត្រួតពិនិត្យ និងរៀបចំកុងតឺន័រ ។ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ លោកជានាយករង ទទួលបន្ទុករួមចាត់ចែងត្រួតពិនិត្យភារកិច្ចទូទៅនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅ ។ ចាប់ពីឆ្នាំ២០១៣ ដល់បច្ចុប្បន្ន លោកជាតំណាងនិយោជិត និងចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន លោកជានាយកប្រតិបត្តិការទំនិញទូទៅ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

## ៣. ករណីអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធរបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធករ |
|---|---|---|---|
| ១ | ឯកឧត្តម លូ គឹមឈន់ | មិនមាន | |
| ២ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា | មិនមាន | |
| ៣ | ឯកឧត្តម ឈួន រិន | មិនមាន | |
| ៤ | ឯកឧត្តម កឹម ស៊ីថន | មិនមាន | |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | ១. ក្រុមហ៊ុន អមរា ឃែភីថល ម.ក<br>២. ក្រុមហ៊ុន អិមវ៉ែយូ អ៊ិនវេសម៉ិន ម.ក<br>៣. ក្រុមហ៊ុន មេហ្គា លីស៊ីង ភីអិលស៊ី | ប្រធានក្រុមហ៊ុន<br>ប្រធានក្រុមហ៊ុន<br>ប្រធានក្រុមប្រឹក្សាភិបាល |
| ៦ | លោក KUME Hidetoshi | មិនមាន | |
| ៧ | លោក លូ លីខេង | មិនមាន | |

## ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់នូវបេសកកម្មរួមសម្រាប់តម្រង់ទិស និងត្រួតពិនិត្យលើ កសស ។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាលមានតួនាទី ភារកិច្ច ការទទួលខុសត្រូវ ដូចខាងក្រោម ៖

- សម្រេចតាមសំណើរបស់អគ្គនាយក នូវលក្ខន្តិកៈបុគ្គលិករចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ កសស ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាធរមាន
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ កសស
- ពិនិត្យ និងអនុម័តលើផែនការអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃការតម្រង់ទិសរបស់ កសស
- ពិនិត្យ និងអនុម័តផែនការអាជីវកម្ម សេវាកម្ម ហិរញ្ញវត្ថុ និងវិនិយោគរបស់ កសស
- អនុម័តលើរបាយការណ៍របស់សវនករឯករាជ្យប្រចាំត្រីមាស និងប្រចាំឆ្នាំ
- អនុម័តលើរបាយការណ៍សកម្មភាពការងារប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ចាត់ចែងធ្វើឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដែលបានកំណត់ដោយអនុក្រឹត្យ ស្តីពីការបង្កើត កសស ឬ ដោយលក្ខន្តិកៈរបស់ កសស
- អនុម័តចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ កសស និងការផ្តល់លាភការសម្រាប់ បុគ្គលិក-និយោជិត ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់នូវកម្រិតនៃការធ្វើឱ្យសម្រេចនូវគោលដៅ ដែលកំណត់ដោយ កសស និងដាក់ចេញនូវវិធានការសម្រាប់កែលម្អចាំបាច់
- ពិនិត្យ និងអនុម័តលើសំណើសុំកែសម្រួលលក្ខន្តិកៈ កសស និងលក្ខន្តិកៈបុគ្គលិក
- ពិនិត្យ និងអនុម័តថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មរបស់ កសស
- ពិនិត្យ និងអនុម័តលើគម្រោងបែងចែកប្រាក់ចំណេញ ឬគម្រោងបំពេញឱនភាព កសស
- ពិនិត្យ និងអនុម័តលើសំណូមពរក្នុងការបង្កើន ឬ បន្ថយដើមទុនរបស់ កសស
- ពិនិត្យ និងអនុម័តលើការអនុវត្តកិច្ចលទ្ធកម្មនានារបស់ កសស
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សាខា ទីភ្នាក់ងារ ឬ តំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ កសស
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណា ដែលមិនអាចអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ

ក្រុមប្រឹក្សាភិបាលអនុវត្តសិទ្ធិ និងអំណាចផ្សេងទៀត ដូចមានកំណត់នៅក្នុងច្បាប់ស្តីពី សហគ្រាសសាធារណៈ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ៣-មករា-២០២៥ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អាណត្តិទី៩<br>ពិភាក្សា និងអនុម័ត<br>(វិសាមញ្ញ) | ឯកឧត្តម លូ គឹមឈន់<br>ឯកឧត្តម ឈួន រិន<br>ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម គឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. KUME Hidetoshi<br>លោក លូ លីខេង |
| ២ | ៨-កុម្ភៈ-២០២៥ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អាណត្តិទី៩ លើកទី៣<br>ពិភាក្សា និងអនុម័ត<br>(សាមញ្ញ) | ឯកឧត្តម លូ គឹមឈន់<br>ឯកឧត្តម ឈួន រិន<br>ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម គឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. KUME Hidetoshi<br>លោក លូ លីខេង |
| ៣ | ២០-ឧសភា-២០២៥ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អាណត្តិទី៩ លើកទី៤<br>ពិភាក្សា និងអនុម័ត<br>(សាមញ្ញ) | ឯកឧត្តម លូ គឹមឈន់<br>ឯកឧត្តម ឈួន រិន<br>ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម គឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. KUME Hidetoshi<br>លោក លូ លីខេង |
| ៤ | ១៨-សីហា-២០២៥ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អាណត្តិទី៩ លើកទី៥<br>ពិភាក្សា និងអនុម័ត<br>(សាមញ្ញ) | ឯកឧត្តម លូ គឹមឈន់<br>ឯកឧត្តម ឈួន រិន<br>ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម គឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. KUME Hidetoshi<br>លោក លូ លីខេង |
| ៥ | ២១-វិច្ឆិកា-២០២៥ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អាណត្តិទី៩ លើកទី៦<br>ពិភាក្សា និងអនុម័ត<br>(សាមញ្ញ) | ឯកឧត្តម លូ គឹមឈន់<br>ឯកឧត្តម ឈួន រិន<br>ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម គឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>Mr. KUME Hidetoshi<br>លោក លូ លីខេង |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១.១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ហ៊ុន មុន្នីវណ្ណ | ប្រធាន | ១៩-សីហា-២០២៤ | ៤ | ៤ |
| ២ | ឯកឧត្តម គឹម ស៊ីថន | អនុប្រធាន | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៣ | លោក KUME Hidetoshi | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៤ | លោក ណុំ ស៊ីនិត | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៥ | លោក ទី សាគុណ | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៦ | លោក ម៉ែន ចាន់ | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៧ | លោក សូ សៀង | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |

- **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម**

  គណៈកម្មាធិការសវនកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖
  - ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
  - ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
  - ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
  - ពិនិត្យការធ្វើសវនកម្មខាងក្រៅ
  - ធ្វើសវនកម្មលើសកម្មភាពការងារ និងអាជីវកម្ម កសស
  - រាយការណ៍ជូនក្រុមប្រឹក្សាភិបាលលើសកម្មភាពការងាររបស់ខ្លួន
  - បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

- **លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម**

  នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការសវនកម្ម បានរៀបចំកិច្ចប្រជុំចំនួន ៤ លើក ដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈកម្មាធិការសវនកម្ម | តំណាងថ្នាក់ដឹកនាំ កសស |
|---|---|---|---|---|
| ១ | ៧-កុម្ភៈ-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការសវនកម្ម<br>អាណត្តិទី៩ លើកទី៣ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯកឧត្តម គឹម ស៊ីថន<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់<br>លោក សូ សៀង | លោក ថៃ ឬទ្ធី<br>លោក វ័ន្ត សិលា<br>លោក ពិត ប្រាកដ<br>លោក គឹម ហោ |
| ២ | ១៩-ឧសភា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការសវនកម្ម<br>អាណត្តិទី៩ លើកទី៤ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯកឧត្តម សុខ សុភ័ក្រ្ត<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់<br>លោក សូ សៀង | លោក ថៃ ឬទ្ធី<br>លោក ពិត ប្រាកដ<br>លោក វ័ន្ត សិលា<br>លោក លូ លីខេង<br>លោក ថៃ ម៉េងលី<br>លោក ងួន រតនា |

| | | | | |
|---|---|---|---|---|
| ៣ | ១៧-សីហា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការសវនកម្ម<br>អាណត្តិទី៩ លើកទី៥ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯកឧត្តម គឹម ស៊ីថន<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់<br>លោក សូ សៀង | លោក ថៃ ឫទ្ធី<br>លោក រ័ត្ន សិលា<br>លោក ពិត ប្រាកដ<br>លោក មាន គឹង<br>លោក អ៊ុក វណ្ណារ៉ា<br>លោក ស៊ឹង សេណូ |
| ៤ | ២០-វិច្ឆិកា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការសវនកម្ម<br>អាណត្តិទី៩ លើកទី៦ | លោក ហ៊ុន មុន្នីវណ្ណ<br>ឯកឧត្តម គឹម ស៊ីថន<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ទី សាគុណ<br>លោក ម៉ែន ចាន់<br>លោក សូ សៀង | លោក ថៃ ឫទ្ធី<br>លោក រ័ត្ន សិលា<br>លោក ពិត ប្រាកដ<br>លោកស្រី ជ័យ សុគន្ធា<br>លោក ជីវ ច័ន្ទសុផល<br>លោក សោម ករណី<br>លោក គឹម ហោ |

នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការសវនកម្ម សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

**១. សម័យប្រជុំលើកទី១: ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥**

- ការពិនិត្យឡើងវិញ និងការឯកភាពលើកំណត់ហេតុប្រជុំគ្រាមុន
- បញ្ហាដែលកើតមានឡើង បន្ទាប់ពីកំណត់ហេតុប្រជុំគ្រាមុន
- វឌ្ឍនភាព និងលទ្ធផលសវនកម្មផ្ទៃក្នុង-របាយការណ៍ត្រីមាសទី៤ ឆ្នាំ២០២៤
- ការពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍សវនកម្មត្រីមាសទី៤ ឆ្នាំ២០២៤

**២. សម័យប្រជុំលើកទី២: ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥**

- ការពិនិត្យឡើងវិញ និងការឯកភាពលើកំណត់ហេតុប្រជុំគ្រាមុន
- បញ្ហាដែលកើតមានឡើង បន្ទាប់ពីអង្គប្រជុំគ្រាមុន
- វឌ្ឍនភាព និងលទ្ធផលសវនកម្មផ្ទៃក្នុង-របាយការណ៍ត្រីមាសទី១ ឆ្នាំ២០២៥
- ការពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍សវនកម្មត្រីមាសទី១ ឆ្នាំ២០២៥

**៣. សម័យប្រជុំលើកទី៣: ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥**

- ការពិនិត្យឡើងវិញ និងការឯកភាពលើកំណត់ហេតុប្រជុំគ្រាមុន
- បញ្ហាដែលកើតមានឡើង បន្ទាប់ពីកំណត់ហេតុប្រជុំគ្រាមុន
- វឌ្ឍនភាព និងលទ្ធផលសវនកម្មផ្ទៃក្នុង-របាយការណ៍ត្រីមាសទី២ ឆ្នាំ២០២៥
- ការពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍សវនកម្មត្រីមាសទី២ ឆ្នាំ២០២៥

**៤. សម័យប្រជុំលើកទី៤: ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥**

- ការពិនិត្យឡើងវិញ និងការឯកភាពលើកំណត់ហេតុប្រជុំគ្រាមុន
- បញ្ហាដែលកើតមានឡើង បន្ទាប់ពីអង្គប្រជុំគ្រាមុន
- វឌ្ឍនភាព និងលទ្ធផលសវនកម្មផ្ទៃក្នុង-របាយការណ៍ត្រីមាសទី៣ ឆ្នាំ២០២៥
- ការពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍សវនកម្មត្រីមាសទី៣ ឆ្នាំ២០២៥

## ១.២ គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ឈួន វិន | ប្រធាន | ១៩-សីហា-២០២៤ | ២ | ២ |
| ២ | ឯកឧត្តម កឹម ស៊ីថន | អនុប្រធាន | ១៩-សីហា-២០២៤ | ២ | ២ |
| ៣ | លោក លូ លីខេង | សមាជិក | ១៩-សីហា-២០២៤ | ២ | ២ |
| ៤ | លោក KUME Hidetoshi | សមាជិក | ១៩-សីហា-២០២៤ | ២ | ២ |
| ៥ | លោក ណុំ ស៊ីនិត | សមាជិក | ១៩-សីហា-២០២៤ | ២ | ២ |
| ៦ | លោក ថោង វីរ៉ូ | សមាជិក | ១៩-សីហា-២០២៤ | ២ | ២ |
| ៧ | លោក រ័ត្ន សិលា | សមាជិក | ១៩-សីហា-២០២៤ | ២ | ២ |

- **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ**

  គណៈកម្មាធិការតែងតាំង និងលាភការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

  - ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវឌ្ឍ និងនីតិវិធីនៃការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
  - វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើសុំទៅក្រុមប្រឹក្សាភិបាល
  - ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានា
  - រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬ ប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
  - បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

- **លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ**

  នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការតែងតាំង និងលាភការ បានរៀបចំកិច្ចប្រជុំចំនួន ២ លើក ដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈកម្មាធិការតែងតាំង និងលាភការ | តំណាងថ្នាក់ដឹកនាំ កសស |
|---|---|---|---|---|
| ១ | ១៩-ឧសភា-២០២៥ | កិច្ចប្រជុំ គណៈកម្មាធិការតែងតាំង និងលាភការ អាណត្តិទី៩ លើកទី២ | ឯកឧត្តម ឈួន វិន<br>ឯកឧត្តម កឹម ស៊ីថន<br>លោក លូ លីខេង<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ថោង វីរ៉ូ<br>លោក រ័ត្ន សិលា | លោក ថៃ ឫទ្ធី<br>លោក ពិត ប្រាកដ<br>លោក សូ សៀង<br>លោក ងួន រតនា |
| ២ | ២០-វិច្ឆិកា-២០២៥ | កិច្ចប្រជុំ គណៈកម្មាធិការតែងតាំង និងលាភការ អាណត្តិទី៩ លើកទី៣ | ឯកឧត្តម ឈួន វិន<br>ឯកឧត្តម កឹម ស៊ីថន<br>លោក លូ លីខេង<br>លោក KUME Hidetoshi<br>លោក ណុំ ស៊ីនិត<br>លោក ថោង វីរ៉ូ<br>លោក រ័ត្ន សិលា | លោក ថៃ ឫទ្ធី<br>លោក ពិត ប្រាកដ<br>លោក សូ សៀង<br>លោក សោម ករណី<br>លោក ថៃ ម៉េងលី |

នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការតែងតាំង និងលាភការ សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

**១. សម័យប្រជុំលើកទី១: ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី ការបណ្តុះបណ្តាលបុគ្គលិក កសស ៤ខែ ឆ្នាំ២០២៥
- ពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងារ ក្រុមប្រឹក្សាភិបាល កសស សម្រាប់ឆ្នាំ២០២៤
- ករណី ការបន្ថែមរបបសន្តិសុខសង្គម (ប្រាក់សោធននិវត្តន៍ប្រចាំខែ) ជូននិវត្តជន របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

**២. សម័យប្រជុំលើកទី២: ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី វឌ្ឍនភាពការងារព័ត៌មានវិទ្យា
- របាយការណ៍ របស់នាយកដ្ឋានប្រតិបត្តិការទីលានកុងតឺន័រ ស្តីពីតម្រូវការធនធានមនុស្ស ត្រៀមសម្រាប់ប្រតិបត្តិការចំណតផែកុងតឺន័រទឹកជ្រៅថ្មី-ជំហានទី១
- របាយការណ៍ស្តីពី ការបណ្តុះបណ្តាលបុគ្គលិក កសស ៩ខែ ឆ្នាំ២០២៥
- ពិនិត្យ និងផ្តល់យោបល់លើ សេចក្តីព្រាង ផែនការធនធានមនុស្ស និងផែនការបណ្តុះបណ្តាលបុគ្គលិក សម្រាប់ឆ្នាំ២០២៦

## ១.៣ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា | ប្រធាន | ១៩-សីហា-២០២៤ | ៤ | ៤ |
| ២ | ឯកឧត្តម ឈួន រិន | អនុប្រធាន | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៣ | លោក KUME Hidetoshi | អនុប្រធាន | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៤ | ឯកឧត្តម គឹម ស៊ីថន | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៥ | លោក ហ៊ុន មុន្នីវណ្ណ | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៦ | លោក ណុំ ស៊ីនិត | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៧ | លោក ថៃ ឬទ្ធី | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |
| ៨ | លោក ពិត ប្រាកដ | សមាជិក | ១៩-សីហា-២០២៤ | ៤ | ៤ |

- **តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- វិភាគហានិភ័យរួមមាន ការពិពណ៌នាហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យ
- ប៉ាន់ស្មានហានិភ័យ
- វាយតម្លៃហានិភ័យ
- លើកវិធានការទប់ទល់ហានិភ័យ
- តាមដានអំពីហានិភ័យ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

- **លទ្ធផលការងាររបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ បានរៀបចំកិច្ចប្រជុំចំនួន ៤ លើក ដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ | តំណាងថ្នាក់ដឹកនាំកសស |
|---|---|---|---|---|
| ១ | ៨-កុម្ភៈ-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការ<br>គ្រប់គ្រងហានិភ័យ<br>អាណត្តិទី៩ លើកទី៣ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម ស៊ុយ សាន<br>លោក KUME Hidetoshi<br>ឯកឧត្តម សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត<br>លោក ថៃ ឬទ្ធី<br>លោក ពិត ប្រាកដ | លោក វ៉ន្ន សិលា<br>លោក សូ សៀង<br>លោក សោម ករុណា |
| ២ | ២០-ឧសភា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការ<br>គ្រប់គ្រងហានិភ័យ<br>អាណត្តិទី៩ លើកទី៤ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម ស៊ុយ សាន<br>លោក KUME Hidetoshi<br>ឯកឧត្តម សុខ សុភ័ក្ត្រ<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត<br>លោក ថៃ ឬទ្ធី<br>លោក ពិត ប្រាកដ | លោក វ៉ន្ន សិលា<br>លោក សូ សៀង |
| ៣ | ១៨-សីហា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការ<br>គ្រប់គ្រងហានិភ័យ<br>អាណត្តិទី៩ លើកទី៥ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម ឈួន រិន<br>លោក KUME Hidetoshi<br>ឯកឧត្តម កឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត<br>លោក ថៃ ឬទ្ធី<br>លោក ពិត ប្រាកដ | លោក វ៉ន្ន សិលា<br>លោក សូ សៀង |
| ៤ | ២១-វិច្ឆិកា-២០២៥ | កិច្ចប្រជុំ<br>គណៈកម្មាធិការ<br>គ្រប់គ្រងហានិភ័យ<br>អាណត្តិទី៩ លើកទី៦ | ឯ.ឧ បណ្ឌិតសភាចារ្យ ផាន់ ផល្លា<br>ឯកឧត្តម ឈួន រិន<br>លោក KUME Hidetoshi<br>ឯកឧត្តម កឹម ស៊ីថន<br>លោក ហ៊ុន មុន្នីវណ្ណ<br>លោក ណុំ ស៊ីនិត<br>លោក ថៃ ឬទ្ធី<br>លោក ពិត ប្រាកដ | លោក វ៉ន្ន សិលា<br>លោក សូ សៀង |

នៅក្នុងឆ្នាំ២០២៥ នេះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សម្រេចបានលទ្ធផលការងារដូចខាងក្រោម៖

**១. សម័យប្រជុំលើកទី១: ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី ស្ថានភាពការងារអាជីវកម្ម កសស និងបញ្ហាប្រឈមក្នុងឆ្នាំ២០២៤
- របាយការណ៍វឌ្ឍនភាពស្តីពី គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី-ដំហានទី១, ដំហានទី២, ដំហានទី៣ និងការរៀបចំផែនការមេសម្រាប់អនាគតរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- របាយការណ៍ស្តីពី វឌ្ឍនភាពការងារ ប្រព័ន្ធព័ត៌មានវិទ្យារបស់ កសស
- ពិនិត្យ និងពិភាក្សាលើ តម្រូវការប្រើប្រាស់ឃ្លាំងលេខ២ សម្រាប់ស្តុកអង្ករក្នុងការនាំចេញ ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ក្នុងការរក្សាទុកទំនិញរឹបអូសរបស់ក្រុមហ៊ុន KrisEnergy
- ពិនិត្យ និងពិភាក្សាលើ ករណីនាវាផលិតកម្មប្រេងកាត (Ingenium II) របស់ក្រុមហ៊ុន KrisEnergy ដែលត្រូវបានរឹបអូស និងរក្សាទុកនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**២. សម័យប្រជុំលើកទី២: ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី ស្ថានភាពការងារអាជីវកម្ម កសស និងបញ្ហាប្រឈមក្នុងត្រីមាសទី១ ឆ្នាំ២០២៥
- ពិនិត្យ និងពិភាក្សាលើ ការស្នើសុំបញ្ជាក់ពីការចូលរួមដួលទីតាំងដីសក្តានុពលថ្មី (PAS00) របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់រៀបចំអភិវឌ្ឍគម្រោងមជ្ឈមណ្ឌលភស្តុភារកម្មក្រុងព្រះសីហនុ (SHV-LC) (លិខិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៣៨៣៧ សហវ. លស.អរជ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ និងលិខិតក្រសួងសធារណការ និងដឹកជញ្ជូន លេខ ២៤៥១ សក.អភក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥)

**៣. សម័យប្រជុំលើកទី៣: ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី ស្ថានភាពការងារអាជីវកម្ម កសស និងបញ្ហាប្រឈម ក្នុងត្រីមាសទី២ ឆ្នាំ២០២៥
- របាយការណ៍ស្តីពីស្ថានភាពអាជីវកម្ម សមត្ថភាព និងការត្រៀមរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ផ្សេងៗ ដែលអាចកើតមានបណ្តាលមកពីបញ្ហាព្រំដែនកម្ពុជា-ថៃ និងសេចក្តីជូនដំណឹងស្តីពី ការចូលរួមដោះស្រាយ ដើម្បីបង្កើនប្រសិទ្ធភាព និងទប់ស្កាត់ការស្ទះចរាចរណ៍នាវា-រថយន្តនៅ កសស
- ពិនិត្យ និងពិភាក្សា ករណីក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ (Royal Railway Co., Ltd) បានជំពាក់បំណុល កសស
- ពិនិត្យ និងពិភាក្សា កិច្ចសហប្រតិបត្តិការជាមួយ International Finance Corporation (IFC) លើដីរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ មានទីតាំងនៅតាមបណ្តោយផ្លូវ **ហ៊ុន សែន** កែវផុស ភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

**៤. សម័យប្រជុំលើកទី៤: ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥**

- របាយការណ៍ស្តីពី ស្ថានភាពការងារអាជីវកម្ម កសស និងបញ្ហាប្រឈមក្នុងត្រីមាសទី៣ ឆ្នាំ២០២៥
- ពិនិត្យ និងពិភាក្សាលើ គម្រោងអភិវឌ្ឍន៍ដេប៉ូស្តុកកុងតឺន័រ (Inland Container Depot-ICD) និង Pre-Gate នៅតាមបណ្តោយផ្លូវលេខ១៤៦B ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ពិនិត្យ និងពិភាក្សាលើ ផែនការអាជីវកម្ម (សេវាកម្ម) ហិរញ្ញវត្ថុ កសស ឆ្នាំ២០២៦
- ពិនិត្យ និងពិភាក្សា ករណីក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ (Royal Railway Co., Ltd) បានជំពាក់បំណុល កសស
- ពិនិត្យ និងពិភាក្សា ករណីក្រុមហ៊ុន ហួលិ ស្ទៀល (ខេមបូឌា) ឯ.ក (HUALE STEEL (Cambodia) Co., Ltd.) បានជំពាក់បំណុល កសស
- ពិនិត្យ និងពិភាក្សា ករណីក្រុមហ៊ុន បកស៍ វីល (ខេមបូឌា) ឯ.ក (Box Ville (Cambodia) Co., Ltd) បានជំពាក់បំណុល កសស

### ១.៤ គណៈកម្មាធិការផ្សេងទៀត

- តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការផ្សេងទៀត
  នៅក្នុងឆ្នាំ២០២៥ នេះ កសស មិនទាន់មានគណៈកម្មាធិការផ្សេងទៀតនៅឡើយទេ ។
- លទ្ធផលការងាររបស់គណៈកម្មាធិការផ្សេងទៀត
  នៅក្នុងឆ្នាំ២០២៥ នេះ មិនទាន់មានលទ្ធផលការងាររបស់ កម្មាធិការផ្សេងទៀតទេ ។

## ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

នៅក្នុងឆ្នាំ២០២៥ នេះ សមាជិកគណៈកម្មាធិការ មិនមានការប្រែប្រួលទេ ។

## គ. លាភការ ឬប្រាក់បំណាច់

## ១. គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

- លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាលរបស់ កសស ត្រូវបានផ្តល់ជូនដូចខាងក្រោម ៖
  - ការឧបត្ថម្ភលើមធ្យោបាយធ្វើដំណើរ
  - ការឧបត្ថម្ភទូរស័ព្ទ
  - ការឧបត្ថម្ភម៉ោងប្រជុំ
  - ប្រាក់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ។
- លាភការ ឬប្រាក់បំណាច់សម្រាប់បុគ្គលិកជាន់ខ្ពស់របស់ កសស ត្រូវបានផ្តល់ជូនដូចខាងក្រោម ៖
  - ប្រាក់បៀវត្សសុទ្ធ
  - ប្រាក់បំណាច់មុខងារភារកិច្ច
  - ប្រាក់វិភាជន៍គ្រួសារ ប្រាក់ថ្លៃបាយ ប្រាក់ថ្ងៃបុណ្យ
  - ប្រាក់បៀវត្សទិន្នផលការងារ
  - ប្រាក់បូណឹស ។

## ២. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១ ០៣៦ ០០០ ០០០ រៀល | |
| ២ | អភិបាលប្រតិបត្តិ | ៣៦០ ០០០ ០០០ រៀល | |
| ៣ | បុគ្គលិកជាន់ខ្ពស់ | ២ ៩៨២ ២៦១ ០០០ រៀល | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ៧៦៣ ៥១៩ ០០០ រៀល | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ក្រុមប្រឹក្សាភិបាលបានវាយតម្លៃលើលទ្ធផលការងារប្រចាំឆ្នាំ២០២៥ | - ប្រសិទ្ធភាពការងារចាត់ចែង និងសម្របសម្រួលការអនុវត្តភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាល ជាមួយ កសស<br>- ការប្តេជ្ញាចិត្តខ្ពស់ អនុវត្តភារកិច្ច ដើម្បីផលប្រយោជន៍ កសស និងភាគហ៊ុនិក<br>- ប្រសិទ្ធភាពក្នុងការបង្កើត តាមដាន វាយតម្លៃផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងចំណូល-ចំណាយ និងផែនការអាជីវកម្ម-សេវាកម្មរបស់ កសស<br>- ប្រសិទ្ធភាពក្នុងការចាត់ចែងធ្វើឱ្យដំណើរការនូវគណៈកម្មាធិការនានា ដែលបានកំណត់ដោយអនុក្រឹត្យ ស្តីពីការបង្កើត កសស ឬដោយលក្ខន្តិកៈរបស់ កសស<br>- នីត្យានុកូលភាព ទេពកោសល្យ និងសមត្ថភាពក្នុងដំណើរការគណៈកម្មាធិការ ក្នុងបេសកកម្មរបស់ខ្លួនស្របតាមលក្ខន្តិកៈ បទប្បញ្ញត្តិជាធរមាន<br>- លទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព<br>- ប្រសិទ្ធភាពក្នុងការបង្កើត តាមដាន និងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃ កសស<br>- ប្រសិទ្ធភាពក្នុងការបង្កើត តាមដាន និងវាយតម្លៃប្រព័ន្ធសវនកម្ម<br>- ប្រសិទ្ធភាពក្នុងការបង្កើត តាមដាន និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងហានិភ័យ<br>- ប្រសិទ្ធភាពក្នុងការរៀបចំគោលនយោបាយស្តីពីការគ្រប់គ្រង និងការផ្តល់លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់<br>- ប្រសិទ្ធភាពក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ និងនីតិវិធីជ្រើសតាំងអភិបាល<br>- ប្រសិទ្ធភាពក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មកាធិការនានារបស់ក្រុមប្រឹក្សាភិបាល<br>- ប្រសិទ្ធភាពក្នុងការបង្កើតយន្តការ និងនីតិវិធីនៃការការពារសិទ្ធិរបស់ភាគហ៊ុនិក<br>- ប្រសិទ្ធភាពក្នុងការបង្កើតយន្តការ និងនីតិវិធីនៃការបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ។ |

## ខ. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

នៅក្នុងឆ្នាំ២០២៥ នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានបញ្ជូន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស ដូចខាងក្រោម៖

- ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៥ បានចូលរួមកិច្ចប្រជុំ PIANC-Japan Cambodia Seminar 2025 ប្រទេសជប៉ុន រៀបចំដោយ Ministry of Land Infrastructure Tourism and Transport (MLIT) JAPAN ។
- ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន នៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី VHF Data Exchange System នៅប្រទេសសិង្ហបុរី ។
- ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាកសាងសមត្ថភាព ស្តីពីហិរញ្ញវត្ថុនិរន្តរភាព និងផែនទីបង្ហាញផ្លូវ សម្រាប់វិនិយោគិន នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ រៀបចំដោយនិយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី២៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ បានចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្ម លើកទី៣ (3rd TPR) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។
- ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផល និងការរកឃើញរបស់វេទិកាដឹកជញ្ជូនអន្តរជាតិ ITF (International Transport Forum) នៃគម្រោងកម្មវិធីនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធនៅតំបន់អាស៊ី SIPA នៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ប្រធានបទសំខាន់ៗ សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនតាមរយៈ Online រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាការបញ្ជ្រាបការយល់ដឹង និងជំរុញការបោះផ្សាយលក់មូលបត្រក្រោមប្រធានបទ យន្តការថ្មីនៃការកៀរគរហិរញ្ញប្បទាន តាមរយៈការបោះផ្សាយលក់សញ្ញាបណ្ណក្រោមក្របខណ្ឌបណ្ណបំណុលរយៈពេលមធ្យម នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រៀបចំដោយនិយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី ការធ្វើអង្កេតសំណើគម្រោងស្នើសុំហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការពីរដ្ឋាភិបាលជប៉ុន (Japan's ODA Request Survey Workshop) សម្រាប់ឆ្នាំសារពើពន្ធ ២០២៦ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី ជម្រើសម៉ូឌែលប្រមូលទិន្នន័យក្នុងប្រព័ន្ធទន្លេមេគង្គ ក្រោមគម្រោងពង្រឹងសមត្ថភាពកំពង់ផែក្នុងព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Fairfield by Marriott Phnom Penh រៀបចំដោយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ។
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការមេសម្រាប់វិស័យមូលបត្រ ឆ្នាំ២០២៥-២០៣៥ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រៀបចំដោយនិយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមវេទិកាស្តីពី Maritime Road Port International Cooperation Forum (MPF) នៅទីក្រុងនីងបូ ប្រទេសចិន រៀបចំដោយ Maritime Technical Co-operation Center for Asia (MTCC) ។

- ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យ និងផ្តល់យោបល់លើការសិក្សាតំបន់កំពង់ផែក្រោមគម្រោងពង្រឹងសមត្ថភាពរដ្ឋបាលកំពង់ផែ ក្នុងព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Sun & Moon Riverside Hotel រៀបចំដោយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ។
- ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធនៃការបង្ហាញព័ត៌មានអាជីវកម្មដំណាក់កាលទី១ នៅទីស្តីការនិយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការដាក់អោយអនុវត្តប្រព័ន្ធតាមដាន និងជូនដំណឹងការកិច្ចលទ្ធកម្មសម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ នៅ SUN & MOON Riverside Hotel រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះនៃច្បាប់ស្តីពីសន្តិសុខនាវាអន្តរជាតិ និងបបរិយកាសកំពង់ផែ និងវិធានការត្រួតពិនិត្យច្រកចេញ-ចូលកំពង់ផែ នៅសាលប្រជុំកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី កាតព្វកិច្ចសារពើពន្ធចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិនៅសណ្ឋាគារកាំបូឌីយ៉ាណារៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ។
- ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាកសាងសមត្ថភាពស្តីពី សញ្ញាបណ្ណបៃតង សង្គម និងចីរភាព និងសញ្ញាបណ្ណផ្សារភ្ជាប់ និងចីរភាព នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ីភ្នំពេញ រៀបចំដោយ និយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួង ស្តីពីកម្មវិធីវគ្គបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ នៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលើកទី២ ស្តីពីអត្ថប្រយោជន៍ នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម នៅសណ្ឋាគារ Novatel រៀបចំដោយ ក្រសួងពាណិជ្ជកម្ម ។
- ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើកទី៤ លើសេចក្តីព្រាងច្បាប់ស្តីពី ភស្តុភារកម្ម នៅសណ្ឋាគារ Fairfield by Marriott Phnom Penh រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី ការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព របស់កម្ពុជាដំណើសញ្ញាបណ្ណបៃតងឆ្ពោះទៅកាន់ ការវិនិយោគអាកាសធាតុ នៅរាជធានីភ្នំពេញ រៀបចំដោយ និយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពបញ្ច្រាបយេនឌ័រ ឆ្នាំ២០២៦-២០២៨ នៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយពី ការដាក់ឱ្យអនុវត្តផែនការគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឆ្នាំ២០២៥-២០៣៥ នៅសណ្ឋាគារ អេមព្រីស អង្គរ រីសត និងស្ប៉ា សៀមរាប រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងពាក់ព័ន្ធការងារបរិស្ថាន និងសង្គម នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន។
- ថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី វិស័យមូលបត្រនៅកម្ពុជាសម្រាប់សាស្ត្រាចារ្យសាកលវិទ្យាល័យ និងវិនិយោគិនសក្តានុពល នៅសណ្ឋាគារអង្គរមីរ៉ាខន រីសត និងស្ប៉ា រៀបចំដោយ និយ័តករមូលបត្រកម្ពុជា ។

- ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលា ស្តីពី ថ្នាក់ដឹកនាំបុរសគំរូ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយបរិយាបន្ន ការចែករំលែកបទពិសោធន៍ និងការប្តេជ្ញាចិត្តសម្រាប់ពេលអនាគត នៅសណ្ឋាគារ Fairfield by Marriott Phnom Penh រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន។
- ថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាបច្ចេកទេសរួមរវាងវេទិកាទីផ្សារមូលធនអាស៊ាន និងក្រុមប្រឹក្សាស្តង់ដារប្រកបដោយចីរភាពអន្តរជាតិ និងសន្និសីទអន្តរជាតិវេទិកាទីផ្សារមូលធនអាស៊ានឆ្នាំ២០២៥ នៅប្រទេសម៉ាឡេស៊ី រៀបចំដោយ និយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស សម្រាប់គម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទាន ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ ពីការឱ្យខ្ចីផ្ទាល់ពីរដ្ឋ និងពីមូលបត្ររដ្ឋ នៅសណ្ឋាគារ Sun & Moon ភ្នំពេញ រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចូលរួម សិក្ខាសាលាពិគ្រោះយោបល់ (Retreat Seminar) លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា នៅសាលាខេត្តកែប រៀបចំដោយ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ។
- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី ការរៀបចំគ្រប់គ្រងតំបន់កំពង់ផែជាតិ ក្រោមគម្រោងពង្រឹងសមត្ថភាពរដ្ឋបាលកំពង់ផែ ក្នុងព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Fairfield by Marriott Phnom Penh រៀបចំដោយ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ។
- ថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីវិធីសាស្ត្រក្នុងការប្រមូល ចងក្រងនិងវិភាគស្ថិតិ និងផ្សព្វផ្សាយស្ថិតិវិស័យសាធារណការ និងដឹកជញ្ជូនប្រចាំឆ្នាំ នៅសណ្ឋាគារអង្គរអេរ៉ា រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពី ការបង្ហាញព័ត៌មានចីរភាពនៅ ទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រៀបចំដោយ និយ័តករមូលបត្រកម្ពុជា ។
- ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី Oil and HNS Sensitivity Mapping for Cambodia នៅសណ្ឋាគារ TRIBE PHNOM PENH ភ្នំពេញ រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន។
- ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងច្បាប់ស្តីពី ភស្តុភារកម្ម នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន។
- ថ្ងៃទី១១ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាស្តីពី Seminar on Procurement and Implementation under Japanese ODA Loans នៅសណ្ឋាគារ Angkor Miracle Hotel រៀបចំដោយ JICA ។
- ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីបង្គោល ក្នុងការរៀបចំធាតុចូល និងការផ្សព្វផ្សាយគម្រោងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ២០២៦-២០២៨ នៅសណ្ឋាគារ សុខាភ្នំពេញ រៀបចំដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់ នៅសណ្ឋាគារ Hyatt Regency Phnom Penh រៀបចំដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ។

# ផ្នែកទី៣

# ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌ សម្រាប់អនុវត្តធុរកិច្ច របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

### គោលការណ៍នៃក្រមសីលធម៌

ប្រការ ១. សេចក្ដីផ្ដើម

យោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរួមទាំងប្រកាសស្ដីពី អភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងជាការប្ដេជ្ញាជម្រុញឱ្យមានការអនុវត្តន៍ការងារប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ កសស បានអនុម័តក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តឱ្យមានភាពស្មោះត្រង់ និងឥរិយាបថប្រកបដោយសីលធម៌ក្នុងការធ្វើអាជីវកម្ម ដើម្បីធានាឱ្យបាននូវសមភាព និងជៀសវាងអំពីទំនាស់ផលប្រយោជន៍ ។
- លើកទឹកចិត្តក្នុងការផ្ដល់ព័ត៌មានចាំបាច់នានាដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឱ្យបានពេញលេញ ច្បាស់លាស់ ត្រូវត្រឹម និងទាន់ពេល ។
- លើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- ធានាការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុន រួមបញ្ចូលទាំងកាលានុវត្តភាពអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអរូបិយ និងព័ត៌មានសម្ងាត់របស់ក្រុមហ៊ុន ។
- បញ្ចៀសនូវអាកប្បកិរិយាមិនត្រឹមត្រូវ ឬទង្វើឆ្គាំឆ្គងទាំងឡាយ ។

អាជីវកម្មរបស់ កសស ត្រូវស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំទូទៅដោយក្រុមប្រឹក្សាភិបាល ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានការទទួលខុសត្រូវជាចម្បង ក្នុងការសម្រេចចិត្តអាជីវកម្មដែលខ្លួនជឿជាក់ថាផ្ដល់ប្រយោជន៍ល្អដល់ កសស និងសម្រាប់ភាគហ៊ុនិកទាំងអស់របស់ កសស ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវយល់ច្បាស់ពីក្រមសីលធម៌ ហើយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ និងវិធានដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ។

ប្រការ ២. និយមន័យ

នៅក្នុងបរិបថនៃក្រមសីលធម៌ ពាក្យខាងក្រោមត្រូវបានឱ្យនិយមន័យដូចតទៅ៖

- ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ៖ សំដៅដល់រាល់ច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា រួមមានជាអាទិ៍ ច្បាប់ អនុក្រឹត្យ ប្រកាស វិធាន និងគោលការណ៍ណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចដូចជា ន.ម.ក និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហៅកាត់ថា ផ.ម.ក ដែលច្បាប់ និងបទប្បញ្ញត្តិ ទាំងនោះត្រូវអនុវត្តន៍ទៅលើ កសស អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ កសស ។
- អភិបាល ៖ សំដៅដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ កសស រួមបញ្ចូលទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ ។
- បុគ្គលិកជាន់ខ្ពស់ ៖ សំដៅដល់បុគ្គលទាំងឡាយណា មានមុខតំណែងចាប់ពីប្រធាននាយក រហូតដល់អគ្គនាយក រួមទាំងប្រធានលេខាធិការ និងអ្នកដែលមានមុខតំណែងសំខាន់ៗផ្សេងទៀតក្នុង កសស ដែល កំណត់ដោយក្រុមប្រឹក្សាភិបាល កសស ។

ប្រការ ៣. ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនអភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ត្រូវអនុវត្ត និងព្យាយាមធ្វើឱ្យ កសស អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ ប្រសិនបើអភិបាល ឬបុគ្គលិក ជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយ បានបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ដែលបានដឹងត្រូវផ្តល់ព័ត៌មានជូនប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក ប្រធានគណៈកម្មាធិការសវនកម្ម ឬសវនកម្មផ្ទៃក្នុង ។

ប្រការ ៤. អំពីទំនាស់ផលប្រយោជន៍

បន្ថែមលើបទប្បបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៤៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែល អាចកើតមានជាមួយ កសស ។

ជាទូទៅ ទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬអាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ ៖

ក. ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ កសស ។

ខ. លទ្ធភាពរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ កសស ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈពីប្រតិបត្តិការ ឬទំនាក់ទំនងណាមួយ ដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ កសស តាមការកំណត់របស់ ន.ម.ក ឬ ផ.ម.ក ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ កសស ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួន ជាលាយលក្ខណ៍អក្សរទៅ កសស ស្នើឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក្នុងករណីដែល ៖

ក. អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះជាភាគីនៃកិច្ចសន្យា ឬជាអ្នកស្នើធ្វើជាមួយនឹង កសស

ខ. អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះមានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬនីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ កសស ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង កសស ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យ របស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពី ១% (មួយភាគរយ) នៃ ភាគហ៊ុនរបស់ កសស ឡើយ ។

ប្រការ ៥. កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ កសស នៅពេលសមស្រប ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង ៖

ក. ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង កសស ។

ខ. ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ កសស ឬឋានៈ និងមុខតំណែងរបស់ខ្លួន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

គ. ប្រកួតប្រជែងជាមួយ កសស ។

ក្រុមប្រឹក្សាភិបាល និងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះដោយពិចារណាលើអង្គហេតុ និង ស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ ។

ប្រការ ៦. ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឱ្យមាន ភាពស្មើគ្នាក្នុងការទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិតរបស់ កសស ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ ដោយប្រើប្រាស់ឧបាយកល ការមិនស្មោះត្រង់ ការលាក់បាំង ការបំភ័ន្ត ព័ត៌មានសំខាន់ៗ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយ អំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម ។

ការប្រើប្រាស់សិទ្ធអំពីព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ កសស ឬការបញ្ចុះបញ្ចូលអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ កសស ទាំងអតិត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះ ត្រូវបានហាមឃាត់ជាដាច់ខាត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិត និងដើម្បីផល ប្រយោជន៍របស់ កសស និងភាគហ៊ុនិកទាំងអស់របស់ កសស ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយក ផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពី តតិយជនដោយសារមុខតំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ។

ប្រការ ៧. ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ កសស

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវជំរុញឱ្យមាន ការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវដោយមានការទទួលខុសត្រូវនូវទ្រព្យសម្បត្តិរបស់ កសស រួមទាំង ទ្រព្យរូបិយ និងទ្រព្យអរូបិយ ។

ទ្រព្យសម្បត្តិរបស់ កសស មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធបញ្ញា ឧបករណ៍ ប្រភព ធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀត ដែលជាកម្មសិទ្ធរបស់ កសស ឬទ្រព្យដែល កសស ជួលពីគេ ឬ ទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ កសស ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្ម ស្របច្បាប់របស់ កសស តែប៉ុណ្ណោះ ។

ប្រការ ៨. បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម (ប្រសិនបើមាន) ឬសវនករផ្ទៃក្នុងរបស់ កសស ត្រូវទទួលខុសត្រូវក្នុងការ រៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យមើលពាក្យបណ្តឹង ទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងៗទៀតដែលទាក់ទងទៅនឹងសវនកម្ម ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវន ករផ្ទៃក្នុងរបស់ កសស ។ ការស្នើសុំឱ្យពិនិត្យបណ្តឹងជាសម្ងាត់អាចធ្វើឡើងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ប្រការ ៩. ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ កសស ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ទៅនាយក ឬ បុគ្គលដែលមានសមត្ថកិច្ចនៅក្នុង កសស នៅពេលដែលទង្វើខុសច្បាប់ ឬអសីលធម៌ណាមួយអាចនឹងធ្វើឱ្យប៉ះ ពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់អាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ កសស ឬវាអាចនឹងនាំឱ្យមានការទទួលខុសត្រូវធ្ងន់ធ្ងរ តាមផ្លូវច្បាប់ ។

ប្រការ ១០. ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិជាធរមាន បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយ កសស ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុនរបស់ កសស ។

ប្រការ ១១. ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ កសស ដែលខ្លួនបានដឹង លើកលែងតែក្នុងករណីដែល កសស អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈ ដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ កសស ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ កសស ឬអតិថិជនរបស់ កសស ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយនឹងអគ្គនាយក ឬប្រធានក្រុមប្រឹក្សាភិបាលប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះគិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសម្ងាត់នោះ ។

ប្រការ ១២. ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ កសស ដើម្បីឱ្យចេញសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មាន ដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធររដ្ឋរួមបញ្ចូលទាំង ន.ម.ក អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់ ន.ម.ក និង ផ.ម.ក ។

ម្យ៉ាងវិញទៀតក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬគ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ ន.ម.ក និង / ឬ ផ.ម.ក ឬការជូនដំណឹងជាសាធារណៈ ផ្សេងៗទៀតរបស់ កសស ពាក់ព័ន្ធអាជីវកម្មទូទៅ លទ្ធផល លក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធហើយចាត់វិធានការសមស្រប សម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវទាន់ពេល និងអាចយល់បាន ។

ក្នុងទំហំដែលពាក់ព័ន្ធទៅនឹងនីតិវិធី និងការត្រួតពិនិត្យ ការផ្តល់ព័ត៌មានរបស់ កសស អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ ព័ត៌មានរបស់ កសស ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ កសស ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ កសស ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬក្រៅ កសស រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត ។

ប្រការ ១៣. វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះ អាចត្រូវបានធ្វើវិសោធនកម្ម ឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ កសស ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ ជាវិធានទូទៅ ក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់នោះទេ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌ និងស្វែងរកការពន្យល់ និងការផ្ដល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារបន្ថែម និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌ ជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំទាស់ជាមួយនឹងក្រមសីលធម៌ ។

<u>ការអនុវត្តក្រមសីលធម៌</u>

ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ កសស នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ និងមានអានុភាពអនុវត្តចាប់ពី កសស ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈដោយ ន.ម.ក និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២៥ នេះ ជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត វិនិយោគិនរបស់ កសស និងសាធារណៈជន ។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានប្រគល់ភារកិច្ចជូននាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីធ្វើការត្រួតពិនិត្យជាប្រចាំ និងជម្រុញលើកទឹកចិត្តដល់គ្រប់និយោជិតរបស់ កសស ឱ្យរាយការណ៍ពីភស្តុតាងនៃទង្វើខុសច្បាប់ ឬអសីលធម៌ ទៅនាយកដ្ឋាន ឬបុគ្គលមានសមត្ថកិច្ច នៅពេលដែលមានការប្រព្រឹត្តទង្វើផ្ទុយពីច្បាប់ ឬអសីលធម៌ណាមួយ ដែលអាចនឹងធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់អាជីវកម្ម និងកេរ្តិ៍ឈ្មោះរបស់ កសស ឬអាចនាំឱ្យមានការទទួលខុសត្រូវធ្ងន់ធ្ងរតាមផ្លូវច្បាប់ ។

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | ពុំមាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | ពុំមាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ពុំមាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | ពុំមាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | ពុំមាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | ពុំមាន |

### ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

នៅក្នុងឆ្នាំ២០២៥ នេះ ពុំមានប្រតិបត្តិការនេះកើតឡើងចំពោះ កសស ទេ ។

# ផ្នែកទី៤

# គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

## ក. តួនាទី និងភារកិច្ច

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានភារកិច្ចតាមដានស្ថានភាពហានិភ័យ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ព្រមទាំងកំណត់ទិសដៅសម្រាប់ការអនុវត្តសកម្មភាពនានា ដើម្បីកាត់បន្ថយហានិភ័យឱ្យស្ថិតនៅក្នុងកម្រិតសមស្របណាមួយអាចទទួលយកបាន ដើម្បីធានាការសម្រេចបាននូវចក្ខុវិស័យរបស់ កសស ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ក៏មានតួនាទីសម្របសម្រួល និងជម្រុញកែលម្អការគ្រប់គ្រងហានិភ័យ ។ បន្ថែមលើនេះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យនឹងបន្តគាំទ្រគណៈកម្មាធិការសវនកម្ម ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ អនុលោមភាពតាមបទប្បញ្ញត្តិដែលបានកំណត់ដោយ ន.ម.ក សម្រាប់ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈពាក់ព័ន្ធនឹងដំណើរការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ។

ជាពិសេស គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវអនុវត្ត ឬចាត់ចែងភារកិច្ចដូចខាងក្រោម ៖

- ការវិភាគ និងចាត់ថ្នាក់អាទិភាពហានិភ័យអាជីវកម្ម៖ ត្រួតពិនិត្យ វាយតម្លៃ ហានិភ័យបច្ចុប្បន្ន ហានិភ័យដែលកំពុងកើតមាន ដោយធ្វើការវិភាគទំនាក់ទំនង និងកម្រិតរវាងហានិភ័យនីមួយៗ ។
- ការកំណត់យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ៖ ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស្ថេរភាពនៃការគ្រប់គ្រងហានិភ័យរបស់ ក.ស.ស ។
- ការធានាតម្លាភាព និងការដោះស្រាយហានិភ័យតាមអាទិភាព៖ ផ្តល់ទិសដៅច្បាស់លាស់សម្រាប់ការបែងចែកធនធាន និងការចាត់តាំងភារកិច្ច ក្នុងការអនុវត្តសកម្មភាពដើម្បីកាត់បន្ថយហានិភ័យអាជីវកម្ម។
- ការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យប្រតិបត្តិការ៖ ផ្តល់ការណែនាំទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យប្រតិបត្តិការ រួមមាននីតិវិធី និងរចនាសម្ព័ន្ធគ្រប់គ្រង ។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយផ្អែកលើការពិនិត្យសមត្ថភាពនៃដំណើរការគ្រប់គ្រងដើម្បីសម្រេចបាននូវគោលបំណងស្របតាមសេចក្តីកំណត់ស្តីពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់សវនដ្ឋាន ។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

### ១.១ ភារកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មខាងក្រៅ
- ធ្វើសវនកម្មលើសកម្មភាពការងារ និងអាជីវកម្ម កសស
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលលើសកម្មភាពការងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល

### ១.២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទ ដកហូត/លាលែង | មូលហេតុ |
|---|---|---|---|---|---|
| ១ | លោក ម៉ែន ចាន់ | ប្រធាន | ២៥-ធ្នូ-២០១៥ | | |
| ២ | លោក ជីវ ច័ន្ទសុភាព | អនុប្រធាន | ១០-មេសា-២០២០ | | |
| ៣ | លោក ហោ សុធី | អនុប្រធាន | ១០-មេសា-២០២០ | | |

នៅក្នុងឆ្នាំ២០២៥ នេះ ពុំមានការដកហូត/ការលាលែងតំណែងប្រធាន ឬអនុប្រធានសវនកម្មផ្ទៃក្នុងទេ ។

### ១.៣ ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

នៅក្នុងឆ្នាំ២០២៥ នេះ កសស មិនមានការតែងតាំងប្រធាន/អនុប្រធានសវនករផ្ទៃក្នុងថ្មីទេ ។

## ២. សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | PricewaterhouseCooper (Cambodia) Ltd. | ១៣-កុម្ភៈ-២០២៥ | ៤៤២.៨៩៥.000 រៀល | មិនមាន |

❖ **មូលហេតុនៃការផ្លាស់ប្តូរ ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ**

នៅក្នុងឆ្នាំ២០២៥ នេះ កសស មានការផ្លាស់ប្តូរក្រុមហ៊ុនសវនកម្មឯករាជ្យពីក្រុមហ៊ុន Ernst & Young (Cambodia) Ltd. ទៅក្រុមហ៊ុន PricewaterhouseCooper (Cambodia) Ltd. ដោយសារក្រុមហ៊ុន Ernst & Young (Cambodia) Ltd. បានបញ្ចប់អាណត្តិ ។

# ផ្នែកទី៥

# ភាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខមាលភាពរបស់អតិថិជន | យកចិត្តទុកដាក់ និងបំពេញតម្រូវការអតិថិជន | ផ្តល់សេវាកម្មជូនអតិថិជនឱ្យបានទាន់ពេលវេលា |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | អនុវត្តនីតិវិធីលទ្ធកម្ម | ដេញថ្លៃ និងពិគ្រោះថ្លៃ |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | តំណាងនិយោជិត | បោះឆ្នោតរើសតំណាងនិយោជិត |
| ៤ | ការគាំពារបរិស្ថាន | ដើម្បីគ្រប់គ្រងបរិស្ថានក្នុងកំពង់ផែ | ផែនការគ្រប់គ្រងសុខភាព សុវត្ថិភាព និងបរិស្ថានកំពង់ផែ |
| ៥ | អន្តរកម្មជាមួយសហគមន៍ | ដើម្បីជួយអភិវឌ្ឍន៍សហគមន៍ | ផ្តល់វិភាគទានដល់សហគមន៍តាមភាពជាក់ស្តែង |
| ៦ | ការការពារសិទ្ធរបស់ម្ចាស់បំណុល | ធានានូវការទូទាត់សាច់ប្រាក់បម្រុងសម្រាប់បំណុលទៅតាមកាលវសានមួយៗ | ទូទាត់បំណុលឱ្យបានទាន់ពេលវេលា |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | បង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យបានរឹងមាំ | បានត្រួតពិនិត្យដោយសវនករផ្ទៃក្នុង |
| ៨ | ផ្សេងៗ | | |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | ការចូលរួមការងារសង្គមរួមមាន ៖<br>- ការកសាងហេដ្ឋារចនាសម្ព័ន្ធ<br>- ការលើកកម្ពស់វិស័យអប់រំ និងវិស័យពុទ្ធចក្រ<br>- ការឧបត្ថម្ភគាំទ្រវីរៈកងទ័ព ជនភៀសសឹក ជនរងគ្រោះ និងឧបត្ថម្ភផ្សេងៗ | ទឹកប្រាក់សរុបប្រមាណ ១៤.៦៥៩.៦៨០ពាន់រៀល | - សាងសង់អគារសិក្សា ១ខ្នង កម្ពស់៣ជាន់ ស្មើនឹង ១៨បន្ទប់ មានទទឹង ៩ម៉ែត្រ និងបណ្តោយ ៦៤ម៉ែត្រ នៅវិទ្យាល័យអប់រំពិសេសក្រុងតាខ្មៅ ស្ថិតនៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល<br>- ជួសជុលកែលម្អ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សាលាមត្តេយ្យធនធាន ហ៊ុន សែន ព្រៃនប់ ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ<br>- ឧបត្ថម្ភគាំទ្រ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នៃបញ្ជាការដ្ឋានការពារកោះ-ឆ្នេរ និងបញ្ជាការដ្ឋានមូលដ្ឋានសមុទ្រ<br>- ជួសជុលកែលម្អ និងសាងសង់អគារសាលប្រជុំ ទីចាត់ការវិទ្យាល័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ តាមបណ្តាឃុំ នៃស្រុកស្រីសន្ធរ ខេត្តកំពង់ចាម<br>- ចូលរួមកសាងនូវសមិទ្ធិផលនានា តាមបណ្តាវត្ត ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម<br>- ឧបត្ថម្ភនូវសម្ភារៈបច្ចេកទេសសិក្សា (LCD Projector) ចំនួន ១២ ឈុត នៅវិទ្យាល័យ ហ៊ុន សែន វាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ |

| | | | |
|---|---|---|---|
| | | | - ឧបត្ថម្ភម៉ូតូសម្រាប់ជារង្វាន់ ជូនជ័យលាភីសិស្សនិទ្ទេស A និងចែករង្វាន់ជូនសិស្សានុសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០២៤-២០២៥ នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម, ស្រុកកោះធំ ខេត្តកណ្ដាល និងក្រុង-ខេត្តព្រះសីហនុ<br>- ចូលរួមឧបត្ថម្ភស័ង្កសី និងសម្ភារៈ ជូនដល់ជនរងគ្រោះដោយសារខ្យល់កន្ត្រាក់ ស្ថិតនៅភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ<br>- ចូលរួមជាមួយ សាខាកាកបាទក្រហមកម្ពុជា ខេត្តព្រះសីហនុ នាឱកាសខួបលើកទី១៦២ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨.ឧសភាឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ"<br>- ចូលរួមក្នុងយុទ្ធនាការ "១ម៉ឺនរៀល១ម៉ឺននាក់" ឆ្នាំ២០២៥ របស់មូលនិធិគន្ធបុប្ផាកម្ពុជា<br>- ចូលរួមជាមួយ ក្រសួងសាធារណការ និងដឹកជញ្ជូន ឧបត្ថម្ភគាំទ្រក្នុងសកម្មភាពមនុស្សធម៌ និងការលើកទឹកចិត្តជូន វីរកងទ័ពជួរមុខ និងជួយជនភៀសសឹក<br>- ចូលរួមជាមួយ រដ្ឋបាលខេត្តព្រះសីហនុ ក្នុងការឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តជូន វីរកងទ័ពជួរមុខ ព្រមទាំងបងប្អូនប្រជាពលរដ្ឋដែលត្រូវបានជម្លៀសខ្លួនទៅកាន់ទីកន្លែងសុវត្ថិភាពនានាក្នុងខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ<br>- ចូលរួមជាមួយ រដ្ឋបាលស្រុកស្រីសន្ធរ និងរដ្ឋបាលខេត្តកំពង់ចាម ដើម្បីចុះសួរសុខទុក្ខ និងនាំយកអំណោយជូន នាយទាហាន នាយទាហានរង ពលទាហាន និងកងកម្លាំងប្រដាប់អាវុធ ដែលឈរជើងជួរមុខនៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ<br>- ឧបត្ថម្ភគាំទ្រនូវស្បៀងអាហារ និងសម្ភារៈប្រើប្រាស់ជូន ជនភៀសសឹក បងប្អូន-សាច់ញាតិវីរៈកងទ័ពការពារជាតិ ចំនួន ៨១០គ្រួសារ និងសិស្សានុសិស្សភៀសសឹក ចំនួន ២៩៤នាក់ ដែលភៀសខ្លួនពីតំបន់ព្រំដែន ទៅកាន់ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម<br>- ចូលរួមជាមួយ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឧបត្ថម្ភគាំទ្រវីរៈកងទ័ពជួរមុខ ដែលឈរជើងការពារជាតិ ការពារបូរណភាពទឹកដីប្រឆាំងនឹងការឈ្លានពាននៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ និងជួយដល់ជនភៀសសឹក<br>- ចូលរួមមូលនិធិសប្បុរសធម៌ ដើម្បីជួយដល់បងប្អូនប្រជាពលរដ្ឋភៀសខ្លួន យោធិន គ្រួសារយោធិនពលី យោធិនរងរបួស-ធ្លាក់ខ្លួនពិការ ដោយសារសង្គ្រាមឈ្លានពាន នៅខេត្តមណ្ឌលគិរី<br>- ចូលរួមឧបត្ថម្ភគាំទ្រ វីរៈកងទ័ពជួរមុខប្រចាំការនៅតាមបណ្ដាកោះរួមមាន៖ កោះពូលូវ៉ៃ លេខ៥, កោះព្រីង, កោះតាងលេខ៣ និងកោះកុងក្រៅលេខ២ (កោះយ៉)<br>- ចូលរួមជាមួយ ក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តព្រះសីហនុ ដើម្បីឧបត្ថម្ភគាំទ្រកងទ័ពជួរមុខ ដែលឈរជើងការពារជាតិ ការពារបូរណភាពទឹកដី ប្រឆាំងនឹងការឈ្លានពាន និងជួយជនភៀសសឹកនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ<br>- ចូលរួមឧបត្ថម្ភគាំទ្របងប្អូនប្រជាពលរដ្ឋភៀសសឹក ដែលបានភៀសខ្លួនចេញពីតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ មកស្នាក់នៅតាមទីតាំង |

| | | | |
|---|---|---|---|
| | | | សុវត្ថិភាពនានាក្នុងខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តកោះកុង និងខេត្តព្រះវិហារ<br>- សំណេះសំណាល និងឧបត្ថម្ភគាំទ្រ ដើម្បីលើកទឹកចិត្តជូនបងប្អូនកងនាវីទាំងអស់ នៃបញ្ជាការដ្ឋានមូលដ្ឋានសមុទ្រ និងបញ្ជាការដ្ឋានការពារកោះ-ឆ្នេរ ដែលឈរជើងការពារជាតិ និងការពារបូរណភាពទឹកដី ប្រឆាំងនឹងការឈ្លានពាន<br>- ចូលរួមក្នុងគម្រោងសាងសង់ផ្ទះជូន អតីតយុទ្ធជន និងនិវត្តជនមន្ត្រីរាជការស៊ីវិល នៃសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា<br>- ឧបត្ថម្ភគាំទ្រដំណើរការកម្មវិធី "មនសិកាពលរដ្ឋល្អ" សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ របស់ស.ស.យ.ក ខេត្តព្រះសីហនុ<br>- ឧបត្ថម្ភគាំទ្រ "គម្រោងដាំដើមផ្កានៅសួនខ័ណ្ឌចែកទ្រូងផ្លូវចំនួន៤គម្រោង ស្ថិតនៅតាមបណ្ដោយផ្លូវជាតិ មហាវិថី និងរុក្ខវិថី ក្នុងខេត្តព្រះសីហនុ"<br>- សាងសង់ចេតិយជូន វីរយុទ្ធជន ដែលបានពលីជីវិតក្នុងបុព្វហេតុការពារទឹកដីនិងតម្កល់អដ្ឋិធាតុនៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម<br>- ចូលរួមក្នុងដំណើរការជួសជុល និងកែលម្អអគារស្នាក់ការ រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ស្ថិតនៅវិថីឧកញ៉ាឈុន សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>- ចូលរួមឧបត្ថម្ភគាំទ្រ កងកម្លាំងអន្តរាគមន៍ជួរមុខ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ ដែលឈរជើងនៅជួរមុខការពារបូរណភាពដែនដី ប្រឆាំងនឹងការឈ្លានពាន |

# ផ្នែកទី៦

# ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មាន បង្ហាញ | មូលហេតុ |
|---|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកកម្ម/ គោលដៅអាជីវកម្ម | មានបង្ហាញ | |
| ២ | សូចនាករហិរញ្ញវត្ថុ | មានបង្ហាញ | |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មានបង្ហាញ | |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មានបង្ហាញ | |
| ៥ | គោលនយោបាយភាគលាភ | មានបង្ហាញ | |
| ៦ | ជីវប្រវត្តរបស់អភិបាល | មានបង្ហាញ | |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មានបង្ហាញ | |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ | |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ | |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មានបង្ហាញ | |

ក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៥ នេះ កសស មិនបានបង្ហាញនូវសូចនាករមិនមែនហិរញ្ញវត្ថុ ប៉ុន្តែបានបង្ហាញតារាងស្ថិតិលម្អិត និងក្រាហ្វិចអំពីប្រតិបត្តិការរបស់ខ្លួន ។

## ខ. ពិព័ណ៌នាអំពីយន្តការ នៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីគោលនយោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

យន្តការនៃការផ្តល់ព័ត៌មានរបស់ កសស អំពីរបាយការណ៍ប្រចាំត្រីមាស ឬប្រចាំឆ្នាំ គឺបុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ត្រូវរៀបចំព័ត៌មានស្របតាមប្រកាសរបស់និយ័តករមូលបត្រកម្ពុជាលេខ ០០៧/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ច្បាស់លាស់អំពីឈ្មោះ និងអក្សរកូដ, កាលបរិច្ឆេទ និងពេលវេលានៃការបញ្ជូន ហើយផ្តល់ជូន ទីផ្សារមូលបត្រប្រតិស្រុត និង/ឬ និយ័តករមូលបត្រកម្ពុជា ដោយផ្ទាល់ ឬតាមរយៈទូរសារ ឬសារអេឡិចត្រូនិច ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត ។ ចំពោះព័ត៌មានដែលត្រូវផ្តល់ជាភាសាអង់គ្លេសត្រូវបញ្ជាក់ថា "Unofficial Translation" និងអាចមានហត្ថលេខារបស់បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន ។

ក្រៅពីព័ត៌មានសាជីវកម្មដែលត្រូវផ្សព្វផ្សាយជាសាធារណៈ កសស អាចផ្តល់ឯកសារសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ជូនទីផ្សារមូលបត្រប្រតិស្រុត និង/ឬ និយ័តករមូលបត្រកម្ពុជា ដោយបញ្ជាក់ថា " មិនសម្រាប់ផ្សព្វផ្សាយជាសាធារណៈ " ។ ក្នុងករណីចាំបាច់ និងបន្ទាន់ ការផ្តល់ព័ត៌មានសាជីវកម្មអាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច និងត្រូវធ្វើជាលាយលក្ខណ៍អក្សរភ្លាម ។ បុគ្គលិកទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន គឺ លោក **ពិត ប្រាកដ** នាយកគណនេយ្យ-ហិរញ្ញវត្ថុ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាល កសស ព្រមទាំងក្រុមជំនួយការ ។

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១. យន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

កសស ធ្វើការទំនាក់ទំនងទៅវិនិយោគិន តាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ កសស ក្នុងការផ្តល់ព័ត៌មានជូនភាគហ៊ុនិក និងវិនិយោគិន ។ ក្នុងករណីវិនិយោគិនមានបំណងសាកសួរព័ត៌មានមក កសស អាចអញ្ជើញមកទំនាក់ទំនងតាមព័ត៌មានដូចខាងក្រោម ៖

- គេហទំព័រ : www.pas.gov.kh
- Facebook Page : កំពង់ផែស្វយ័តក្រុងព្រះសីហនុ Sihanoukville Autonomous Port - PAS
  : www.fb.com/pas.gov.kh
- PAS Mobile App : មាននៅក្នុង App Store និង Play Store
- ទូរស័ព្ទដៃ : ០៧៨ ៤៩៦ ៧៨៩
- មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ របស់ កសស
- អាសយដ្ឋាន : តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

### ២. ទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងឆ្នាំ២០២៥

- នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ០៨:00 ព្រឹក កសស បានរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី៨ ក្រោមអធិបតីភាព **ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាត នៅសណ្ឋាគារ Raffles Hotel Royal រាជធានីភ្នំពេញ ដែលមានកូរ៉ុមចំនួន ៩៥,៦៩% និងភាគហ៊ុនិកចំនួន ១០៩ រូប ស្មើនឹង ៨២.០៧៤.៧៤៦ ភាគហ៊ុន ។
- នាថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ កសស បានចូលរួមក្នុងកម្មវិធី " MY FIRST STOCK 2025 " ដែលបានប្រារព្ធឡើងនៅផ្សារទំនើបអ៊ីអនម៉ុលភ្នំពេញ ដោយមានការចូលរួមពីតំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនចំនួន ១៨ ។

kកំពង់ផែស្វយ័តក្រុងព្រះសីហនុ





**អាសយដ្ឋាន**

តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ព្រះរាជាណាចក្រកម្ពុជា

**ទំនាក់ទំនង**

០៣៤ ៩៣៣ ៤១៦
០៣៤ ៩៣៣ ៥១១
០៧៨ ៤៩៦ ៧៨៩

www.pas.gov.kh
pasinfo@pas.gov.kh
Sihanoukville Autonomous Port